ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ



# របាយការណ៍ប្រចាំឆ្នាំ២០២២

**គោលដៅយុទ្ធសាស្ត្រចម្បងរបស់ រ.ទ.ស.ភ មានដូចខាងក្រោម៖**

ពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដារដូចគ្នានៅក្នុងរាជធានីភ្នំពេញ។ វិភាគថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក បង្កើនប្រសិទ្ធិភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស។ តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និង បរិស្ថាន។ ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។


លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ: (៨៥៥)២៣ ៧២៤០៤៦
លេខទូរសារ: (៨៥៥)២៣ ៤២៧៦៥៧

អ៊ីម៉ែល:
ir@ppwsa.com.kh

# ទស្សនវិស័យ និងបេសកកម្ម

## ទស្សនវិស័យ

រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឱ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួលដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជនខេត្ត-ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោក មានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។

## បេសកកម្ម

បេសកកម្មរបស់ រ.ទ.ស.ភ គឺធានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ម៉ោង លើ ២៤ម៉ោង ក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់និងរាជធានីភ្នំពេញដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ។ក្រៅពីនេះ រ.ទ.ស.ភ បាននឹងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួន ដល់បណ្តារដ្ឋាករទឹកខេត្ត-ក្រុងមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកតាមសំណូមពរសំដៅសម្រេចអោយបាននូវ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (CSDGs)។

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|
| ទ្រព្យសកម្មសរុប( ពាន់រៀល ) | ២.៦៨៤.១៣៥.៨៧៥ | ២.៣០៦.៨០៦.១៧៤ | ១.៨៦៤.៦១៨.១៤០ |
| បំណុលសរុប( ពាន់រៀល ) | ១.៤១១.៩២២.៨២៨ | ១.១៤០.១៧៧.៩៦១ | ៨៨២.៥៦៥.៤៨៣ |
| មូលធនសរុប( ពាន់រៀល ) | ១.២៧២.២១៣.០៤៧ | ១.១៦៦.៦២៨.២១៣ | ៩៨២.០៥២.៦៥៧ |

| លទ្ធផលហិរញ្ញវត្ថុ | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|
| ចំណូលសរុប( ពាន់រៀល ) | ៣៤៦.១៧៨.១៥៦ | ៣៦៩.១៤៥.២៥៧ | ៣២៤.៣៦៧.៨៥៦ |
| ចំណេញមុនបង់ពន្ធប្រាក់ចំណេញ( ពាន់រៀល ) | ១៣០.៥១៥.៨៩២ | ១៦៥.៨៥៦.៥៨៦ | ១២០.៧៤៦.៤៧៧ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ( ពាន់រៀល ) | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ | ៨៨.៣៥១.៨៤៥ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ( ពាន់រៀល ) | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ | ៨៨.៣៥១.៨៤៥ |

| អនុបាតហិរញ្ញវត្ថុ | | ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|---|
| អនុបាតសាធនភាព | | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត( ចំនួនដង ) | ២,២១ | ១,៦៥ | ១,០៨ |
| | អនុបាតចរន្តលឿន( ចំនួនដង ) | ១,៤៦ | ១,១១ | ០,៦៨ |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រពសកម្ម( ភាគរយ ) | ៤,៣៤ | ៦,២០ | ៥,០៩ |
| | អនុបាតចំណេញធៀបនឹងមូលធន( ភាគរយ ) | ៨,៨៧ | ១២,០៣ | ៩,៣២ |
| | អនុបាតគម្លាតចំណេញដុល ( ភាគរយ ) | ៣៦,០៧ | ៤២,៥៦ | ៣៩,៩៥ |
| | អនុបាតគម្លាតចំណេញភាព ( ភាគរយ ) | ៣១,២៥ | ៣៥,០២ | ២៧,២៤ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ( រៀល ) | ១.២៤៣,៩០ | ១.៤៨៦,៣៧ | ១.០១៥,៨៥ |
| អនុបាតលទ្ធភាពសងការប្រាក់ ( ចំនួនដង ) | | ១០,៣២ | ៣២,៧៦ | ១០,២៥ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## បម្រែបម្រួលតម្លៃភាគហ៊ុន (គិតជារៀល) និងទំហំជួញដូរ




## ប្រាក់ចំណេញតាមបណ្តាឆ្នាំនីមួយៗ (លានរៀល)




## ប្រាក់ចំណេញសម្រាប់ឆ្នាំ២០២២ (លានរៀល)



# សមាសភាព
# ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ស៊ឹម ស៊ីថា**
រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍

**ប្រធានក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ឡុង ណារ៉ូ**
អគ្គនាយក
រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម មី វ៉ាន់**
រដ្ឋលេខាធិការ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម នួន ផារ័ត្ន**
អភិបាលរងនៃគណៈអភិបាល
រាជធានីភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ម៉ា ណូរ៉ាវីន**
តំណាងនិយោជិត
នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ណាំ ចន្ទ្រី**
អភិបាលមិនប្រតិបត្តិតំណាង
ភាគហ៊ុនិកឯកជន

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ស្រេង សំឌិក**
អភិបាលឯករាជ្យ

**សមាជិកក្រុមប្រឹក្សាភិបាល**

# សេចក្ដីថ្លែងរបស់ ប្រធានក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ស៊ឹម ស៊ីថា**
រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ប្រធានក្រុមប្រឹក្សាភិបាល**

## ក្នុងឆ្នាំ២០២២ នេះ

" ដោយទទួលបានទំនុកចិត្តពីរាជរដ្ឋាភិបាល ជាមួយនឹងការឧបត្ថម្ភគាំទ្រពីក្រសួងអាណាព្យាបាលទាំងពីរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានបំពេញកាតព្វកិច្ចដោយជោគជ័យ គ្រប់សកម្មភាពធុរកិច្ចរបស់ខ្លួន។ យើងកំពុងបន្តអភិវឌ្ឍសេវាទឹកស្អាតជារៀងរាល់ថ្ងៃ ទាំងគុណភាពនិងបរិមាណដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាជននៃទីក្រុងភ្នំពេញ និងទីក្រុងតាខ្មៅ និងចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍរបស់ទីក្រុងទាំងពីរ។ "

ក្នុងឆ្នាំ២០២២នេះ រ.ទ.ស.ភ បានទទួលចំណូលសរុប ៣៤៦.១៧៨.១៥៦.០០០រៀល និងប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល ១៣០.៥១៥.៨៩២.០០០រៀល។ លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិកមានចំនួន ១០៨.១៨៥.៨៦៥.០០០រៀល។ ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន( Basic Earnings per Share ) គឺ ១.២៤៣,៩០រៀល។

រ.ទ.ស.ភ វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ។ ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្ម-សេវាកម្ម និងធានាគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្ម សេវាកម្ម និងឧស្សាហកម្ម។ ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុងឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សា-ភិបាល និងដោយអនុលោមតាមច្បាប់។

សហប្រតិបត្តិការលើផ្នែកបច្ចេកទេសពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍទាំងក្នុង និងក្រៅប្រទេសដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ធានាឱ្យបាននូវចេរភាពដំណើរការផលិតកម្មអាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទ ដើម្បីកាត់បន្ថយថ្លៃដើមទឹកប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្ដាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។

## សេវាដ៏មានប្រសិទ្ធភាព

យើងនៅតែបន្តធានាការផ្គត់ផ្គង់ទឹកស្អាត ២៤ម៉ោង/២៤ម៉ោង ជាមួយនឹងគុណភាពដែលអាចទទួលទានបានដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ។ ក្នុងឆ្នាំ២០២២នេះ យើងបានដាក់បំពង់មេនាំទឹក និងបណ្ដាញចែកចាយទឹកស្អាតសរុបប្រវែង ៤១០.៣៨៤,៧៩ម៉ែត្រ និងផលិតបានចំនួន ២៣៩.២០៨.៦៥៧ម$^{៣}$។ កំណើនអតិថិជនក្នុងគ្រាបានចំនួន ២៣.៨០០បណ្ដាញ ក្នុងនោះអតិថិជនចំណូលទាបចំនួន ១.៤៤៧បណ្ដាញ និងអត្រាទឹកបាត់បង់ស្ថិតក្នុងកម្រិត ៨,៥០% ប៉ុណ្ណោះ។

## ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន៦លើក ដូចខាងក្រោម៖

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញលើកទី១ (កិច្ចប្រជុំលើកទី១១) អាណត្តិទី៧**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញលើកទី១ អាណត្តិទី៧ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១០:០០ តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-អនុម័តលើសំណើសុំតែងតាំងស្នងការគណនី

ក្រុមប្រឹក្សាភិបាល បានឯកភាពទុកពេលវេលាជូនឯកឧត្តម នេត មុន្នី ធ្វើការសិក្សា និងផ្តល់មតិបន្ថែម អំពីនីតិវិធីនៃការជ្រើសរើសភ្នាក់ងារគណនេយ្យ និងបានណែនាំឱ្យ រ.ទ.ស.ភ ធ្វើលិខិតសុំការណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការរៀបចំតែងតាំងភ្នាក់ងារគណនេយ្យរបស់ រ.ទ.ស.ភ ។

២) សំណើសុំពិនិត្យ-អនុម័តតែងតាំងបុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ

ក្រុមប្រឹក្សាភិបាលបាន អនុម័ត-ឯកភាពជាឯកច្ឆន្ទតាមការស្នើរបស់គណៈកម្មាធិការតែងតាំងនិងលាភការ ដោយតែងតាំងបុគ្គលិកជាន់ខ្ពស់ចំនួន៧រូប និងលេខាធិការសហគ្រាសចំនួន១រូប គឺ៖

| | |
|---|---|
| ១) លោក ជា សតិភទ្ទ | តែងតាំងជាអគ្គនាយករងទទួលបន្ទុកសាខាសេវាកម្មទឹកស្អាតនិងអនាម័យ |
| ២) លោក ដេង ប៉ូលីដែន | តែងតាំងជា អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច |
| ៣) លោក ផេង ទី | តែងតាំងជា អគ្គនាយករងទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក |
| ៤) លោក ជូ ផល្លា | តែងតាំងជាលេខាធិការសហគ្រាស ដែលមានឋានៈស្មើអគ្គនាយករង |
| ៥) លោក សុខ ណារ៉េត | តែងតាំងជា ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ |
| ៦) លោក ទុយ ប៊ុនសេរីទ្ធ | តែងតាំងជា ប្រធាននាយកដ្ឋាន នៃសាខាសេវាកម្មទឹកស្អាតនិងអនាម័យ |
| ៧) លោក កាំង សោភីណា | តែងតាំងជា ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក |
| ៨) លោក កែម កានវិចិត្រ | តែងតាំងជា ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម |

ព្រមទាំងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ចំនួន ២រូប គឺលោក ដេង ប៉ូលីដែន និងលោក ជូ ផល្លា។

៣) របាយការណ៍បច្ចុប្បន្នភាពស្តីពីលទ្ធផលចុះអង្កេតទីតាំងអតិថិជនលក់ទឹកបន្តឱ្យកម្មករ កម្មការិនី និងសិស្សនិស្សិត នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ

*ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍ និងស្នើឱ្យ រ.ទ.ស.ភ ទទួលយកនូវអនុសាសន៍ ណែនាំរបស់ក្រុមប្រឹក្សាភិបាលទាំង៥ចំណុចខាងលើ ទៅអនុវត្តបន្ត។*

៤) ផ្សេងៗ

ក) សំណើសុំពិនិត្យ-សម្រេចលើការធ្វើបច្ចុប្បន្នភាពសមាសភាពគណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវជម្រះពីបញ្ជីសារពើភណ្ឌរបស់ រ.ទ.ស.ភ

*ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាពកែសម្រួលសមាសភាពគណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវជម្រះពីបញ្ជីសារពើភណ្ឌរបស់ រ.ទ.ស.ភ ដោយបញ្ចូលលោក ដេង ប៉ូលីដែន ជាសមាជិកគណៈកម្មការ។*

ខ) សំណើសុំអនុញ្ញាតជាគោលការណ៍តែងតាំងលោក រស់ គឹមលាង ជាជំនួយការអគ្គនាយក នៅក្រោយពេលត្រូវបានដាក់ឱ្យចូលនិវត្តន៍

*ក្រុមប្រឹក្សាភិបាល បានអនុញ្ញាតជាគោលការណ៍ លើសំណើសុំតែងតាំងលោក រស់ គឹមលាង ជាទីប្រឹក្សា រ.ទ.ស.ភ នៅក្រោយពេលលោកត្រូវបានដាក់ឱ្យចូលនិវត្តន៍។*

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញលើកទី១២ អាណត្តិទី៧**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញលើកទី១២ អាណត្តិទី៧ កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៩:០០ តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-អនុម័តបេក្ខភាពអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ដើម្បីធ្វើការបោះឆ្នោតជ្រើសតាំងក្នុងមហាសន្និបាតភាគហ៊ុនិក

*ក្រុមប្រឹក្សាភិបាល បានឯកភាពជាគោលការណ៍ ទទួលយកបេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនចំនួន១រូប និងបេក្ខភាពអភិបាលឯករាជ្យចំនួន៤រូប ដែលបានស្នើឡើងខាងលើ ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិកលើកទី១០ ធ្វើការបោះឆ្នោតអនុម័តគាំទ្រ និងជ្រើសតាំង ហើយ រ.ទ.ស.ភ ត្រូវធ្វើលិខិតស្នើសុំការបញ្ជាក់បន្ថែមពី ន.ម.ក ថាតើបេក្ខជនដែលត្រូវបានភាគហ៊ុនិកឯកជនជានីតិបុគ្គល (ក្រុមហ៊ុន) កំពុងកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ក្នុងចំនួនគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌតម្រូវតែងតាំងជាតំណាងឈរឈ្មោះជាបេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន អាចត្រូវបានអនុញ្ញាតឱ្យដាក់ជូនមហាសន្និបាតភាគហ៊ុនិកធ្វើការបោះឆ្នោតជ្រើសតាំងដែរទេ ក្នុងករណីដែលបេក្ខជនពុំមានចំណែកកម្មសិទ្ធិនៅក្នុងភាគហ៊ុនទាំងនោះ។ បេក្ខភាពនិងចំនួនបេក្ខភាពខាងលើ អាចនឹងត្រូវធ្វើការកែប្រែ ដោយផ្អែកទៅតាមអនុសាសន៍ណែនាំរបស់ ន.ម.ក ហើយនឹងត្រូវរាយការណ៍សម្រេចអនុម័តចុងក្រោយ ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិក។*

២) សំណើសុំពិនិត្យ-អនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០២១ និងគោលការណ៍បែងចែកប្រាក់ចំណេញ និងបែងចែកភាគលាភដល់ភាគហ៊ុនិកឆ្នាំ២០២១

*ក្រុមប្រឹក្សាភិបាល បានអនុម័ត ៖*

*១. ឯកភាពជាឯកច្ឆន្ទលើសំណើសុំបែងចែកប្រាក់ចំណេញឆ្នាំ២០២១ ដូចខាងក្រោម៖*

| | | |
|---|---|---|
| *- រង្វាន់សរសើរមន្ត្រី-និយោជិត (បីខែ)* | : | *៨.៧៦៧.៥១១.៣០៨,០០រៀល* |
| *- មូលនិធិបម្រើផលប្រយោជន៍សង្គម (៥%)* | : | *៤.២០២.១៦២.៣០២,៧៩រៀល* |
| *- មូលនិធិបម្រុងតាមច្បាប់ (៥%)* | : | *៦.៤៦៣.៦៩៥.៨៥៩,០០រៀល* |
| *- មូលនិធិបម្រុងដោយសេរី (៥%)* | : | *៦.៤៦៣.៦៩៥.៨៥៩,០០រៀល* |
| *២.ឯកភាពជាឯកច្ឆន្ទលើប្រាក់ចំណេញរក្សាទុក* | : | *៨៩.៣៨៤.៨៤៥.០៨០,០០រៀល* |
| *៣. ភាគលាភសរុបដែលត្រូវបែងចែក* | : | *២៦.៩៦១.៦៨០.២២០,០០រៀល* |
| *- ទិន្នផលភាគលាភ* | : | *៤%* |
| *- ចំនួនភាគលាភក្នុងមួយភាគហ៊ុន* | : | *៣១០រៀល/ភាគហ៊ុន* |
| *- អនុបាតនៃការបែងចែកភាគលាភ* | : | *២០,៨៦%* |
| *- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ* | : | *៣០ ឧសភា ២០២២* |

*- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ ថ្ងៃទី៨ខែមិថុនា ឆ្នាំ២០២២ និងបញ្ចប់ថ្ងៃទី១៤ខែមិថុនា ឆ្នាំ២០២២។*

៣) របាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី១ និងផែនការត្រីមាសទី២ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងលើរបាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី១ និងផែនការ ត្រីមាសទី២ ឆ្នាំ២០២២។ ដោយឡែក បញ្ហាដោះស្រាយផលប៉ះពាល់ដែលរាំងស្ទះដល់ការដាក់បំពង់មេ ប្រវែង១.៣៣០ម៉ែត្រ លើផ្លូវ១៤៣R សូមប្រគល់ភារកិច្ចជូនឯកឧត្តម នួន ផារ័ត្ន ជួយអន្តរាគមន៍បន្ថែមលើ ដំណោះស្រាយដែល រ.ទ.ស.ភ ស្នើឡើង និងជួយផ្តល់ជម្រើសក្នុងការដោះស្រាយដល់ការអនុវត្តដើម្បីបញ្ចៀស ភាពរាំងស្ទះ។*

៤) សំណើសុំពិនិត្យ និងផ្តល់អនុសាសន៍ក្នុងការប្រើប្រាស់បដិភាគរបស់ រ.ទ.ស.ភ សម្រាប់ការងារផ្គត់ផ្គង់ និងដាក់បំពង់មេនាំទឹកឆៅទំហំ៨០០ម.ម ចេញពីស្ថានីយបូមទឹកឆៅ មករោងចក្រប្រព្រឹត្តកម្មទឹកស្អាត ភូមិព្រែក ក្នុងក្របខណ្ឌគម្រោងពង្រីកសមត្ថភាពផលិតទឹក ៤៥.០០០ម$^{៣}$/ថ្ងៃ ក្រោមជំនួយឥតសំណង របស់រាជរដ្ឋាភិបាលជប៉ុន ក្នុងរូបភាពជា Special Purpose Company (SPC)

*ក្រុមប្រឹក្សាភិបាល បានផ្តល់ការគាំទ្រជាគោលការណ៍ទៅលើជម្រើសទី៣ និងស្នើឱ្យ រ.ទ.ស.ភ សិក្សា លម្អិតតម្លៃនៃគម្រោងទាំងមូលឡើងវិញ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។*

៥) សំណើសុំពិនិត្យ-សម្រេចអនុញ្ញាតឱ្យ រ.ទ.ស.ភ ដាក់បំពង់ទំហំ៦០០ម.ម ប្រវែង២.៨៨២ម៉ែត្រក្រៅផែនការ ក្នុងស្ថានភាពបន្ទាន់ នៅលើផ្លូវជាតិលេខ២ ចាប់ពីរង្វង់មូលតាខ្មៅ ដល់ស្ពានព្រែកហូរ

*ក្រុមប្រឹក្សាភិបាល បានឯកភាពជាគោលការណ៍ឱ្យ រ.ទ.ស.ភ អនុវត្តនូវគម្រោងក្រៅផែនការនេះ ដោយអនុញ្ញាតធ្វើនិយ័តកម្មផែនការនាពេលក្រោយ តែឱ្យបាននៅមុនឆមាសទី២ ឆ្នាំ២០២២។*

៦) សំណើសុំអនុញ្ញាតរៀបចំឯកសារទស្សនាទាន (Concept Note) របស់គម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធជំហានទី៣ (១៣០.០០០ម$^3$/ថ្ងៃ) និងរោងចក្រភូមិព្រែក (១០០.០០០ម$^3$/ថ្ងៃ) ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*ក្រុមប្រឹក្សាភិបាល បានឯកភាពគាំទ្រឱ្យ រ.ទ.ស.ភ រៀបចំ Concept Note អំពីគម្រោងទាំង៣នេះ ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានទាន់តាមពេលវេលាកំណត់។*

៧) សំណើសុំពិនិត្យ-អនុម័តលើពិធីមហាសន្និបាតភាគហ៊ុនិកលើកទី១០

*ក្រុមប្រឹក្សាភិបាល បានណែនាំឱ្យ រ.ទ.ស.ភ អនុវត្តតាមអនុសាសន៍ណែនាំខាងលើ និងបានអនុម័តឯកភាព ៖*

*១) យកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ជាថ្ងៃប្រារព្ធពិធីមហាសន្និបាតភាគហ៊ុនិកលើកទី១០ និងថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ជាកាលបរិច្ឆេទកំណត់ទុកសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១០*

*២) ដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី១០ រួមទាំងការបោះឆ្នោត នឹងរៀបចំតាមប្រព័ន្ធអនឡាញ (Online)*

*៣) មហាសន្និបាតចាប់ផ្តើមពីម៉ោង៨:០០ ដោយគ្រោងរៀបចំឱ្យមានរបៀបវារៈដូចខាងក្រោម ៖*

- *ចុះវត្តមាន (តាមប្រព័ន្ធ Online)*
- *ប្រកាសហេតុ*
- *គោរពទង់ជាតិ*
- *បទបង្ហាញស្តីពីលទ្ធផលអាជីវកម្មឆ្នាំ២០២១ និងទិសដៅអាជីវកម្មឆ្នាំ២០២២ របស់សហគ្រាស*
- *បោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក*
- *បោះឆ្នោតអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល*
- *បោះឆ្នោតអនុម័តគាំទ្របេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន*
- *បោះឆ្នោតជ្រើសតាំងបេក្ខភាពអភិបាលឯករាជ្យ*
- *មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណរបស់ប្រធានគណៈអធិបតី*

*៤) ប្រគល់ភារកិច្ចធ្វើបទបង្ហាញពីលទ្ធផលអាជីវកម្ម និងទិសដៅអាជីវកម្មរបស់សហគ្រាស ជូនអគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច (លោក ដេង ប៉ូលីដែន)*

*៥) ផ្ទេរសិទ្ធិជូនឯកឧត្តមអគ្គនាយក ក្នុងការរៀបចំដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី១០ និងអនុញ្ញាតឱ្យ រ.ទ.ស.ភ ធ្វើសេចក្តីសម្រេចផ្ទេរសិទ្ធិនេះ ដោយយោងស្មារតីកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១២ នេះ។*

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញលើកទី២ (កិច្ចប្រជុំលើកទី១៣) អាណត្តិទី៧**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលវិសាមញ្ញលើកទី២ អាណត្តិទី៧ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៨:៣០ តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) របាយការណ៍លទ្ធផលស្តីពីការសិក្សាផែនការមេ (Master Plan) ដំណាក់កាលទី៣

*ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាពទទួលជ្រាបជារបាយការណ៍ និងលើកទឹកចិត្ត រ.ទ.ស.ភ បន្តកសាងឯកសារនេះឱ្យបានចប់ជាផ្លូវការ។*

២) សំណើសុំពិនិត្យ-សម្រេចកញ្ចប់ហិរញ្ញវត្ថុថវិកាបដិភាគរបស់ រ.ទ.ស.ភ គម្រោងផ្គត់ផ្គង់ទឹកស្អាតបឹងធំ ក្រោមហិរញ្ញប្បទានឥតសំណងរដ្ឋាភិបាលជប៉ុន

*ក្រុមប្រឹក្សាភិបាល បានឯកភាពអនុម័តលើកញ្ចប់ថវិកាបដិភាគរបស់ រ.ទ.ស.ភ ដែលមានទឹកប្រាក់ចំនួន ៩៣០.០០០ដុល្លារអាមេរិក សម្រាប់ផ្គត់ផ្គង់ទឹកស្អាតបឹងធំ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន។*

៣) របាយការណ៍ស្តីពីសំណើសុំកិច្ចអន្តរាគមន៍រកទុនវិនិយោគ ដើម្បីអនុវត្តគម្រោងសាងសង់រោងចក្រ ប្រព្រឹត្តកម្មទឹកស្អាតអាកាសយានដ្ឋានអន្តរជាតិតេជោ ក្រុងតាខ្មៅ និងរោងចក្រប្រព្រឹត្តកម្មទឹកស្អាត ខ្សាច់កណ្តាល

*ក្រុមប្រឹក្សាភិបាល បានផ្តល់ការគាំទ្រទៅលើគម្រោងទាំង២ខាងលើនេះ និងប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គនាយក ក្នុងការស្នើសុំជំនួយបច្ចេកទេសឥតសំណងពីសាធារណរដ្ឋកូរ៉េ សម្រាប់ធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងទាំង២ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងរាយការណ៍ជូនក្រុមប្រឹក្សាភិបាលនាពេលក្រោយ។ ដោយឡែក បញ្ហាដីទីតាំងអនុវត្តគម្រោង នឹងត្រូវលើកយកមកពិភាក្សាផ្អែកលើលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពនេះ។*

៤) សំណើសុំពិនិត្យ-អនុម័តកែសម្រួលសមាសភាពគណៈកម្មាធិការលទ្ធកម្ម

*ក្រុមប្រឹក្សាភិបាល បានឯកភាពកែសម្រួលសមាសភាពគណៈកម្មាធិការលទ្ធកម្មថ្មីដូចខាងក្រោម ៖*

| | | |
|---|---|---|
| *១)* | *ឯកឧត្តម ឡុង ណារ៉ូ* | *ជាប្រធាន* |
| *២)* | *លោក ជូ ផល្លា* | *ជាអនុប្រធាន* |
| *៣)* | *លោក សុខ ណារ៉េត* | *ជាសមាជិក* |
| *៤)* | *លោក លន់ ផានិត* | *ជាសមាជិក* |
| *៥)* | *លោក កែម កានសំរិទ្ធ* | *ជាសមាជិក* |
| *៦)* | *លោក ផាន់ នរិទ្ធ* | *ជាសមាជិក* |
| *៧)* | *លោកស្រី ស៊ឹម វល្លិកា* | *ជាលេខាធិការ។* |

*ព្រមទាំងពញ្ញាក់ស្មារតីឱ្យអនុវត្តទៅតាមមាត្រា៧ នៃអនុក្រឹត្យលេខ១៣ អនក្រ.បក ផងដែរ។*

៥) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងដំណាច់ឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងដំណាច់ឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២២។*

៦) របាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គមចុងឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមចុងឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២២។*

៧) របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី១ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍ និងណែនាំឱ្យសវនកម្មផ្ទៃក្នុងរៀបចំទម្រង់របាយការណ៍ជាតារាងវិញ ដើម្បីងាយស្រួលក្នុងការពិនិត្យលម្អិតទៅតាមផ្នែកនីមួយៗ។*

៨) ផ្សេងៗ

*ក) សំណើសុំផ្តល់អនុសាសន៍លើការត្រៀមរៀបចំសម្ពោធបើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតក្រុងតាខ្មៅ*

*ក្រុមប្រឹក្សាភិបាលបានឯកភាពប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គនាយក ក្នុងការរៀបចំឯកសារស្នើសុំគោលការណ៍ផ្លូវការពីថ្នាក់ដឹកនាំក្រសួង ដើម្បីស្នើសុំពេលវេលាដាក់ស្តែងសម្រាប់ប្រារព្ធពិធីសម្ពោធ បើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតក្រុងតាខ្មៅ និងរៀបចំកិច្ចការពិធីការសម្រាប់ពិធី សម្ពោធនេះផងដែរ។*

*ខ) វេទិកាផ្តល់ចំណាប់អារម្មណ៍ និងការប្តេជ្ញាចិត្តរបស់បុគ្គលិកជាន់ខ្ពស់៨រូប ដែលទើបតែងតាំងថ្មី*

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញលើកទី១៤ អាណត្តិទី៧**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញលើកទី១៤ អាណត្តិទី៧ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង៩:០០ តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) ការប្រកាសចូលកាន់តំណែងជាផ្លូវការនូវអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន និងអភិបាលឯករាជ្យក្នុង ក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ អាណត្តិទី៧

២) សំណើសុំពិនិត្យ-សម្រេចលើការបន្តអាណត្តិរបស់ប្រធានសវនកម្មផ្ទៃក្នុង

*ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាពតាមសំណើ ដោយអនុញ្ញាតបន្តអាណត្តិជូនលោកស្រី សេង គាតារា ឱ្យបំពេញមុខងារជាប្រធានសវនកម្មផ្ទៃក្នុង រយៈពេល២ឆ្នាំបន្តទៀត។*

៣) សំណើសុំពិនិត្យ-សម្រេចកែសម្រួលសមាសភាពគណៈកម្មាធិការសវនកម្ម

*ក្រុមប្រឹក្សាភិបាល បានឯកភាពកែសម្រួលសមាសភាពគណៈកម្មាធិការសវនកម្មថ្មីដូចខាងក្រោម ៖*

*១) លោក ស្រេង សំឌិក សមាជិកក្រុមប្រឹក្សាភិបាល ជាប្រធានអភិបាលឯករាជ្យ*

*២) ឯកឧត្តម ម៉ី វ៉ាន់ សមាជិកក្រុមប្រឹក្សាភិបាល ជាអនុប្រធានតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*៣) លោក ណាំ ចន្ទ្រី សមាជិកក្រុមប្រឹក្សាភិបាល ជាសមាជិក អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន*

*៤) ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យវេជ្ជអម រ.ទ.ស.ភ ជាសមាជិក*

*៥) លោក ម៉ា ណូរ៉ាវីន សមាជិកក្រុមប្រឹក្សាភិបាល ជាសមាជិក តំណាងនិយោជិត រ.ទ.ស.ភ*

៤) សំណើសុំផ្តល់អនុសាសន៍លើពង្រាងឯកសារ និងឧបករណ៍ជំនួយដល់អភិបាលកិច្ចសាជីវកម្មរបស់ក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ

*ក្រុមប្រឹក្សាភិបាល បានអនុម័តទទួលយកនូវលទ្ធផលនៃសេចក្តីព្រាងឯកសារនិងឧបករណ៍ជំនួយដល់អភិបាលកិច្ចសាជីវកម្មរបស់ រ.ទ.ស.ភ ទាំង៤ចំណុចខាងលើ សម្រាប់ជាត្រីវិស័យដើម្បីយកទៅអនុវត្ត។*

៥) សំណើសុំពិនិត្យ-សម្រេចកំណត់ដែនបេសកកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ រ.ទ.ស.ភ នៅក្រៅក្របខ័ណ្ឌរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ឱ្យស្របតាមប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥

*ក្រុមប្រឹក្សាភិបាល បានឯកភាពគាំទ្រទាំងស្រុងលើសំណើសុំកំណត់ដែនបេសកកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ រ.ទ.ស.ភ នៅក្រៅ ក្របខ័ណ្ឌរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ឱ្យស្របតាមប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥ និងបានផ្តល់អនុសាសន៍ណែនាំដល់ រ.ទ.ស.ភ ដូចខាងក្រោម ៖*

*១) ត្រូវធ្វើនិយ័តកម្មគម្រោងផែនការពង្រីកបណ្តាញផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន និងផែនទីបង្ហាញពីតំបន់ដែលត្រូវឈានទៅដល់ ដោយពុំទាន់ចាំបាច់រំលេចពីផលប៉ះពាល់ដល់ផ្នែកឯកជន ដែលជាកិច្ចការត្រូវដោះស្រាយតាមជាក់ស្តែង នាពេលក្រោយនោះទេ។*

*២) ត្រូវធ្វើលិខិតស្នើសុំការគាំទ្រពីក្រសួងអាណាព្យាបាលទាំងពីរ ដោយយោងផែនការពង្រីកបណ្តាញ ផ្គត់ផ្គង់ទឹកស្អាតដែលបានធ្វើនិយ័តកម្មខាងលើ។ បន្ទាប់ពីទទួលបានការគាំទ្រពីក្រសួងអាណាព្យាបាលទាំងពីររួចហើយ រ.ទ.ស.ភ អាចចាប់ផ្តើមបង្ហាញដៃគូអភិវឌ្ឍន៍ឱ្យបានជ្រាបអំពីផែនការនេះ ដើម្បីទាក់ទាញការចាប់អារម្មណ៍។*

៦) សំណើសុំពិនិត្យឡើងវិញនូវសំណើសុំកែសម្រួលព្រំប្រទល់ដីនៅរោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធ

*ក្រុមប្រឹក្សាភិបាល បានឯកភាពគាំទ្រទាំងស្រុងចំពោះសំណើខាងលើ ដោយយកលក្ខខណ្ឌទាំង៦ចំណុច ខាងលើ សម្រាប់ធ្វើជាមូលដ្ឋាននៃការចរចារជាផ្លូវការជាមួយសាមីម្ចាស់កម្មសិទ្ធិដី ក្នុងការកែសម្រួលព្រំប្រទល់ដីនៅរោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធ។*

៧) របាយការណ៍ស្តីពីករណីដីបម្រុងទុក ទំហំ២ហិកតា ស្ថិតនៅលើទីតាំងកោះនរាថ្មី សម្រាប់ធ្វើរោងចក្រប្រព្រឹត្តកម្មទឹកស្អាតនៅថ្ងៃអនាគត

*ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជារបាយការណ៍ និងបានណែនាំឱ្យ រ.ទ.ស.ភ អនុវត្តតាមអនុសាសន៍ខាងលើ។*

៨) របាយការណ៍ស្តីពីថវិកា និងការកែសម្រួលផែនការលទ្ធកម្មគម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ជំហានទី២

*ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជារបាយការណ៍ និងឯកភាពលើការកែសម្រួលផែនការលទ្ធកម្មគម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែងជំហានទី២។*

៩) របាយការណ៍ស្តីពីលទ្ធផលការងារត្រីមាសទី២-ឆមាសទី១ និងផែនការត្រីមាសទី៣ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍។*

១០) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្ម អនុវត្តក្នុងត្រីមាសទី២ ឆ្នាំ២០២២ និងសំណើសុំពិនិត្យ-អនុម័តលើផែនការលទ្ធកម្មកែតម្រូវឆមាសទី២ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី២ និងអនុម័តឯកភាពលើផែនការលទ្ធកម្មកែតម្រូវឆមាសទី២ ឆ្នាំ២០២២។*

១១) របាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គមត្រីមាសទី២ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពលើរបាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គមត្រីមាសទី២ ឆ្នាំ២០២២ ព្រមទាំងបានឯកភាពគាំទ្រលើសំណើទាំងពីរ និងទឹកប្រាក់គ្រោងចំណាយសរុប ៥២៨.០២៣.២០០រៀល។ លើសពីនេះ ក្រុមប្រឹក្សាភិបាលបានផ្តល់អនុសាសន៍បន្ថែមឱ្យ រ.ទ.ស.ភ ពិចារណា ពង្រាយការជួយឧបត្ថម្ភដល់ខេត្តដទៃទៀតដែលមិនធ្លាប់ទទួលបានការឧបត្ថម្ភពី រ.ទ.ស.ភ កន្លងមក ពោលគឺ មិនលើកទឹកចិត្តឱ្យបន្តឧបត្ថម្ភចំពោះខេត្តដែលធ្លាប់ទទួលបានការជួយឧបត្ថម្ភពី រ.ទ.ស.ភ រួចហើយនោះទេ លើកលែងតែមានអនុសាសន៍ណែនាំពីថ្នាក់ដឹកនាំតែប៉ុណ្ណោះ។*

១២) របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី២ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍ និងបានណែនាំឱ្យសវនកម្មផ្ទៃក្នុងធ្វើសេចក្តីណែនាំស្តីពីយន្តការនៃការតាមដាន និងការលើកសរសើរចំពោះសវនដ្ឋានដែលអនុវត្តបានល្អប្រចាំត្រីមាស ឬឆ្នាំ ដែលជាឧបករណ៍សម្រាប់ឱ្យនាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្សធ្វើការវាយតម្លៃ ក៏ដូចជាការផ្តល់រង្វាន់ជូនចំពោះសវនដ្ឋានដែលអនុវត្តការងាររបស់ខ្លួនបានល្អ។*

១៣) ផ្សេងៗ

ក) សំណើសុំផ្តល់អនុសាសន៍លើផលប៉ះពាល់ដែលបង្កឡើងដោយក្រុមហ៊ុន "Sanghai Construction Group Co.Ltd" ទៅលើបំពង់ទឹកទំហំ២០០ម.ម និង៣០០ម.ម របស់ រ.ទ.ស.ភ ក្រោមគម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងទី៣ របស់រាជរដ្ឋាភិបាល

*ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជាព័ត៌មាន និងបានស្នើឱ្យ រ.ទ.ស.ភ អនុវត្តតាមអនុសាសន៍របស់ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ ។*

ខ) របាយការណ៍ស្តីពីការសិក្សាលើការប្រើប្រាស់ទឹកតាមបន្ទប់ជួលចំនួន៤ទីតាំង នៅខណ្ឌពោធិ៍សែនជ័យ

*ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជាព័ត៌មាន និងឯកភាពគាំទ្រលើជំរើសការជម្រើសទី២ ដែលបានស្នើឡើងខាងលើ។*

គ) របាយការណ៍ស្តីពីស្ថានភាពការប្រើប្រាស់ទឹកនៅបុរីឈូកវ៉ា២ និងសង្កាត់កំបូល ក្រោយការរៀបចំបណ្តាញផ្គត់ផ្គង់បន្ថែម

*ក្រុមប្រឹក្សាភិបាល បានទទួលជ្រាបជាព័ត៌មាន។*

ឃ) សំណើសុំពិនិត្យ-សម្រេចស្តីពីសំណើសុំការអនុញ្ញាតចាក់ដីប្រមាណ ១៤.៧១០ម$^{៣}$ ដើម្បីសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបឹងធំ (៥.០០០ម$^{៣}$/ថ្ងៃ)

*ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាពតាមសំណើ។*

ង) របាយការណ៍ស្តីពីស្ថានភាពដាក់បំពង់មេនាំទឹកស្អាតទំហំ ១៤០០ម.ម លើបណ្តោយផ្លូវ៣០ម៉ែត្រ ស្ថិតនៅក្នុងសង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

*ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជាព័ត៌មាន ព្រមទាំងបានណែនាំឱ្យ រ.ទ.ស.ភ ធ្វើរបាយការណ៍លម្អិតអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងក្របខ័ណ្ឌអនុវត្តគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ដើម្បីគោរពជូនឯកឧត្តមអភិបាលរាជធានីភ្នំពេញ ដោយស្នើសុំការចូលរួម និងកិច្ចអន្តរាគមន៍បន្ថែមពីឯកឧត្តម ឃួង ស្រេង។*

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៦រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**
**សមាជិកក្រុមប្រឹក្សាភិបាលអវត្តមានចំនួន១រូប ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញលើកទី១៥ អាណត្តិទី៧**

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញលើកទី១៥ អាណត្តិទី៧ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៨:៣០ តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈដូចខាងក្រោម ៖

១) សំណើសុំពិនិត្យ-អនុម័តជម្រះចេញពីបញ្ជីនូវសន្និធិ សម្ភារ-បរិក្ខារ ដែលបាត់បង់និងខូចគុណភាពដែលទទួលបានពីរដ្ឋាករទឹកខេត្តព្រះសីហនុ

*ក្រុមប្រឹក្សាភិបាល បានអនុម័តជាគោលការណ៍ ៖*

១) ឯកភាពឱ្យ រ.ទ.ស.ភ លើកសំណើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ-សម្រេចលើការជម្រះចេញពីបញ្ជីនូវសន្និធិមិនមានក្នុងស្តុក និងសន្និធិចាស់ខូចគុណភាព និងបាត់បង់ដែលមានទឹកប្រាក់សរុប៤១៨.៤០៦.៣៧៥,៤៨រៀល។

២) ឯកភាពឱ្យកត់ត្រាសម្ភារជាសន្និធិដែលមានទឹកប្រាក់សរុប១.៤០៤.៤៥៦.០៣៦,០១រៀល ដើម្បី បង្កើនដើមទុន ព្រមទាំងប្រគល់សិទ្ធិជូនឯកឧត្តមអគ្គនាយកក្នុងការចរចាជាមួយក្រុមហ៊ុនអានកូ ដោយត្រូវមានកំណត់ហេតុបញ្ជាក់ពីការទទួលស្គាល់បំណុលជាសម្ភារសន្និធិដែលមានទឹកប្រាក់សរុប៣៨.៧៦៤.៦៩៥,២៤រៀល និងពិភាក្សាអំពីជម្រើសនៃការសងមកវិញ (ជាសាច់ប្រាក់ ឬជាសម្ភារ)។

២) សំណើសុំពិនិត្យ-អនុម័តគម្រោងសិក្សាបឋមសមិទ្ធិលទ្ធភាពនៃបច្ចេកវិទ្យាឈ្លាសវៃក្នុងការគ្រប់គ្រងចែកចាយទឹកនៅកម្ពុជា (Smart Water Management System)

ក្រុមប្រឹក្សាភិបាល បានអនុម័តគាំទ្រទៅលើគម្រោងសិក្សាសមិទ្ធិលទ្ធភាពបឋមនៃបច្ចេកវិទ្យាឈ្លាសវៃក្នុងការគ្រប់គ្រងប្រព័ន្ធចែកចាយទឹករបស់ រ.ទ.ស.ភ ក្នុងលក្ខខណ្ឌដែលគម្រោងនេះទទួលបានហិរញ្ញប្បទានឥតសំណង (Grant Aid)។

៣) សំណើសុំអនុសាសន៍ណែនាំទៅលើបំណុលថ្លៃប្រើប្រាស់ទឹករបស់ក្រសួងការពារជាតិ

ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍និងបានស្នើសុំឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាភិបាល ជួយអន្តរាគមន៍ជំរុញនិងពន្លឿនការងារនេះនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអាចឈានទៅដោះស្រាយបំណុលថ្លៃទឹកនេះបានលឿន ចៀសវាងការបង្គរបំណុលកាន់តែច្រើនឡើង។

៤) របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០២២ (៨ខែបូក៤ខែប៉ាន់ស្មាន) និងសំណើសុំពិនិត្យ-អនុម័តលើគម្រោងផែនការសហគ្រាស និងទុនវិនិយោគឆ្នាំ២០២៣

ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងទៅលើរបាយការណ៍លទ្ធផលការងារឆ្នាំ២០២២ (៨ខែបូក៤ខែប៉ាន់ស្មាន) និងអនុម័ត-ឯកភាពជាឯកច្ឆន្ទលើរាល់សំណើដែលបានលើកឡើងសម្រាប់ផែនការឆ្នាំ២០២៣ ព្រមទាំងបានឯកភាពដំឡើងប្រាក់បៀវត្សរ៍មូលដ្ឋានឆ្នាំ២០២៣ ចំនួនដប់ភាគរយ (១០%) និងដំឡើងកាំបៀវត្សរ៍ចំនួនមួយ(១)កាំ ជូនដល់មន្ត្រី-និយោជិតក្នុងក្របខ័ណ្ឌទាំងបួន។ ក្នុងនេះសន្ទស្សន៍សំខាន់ៗនៃគម្រោងផែនការសហគ្រាស និងទុនវិនិយោគសម្រាប់ឆ្នាំ២០២៣ ដែលត្រូវលើកជាសំណើស្នើសុំការគាំទ្រ និងការអនុម័តពីក្រសួងអាណាព្យាបាលទាំង២ មានដូចខាងក្រោម៖

១) គម្រោងចំណូលសរុប ៤១៣.៨៥៥.៤៣៦.០០០រៀល

២) គម្រោងចំណាយសរុប ២៦៧.៩៤០.០៩០.០០០រៀល

| | | |
|---|---|---|
| ក្នុងនោះ៖ | ២.១. ចំណាយដំណើរការសហគ្រាស | ១៧៦.២៨៦.០០០.០០០រៀល |
| | ២.២. ខាតលើអត្រាប្តូរប្រាក់ | ១៥.៦៥៣.៩១០.០០០រៀល |
| | ២.៣. រំលស់ | ៦៣.១៧៣.០៩៦.០០០រៀល |
| | ២.៤. ការប្រាក់ធនាគារ | ៣.៥៧៤.៥១៣.០០០រៀល |
| | ២.៥. ដោះដូរនាឡិកា | ៣.៤១៤.០៧៨.០០០រៀល |
| | ២.៦. ចំណាយក្រៅដំណើរការសហគ្រាស | ៥.៨៣៨.៤៩៣.០០០រៀល |

៣) គម្រោងចំណេញក្រោយបង់ពន្ធ ១១៦.៧៨១.២៦០.០០០រៀល

៤) គម្រោងវិនិយោគសរុប ៤៤១.៩៥៥.៨៧៣.៨៧៩រៀល

| | | |
|---|---|---|
| ក្នុងនោះ៖ | ៤.១. ថវិកាបដិភាគ | ១២៩.៦៤៥.៤១២.២៥៩រៀល |
| | ៤.២. ហិរញ្ញប្បទានទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ (AFD) | ១៧៨.៩៤៥.៦៣៥.៥៧៦រៀល |
| | ៤.៣. ធនាគារវិនិយោគអឺរ៉ុប (EIB) | ១៣៣.៣៦៤.៨២៦.០៤៤រៀល |

៥) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២២ និងសំណើសុំពិនិត្យ-អនុម័ត លើគម្រោងផែនការលទ្ធកម្មឆ្នាំ២០២៣

*ក្រុមប្រឹក្សាភិបាល បានអនុម័ត-ឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២២ និងគម្រោងផែនការលទ្ធកម្មសម្រាប់ឆ្នាំ២០២៣។*

៦) របាយការណ៍ស្តីពីមូលនិធិបម្រើផលប្រយោជន៍សង្គមអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២២ និងសំណើសុំ ពិនិត្យអនុម័តលើគម្រោងប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមឆ្នាំ២០២៣

*ក្រុមប្រឹក្សាភិបាល បានអនុម័ត ៖*

*១) ឯកភាពទាំងស្រុងលើរបាយការណ៍ប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២២ និងគម្រោងចំណាយសម្រាប់ឆ្នាំ២០២៣។*

*២) ឯកភាពទៅលើសំណើសុំរៀបចំបណ្តាញទឹកស្អាតចូលក្នុងបរិវេណសាកលវិទ្យាល័យការពារជាតិ ដែលត្រូវចំណាយថវិកាប្រមាណ៣៣.៧៥៩.៨២៥រៀល។ រីឯសំណើទាំង២ របស់កងពលតូចអន្តរាគមន៍លេខ៨ ដែលជាសម្ព័ន្ធមេត្រីភាពវិញ រ.ទ.ស.ភ ត្រូវចាត់ក្រុមការងារជំនាញចុះពិនិត្យ និងវាយតម្លៃដល់ទីតាំងជាក់ស្តែង និងលើកសំណើសុំការអនុម័តពីក្រុមប្រឹក្សាភិបាលនាកិច្ចប្រជុំលើកក្រោយ។*

*៣) ឯកភាពជាគោលការណ៍ឱ្យគណៈប្រតិភូ រ.ទ.ស.ភ បានចុះទៅសួរសុខទុក្ខ និងនាំយកនូវអំណោយ ជាសម្ភារ-បរិក្ខារនានាទៅឧបត្ថម្ភជូនដល់កងទ័ពនៃកងពលតូចអន្តរាគមន៍លេខ៨ នាចុងឆ្នាំ២០២២ នេះ។*

៧) របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រីមាសទី៣ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាល បានឯកភាពទាំងស្រុងទៅលើលទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រីមាសទី៣ ឆ្នាំ២០២២ និងឯកភាពជាគោលការណ៍ទទួលយកសំណើរបស់គណៈកម្មាធិការសវនកម្ម សុំជ្រើសរើសសវនករឯករាជ្យសម្រាប់រយៈពេល២ឆ្នាំម្តង តែត្រូវរៀបចំកិច្ចការនេះទៅតាមនីតិវិធីជាធរមាន និងស្នើសុំការអនុញ្ញាតជាគោលការណ៍ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសិន។*

៨) ផ្សេងៗ

ក) សំណើសុំពិនិត្យ-អនុម័តជាគោលការណ៍លើដំណោះស្រាយបំណុលរបស់អភិបាលនិងមន្ត្រី-និយោជិត ដែលបានខ្ចីទិញភាគហ៊ុន រ.ទ.ស.ភ ក្នុងដំណាក់កាល IPO

*ក្រុមប្រឹក្សាភិបាល បានអនុម័តឯកភាពជាគោលការណ៍ចំពោះសំណើរបស់ រ.ទ.ស.ភ ទាំង៣ ចំណុចខាងលើ។*

ខ) គោលការណ៍ណែនាំស្តីពីការជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិក ឯកជន របស់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ

*ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍ និងបានណែនាំឱ្យ រ.ទ.ស.ភ ដកស្រង់នូវបទពិសោធន៍ក្នុងការជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន នាពេលកន្លងទៅ យកមកចងក្រងទុកជាបណ្តុំឯកសារគំរូសម្រាប់ជាមេរៀនទៅថ្ងៃក្រោយ។*

គ) របាយការណ៍ស្តីពីអាណត្តិបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ ។

*ក្រុមប្រឹក្សាភិបាល បានឯកភាពទទួលជ្រាបជារបាយការណ៍ និងបានណែនាំឱ្យ រ.ទ.ស.ភ ចាប់ផ្តើមកិច្ចការរៀបចំបែបបទស្នើសុំតែងតាំងក្រុមប្រឹក្សាភិបាលអាណត្តិថ្មីនាខែវិច្ឆិកា ឆ្នាំ២០២២ ខាងមុខនេះ ដោយត្រូវធ្វើលិខិតស្នើសុំគោលការណ៍អនុញ្ញាតជាមុនពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលជាអាណាព្យាបាលបច្ចេកទេស ព្រមទាំងបញ្ជាក់នៅក្នុងលិខិតនោះអំពីសមាសភាពក្រុមប្រឹក្សាភិបាល ដូចមានចែងក្នុងអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការកែសម្រួលមាត្រា៨ថ្មី នៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើត រ.ទ.ស.ភ មុននឹងក្រសួងធ្វើលិខិតស្នើសុំសមាសភាពតំណាងក្រសួង-ស្ថាប័នចូលរួមក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ ក្នុងអាណត្តិថ្មី (លើកលែងតែសមាសភាពជាតំណាងនិយោជិត រ.ទ.ស.ភ, អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន និងអភិបាលឯករាជ្យ ដែលត្រូវជ្រើសរើសឱ្យបន្តអាណត្តិតាមរយៈការបោះឆ្នោត)*

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

- **លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញលើកទី១៦ អាណត្តិទី៧**

 វ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញលើកទី១៦ អាណត្តទី៧ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង៨:៣០ តាម Online ដោយប្រើកម្មវិធី ZOOM ដែលមានរបៀបវារៈដូចខាងក្រោម៖

១) សំណើសុំអនុម័តលើកម្មវិធីប្រជុំក្រុមប្រឹក្សាភិបាលឆ្នាំ២០២៣

*ក្រុមប្រឹក្សាភិបាលបានអនុម័ត-ឯកភាព៖*

*១) សម្រាប់ខែមីនា កំណត់យកថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣*

*២) សម្រាប់ខែមិថុនា កំណត់យកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣*

*៣) សម្រាប់ខែកញ្ញា កំណត់យកថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣*

*៤) សម្រាប់ខែធ្នូ កំណត់យកថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣។*

២) របាយការណ៍ស្តីពីលទ្ធផលការងារ១០ខែ បូក២ខែប៉ាន់ស្មានឆ្នាំ២០២២ និងផែនការត្រីមាសទី១ ឆ្នាំ២០២៣

*ក្រុមប្រឹក្សាភិបាលបាន៖*

*១- ឯកភាពទាំងស្រុងទៅលើទិសដៅផែនការត្រីមាសទី១ ឆ្នាំ២០២៣ ដែលជាផ្នែកមួយនៃផែនការ ប្រចាំឆ្នាំ២០២៣ ដែលបានទទួលការឯកភាពជាគោលការណ៍រួចហើយ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈលិខិតលេខ២០៩១ MISTI/២០២២ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ និងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈលិខិតលេខ១២៤០៣ សហវ-អទច ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២។*

*២- គាំទ្រទៅលើគំនិតផ្តួចផ្តើមក្នុងការស្នើសុំទិញដីទាំង៥ទីតាំង រួមទាំងការផ្តល់ជម្រើសសម្រាប់ការលក់ ឬដោះដូរដី ដូចបានលើកឡើងខាងលើ ដោយត្រូវគិតគូរដល់គោលការណ៍ ៣ចំណុច ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានណែនាំដូចមានចែងក្នុងលិខិតយោងខាងលើនេះដើម្បីអនុវត្តគម្រោងពង្រីកសមត្ថភាពផលិតកម្ម ស្របតាមផែនការមេទី៣ (ឆ្នាំ២០២១-២០៣០) និងអនុញ្ញាតឱ្យ វ.ទ.ស.ភ បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីចុះពិនិត្យ សិក្សាស្រាវជ្រាវ និងទិញដី ក៏ដូចជាតម្រូវការលក់ ឬដោះដូរដី ដោយអនុវត្តឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីជាធរមាន ព្រមទាំងរាយការណ៍ជូនក្រុមប្រឹក្សាភិបាលជាបន្តបន្ទាប់នៅក្នុងកិច្ចប្រជុំក្រោយៗទៀត និងលើកយោបល់ស្នើសុំគោលការណ៍អនុញ្ញាតពីក្រសួងអាណាព្យាបាលទាំង២។*

៣) របាយការណ៍ស្តីពីលទ្ធផលកិច្ចលទ្ធកម្ម ត្រីមាសទី៤ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាលបានឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មត្រីមាសទី៤ ឆ្នាំ២០២២។*

៤) របាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម ត្រីមាសទី៤ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាលបាន ៖*

*១- ឯកភាពទាំងស្រុងទៅលើរបាយការណ៍ ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម ត្រីមាសទី៤ ឆ្នាំ២០២២។*

*២- ឯកភាពទៅលើសំណើសុំសាងសង់អគារសិក្សា១ខ្នងមាន៥បន្ទប់ ស្ថិតនៅក្នុងក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ដែលមានថវិកាគ្រោងចំណាយប្រមាណ៦០.០០០ដុល្លារអាម៉េរិក។*

*៣- ផ្តល់ជាការគាំទ្រ ចំពោះគំនិតផ្តួចផ្តើមរបស់ វ.ទ.ស.ភ ក្នុងការចុះទៅពិនិត្យសិក្សាជាក់ស្តែងស៊ីជម្រៅឡើងវិញ ទៅលើស្ថានភាពនៃប្រព័ន្ធផ្គត់ផ្គង់ទឹកនៅកងពលតូចអន្តរាគមន៍លេខ៨ ដែលជាសម្ព័ន្ធមេត្រីភាពរបស់ វ.ទ.ស.ភ ។*

៥) របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី៤ ឆ្នាំ២០២២

*ក្រុមប្រឹក្សាភិបាលបានឯកភាពទាំងស្រុងទៅលើលទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រីមាសទី៤ ឆ្នាំ២០២២ និងឯកភាពលើសំណើសុំជ្រើសរើសសវនករឯករាជ្យរយៈពេល១ឆ្នាំ សម្រាប់ការផ្តល់សេវាសវនកម្មត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានហិរញ្ញវត្ថុជូន វ.ទ.ស.ភ ការិយបរិច្ឆេទ២០២៣។*

៦) ផ្សេងៗ- សំណើសុំគោលការណ៍អនុញ្ញាតទិញដីចំនួន៥កន្លែង សម្រាប់សាង់សង់ស្ថានីយបូមទឹកផៅរោងចក្រ ផលិតទឹកស្អាតបាក់ខែងជំហានទី៣, ស្ថានីយបូមទឹកផៅ និងរោងចក្រផលិតទឹកស្អាតអាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ, ស្ថានីយបូមទឹកផៅ និងរោងចក្រផលិតទឹកស្អាតខ្សាច់កណ្ដាល

*ក្រុមប្រឹក្សាភិបាលបានពិភាក្សាទៅលើរបៀបវារៈនេះរួចហើយ ដោយភ្ជាប់ជាមួយរបៀបវារៈទី២ ខាងលើ។*

**សមាជិកក្រុមប្រឹក្សាភិបាលវត្តមានចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ។**

រ.ទ.ស.ភ មានយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការពង្រីកបណ្ដាញចែកចាយទឹក ដោយមានទំនាក់ទំនងជាមួយនឹងការពង្រីកសមត្ថភាពប្រព្រឹត្តកម្ម ហើយការពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ គឺធ្វើយ៉ាងណារក្សាអត្រានិងស្តង់ដារដូចគ្នា នៅក្នុងរាជធានីភ្នំពេញ និងតាំងចិត្តខ្ពស់ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

សម្រាប់ឆ្នាំ២០២៣ យើងគ្រោងផលិតទឹកស្អាត ២៧៣.២៦៣.១០០ម$^{៣}$ ជាមួយនឹងការពង្រីកបណ្ដាញចែកចាយទឹកបន្ថែម ៤៦២.៨០០ម៉ែត្រ និងគ្រោងចំណូលសរុបចំនួន ៤១៣.៨៥៥.៤៣៦.០០០រៀល និងចំណាយសរុបចំនួន ២៦៧.៩៤០.០៩០.០០០រៀល ដូចដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលទាំងពីរ។

## សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងនូវសេចក្ដីដឹងគុណដ៏ជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាល អាណាព្យាបាលទាំងពីរ គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និយ័តករមូលបត្រកម្ពុជា ផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលបានផ្ដល់ទំនុកចិត្តនិងការគាំទ្រចំពោះ រ.ទ.ស.ភ ។

យើងក៏មានមោទនភាព និងសូមថ្លែងអំណរគុណចំពោះមន្ត្រី និងនិយោជិតគ្រប់ថ្នាក់របស់ រ.ទ.ស.ភ ដែលបានខិតខំបំពេញការងារដោយស្មារតីទទួលខុសត្រូវខ្ពស់ ជំរុញឱ្យសម្រេចបាននូវលទ្ធផលដ៏ល្អប្រសើរនេះ។

ថ្ងៃពុធ ៩រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាភិបាល**

**ស៊ឹម ស៊ីថា**

# សេចក្ដីថ្លែងរបស់អគ្គនាយក



**ឯកឧត្តម ឡុង ណារ៉ូ**
អគ្គនាយក

## សមិទ្ធិផលសម្រេចបានក្នុងឆ្នាំ២០២២

"តាងនាម រ.ទ.ស.ភ ខ្ញុំមានកិត្តិយសនិងក្ដីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០២២ និងរបាយការណ៍ហិរញ្ញវត្ថុ របស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ រ.ទ.ស.ភ បានកត់ត្រានូវរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ នេះ ដោយទទួលបានចំណូលសរុបចំនួនប្រមាណ ៣៤៦ប៊ីលានរៀល និងចំណេញមុនបង់ពន្ធលើប្រាក់ចំណូលចំនួនប្រមាណ ១៣១ប៊ីលានរៀល និងលទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិកចំនួនប្រមាណ ១០៨ប៊ីលានរៀល។"

## សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០២២

ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាល ក្រសួងអាណាព្យាបាល និង ក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងឆ្នាំនេះ រ.ទ.ស.ភ នៅតែមានការវិវឌ្ឍន៍យ៉ាងខ្លាំងក្លា ដោយការគ្រប់គ្រងហានិភ័យបានល្អប្រសើរបានប្រើប្រាស់ នូវធនធានហិរញ្ញវត្ថុមានប្រសិទ្ធភាពខ្ពស់ និង គ្រប់គ្រងការចំណាយបានយ៉ាងហ្មត់ចត់ ជាពិសេសដោយការយកចិត្ត ទុកដាក់ខ្ពស់លើការកាត់បន្ថយអត្រាទឹកបាត់បង់។ ទោះបីសកម្មភាពជួសជុលនិងពង្រីកថ្នល់ទូទាំងរាជធានីភ្នំពេញ ជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលបណ្ដាលឱ្យមានការលេចធ្លាយបំពង់ទឹក ដូចបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យរួច ក៏នៅក្នុងឆ្នាំ២០២២ នេះ រ.ទ.ស.ភ ទទួលបានចំណូលសរុបចំនួន ៣៤៦.១៧៨.១៥៦.០០០រៀល ហើយប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញមានចំនួន ១៣០.៥១៥.៨៩២.០០០រៀល និងប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិកមានចំនួន ១.២៤៣,៩០រៀល ។ នាចុងការិយបរិច្ឆេទនេះទ្រព្យសកម្មសរុបបានកើនឡើងរហូតដល់ចំនួន ២.៦៨៤.១៣៥.៨៧៥.០០០រៀល ចំណែកឯដើមទុនវិញបានកើនឡើងរហូតដល់ចំនួន ១.២៧២.២១៣.០៤៧.០០០រៀល។ ការកើនឡើងនេះដោយសារ រ.ទ.ស.ភ សម្រេចបានជោគជ័យយ៉ាងធំធេងក្នុងការកាត់បន្ថយអត្រាទឹកបាត់បង់ឱ្យនៅក្នុងកម្រិតលេខ១ខ្ទង់ដែលអត្រានៅក្នុងឆ្នាំ២០២២នេះ មានត្រឹមតែ ៨,៥០%។ ការកាត់បន្ថយទឹកបាត់បង់ជាកត្តាស្លាប់-រស់ របស់ រ.ទ.ស.ភ ក្នុងដំណើរការប្រព្រឹត្តកម្មនិងអាជីវកម្មរបស់ខ្លួន។ ជាមួយគ្នានេះដែរ ដើម្បីសម្របទៅតាមការប្រែប្រួលនៃអតិផរណា យើងបានធ្វើការកែសម្រួលនូវថ្លៃលក់ទឹកស្អាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់បច្ចុប្បន្នដែលធ្វើឱ្យយើងនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ ដែលអាចបង្កលក្ខណៈឱ្យយើងមានទឹកស្អាតសម្រាប់ផ្គត់ផ្គង់ និងអាចផឹកបានពីក្បាលរ៉ូប៊ីណេដល់រាប់ម៉ឺនគ្រួសារ រួមទាំងគ្រួសារមានចំណូលទាបក្នុងតម្លៃមួយដ៏សមរម្យ ដើម្បីចូលរួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលកម្ពុជា។ រ.ទ.ស.ភ មានសមត្ថភាពផ្គត់ផ្គង់ទឹក ២៤ម៉ោង/ថ្ងៃ និង៧ថ្ងៃ/សប្ដាហ៍ ដោយក្នុងឆ្នាំនេះអាចធ្វើការផលិតទឹកស្អាតបានចំនួន ២៣៩.២០៨.៦៥៧ម$^{៣}$ ។

ការធ្វើប្រព្រឹត្តកម្មទឹកស្អាត គឺគោរពតាមស្តង់ដារគុណភាពទឹកជាតិ និងអង្គការសុខភាពពិភពលោក(WHO) ដោយមានបន្ទប់ពិសោធន៍គុណភាពទឹកអាចវិភាគបាន៥៣មុខ ជាមួយគ្នានេះយើងតែងតែបានធ្វើការវិភាគគុណភាពទឹក ពីមន្ទីរពិសោធន៍ ក្រៅប្រទេស(មន្ទីរពិសោធន៍ សិង្ហបុរី និងសៀងហៃ) ផងដែរ ។ ការយកចិត្តទុកដាក់លើគុណភាពទឹកនេះធ្វើឱ្យ រ.ទ.ស.ភ អាចធានាជូនអតិថិជនបាននូវការផឹកដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ ដើម្បីចូលរួមចំណែកក្នុងការទទួលខុសត្រូវចំពោះសង្គម ក្នុងគោលដៅជំរុញឱ្យប្រជាជនគ្រប់រូបមានទឹកស្អាតប្រើប្រាស់ ដែលជាកម្មវិធីទឹកស្អាតសម្រាប់ទាំងអស់គ្នា (Water for All) ដោយមានសេវាអនាម័យត្រឹមត្រូវ ដើម្បីការរស់នៅប្រកបដោយសុខមាលភាព មានជីវភាពល្អប្រសើរ និងមានបរិស្ថានល្អ។

ទិសដៅនៃការពង្រីកបណ្តាញចែកចាយទឹក គឺទៅតំបន់មានសក្តានុពលសេដ្ឋកិច្ច ដោយមិនមើលរំលងប្រជាពលរដ្ឋដែលមានចំណូលទាប ដោយក្នុងឆ្នាំ២០២២ នេះ រ.ទ.ស.ភ ដាក់បំពង់បានប្រវែង ៣៩៦.០៥៧,៨៣ម៉ែត្រ ដែលធ្វើឱ្យប្រវែងបំពង់មេ និងបំពង់ចែកចាយទឹកបច្ចុប្បន្នសរុបស្មើនឹងប្រមាណ ៤.២៤៥គីឡូម៉ែត្រ និងរក្សាសម្ពាធជាមធ្យម២០ម៉ែត្រក្នុងបណ្តាញចែកចាយទឹកទាំងមូល ដែលបំពង់ចាប់ពីទំហំ៦៣ម.ម ដល់ទំហំ១៦០០ម.ម ដោយ រ.ទ.ស.ភ បានធ្វើការដាក់ដោយខ្លួនឯង។យើងបានខិតខំធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាព សេវាអតិថិជនដើម្បីស្វែងរក និងបង្កើនចំនួនអតិថិជនធំៗដែលមានតម្រូវការទឹកច្រើន ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការប្រមូលប្រាក់ថ្លៃទឹកដែលអត្រាទារប្រាក់ក្នុងឆ្នាំនេះ រក្សាបានជាអតិបរិមា ហើយកំណើនបណ្តាញអតិថិជនសម្រាប់ចុងឆ្នាំ២០២២នេះ បានកើនឡើងដល់ចំនួន ៤៥១.៥៥៤ បណ្តាញ។

## ការរំពឹងទុកសម្រាប់ឆ្នាំ២០២៣

ចំពោះឆ្នាំ២០២៣ ខាងមុខ យើងនឹងខិតខំប្រឹងប្រែងព្យាយាមបន្ថែមទៀតដើម្បីធ្វើឱ្យកាន់តែប្រសើរក្នុងការពង្រឹងនូវអភិបាលកិច្ច សាជីវកម្មល្អរបស់ រ.ទ.ស.ភ ហើយនៅតែប្រកាន់ខ្ជាប់នូវទស្សនវិស័យ និងបេសកកម្ម ដែលបានលើកពីបណ្តាឆ្នាំមុនដដែល ។ ទិសដៅសម្រាប់ឆ្នាំ២០២៣ រ.ទ.ស.ភ សង្ឃឹមថានឹងទទួលបានប្រាក់ចំណេញពិត ប្រមាណ ១១៦.៧៨១.២៦០.០០០រៀល ដែលក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលបានអនុម័ត។

រ.ទ.ស.ភ. ក៏នៅតែប្តេជ្ញាចិត្តផ្តល់សេវាកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាពនិងប្រសិទ្ធភាព ដើម្បីផ្តល់ការជឿជាក់ពីអតិថិជន។ ជាងនេះទៅទៀត រ.ទ.ស.ភ នៅតែខិតខំផ្តល់បណ្តាញទឹកជូនប្រជាពលរដ្ឋដែលមាន ចំណូលទាបតាមរូបភាព ឧបត្ថម្ភថ្លៃសិទ្ធិជាវទឹក ស្របទៅតាមកម្រិតជីវភាពគ្រួសារនីមួយៗ ពី៣០% ៥០% ៧០% និង ១០០% ដើម្បីអនុវត្តគម្រោងចែកចាយទឹក ពិសេសជូនសហគមន៍ក្រីក្រ ដោយប្រើថវិការបស់ រ.ទ.ស.ភ ដើម្បីប្រយោជន៍ប្រជាជន។

## សេចក្តីថ្លែងអំណរគុណ

ជាថ្មីម្តងទៀត រ.ទ.ស.ភ មានសេចក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីរាជរដ្ឋាភិបាលក៏ដូចជាអាណាព្យាបាលទាំងពីរគឺ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសូមសម្តែងនូវអំណរគុណដល់ក្រុមប្រឹក្សាភិបាល ចំពោះការគាំទ្រ និង ការដឹកនាំល្អ សម្រាប់ឆ្នាំ២០២២ និង សូមថ្លែងអំណរគុណជូនចំពោះអតិថិជនទាំងអស់ដែលបានគាំទ្រ ដែលធ្វើឱ្យ រ.ទ.ស.ភ បានទទួលជោគជ័យដូចសព្វថ្ងៃនេះ។

ថ្ងៃពុធ ៥កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៣
**អគ្គនាយក រ.ទ.ស.ភ**

**ឡុង ណារ៉ូ**

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម i
ព័ត៌មានហិរញ្ញវត្ថុសង្ខេប ii
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប iii
សមាសភាពក្រុមប្រឹក្សាភិបាល iv
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល vi
សេចក្តីថ្លែងរបស់អគ្គនាយក xvii

**ផ្នែកទី១: ព័ត៌មានទូទៅពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** **០១**
ក- អត្តសញ្ញាណរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១
ខ- លក្ខណៈនៃធុរកិច្ច ០១
គ- សម្ព័ន្ធភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១
ឃ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ ០១
ង- ស្ថានភាពទីផ្សារ ០២
ច- ស្ថានភាពប្រកួតប្រជែង ០២
ឆ- ផែនការអនាគត ០២
ជ- កត្តាហានិភ័យ ០២

**ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** **០៨**
ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ០៨
ខ- រចនាសម្ព័ន្ធចំណូល ១០

**ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម** **១១**
ក- អង្គការលេខ ១១
ខ- ក្រុមប្រឹក្សាភិបាល ១២
គ- បុគ្គលិកជាន់ខ្ពស់ ១២

**ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** **១៤**
ក- ព័ត៌មានអំពីមូលបត្រ ១៤
ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ ១៤
គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ១៤
ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ១៤
ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ ១៥

**ផ្នែកទី៥: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង** **១៦**

**ផ្នែកទី៦: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ** **១៨**

**ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍** **២០**
ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ២០
ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ ២០
គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម ២០
ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់
និងភាគហ៊ុនិកដែមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ២០
ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជី
លក់មូលបត្រក្រុមហ៊ុនបុត្រសម្ព័ន្ធឬក្រុមហ៊ុនហូលឌីងរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ២០
ច- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល
ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជា អភិបាល ២០
ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម
ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពី រ.ទ.ស.ភ.  ២០
ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពី រ.ទ.ស.ភ.
ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ២០

**ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** **២១**
ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ២១
ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ២៥
គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ២៦
ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ២៦
ង- ផលប៉ះពាល់នៃអតិផរណា ២៦
ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ២៧

**ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** **២៨**

**ហត្ថលេខាអភិបាលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** **២៩**

ឧបសម្ព័ន្ធ១ ៖ របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២២
ឧបសម្ព័ន្ធ២ ៖ របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការប្រចាំឆ្នាំ២០២២
ឧបសម្ព័ន្ធ៣ ៖ របាយការណ៍ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ សម្រាប់
ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២
ឧបសម្ព័ន្ធ៤ ៖ លទ្ធផលពិនិត្យគុណភាពទឹក ពីរោងចក្រផលិតទឹកស្អាតចំការមន Test Report 7191297902-01-CHM22-PN

# ផ្នែកទី១: ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ក- អត្តសញ្ញាណ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

### PHNOM PENH WATER SUPPLY AUTHORITY (PPWSA)

- លេខកូដស្តង់ដារៈ KH1000010004
- ទីស្នាក់ការៈ អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- លេខទូរស័ព្ទៈ (៨៥៥) ៣១ ៣២២ ៦៣៤៥
- គេហទំព័រៈ www.ppwsa.com.kh អ៊ីម៉ែលៈ ir@ppwsa.com.kh
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មៈ Co.០៨៣៩Et/២០១២
  កាលបរិច្ឆេទៈ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២
- លេខអាជ្ញាបណ្ណអាជីវកម្មៈ អនុក្រឹត្យលេខ៥២អនក្រ.បក
  កាលបរិច្ឆេទៈ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខៈ ០១២/១២គ.ម.ក/ស.ស.រ.
  កាលបរិច្ឆេទៈ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២
- ឈ្មោះបុគ្គលតំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញៈ **ឯកឧត្តម ឡុង ណារ៉ូ**

## ខ- លក្ខណៈនៃធុរកិច្ច

- វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ
- ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើន ផលិតម្មសេវាកម្ម និង ធានាគុណភាព ទឹកស្អាតឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្មសេវាកម្មនិងឧស្សាហកម្ម ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុងឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយអនុលោមតាមច្បាប់
- សហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយដៃគូអភិវឌ្ឍក្នុង និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម
- ពង្រីកការផ្គត់ផ្គង់ទឹកនៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដាដូចគ្នានៅក្នុងរាជធានីភ្នំពេញ
- បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស
- វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក
- ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាញអង្គភាពទឹកស្អាតនានាដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក
- តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

## គ- សម្ព័ន្ធភាព រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំមានសម្ព័ន្ធភាពជាមួយក្រុមហ៊ុនណាមួយឡើយ។

## ឃ- ព្រឹត្តការណ៍សំខាន់ៗប្រចាំឆ្នាំ

កាលពីថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ នៅទីស្នាក់ការកណ្តាល រ.ទ.ស.ភ បានប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាគម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅរវាង រ.ទ.ស.ភ និងក្រុមហ៊ុន KKKCT CONSORTIUM ដែលជាហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាល អ៊ុំ សុថា** ។

គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅ មានទំហំការងារសាងសង់ដូចខាងក្រោម៖

- រោងចក្រប្រព្រឹត្តកម្មទឹកស្អាត មានសមត្ថភាពផលិត ៣០.០០០ ម៉ែត្រគូប/ថ្ងៃ
- ស្ថានីយបូមទឹកផៅសមត្ថភាព ៣៣.០០០ ម៉ែត្រគូប/ថ្ងៃ

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ឃ- ព្រឹត្តការណ៍សំខាន់ៗប្រចាំឆ្នាំ (ត)

- បំពង់មេនាំទឹកឆៅ
- អាងស្តុកទឹកស្អាត
- ម៉ូទ័របូមទឹកស្អាតចែកចាយ
- ប្រព័ន្ធ SCADA

គម្រោងនេះ ជាប្រភេទគម្រោង Special Purpose Company (SPC) លក់ជាដុំជូន រ.ទ.ស.ភ ក្នុងតម្លៃតូចជាង ឬមិនឱ្យលើសពី ៥០០រៀល/ម³ ដែលមានរយៈពេលអនុវត្តគម្រោង ១០ឆ្នាំ (ឆ្នាំ២០២៤ ដល់ឆ្នាំ២០៣៤)។ គម្រោងនឹងផ្តើមដំណើរការសាងសង់នាខែមិថុនា ឆ្នាំ២០២២ និងបញ្ចប់នាខែធ្នូ ឆ្នាំ២០២៤ ដោយក្រុមហ៊ុនម៉ៅការសាងសង់ KKKCT CONSORTIUM និងក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស CONSORTIUM OF NIHON SUIDO CONSULTANTS CO., LTD AND CROWN AGENTS JAPAN LIMITED របស់ប្រទេសជប៉ុន ក្នុងការត្រួតពិនិត្យគម្រោងសាងសង់។

## ង- ស្ថានភាពទីផ្សារ

ទីផ្សារផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺគ្រប់គ្រងតាមរយៈ "ផ្ទៃសេវា ១៤ខណ្ឌ និងក្រុងតាខ្មៅ" ដែលផ្គត់ផ្គង់ទឹកស្អាត ២៤ម៉ោងលើ២៤ម៉ោង ជូនប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដោយមានសម្ពាធទឹកផ្គត់ផ្គង់គ្រប់គ្រាន់ មានគុណភាពទឹកស្អាតស្របតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និងអង្គការWHO និងមានថ្លៃលក់ទឹកសមស្រប។

## ច- ស្ថានភាពប្រកួតប្រជែង

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគឺជាសហគ្រាសសាធារណៈ តែមួយគត់ (Monopoly) ក្នុងការធ្វើអាជីវកម្មនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលមានលក្ខណៈបច្ចេកទេស និងសេដ្ឋកិច្ច។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមិនធ្វើការប្រកួតប្រជែងលើថ្លៃលក់ទឹកនៅក្នុងទីផ្សារទេ និងមិនរងសម្ពាធផ្នែកនយោបាយ ទោះស្ថិតក្នុងដំណាក់កាលណាក៏ដោយ។

## ឆ- ផែនការអនាគត

- ជំរុញការតាមដាន និងអនុវត្តផែនការមេឆ្នាំ ២០២១-២០៣០ ដែលបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពកាលពីឆ្នាំ២០២១ ដើម្បីពង្រឹង និងពង្រីកសក្តានុពល និងវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ។
- កែសម្រួលឱ្យប្រសើរ និងធ្វើនវានុវត្តន៍លើបច្ចេកទេស និងបច្ចេកវិទ្យាក្នុងដំណើរការទូទៅរបស់សហគ្រាសក្នុងវិស័យទឹកស្អាត ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍន៍ឧស្សាហកម្ម ៤.០ ក្នុងការធានានូវនិរន្តរភាព និងដើម្បីចូលរួមកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី។
- បង្កើនប្រសិទ្ធភាពក្នុងការជួសជុលថែទាំប្រព័ន្ធប្រព្រឹត្តកម្ម និងប្រព័ន្ធផ្គត់ផ្គង់ ដើម្បីរក្សាអាយុកាល ប្រើប្រាស់ឱ្យបានយូរអង្វែង និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ២៤ម៉ោងលើ២៤ម៉ោង។
- ធ្វើបច្ចុប្បន្នភាព សិក្សា និងរៀបចំលើឯកសារបទដ្ឋានបច្ចេកទេសឱ្យមានលក្ខណៈស្តង់ដារ ដើម្បីធានានូវគុណភាពខ្ពស់របស់ប្រព័ន្ធផលិតកម្ម និងប្រព័ន្ធផ្គត់ផ្គង់ទឹក។
- កាត់បន្ថយការចំណាយណាដែលមិនចាំបាច់ និងបង្កើនប្រសិទ្ធភាពទារប្រាក់ថ្លៃប្រើប្រាស់ទឹក ព្រមទាំងខិតខំរកចំណូលពីសេវាកម្ម និងចំណូលផ្សេងៗឱ្យបានតាមផែនការ។
- ផ្តល់នូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច ដោយកាត់បន្ថយដើមទុន និងថ្លៃដើមប្រតិបត្តិការ។
- ធ្វើការកាត់បន្ថយអត្រាទឹកបាត់បង់ឱ្យបានកាន់តែស្ថិតក្នុងកម្រិតទាបដែលអាចធ្វើទៅបាន។

## ជ- កត្តាហានិភ័យ (ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់)

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទទួលបន្ទុកការងារផលិតកម្ម និងចែកចាយទឹកសម្រាប់ប្រើប្រាស់ទូទៅក្នុងការបម្រើដល់ផ្នែកសេវាកម្មសាធារណៈជាលក្ខណៈរដ្ឋបាល និងបច្ចេកទេស ដោយមានការធានាទាំងបរិមាណ និងគុណភាពទឹកស្អាតគ្មានមេរោគ ព្រមទាំងអាចផឹកបានពីបណ្តាញដោយផ្ទាល់។ ទោះជាយ៉ាងណាក៏នៅមានកត្តាហានិភ័យមួយចំនួន ដែលកំពុងជួបប្រទះ និងមានវិធានការទប់ស្កាត់ ដូចខាងក្រោម៖

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ជ- កត្តាហានិភ័យ (ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់) ត

### ជ.១- នាយកដ្ឋានផែនការ និងគម្រោង

➢ **ការវិភាគ**

**១-ការងារដាក់បំពង់ ២.០០០ មម ខ្វងក្រោមបាតទន្លេសាប ក្នុងគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ជំហានទី១ ៖**

ការងារខាងលើនេះ ត្រូវបានប៉ាន់ស្មានពន្យារពេលប្រមាណ ៤ខែ ដោយសារកត្តាបច្ចេកទេស បញ្ហាគ្រោះធម្មជាតិ ស្ថានភាពទឹកក្រោមដី ជំងឺឆ្លងកូវីដ១៩ និងស្ថានភាពនៃទីតាំងការដ្ឋានខ្វងអណ្តូង Launching Shaft។

**២-គម្រោងអភិវឌ្ឍកោះនរា**

ការចាក់ដីបំពេញ នៅតំបន់អភិវឌ្ឍកោះនរា បានធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹកទន្លេ នៅទីតាំងស្ថានីយបូមទឹកឆៅនិរោធ ដែលបានធ្វើឱ្យការចំណាយលើការប្រើប្រាស់វត្ថុធាតុដើម ក្នុងដំណើរការប្រព័ន្ធផលិតកម្ម មានការកើនឡើង និងប៉ះពាល់ដល់ថ្លៃដើមផលិតទឹកស្អាត។

**៣-តម្រូវការប្រើប្រាស់ទឹក៖**

កំណើនប្រជាពលរដ្ឋ ការពង្រីកនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងការពង្រីកផ្ទៃដីរដ្ឋបាលនៃរាជធានីភ្នំពេញ បានធ្វើឱ្យការផ្គត់ផ្គង់ទឹកស្អាត នៅក្នុងរាជធានីភ្នំពេញជួបបញ្ហាប្រឈមយ៉ាងខ្លាំង។ ជាក់ស្តែងបច្ចុប្បន្នតម្រូវការប្រើប្រាស់ទឹកស្អាតនៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ មានការកើនឡើងចំនួនប្រមាណ ៧៤៦.០០០ម៣/ថ្ងៃ ស្របនឹងសមត្ថភាពផលិតទឹកស្អាត ជាក់ស្តែងរបស់ រ.ទ.ស.ភ មានត្រឹមតែប្រមាណជាង ៦៣០.០០០ម៣/ថ្ងៃ ប៉ុណ្ណោះ។ ការតបណ្តាញទឹកស្អាត នៅតំបន់ជាយក្រុងមានចំនួនកើតឡើង ស្របពេលសំពាធទឹកផ្គត់ផ្គង់មិនទាន់គ្រប់គ្រាន់។

➢ **ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់**

**១- ការងារដាក់បំពង់ ២.០០០ មម ខ្វងក្រោមបាតទន្លេសាប ក្នុងគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ជំហានទី១ ៖**

បានសិក្សាដាក់បំពង់ជំទំហំ ១.៤០០ មម នៅលើបាតទន្លេ ដើម្បីផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋឱ្យបានទាន់ផែនការ និងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតរបស់ រ.ទ.ស.ភនាដើម ខែឧសភា ឆ្នាំ២០២៣។

**២-គម្រោងអភិវឌ្ឍកោះនរា ៖**

បន្តសហការជាមួយក្រុមហ៊ុន OCIC ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើស្ថានីយបូមទឹកឆៅ និងពន្លឿនការសាងសង់ស្ថានីយបូមទឹកឆៅថ្មី នៅកោះនរា។

**៣-តម្រូវការប្រើប្រាស់ទឹក៖**

- ជម្រុញ និងអនុវត្តស្របតាមផែនការមេឆ្នាំ២០២១ -២០៣០ របស់ រ.ទ.ស.ភ
- ជម្រុញ និងពន្លឿនគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង
- បន្តកែលម្អប្រព័ន្ធផលិតកម្ម និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដើម្បីធានាដល់ដំណើរការឱ្យមានប្រសិទ្ធភាព
- អនុវត្តវិធានការ និងបន្តផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ឱ្យមានការប្រើប្រាស់ទឹកសន្សំសំចៃ ដើម្បីចែករំលែកទឹកស្អាតដល់ប្រជាពលរដ្ឋដែលរស់នៅជាយក្រុង និងឆ្ងាយពីរោងចក្រទឹកស្អាត។

### ជ.២-នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម

➢ **ការវិភាគ**

ស្ថិតក្នុងកាលៈទេសៈអាកាសធាតុប្រែប្រួល ក៏ដូចជាស្ថានភាព ជំងឺ Covid-19 នៅមិនទាន់បាត់ទាំងស្រុង នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម បានគិតពិចារណា និងដាក់ចេញនូវការសម្រេចចិត្ត ដើម្បីអនុវត្តឱ្យខានតែបានក្នុងកាលវេលាដ៏លំបាកនេះ គឺ**ត្រូវតែផលិតទឹកចេញពីរោងចក្រឱ្យអស់សមត្ថភាព និងប្រកបដោយគុណភាព**។

## ជ- កត្តាហានិភ័យ (ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់) ត

### ជ.២-នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម (ត)

➤ **ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់**

ផ្តើមចេញពីការគិតគូរខាងលើនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្មបានសំឡឹងមើលឃើញ និងយកចិត្តទុកដាក់លើប្រព័ន្ធដំណើរការរោងចក្រផលិតទឹកក្នុងទិដ្ឋភាពជាច្រើនក្នុងនោះ ៖

**ក-មនុស្ស (Operator)** : និយោជិតដំណើរការរោងចក្រ ត្រូវតែការពារឃុំគ្រងឱ្យមានសុខសុវត្ថិភាព។

**ខ-គ្រឿងចក្រ (Machine and Spair Part)** : គ្រឿងចក្រនៅតាមរោងចក្រ ត្រូវតែដំណើរការមិនឱ្យអសកម្ម និងមានគ្រឿងបន្លាស់គ្រប់គ្រាន់សម្រាប់ជួសជុលផ្លាស់ប្តូរ ក្នុងករណីមានគ្រឿងចក្រណាមួយ អសកម្មកើតមានឡើងជាយថាហេតុ។

**គ-វត្ថុធាតុដើម (PAC, Salt, Chlorine & Reagent)** : ទឹកផលិតចេញពីរោងចក្រ ត្រូវតែមានគុណភាព ស្របតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និង WHO ដូច្នោះវត្ថុធាតុដើមបម្រើឱ្យការផលិតទឹក ត្រូវតែមានបរិមាណប្រើប្រាស់គ្រប់គ្រាន់នៅក្នុងឃ្លាំងស្តុក។

### ជ.៣-នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធ ផ្គត់ផ្គង់ទឹក

➤ **ការវិភាគ**

**១- ការិយាល័យស្រាវជ្រាវទឹកបាត់បង់**

- ការតបណ្តាញទឹកស្អាតបន្ថែមនៅតាមតំបន់ជាយក្រុងឆ្ងាយៗ ដែលធ្វើឱ្យសម្ពាធខ្សោយ មិនអាចផ្គត់ផ្គង់ជូនអតិថិជនទៅតាមតម្រូវការ ដែលនាំឱ្យមានការតវ៉ាពីអតិថិជន។
- ការលេចធ្លាយនៅលើរណ្តៅកៅស៊ូ និងបេតុងអាម៉េ ដែលមានកម្រាស់ក្រាស់ៗ ធ្វើឱ្យពិបាកក្នុងការស្តាប់ និងស្វែងរកចំណុចលេចធ្លាយ ដោយត្រូវប្រើប្រាស់ពេលយូរក្នុងការរុករក ដើម្បីជួសជុល។
- ចំនួននៃការលេចធ្លាយភាគច្រើនបណ្តាលមកពីបំពង់ដែលមានអាយុកាលចាស់ និងកត្តាសម្ភារមួយភាគច្រើនលើបណ្តាញចូលផ្ទះទំហំទុយោពី ២៥មម ដល់ ៣២មម ដែលបានដំឡើងក្នុងឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០០។

**២-ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក**

តាមបណ្តាការដ្ឋានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យ ក្នុងរាជធានីភ្នំពេញគ្រប់ទីកន្លែង មានដូចជា ៖ ការកែសម្រួលប្រព័ន្ធលូ ធ្វើផ្លូវ និងពង្រីកផ្លូវ ដីកដាក់ប្រព័ន្ធខ្សែក្រោមដីគ្រប់ប្រភេទ ដោយមិនមានការជូនដំណឹងឱ្យបានទាន់ពេលវេលា ដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធចាយចាយទឹករបស់អង្គភាពយើង។

**៣-ការិយាល័យថែទាំប្រព័ន្ធមេនាំទឹក**

សម្ភារបរិក្ខារប្រព័ន្ធមេនាំទឹកមួយចំនួនមានសភាពចាស់ ដុះស្នឹម ច្រែះស៊ី អាចបណ្តាលឱ្យផ្ទុះបែកបំពង់ និងខកខានក្នុងការផ្គត់ផ្គង់ជូនអតិថិជន។

➤ **ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់**

**១-ការិយាល័យស្រាវជ្រាវទឹកបាត់បង់**

- សម្រាប់នៅតំបន់ជាយក្រុង គួររង់ចាំមានសម្ពាធទឹកគ្រប់គ្រាន់ និង ការដាក់ឱ្យដំណើរការជាផ្លូវការនូវរោងចក្រផលិតទឹកស្អាតបាក់ខែងដំហានទី១ នាពេលខាងមុខនេះ។
- ពិនិត្យលទ្ធភាពចុះសិក្សា ស្រាវជ្រាវពេលយប់ និងមានមធ្យាបាយគ្រប់គ្រាន់សម្រាប់បម្រើឱ្យការងារនេះ។
- ពិនិត្យលទ្ធភាពផ្លាស់ប្តូរបំពង់ចាស់ចេញ និងពិនិត្យគុណភាពសម្ភារនេះឡើងវិញ ដោយដាក់ជំនួសវិញនូវសម្ភារថ្មី និងគុណភាពល្អ ដើម្បីកាត់បន្ថយការលេចធ្លាយបន្តទៀត។

**២- ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក**

បន្តកិច្ចសហការជាមួយអាជ្ញាធរដែនដីឱ្យបានល្អ ដើម្បីជូនដំណឹងឱ្យបានទាន់ពេលវេលា។ ទន្ទឹមនឹងនេះដែរក៏មានការពិន័យយ៉ាងធ្ងន់ធ្ងរ ដល់អ្នកបង្កផលប៉ះពាល់ដល់ប្រព័ន្ធចែកចាយទឹករបស់អង្គភាពផងដែរ។ម្យ៉ាងវិញទៀត រាល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទាំងអស់ក៏មានចាត់កម្លាំងចុះប្រចាំការតាមការដ្ឋាននានា ដើម្បីបញ្ចៀសរាល់ការប៉ះពាល់ដល់បណ្តាញទឹក ឱ្យនៅទាបបំផុតដែលអាចធ្វើទៅបាន។

# ផ្នែកទី១: ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ជ- កត្តាហានិភ័យ (ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់) ត

### ជ.៣-នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធ ផ្គត់ផ្គង់ទឹក (ត)

### ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់ (ត)

**៣-ការិយាល័យថែទាំប្រព័ន្ធមេនាំទឹក**

បន្តជួសជុល ថែទាំ លាបថ្នាំថ្មីឡើងវិញ ដើម្បីធានាបាននូវសុវត្ថិភាពរបស់បំពង់ និងបរិក្ខារទាំងអស់នោះ។

### ជ.៤-នាយកដ្ឋានអាជីវកម្ម

➢ ការវិភាគ

**១-ការិយាល័យចំណូល**

- យន្តការគ្រប់គ្រងការងារអានលេខ ចេញវិក្កយបត្របម្រើសេវាកម្មជាមួយអតិថិជន និងការជំរុញបំណុលថ្លៃទឹកនៅមានកម្រិត។
- ពេលឈឺ ឬមានគ្រោះថ្នាក់ផ្សេងៗ ពុំមានអ្នកជំនួស (ភ្នាក់ងារអានលេខ និងចែកវិក្កយបត្រទឹក)។
- ភ្នាក់ងារអានលេខ ប្រឈមនឹងការបាត់បង់មធ្យោបាយធ្វើដំណើរពេលចុះបំពេញភារកិច្ច។

**២-ការិយាល័យទំនាក់ទំនងអតិថិជន**

- ការយល់ដឹងពីបច្ចេកទេស និងបច្ចេកវិទ្យាស្តីអំពី Smart Meter នៅមានកម្រិត។
- ក្រុមជម្រុញ និងផ្អាកការផ្គត់ផ្គង់ទឹក ជួបបញ្ហាប្រឈមជាមួយអតិថិជន ពេលចុះបំពេញភារកិច្ច។
- ការងារកែសម្រួលទីតាំងនាឡិកាទឹក មានការលំបាកដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់និងលំនៅដ្ឋាន។
- ឧបករណ៍សម្រាប់វាស់ស្ទង់នាឡិកាទឹក មានតែក្រោមទំហំ ១៥០ មម លើសពីនេះពុំមាន។

**៣-ការិយាល័យបណ្តាញចូលផ្ទះ**

- ការគ្រប់គ្រងចរន្តការងារ និង បច្ចេកទេសតបណ្តាញចូលផ្ទះ នៅខ្វះចន្លោះលើការងារត្រួតពិនិត្យតាមដានលទ្ធផល និងគុណភាព។
- គ្រប់ការិយាល័យ នៃនាយកដ្ឋានអាជីវកម្ម មានការប្រឈមជាមួយនឹងបញ្ហាជំងឺកូវីដ-១៩ ផងដែរ។

➢ ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់

**១-ការិយាល័យចំណូល**

- ពង្រឹងវិន័យ ការត្រួតពិនិត្យទិន្នផលការងារជាប្រចាំ កែសម្រួលទម្រង់សេវាអតិថិជន កែសម្រួលក្រុមជំរុញ និង Spot Check របស់ថ្នាក់នាយកដ្ឋានចំពោះបំណុលធំៗ។
- រំលឹកណែនាំដល់ភ្នាក់ងារជាប្រចាំ ឱ្យគោរពច្បាប់ចរាចរណ៍ និងទុកដាក់មធ្យោបាយឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ប្រជុំជាស់តឿន និងណែនាំដល់ភ្នាក់ងារហាមប៉ះពាល់ប្រាក់បញ្ញើថ្លៃទឹករបស់អតិថិជន ដែលបានផ្ញើមកតាមយើង និងពិនិត្យតាមដានជាប្រចាំ នៅអតិថិជនពុំទូទាត់ថ្លៃទឹក
- ពិនិត្យតាមដានអតិថិជនប្រើប្រាស់ទឹកច្រើន ដើម្បីអញ្ជើញអតិថិជនមកបង់ប្រាក់កក់បន្ថែម ឱ្យបានគ្រប់គ្រាន់តាមគោលការណ៍អង្គភាព។

**២- ការិយាល័យទំនាក់ទំនងអតិថិជន**

- បើកវគ្គបណ្តុះបណ្តាលស្តីពីការថែទាំនាឡិកា Smart Meter ដល់មន្ត្រី-និយោជិតដែលពាក់ព័ន្ធ។
- ធ្វើការផ្សព្វផ្សាយជូនដល់អតិថិជន ឱ្យដឹងអំពីការប្រើប្រាស់ Mobile App របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលនឹងដាក់ឱ្យប្រើប្រាស់នាពេលខាងមុខ។

**៣-ការិយាល័យបណ្តាញចូលផ្ទះ**

- របាយការណ៍ប្រចាំសប្តាហ៍ ដោយផ្ទៀងផ្ទាត់ទទួលពាក្យតបណ្តាញចូលផ្ទះនៅសល់ និងប្រាប់ពីមូលហេតុ។
- រូបថតក្នុងការតបណ្តាញថ្មី និងព័ត៌មានអតិថិជនដាក់ក្នុង SOP។
- បន្តផ្សព្វផ្សាយដល់មន្ត្រី-និយោជិតទាំងអស់ ឱ្យរក្សាអនាម័យល្អ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងការណែនាំនានារបស់ក្រសួងសុខាភិបាល ៣ការពារ ៣កុំ ក្នុងវិធានការការពារនូវការចម្លងជំងឺកូវីដ-១៩។

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ជ- កត្តាហានិភ័យ (ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់) ត

### ជ.៥-មណ្ឌលព័ត៌មានវិទ្យា

➢ **ការវិភាគ**

- ប្រតិបត្តិការប្រចាំថ្ងៃមួយចំនួនតូចអាចមិនទាន់បញ្ចប់ទៅតាមការកំណត់។
- ចរន្តអគ្គិសនីដាច់រយៈពេលលើសពី ០២ ម៉ោង តម្រូវឱ្យយើងត្រូវបិទម៉ាស៊ីនមេទាំងអស់ក្នុងមណ្ឌលទិន្នន័យ ដោយអាគុយរបស់យើងអាចផ្គត់ផ្គង់ចរន្តអគ្គិសនីបានត្រឹមតែ ០២ ម៉ោង ប៉ុណ្ណោះ។

➢ **ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់**

មានការត្រួតពិនិត្យ Job Queue ជាប្រចាំ (រៀងរាល់ម៉ោង ០៨:៣០, ១២:០០ និង១៦:៣០)

### ជ.៦-នីតិកម្ម និងអធិការកិច្ច

➢ **ការវិភាគ**

មិនមានមេធាវីប្រចាំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បន្ទាប់ពីបានបញ្ចប់អាណត្តិដែលធ្វើឱ្យមានការប្រឈមការងារ ផ្លូវច្បាប់ក្នុងការដោះស្រាយជាមួយអតិថិជន ដែលមានឥរិយាបទរឹងទទឹងតាមគោលការណ៍ រ.ទ.ស.ភ។ កង្វះកម្លាំងចុះសហការជាមួយបណ្តានាយកដ្ឋានពាក់ព័ន្ធ

➢ **ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់**

- ស្នើសុំមេធាវីប្រចាំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។
- ត្រូវមានកម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកច្បាប់

➢ **សំណូមពរ**

- ស្នើសុំការចូលរួមសហការពីបណ្តានាយកដ្ឋានជំនាញពាក់ព័ន្ធ។
- ស្នើសុំកម្លាំងបន្ថែម។

### ជ.៧-អង្គភាពលទ្ធកម្ម

➢ **ការវិភាគ**

**១-ជាតុបណ្តុំកករ (PAC)**

ការផ្គត់ផ្គង់ជាតុបណ្តុំកករ (PAC) ដោយសារជាតុបណ្តុំកករ (PAC) មានប្រភពនៅប្រទេសចិន ក្នុងឆ្នាំ ២០២២ ផ្ទុះនូវការឆ្លងរាលដាលជាសកលជម្ងឺ Covid-19 (ករណីប្រធានសក្តិ) ដែលធ្វើឱ្យមានការបារម្ភពី ការផលិត និងដឹកជញ្ជូនមានការយឺតយ៉ាវធ្វើឱ្យប៉ះពាល់ដល់ដំណើរការផលិតកម្ម។

សម្រាប់ផែនការឆ្នាំ២០២២ ការត្រូវធ្វើសំណាកគំរូ (PAC) ទៅមន្ទីរពិសោធន៍ SGS នៅប្រទេសចិន ដោយសារជម្ងឺ Covid-19 រាលដាលជាសកល ស្ថាប័នគយប្រទេសចិនពុំអនុញ្ញាតឱ្យយកសំណាកគំរូ (PAC) ចេញឡើយ ដោយសារកញ្ចប់បញ្ញើរបស់យើងជាផលិតផលគីមី ធ្វើឱ្យមានការយឺតយ៉ាវក្នុងការចុះកិច្ចសន្យា និងផ្គត់ផ្គង់។

**២-អំបិលសម្រាប់ផលិតក្លរ៉ទឹក**

ការផ្គត់ផ្គង់អំបិលសម្រាប់ផលិតក្លរ៉ទឹកដោយសារអំបិលសម្រាប់ផលិតក្លរ៉ទឹក មានប្រភពនៅប្រទេសចិន ដែលក្នុងឆ្នាំ២០២២ ផ្ទុះនូវការឆ្លងរាលដាលជាសកលនៃជម្ងឺ Covid-19 (ករណីប្រធានសក្តិ) មានក្តីបារម្ភពីការផលិត និងដឹកជញ្ជូនមានការយឺតយ៉ាវធ្វើឱ្យប៉ះពាល់ដល់ដំណើរការផលិតកម្ម។

➢ **ទស្សនៈអ្នកគ្រប់គ្រង និងវិធាការទប់ស្កាត់**

**ក-ជាតុបណ្តុំកករ (PAC)**

ក្នុងបរិបទ (ប្រធានសក្តិ) អង្គភាពលទ្ធកម្មបានសហការជាមួយនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម សិក្សាពីល្បឿននៃការប្រើប្រាស់ប្រចាំថ្ងៃ ស្ថានភាពឃ្លាំងស្តុកអតិបរិមានៃជាតុបណ្តុំកករ (PAC) និងបានស្នើសុំគោលការណ៍បញ្ជាទិញនូវចំនួនអតិបរិមា ដើម្បីបំរុងទុកបានទាន់ពេល និងបានស្រាវជ្រាវពីលទ្ធភាពនៃការទិញពីប្រទេសផ្សេង ក្នុងករណីចាំបាច់បន្ទាន់។

## ជ- កត្តាហានិភ័យ (ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់) ត

### ជ.៧-អង្គភាពលទ្ធកម្ម (ត)

- **ទស្សនៈអ្នកគ្រប់គ្រង និងវិធាការទប់ស្កាត់ (ត)**

**ខ- អំបិលសម្រាប់ផលិតក្លរ៉ទឹក**

ក្នុងបរិបទឆ្លងរាលដាលជាសកលនៃជម្ងឺ Covid-19 (ប្រធានសក្តិ) ការដឹកជញ្ជូនអំបិលពីប្រទេសចិន មានការយឺតយ៉ាវដោយសារក្រុមហ៊ុនដឹកជញ្ជូនកាត់បន្ថយជើងដឹកជញ្ជូន ដើម្បីផ្គត់ផ្គង់បានទាន់ពេលវេលា អ្នកផ្គត់ផ្គង់បានស្នើសុំគោលការណ៍ប្តូរប្រភពអំបិលពីប្រទេសចិន មកអំបិលប្រភពពីប្រទេសថៃវិញ។

សម្រាប់ផែនការឆ្នាំ២០២២ ដោយសារស្ថាប័នគយប្រទេសចិនមានការរឹតត្បិតលើការនាំចូលទំនិញ ដែលមានលក្ខណៈគីមី ម្យ៉ាងទៀតក្រុមហ៊ុនដែលចូលរួមដេញថ្លៃផ្គត់ផ្គង់ជាតុបណ្តុំកករ (PAC) និងអំបិល សុទ្ធតែមានប្រភពផលិតនៅប្រទេសចិនដូចគ្នា ដូច្នេះដើម្បីសម្រួលឱ្យការធ្វើតេស្តសំណាកគំរូ និងឈានដល់ ការចុះកិច្ចសន្យាបានទាន់ពេលវេលា អង្គភាពលទ្ធកម្មបាននឹងស្នើសុំគោលការណ៍អនុញ្ញាតពី **ឯកឧត្តមអគ្គនាយក** ឱ្យក្រុមហ៊ុនទាំងនោះយកសំណាកគំរូជាតុបណ្តុំកករ (PAC) ឬអំបិលពីរោងចក្រផលិតបញ្ជូន ទៅមន្ទីរពិសោធន៍ SGS នៅប្រទេសចិនដោយផ្ទាល់ រីឯលទ្ធផលតេស្តរបស់មន្ទីរពិសោធន៍ SGS ផ្ញើរផ្ទាល់មក រ.ទ.ស.ភ ។

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

## ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់

### ក.១.១- លទ្ធផលការងារប្រព្រឹត្តកម្ម

ការប្រព្រឹត្តកម្មទឹកស្អាតនៅក្នុងឆ្នាំ២០២២ នេះ មានដូចក្នុងតារាងខាងក្រោម៖

| **បរិយាយ** | **ផែនការ** (គិតជាម៉ែត្រគូប) | **អនុវត្តជាក់ស្តែង** (គិតជាម៉ែត្រគូប) | **អត្រា** (គិតជា %) |
|---|---|---|---|
| រោងចក្រភូមិព្រែក | ៥៧.១៦៤.000 | ៦១.៨៤៥.៣៤៨ | ១០៨ |
| រោងចក្រជ្រោយចង្វារ | ៦០.៩៥៥.៥00 | ៦៤.៦១៩.២៨២ | ១០៦ |
| រោងចក្រចំការមន | ១៩.៣៩0.៥00 | ២១.៣៦៥.៤១២ | ១១០ |
| រោងចក្រនិរោធ | ៩0.៤៦៥.000 | ៩0.៦៨0.៤៩0 | ១00 |
| រោងចក្រម្លេច | ៣៩៥.១១៤ | ៤១៤.៤៥៩ | ១0៥ |
| រោងចក្រត្បូងឃ្មុំ | ៣៦៥.៥00 | ២៨៣.៦៦៦ | ៧៨ |
| **សរុប** | **២២៨.៧៣៥.៦១៤** | **២៣៩.២0៨.៦៥៧** | **១0៥** |

គុណភាពទឹកតាមបណ្តារោងចក្រប្រព្រឹត្តកម្មទឹកស្អាត និងបណ្តាញចែកចាយ៖

| មុខវិភាគ | ឯកតា | WHO | រោងចក្រ ភូមិព្រែក | រោងចក្រ ជ្រោយចង្វារ | រោងចក្រ ចំការមន | រោងចក្រ និរោធ | រោងចក្រ ម្លេច | រោងចក្រ ត្បូងឃ្មុំ | បណ្តាញចែកចាយ |
|---|---|---|---|---|---|---|---|---|---|
| **ភាពល្អក់** | NTU | ≤ ៥ | 0,៥១ | 0,៥២ | 0,១៨ | 0,៣៧ | 0,៥0 | 0,៦0 | 0,៥៨ |
| **តម្លៃប៉េហាស់** | pH | ៦,៥ - ៨,៥ | ៧,៤៩ | ៧,៩១ | ៧,៥២ | ៧,៤៩ | ៧,២៤ | ៧,៦0 | ៧,៣៦ |
| **ក្ល័រសេរី** | mg/l | 0,១ - ១ | ១,៦៣ | ១,៣២ | ១,២៣ | ១,៤៣ | ១,១៦ | 0,៧៥ | 0,៤៧ |
| **ក្ល័រសរុប** | mg/l | <២ | ១,៨៤ | ១,៤៨ | ១,៤១ | ១,៥៩ | ១,៤១ | 0,៩១ | 0,៥៩ |
| **មេរោគកូលីហ្វម** | cfu/100ml | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **មេរោគអ៊ីកូលី** | cfu/100ml | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

### ក.១.២- លទ្ធផលការងាររៀបចំ ប្រព័ន្ធចែកចាយទឹកស្អាត

ប្រវែងបំពង់ដែលបានដាក់តាមឆ្នាំនីមួយៗ (គិតជាគីឡូម៉ែត្រ)



## ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ( ត )

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹកនិងការងារកាត់បន្ថយទឹកបាត់បង់ (ត)

### ក.១.៣- លទ្ធផលការងារកាត់បន្ថយទឹកបាត់បង់

អត្រាទឹកបាត់បង់របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅមានកម្រិតនៅក្នុងរង្វង់លេខមួយខ្ទង់ប៉ុណ្ណោះ ពោលគឺបានបន្ថយទឹកបាត់បង់មកនៅត្រឹមអត្រា ៨,៥០% ដូចបានបង្ហាញក្នុងក្រាហ្វិចខាងក្រោម។




### ក.២- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម

### ក.២.១- ការងារផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋមានចំណូលទាប




### ក.២.២- ការងារតបណ្តាញចូលផ្ទះ និងការគ្រប់គ្រងអតិថិជន

| ប្រភេទអតិថិជន | ២០១៧ (ចំនួនបណ្តាញ) | ២០១៨ (ចំនួនបណ្តាញ) | ២០១៩ (ចំនួនបណ្តាញ) | ២០២០ (ចំនួនបណ្តាញ) | ២០២១ (ចំនួនបណ្តាញ) | ២០២២ (ចំនួនបណ្តាញ) | ២០២២ (ភាគរយ) |
|---|---|---|---|---|---|---|---|
| ជីវភាព | ២៧១.៣១៧ | ៣០១.៨៣៤ | ៣២១.២១២ | ៣៣៣.០៩៩ | ៣៥០.៤៦៣ | ៣៦០.៩៤៨ | ៧៩,៩៣៤៦ |
| អាជីវកម្ម | ៥៥.៨៩១ | ៥៨.៧៨៩ | ៦២.៣៦៦ | ៦៨.១៣៦ | ៧៤.៣៤៤ | ៨៣.៨៧៤ | ១៨,៥៧៤៥ |
| អង្គភាពរដ្ឋ | ៦៥៥ | ៦៦៤ | ៦៩៦ | ៧៤៤ | ៨២៣ | ៩១៣ | ០,២០២២ |
| អ្នកលក់ទឹក | ០៨ | ០៧ | ០៧ | ១០ | ១១ | ០៩ | ០,០០២០ |
| តំណាងចែកចាយ | ២០ | ២១ | ១៧ | ១៤ | ១៦ | ០៥ | ០,០០១១ |
| Standpipe | - | ១៤ | ១៧ | ១៧ | ១៦ | ១៦ | ០,០០៣៥ |
| បន្ទប់ជួល | ៥.៣៩៧ | ៥.៧០៣ | ៥.៧៥២ | ៥.៧៥៩ | ៥.៧២៨ | ៥.៧៨៩ | ១,២៨២០ |
| **សរុប** | **៣៣៣.២៨៨** | **៣៦៧.០៣២** | **៣៩០.០៦៧** | **៤០៧.៧៧៩** | **៤៣១.៤០១** | **៤៥១.៥៥៤** | |

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ( ត )

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ក.៣- ការងារគ្រប់គ្រងធនធានមនុស្ស




## ខ- រចនាសម្ព័ន្ធចំណូល

| ល. រ | ប្រភពចំណូល | ឆ្នាំ២០២២ | | ឆ្នាំ២០២១ | | ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|---|
| | | ( ពាន់រៀល ) | ភាគរយ | ( ពាន់រៀល ) | ភាគរយ | ( ពាន់រៀល ) | ភាគរយ |
| ១ | ចំណូលពីការលក់ | ២៩៩.៧២៣.៥០៧ | ៨៦,៥៨% | ២៨២.៣៦៩.៧៩៧ | ៧៦,៤៩% | ២៨១.៦៤៩.៣៣៨ | ៨៦,៨៣% |
| ២ | កម្រៃពីសេវាសាងសង់ | ២៤.៩៧៦.៣១៦ | ៧,២១% | ២៦.២៤១.៩៨៩ | ៧,១១% | ២៣.៣២៤.២២៨ | ៧,៩១% |
| ៣ | ចំណូលពីការប្តូររូបិយប័ណ្ណ-សុទ្ធ | - | - | ២.២៧៣.៩៨៤ | ០,៦២% | - | - |
| ៤ | ចំណូលផ្សេងៗ | ២១.៤៧៨.៣៣៣ | ៦,២១% | ៥៨.២៥៩.៤៨៧ | ១៥,៧៨% | ១៩.៣៩៤.២៩០ | ៥,៩៨% |
| | **ចំណូលសរុប** | **៣៤៦.១៧៨.១៥៦** | | **៣៦៩.១៤៥.២៥៧** | | **៣២៤.៣៦៧.៨៥៦** | |

# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក- អង្គការលេខ



# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម (ត)

## ខ- ក្រុមប្រឹក្សាភិបាល

| ល.រ. | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ<br>ក្លាយជាអភិបាល | កាលបរិច្ឆេទ<br>បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម ស៊ឹម ស៊ីថា * | ប្រធានក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ២ | ឯកឧត្តម ឡុង ណារ៉ូ * | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៣ | ឯកឧត្តម ម៉ី វ៉ាន់ * | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៤ | ឯកឧត្តម នួន ផារ័ត្ន * | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៥ | លោក ម៉ា ណូរ៉ាវីន ** | សមាជិកក្រុមប្រឹក្សាភិបាល | ២៧/០២/២០២៣ | ២៧/០២/២០២៦ |
| ៦ | លោក ស្រេង សំឱក | អភិបាលឯករាជ្យ | ១៣/០៥/២០២២ | ១៣/០៥/២០២៥ |
| ៧ | លោក ណាំ ចន្ទ្រី | អភិបាលមិនប្រតិបត្តិ<br>តំណាងភាគហ៊ុនិកឯកជន | ១៣/០៥/២០២២ | ១៣/០៥/២០២៥ |

- ឈ្មោះលេខាធិការសហគ្រាសរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ:
  - **លោក ជូ ផល្លា**
  - **លោក ហួត សុខហេង**

សម្គាល់៖

* យោងតាមអនុក្រឹត្យលេខ ៣១អនក្រ.តត ចុះថ្ងៃសុក្រ ១៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨។

** យោងលក្ខន្តិកៈរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ និងយោងកំណត់ហេតុស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងនិយោជិតអាណត្តិទី៨ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចុះថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣

## គ- បុគ្គលិកជាន់ខ្ពស់

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | ឯកឧត្តម ឡុង ណារ៉ូ | ប្រុស | អគ្គនាយក |
| ២ | ឯកឧត្តម នេត មុន្នី | ប្រុស | មន្ត្រីត្រួតពិនិត្យរដ្ឋ |
| ៣ | លោកសំរិទ្ធ សុរិទ្យា | ប្រុស | អគ្គនាយករង |
| ៤ | លោក ចាន់ ពិសិដ្ឋ | ប្រុស | អគ្គនាយករង |
| ៥ | លោក ម៉ា ណូរ៉ាវីន | ប្រុស | អគ្គនាយករង |
| ៦ | លោកស្រី រឿន ណារី | ស្រី | អគ្គនាយករង |
| ៧ | លោក ជា សតិភទ្ទ | ប្រុស | អគ្គនាយករង |
| ៨ | លោក ផេង ទី | ប្រុស | អគ្គនាយករង |
| ៩ | លោក ដេង ប៉ូលីដែន | ប្រុស | អគ្គនាយករង និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន |
| ១០ | លោក ជូ ផល្លា | ប្រុស | លេខាធិការសហគ្រាស និងជាបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន |
| ១១ | លោក ហួត សុខហេង | ប្រុស | លេខាធិការសហគ្រាស |
| ១២ | លោក សោម សុវណ្ណ | ប្រុស | ប្រធាននាយកដ្ឋានអាជីវកម្ម |
| ១៣ | លោកស្រី សេង គាតាព | ស្រី | ប្រធានសវនកម្មផ្ទៃក្នុង |
| ១៤ | លោក សារ៉ុជ វឌ្ឍនា | ប្រុស | ប្រធានមណ្ឌលព័ត៌មានវិទ្យា |
| ១៥ | ហេង សុផាន់ណារ៉ាត | ប្រុស | ប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស |
| ១៦ | លោក អ៊ូ គុណវឌ្ឍន៍ | ប្រុស | ប្រធាននាយកដ្ឋានផែនការ និងគម្រោង |

# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម (ត)

## គ- បុគ្គលិកជាន់ខ្ពស់ (ត)

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១៧ | លោក សុខ ណារ៉េត | ប្រុស | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ |
| ១៨ | លោក ឈឹម សេរ៉ីផ | ប្រុស | ប្រធាននីតិកម្ម និងអធិការកិច្ច |
| ១៩ | លោក ទុយ ប៊ុនសេរីរិទ្ធ | ប្រុស | ប្រធាននាយកដ្ឋានសាខាសេវាកម្មទឹកស្អាត |
| ២០ | លោក កាំង សោភីណា | ប្រុស | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក |
| ២១ | លោក កែម កានវិចិត្រ | ប្រុស | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម |
| ២២ | លោកស្រី ស៊ឹម វល្លិកា | ស្រី | ប្រធានអង្គភាពលទ្ធកម្ម |
| ២៣ | លោក មាស កុសល | ប្រុស | ជំនួយការអគ្គនាយករងទទួលបន្ទុកផែនការ និងគម្រោង |
| ២៤ | លោកស្រី ប្រាក់ ចាន់មករា | ស្រី | ជំនួយការអគ្គនាយក |
| ២៥ | លោក រស់ បូរិន្ទ | ប្រុស | ជំនួយការអគ្គនាយក |

សម្គាល់: ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាឧបសម្ព័ន្ធ១។

# ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក

## ក- ព័ត៌មានអំពីមូលបត្រ

### ១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

- ឈ្មោះមូលបត្រកម្មសិទ្ធិ: ភាគហ៊ុនធម្មតា
- និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ: PWSA
- ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ: មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត
- តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: ១.០០០រៀល
- ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (IPO Price): ៦.៣០០រៀល
- បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ: ១៣.០៤៥.៩៧៥មូលបត្រកម្មសិទ្ធិ
- មូលធនូបនីយកម្មទីផ្សារ: ៦៥៧.៥១៧.១០៤.៧២០រៀល (ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២)
- ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត: ផ្សារមូលបត្រកម្ពុជា (ផមក)
- កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ: ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២

## ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ៧.១៨០ | ៧.៥០០ | ៧.៨៦០ | ៧.៦៨០ | ៧.៨០០ | ៧.៥០០ |
| | មធ្យម | ៧.១១៤ | ៧.២១៦ | ៧.៦៨០ | ៧.៦០១ | ៧.៧០៣ | ៧.៤៧៥ |
| | អប្បបរមា | ៧.០០០ | ៧.០៦០ | ៧.៤០០ | ៧.៣៦០ | ៧.៥២០ | ៧.៤២០ |
| បរិមាណជួញដូរ | អតិបរមា | ៤៨.២២៦ | ៥៩.៩៣៣ | ៣៣.៥៧២ | ១៣.៧៤៣ | ៧៤.១៧០ | ៨.៩៩២ |
| | មធ្យម | ១២.២០៦ | ១០.៨២៣ | ៧.៦៣៦ | ៤.២២៩ | ១០.០៣៩ | ២.៦៦៥ |
| | អប្បបរមា | ២១៤ | ៦៨៤ | ១.៤៨៥ | ២៨៧ | ៦១៩ | ១៥២ |

| មូលបត្រកម្មសិទ្ធិ | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ៧.៥០០ | ៧.៥០០ | ៧.៤៦០ | ៧.៤៦០ | ៧.៥០០ | ៧.៥៦០ |
| | មធ្យម | ៧.៤៥៤ | ៧.៤៣៤ | ៧.៤៣៦ | ៧.៣៨៨ | ៧.៤២០ | ៧.៤៧៤ |
| | អប្បបរមា | ៧.៤០០ | ៧.៤០០ | ៧.៣៨០ | ៧.២៨០ | ៧.៣០០ | ៧.៤០០ |
| បរិមាណជួញដូរ | អតិបរមា | ៦.៥៥១ | ៤.៧៤៣ | ១០០.០៦០ | ១១.៧៧៤ | ៥.៦៨០ | ១៦.១២៤ |
| | មធ្យម | ១.៣២៧ | ៩៣៩ | ៦.១០៧ | ២.២៥៦ | ១.១៩៥ | ២.១៩២ |
| | អប្បបរមា | ៣៩ | ១០១ | ៦១ | ៣១០ | ១៧៣ | ៣១ |

## គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | រដ្ឋ តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ៧៣.៩២៧.១៨៧ | ៨៥% |
| សរុប | | | ៧៣.៩២៧.១៨៧ | ៨៥% |

## ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ រ.ទ.ស.ភ ពុំមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើននោះទេ។

# ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក (ត)

## ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល៣(បី)ឆ្នាំចុងក្រោយ

| **ព័ត៌មានលំអិតអំពីការបែងចែកភាគលាភ** | **២០២១** | **២០២០** | **២០១៩** |
|---|---|---|---|
| ចំណេញសុទ្ធ (ពាន់រៀល) | ១២៩.២៧៣.៩១៧ | ៨៨.៣៥១.៨៤៥ | ៣៣.២៩១.៩១៣ |
| ភាគលាភជាសាច់ប្រាក់សរុប (ពាន់រៀល) | ២៦.៩៦១.៦៨០ | ២២.៧៨៦.៩៦៨ | ២០.០០៣.៨២៧ |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | គ្មាន | គ្មាន | គ្មាន |
| ភាគលាភផ្សេងៗទៀត | គ្មាន | គ្មាន | គ្មាន |
| អនុបាតនៃការបែងចែកភាគលាភ | ២០,៨៦% | ២៥,៧៩% | ៦០,០៩% |
| ទិន្នផលភាគលាភ | *៤,៣៣% | **៤,៣០% | ***៣,៨៣% |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៣១០រៀល | ២៦២រៀល | ២៣០រៀល |

* ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ គឺ ៧.១៦០រៀល

** ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គឺ ៦.១០០រៀល

*** ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ គឺ ៦.០០០រៀល

## ផ្នែកទី៥:

# របាយការណ៍សវនកម្ម របស់សវនករផ្ទៃក្នុង

## លើការត្រួតពិនិត្យផ្ទៃក្នុង

# របាយការណ៍សវនកម្មផ្ទៃក្នុង

## ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ

### ប្រចាំឆ្នាំ២០២២

### ត្រូវបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ២

# ផ្នែកទី៦:

# របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយ

## សវនករឯករាជ្យ

# របាយការណ៍ក្រុមប្រឹក្សាភិបាល
# និង
# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

**ត្រូវបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ៣**

# ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គល ទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយ រ.ទ.ស.ភ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ច- ប្រតិបត្តិការសំខាន់ៗជាមួយ បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធ ជាមួយបុគ្គលធ្លាប់ជាអភិបាល

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពី រ.ទ.ស.ភ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពី រ.ទ.ស.ភ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

រ.ទ.ស.ភ មានចំណូល៣ប្រភេទធំៗគឺចំណូលបានមកពីការលក់ទឹក សេវាសាងសង់ និងចំណូលផ្សេងៗ៖

- ចំណូលបានមកពីការលក់ទឹករួមមានៈចំណូលពីការប្រើប្រាស់ប្រភេទជីវភាព អាជីវកម្ម ឧស្សាហកម្ម អង្គភាពរដ្ឋ បន្ទប់ជួល និងអ្នកលក់ទឹកបន្ត។ ចំណូលទាំងនេះត្រូវបានរាយការណ៍តាមតម្លៃទទួលបានសុទ្ធ ក្រោយការកាត់កងជាមួយអប្បហារវិភាជន៍ និងឥណទានហើយត្រូវបានទទួលស្គាល់តាមបរិមាណទឹកដែលបានផ្គត់ផ្គង់ជូនអតិថិជនរបស់ខ្លួន។ ការធ្វើវិក្កយបត្រនៃការប្រើប្រាស់ទឹក ត្រូវបានធ្វើឡើងក្នុងរយៈពេលរៀងរាល់២ខែម្តង។

- ចំណូលបានពីសេវាសាងសង់: គឺជាចំណូលបានមកពីសេវាសាងសង់ ទាក់ទិនទៅនឹងការប្តូរ និងការពង្រីកប្រព័ន្ធចែកចាយទឹកដែល រ.ទ.ស.ភ បានសាងសង់ជូនក្រុមហ៊ុនសំណង់មួយ។

- ចំណូលផ្សេងៗរួមមាន: ចំណូលបានមកពីការថែទាំនាឡិកា លក់សម្ភារតបណ្តាញទឹក ការផាកពិន័យលើការប្រើប្រាស់ទឹកពុំមានការអនុញ្ញាតពី រ.ទ.ស.ភ និងផ្សេងៗ។

- **ចំណូលថែទាំនាឡិកា៖** គឺចំណូលបានពីថ្លៃឈ្នួលថែទាំនាឡិកាដោយគិតថ្លៃ៥០រៀលក្នុង១មីលីម៉ែត្រក្នុងមួយខែនៃទំហំនាឡិកាទឹកក្នុងអំឡុងវដ្តនៃការគិតប្រាក់ ហើយត្រូវបានកត់ត្រាជាប្រាក់ចំណូល។ចំណូលនេះត្រូវបានប្រើប្រាស់សម្រាប់ផ្លាស់ប្តូរនាឡិកាជូនអតិថិជននាពេលអនាគត។
- **ចំណូលពីការលក់សម្ភារតបណ្តាញទឹក៖** គឺជាចំណូលទទួលបានពីការលក់នាឡិកាស្ទង់ទឹក បំពង់ និងសម្ភារតភ្ជាប់។
- **ចំណូលពីការផាកពិន័យ៖** គឺជាចំណូលទទួលបានពីការផាកពិន័យលើការបង់ថ្លៃប្រើប្រាស់ទឹកយឺតយ៉ាវ និងពិន័យលើបទល្មើសតបណ្តាញទឹកដោយពុំមានការអនុញ្ញាតពី រ.ទ.ស.ភ។
- **ចំណូលផ្សេងៗ៖** គឺជាចំណូលទទួលបានមកពីការរួមចំណែករបស់អតិថិជនប្រភេទពាណិជ្ជកម្ម និងឧស្សាហកម្មក្នុងការវិនិយោគសម្រាប់ការភ្ជាប់បណ្តាញពិសេសចូលទីតាំងផ្ទាល់របស់ពួកគេ។ក្រៅពីនោះ គឺជាចំណូលដែលទទួលបានពីកម្រៃសេវាលើការទារថ្លៃថែទាំលូទឹកស្អុយរបស់សាលារាជធានីភ្នំពេញ។

➢**ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១**

| បរិយាយ | ឆ្នាំ២០២២(ពាន់រៀល) | ឆ្នាំ២០២១(ពាន់រៀល) | បម្រែបម្រួល(ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណូលសរុប | ៣៤៦.១៧៨.១៥៦ | ៣៦៩.១៤៥.២៥៧ | (២២.៩៦៧.១០១) | (៦,២២%) |

រ.ទ.ស.ភ មានចំណូលសរុប ៣៤៦.១៧៨.១៥៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និង ៣៦៩.១៤៥.២៥៧.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ២២.៩៦៧.១០១.០០០រៀល ស្មើនឹង ៦,២២%។ យើងឃើញថាកត្តាចម្បងនៃការថយចុះនៃចំណូលសរុបនេះ ដោយសារចំណូលផ្សេងៗបានថយចុះចំនួន ៣៦.៧៨១.១៥៤.០០០រៀល ស្មើនឹង ៦៣,១៣% ព្រោះក្នុងឆ្នាំ២០២១ រ.ទ.ស.ភ បានកត់ត្រាទទួលស្គាល់ចំណូលដែលបានមកពីការលើកលែងការបង់ភាគលាភសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៩ និងឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ៣៦.៣៧២.១៧៧.០០០រៀល បើទោះបីជាចំណូលនៃការលក់ក្នុងឆ្នាំ២០២២ បានកើនឡើងចំនួន ១៧.៣៥៣.៧១០.០០០រៀល ស្មើនឹង ៦,១៥% ក៏ដោយ។

### ២- ការវិភាគចំណូលតាមផ្នែក

ការវិភាគចំណូលតាមផ្នែករបស់ រ.ទ.ស.ភ មានដូចខាងក្រោម:

| បរិយាយ | ឆ្នាំ២០២២ (ពាន់រៀល) | | ឆ្នាំ២០២១ (ពាន់រៀល) | |
|---|---|---|---|---|
| ចំណូលថ្លៃលក់ទឹក | ២៩៩.៧២៣.៥០៧ | ៨៦,៥៨% | ២៨២.៣៦៩.៧៩៧ | ៧៦,៤៩% |
| ចំណូលពីសេវាសាងសង់ | ២៤.៩៧៦.៣១៦ | ៧,២១% | ២៦.២៤១.៩៨៩ | ៧,១១% |
| ចំណូលពីការប្តូររូបិយប័ណ្ណ-សុទ្ធ | - | - | ២.២៧៣.៩៨៤ | ០,៦២% |
| ចំណូលផ្សេងៗ | ២១.៤៧៨.៣៣៣ | ៦,២១% | ៥៨.២៥៩.៤៨៧ | ១៥,៧៨% |

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ២- ការវិភាគចំណូលតាមផ្នែក (ត)

មានតែប្រាក់ចំណូលតាមប្រភេទជាសារវន្តត្រូវបានលើកឡើងសម្រាប់ការវិភាគខាងក្រោម៖

➢ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១**

| បរិយាយចំណូល | ឆ្នាំ២០២២ | | ឆ្នាំ២០២១ | | បម្រែបម្រួល | | |
|---|---|---|---|---|---|---|---|
| | បរិមាណ | ទឹកប្រាក់ | បរិមាណ | ទឹកប្រាក់ | បរិមាណ | ទឹកប្រាក់ | ភាគរយ |
| | ម៣ | ពាន់រៀល | ម៣ | ពាន់រៀល | ម៣ | ពាន់រៀល | |
| ជីវភាព | ១១២.០២៧.៦០០ | ១១០.៨៧៣.៥១៩ | ១០៨.២០៣.៤៧០ | ១១២.២៩០.៧៧៤ | ៣.៨២៤.១៣០ | (១.៤១៧.២៥៥) | (១,២៦%) |
| អាជីវកម្ម | ៨៤.៧៧៥.០១៧ | ១៥១.៨៧០.១៥៣ | ៧៤.២៤២.៣០៨ | ១២៨.៥៨២.០៩៩ | ១០.៥៣២.៧០៩ | ២៣.២៨៨.០៥៤ | ១៨,១១% |
| គ្រឹះស្ថានសាធារណៈ | ៩.១៣១.៦៦៨ | ១៩.៦៧១.០៣៦ | ៨.៦៦៥.៥៤២ | ២១.៥០០.១៨៥ | ៤៦៦.១២៦ | (១.៨២៩.១៤៩) | (៨,៥១%) |
| តំណាងចែកចាយ និងបន្ទប់ជួល | ១២.៨១៤.១៨៦ | ១០.៣១៧.៣៨៩ | ១២.៤៩៩.១៨៦ | ៩.៣៣៣.៣៤៥ | ៣១៥.០០០ | ៩៨៤.០៤៤ | ១០,៥៤% |

**ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ (ប្រភេទជីវភាព)**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទជីវភាពមានចំនួន ១១០.៨៧៣.៥១៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និង ១១២.២៩០.៧៧៤.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ១.៤១៧.២៥៥.០០០រៀល ស្មើនឹង ១,២៦%។ យើងឃើញថាការថយចុះនេះដោយសារ ថ្លៃលក់ទឹកជាមធ្យមបានថយចុះចំនួន ៤៨,០៧រៀល/ម៣ ពី ១.០៣៧,៧៧រៀល/ម៣ មកត្រឹម ៩៨៩,៧០ រៀល/ម៣ និង បរិមាណទឹកប្រើប្រាស់ក្នុង១បណ្តាញក្នុង១ខែបានថយចុះចំនួន ០,៣១ម៣ ពី ២៦,៦២ម៣ មកត្រឹម ២៦,៣១ម៣។ ដោយឡែក ចំនួនអតិថិជនបានកើនឡើងចំនួន ១០.៤៨៥បណ្តាញ ពី ៣៥០.៤៦៣បណ្តាញ ទៅ ៣៦០.៩៤៨បណ្តាញ។

**ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម (ប្រភេទអាជីវកម្ម និងឧស្សាហកម្ម)**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទអាជីវកម្មចំនួន ១៥១.៨៧០.១៥៣.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និង ១២៨.៥៨២.០៩៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលមានទឹកប្រាក់កើនឡើងចំនួន ២៣.២៨៨.០៥៤.០០០រៀល ស្មើនឹង ១៨,១១%។ យើងឃើញថាការកើនឡើងនេះដោយសារ ចំនួនអតិថិជនបានកើនឡើង ៩.៥៣០បណ្តាញ ពី ៧៤.៣៤៤បណ្តាញ ទៅ ៨៣.៨៧៤បណ្តាញ, បរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន ០,៥២ម៣ ពី ៨៨,៨៥ម៣ ទៅ ៨៩,៣៧ម៣ និងថ្លៃលក់ទឹកជាមធ្យមបានកើនឡើងចំនួន ៥៩,៥៣រៀល/ម៣ ពី ១.៧៣១,៩២រៀល/ម៣ ទៅ ១.៧៩១,៤៥រៀល/ម៣។

**ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់គ្រឹះស្ថានសាធារណៈ**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទអង្គភាពរដ្ឋចំនួន ១៩.៦៧១.០៣៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និង ២១.៥០០.១៨៥.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ១.៨២៩.១៤៩.០០០រៀល ស្មើនឹង ៨,៥១%។ យើងឃើញថាការថយចុះនេះដោយសារ បរិមាណប្រើប្រាស់ក្នុង១បណ្តាញក្នុង១ខែបានថយចុះចំនួន ១៤២,៦៩ម៣ ពី ៨៨០,១៩ម៣ មកត្រឹម ៧៣៧,៥០ម៣ និងតាមបណ្តាស្ថាប័នរដ្ឋមួយចំនួនមិនទាន់បានទូទាត់ថ្លៃប្រើប្រាស់ទឹកស្អាត។ ដោយឡែក ចំនួនអតិថិជនបានកើនឡើងចំនួន ៩០បណ្តាញ ពី ៨២៣បណ្តាញ ទៅ ៩១៣បណ្តាញ និងថ្លៃលក់ទឹកជាមធ្យម ២.៥០០រៀល។

**ចំណូលបានពីការលក់ទឹកស្អាតជូនតំណាងចែកចាយ និងបន្ទប់ជួល**

ចំណូលពីការលក់ទឹកស្អាតជូនតំណាងចែកចាយ/បន្ទប់ជួលចំនួន ១០.៣១៧.៣៨៩.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និង ៩.៣៣៣.៣៤៥.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលមានទឹកប្រាក់កើនឡើងចំនួន ៩៨៤.០៤៤.០០០រៀល ស្មើនឹង ១០,៥៤%។ យើងឃើញថាការកើនឡើងនេះដោយសារ ចំនួនអតិថិជនបានកើនឡើង ៤៨បណ្តាញ ពី ៥.៧៧១បណ្តាញ ទៅ ៥.៨១៩បណ្តាញ, បរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន ២០,៥៩ម៣ ពី ១៦៤,៣៥ម៣ ទៅ ១៨៤,៩៤ម៣ និងថ្លៃលក់ទឹកជាមធ្យមបានកើនឡើងចំនួន ១០៥,១៥រៀល/ម៣ ពី ៧០០,០០រៀល/ម៣ ទៅ ៨០៥,១៥រៀល/ម៣។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៣-ការវិភាគគម្លាតចំណេញដុល

រ.ទ.ស.ភ បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមប្រភេទ ដូចនេះពុំមានការបង្ហាញ ឲ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឲ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការ ដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រត្តិបត្តិការនឹងលើកយកមកពិភាក្សានៅចំណុចទី ៤- ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធខាងក្រោម។

### ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

ការចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ និង ចំណូល (ចំណាយ) ការប្រាក់សុទ្ធ។ ក្នុងការពិភាក្សា និងការវិភាគនៃចំណាយប្រតិបត្តិការ យើងលើកយកតែចំណាយរំលស់ ទ្រព្យសកម្មរូបីនិងអរូបី ចំណាយលើការប្រើប្រាស់អគ្គិសនី និងចំណាយលើប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត ចំណាយសេវាសាងសង់ ចំណូល (ចំណាយ)ការប្រាក់ យកមកពិភាក្សាដូចខាងក្រោម៖

➢ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១**

| **បរិយាយ** | **ឆ្នាំ២០២២ (ពាន់រៀល)** | **ឆ្នាំ២០២១ (ពាន់រៀល)** | **បម្រែបម្រួល (ពាន់រៀល/ភាគរយ)** | |
|---|---|---|---|---|
| ចំណូលសរុប | ៣៤៦.១៧៨.១៥៦ | ៣៦៩.១៤៥.២៥៧ | (២២.៩៦៧.១០១) | (៦,២២%) |
| ចំណាយរំលស់លើ ទ្រព្យសកម្មរូបី និងអរូបី | (៥៩.៤៥៥.០៧៤) | (៥៥.១៩៤.៤១២) | ៤.២៦០.៦៦២ | ៧,៧២% |
| ចំណាយថ្លៃភ្លើង | (៣៥.២១៨.៧៤៣) | (៣៥.៧៩១.៩៨៣) | (៥៧៣.២៤០) | (១,៦០%) |
| ចំណាយលើអត្ថប្រយោជន៍និយោជិត | (៧០.១៧៥.៤២២) | (៦៣.៦៣១.២៣៧) | ៦.៥៤៤.១៨៥ | ១០,២៨% |
| ចំណាយវត្ថុធាតុដើមសម្រាប់ ផលិតទឹកស្អាត | (១២.១៤០.៧៤០) | (៩.៥៤១.៩៨២) | ២.៥៩៨.៧៥៨ | ២៧,២៣% |
| ចំណាយសេវាសាងសង់ | (១៦.៦១៨.០២៤) | (២២.៤៤៨.២១៣) | (៥.៨៣០.១៨៩) | (២៥,៩៧%) |
| ចំណូលការប្រាក់ | ១៧.៧៣៧.៧៤៦ | ១៣.៥៥៥.០៦៤ | ៤.១៨២.៦៨២ | ៣០,៨៦% |
| ចំណាយការប្រាក់ | (១២.១០៤.៦៩៦) | (៤.៧៩៤.៧៧៩) | ៧.៣០៩.៩១៧ | ១៥២,៤៦% |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | **១៣០.៥១៥.៨៩២** | **១៦៥.៨៥៦.៥៨៦** | **(៣៥.៣៤០.៦៩៤)** | **(២១,៣១%)** |

រ.ទ.ស.ភ មានចំណេញមុនបង់ពន្ធលើប្រាក់ចំណូលចំនួន ១៣០.៥១៥.៨៩២.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និង ១៦៥.៨៥៦.៥៨៦.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ៣៥.៣៤០.៦៩៤.០០០រៀល ស្មើនឹង ២១,៣១%។ យើងឃើញថាកត្តាចម្បងនៃការថយចុះចំណេញមុនបង់ពន្ធលើប្រាក់ចំណូល ដោយសារចំណូលផ្សេងៗបានថយចុះចំនួន ៣៦.៧៨១.១៥៤.០០០រៀល ស្មើនឹង ៦៣,១៣% ព្រោះក្នុងឆ្នាំ២០២១ រ.ទ.ស.ភ បានកត់ត្រាទទួលស្គាល់ចំណូលដែលបានមកពីការលើកលែងការបង់ភាគលាភសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៩-២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ៣៦.៣៧២.១៧៧.០០០រៀល បើទោះបីជាចំណូលនៃការលក់ក្នុងឆ្នាំ២០២២ បានកើនឡើងចំនួន ១៧.៣៥៣.៧១០.០០០រៀល ស្មើនឹង ៦,១៥% ក៏ដោយ។

### ៥- ការវិភាគចំណេញ/(ខាត) និងលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

រ.ទ.ស.ភ ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ រ.ទ.ស.ភ មានកាតព្វកិច្ចត្រូវបង់ពន្ធ លើប្រាក់ចំណូលអត្រា ២០%។ ដោយឡែកពន្ធលើប្រាក់ចំណូលដែលជាប់អត្រា ២០% បានមកពីលទ្ធផលនៃប្រាក់ចំណេញគណនេយ្យទូទាត់ជាមួយនឹងចំណាយដែលមិនអាចកាត់កងបានក្នុងអត្រាពន្ធ ២០%។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

➢ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១**

| | ឆ្នាំ២០២២ (ពាន់រៀល) | ឆ្នាំ២០២១ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ (ក) | ១៣០.៥១៥.៨៩២ | ១៦៥.៨៥៦.៥៨៦ | (៣៥.៣៤០.៦៩៤) | (២១,៣១%) |
| ចំណាយពន្ធលើប្រាក់ចំណូល (ខ) | (២២.៣៣០.០២៧) | (៣៦.៥៨២.៦៦៩) | (១៤.២៥២.៦៤២) | (៣៨,៩៦%) |
| ចំណេញក្នុងការិយបរិច្ឆេទ | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ | (២១.០៨៨.០៥២) | (១៦,៣១%) |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ | (២១.០៨៨.០៥២) | (១៦,៣១%) |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណូល (ខ)/(ក) | ១៧,១១% | ២២,០៦% | | |

រ.ទ.ស.ភ មានចំណេញក្នុងការិយបរិច្ឆេទចំនួន ១០៨.១៨៥.៨៦៥.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និង ១២៩.២៧៣.៩១៧.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដែលមានទឹកប្រាក់ថយចុះចំនួន ២១.០៨៨.០៥២.០០០រៀល ស្មើនឹង១៦,៣១%។ យើងឃើញថាកត្តាចម្បងនៃការថយចុះចំណេញក្នុងការិយបរិច្ឆេទ ដោយសារចំណូលផ្សេងៗបានថយចុះចំនួន ៣៦.៧៨១.១៥៤.០០០រៀល ស្មើនឹង ៦៣,១៣% ព្រោះក្នុងឆ្នាំ២០២១ រ.ទ.ស.ភ បានកត់ត្រាទទួលស្គាល់ចំណូលដែលបានមកពីការលើកលែងការបង់ភាគលាភសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០១៩-២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ៣៦.៣៧២.១៧៧.០០០រៀល បើទោះបីជាចំណូលការប្រាក់-សុទ្ធបានថយចុះចំនួន ៣.១២៧.២៣៥.០០០រៀល ស្មើនឹង ៣៥,៧០% ព្រមទាំងពន្ធលើប្រាក់ចំណូលបានថយចុះចំនួន ៣៨,៩៦% ក៏ដោយ។

## ៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ស្ថានភាពអូសបន្លាយពេលនៃសង្គ្រាមរវាងប្រទេសរុស្សី និងអ៊ុយក្រែន ក៏ដូចជាស្ថានភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកបានបន្តធ្វើអោយប៉ះពាល់ដល់ការរីកចំរើននៃសេដ្ឋកិច្ចពិភពលោក និងនៅក្នុងតំបន់ផងដែរ ប៉ុន្តែទោះជាយ៉ាងណា រ.ទ.ស.ភ នៅតែបន្តប្រតិបត្តិការប្រចាំថ្ងៃ និងនៅតែមានផលចំណេញ ក្នុងត្រីមាសទី៤ ឆ្នាំ២០២២។ ការបន្តរក្សាបាននូវផលចំណេញនេះ ដោយសារចំណូលពីការលក់នៅតែមានកំណើនពីមួយត្រីមាសទៅមួយត្រីមាសផងដែរ គឺដោយសារតែមានកត្តាគាំទ្រ ដូចខាងក្រោម៖

- **អត្រាទឹកបាត់បង់៖** រ.ទ.ស.ភ បានប្រើប្រាស់នូវយន្តការដ៏មានប្រសិទ្ធភាព ដើម្បីកាត់បន្ថយអត្រាទឹក បាត់បង់ស្មើនឹង៨,៥០% នៅឆ្នាំ២០២២នេះ ។ ការរក្សាបានអត្រាទឹកបាត់បង់នៅត្រឹមកម្រិតនេះជាកត្តាចម្បងដែលធ្វើឲ្យ រ.ទ.ស.ភ មានចេរភាពហិរញ្ញវត្ថុ និងអភិវឌ្ឍ សហគ្រាសរក្សានូវស្ថានភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសហគ្រាសប្រកបដោយនិរន្តភាព។

- **ការបង្កើនចំនួនអតិថិជន៖** ដើម្បីទទួលបាននូវចំណូលពីការលក់ទឹកស្អាត រ.ទ.ស.ភ. បានបង្កើនចំនួនអតិថិជន របស់ខ្លួន ដោយពង្រីកផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតទៅតំបន់ដែលពុំទាន់មានការផ្គត់ផ្គង់ទឹកស្អាត ដូចជាការបំពេញផ្ទៃសេវាឲ្យបាន ១០០% នៅក្នុងរាជធានីភ្នំពេញ តំបន់ជុំវិញរាជធានីភ្នំពេញ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច។

- **ការបង្កើនថ្លៃលក់ទឹកមធ្យម៖** តាមរយៈការស្វែងរកអតិថិជន ដែលជាប្រភេទអាជីវកម្ម-ឧស្សាហកម្ម ធ្វើឲ្យថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ កើនឡើងដោយសារតែថ្លៃប្រើប្រាស់ទឹករបស់អតិថិជនប្រភេទនេះ មានកម្រិតខ្ពស់ជាងអតិថិជនប្រភេទផ្សេងទៀត។

- **ការគ្រប់គ្រងលើការចំណាយប្រតិបត្តិការ៖** រ.ទ.ស.ភ ធ្វើការគ្រប់គ្រងលើការចំណាយនេះ ពិសេសការចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនីដែលជាចំណាយដ៏ធំ និងសំខាន់ក្នុងដំណើរការផលិតទឹកស្អាត តាមរយៈការប្រើប្រាស់នូវ បច្ចេកវិទ្យាថ្មីៗ ដូចជាជ្រើសរើសយកការប្រើប្រាស់ម៉ាស៊ីនបូមទឹកដែលអាចប្រែប្រួលទៅតាមសំពាធទឹក ក៏ដូចជាការចាត់ចែងការប្រើប្រាស់នូវវត្ថុធាតុដើមក្នុងការផលិតទឹកប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃខ្ពស់។

ចំពោះការចំណាយដំណើការសហគ្រាស រ.ទ.ស.ភ ក៏បានខិតខំកាត់បន្ថយនូវការចំណាយដែលមិនចាំបាច់ ដូចជាចំណាយរដ្ឋបាលទូទៅ ចំណាយលើការជួសជុលថែទាំទូទៅ ដែលអង្គភាពបានយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យ និងថែទាំឧបករណ៍បរិក្ខាប្រើប្រាស់ជាប្រចាំ ដើម្បីធានាបានគុណភាពប្រើប្រាស់ និងកាត់បន្ថយការចំណាយជួសជុលនានា។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

- **ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវដំណើរការកិច្ចលទ្ធកម្ម៖** រ.ទ.ស.ភ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់បញ្ញត្តិ និងគោលការណ៍ណែនាំផ្សេងៗសម្រាប់ដំណើរការកិច្ចលទ្ធកម្មក្នុងការទិញសម្ភារ បរិក្ខារ និងវត្ថុធាតុដើម ដែលដំណើរការនេះឆ្លុះបញ្ចាំងឱ្យឃើញពី តម្លាភាព និងការប្រកួតប្រជែងថ្លៃទំនិញនៅលើទីផ្សារដែលជាហេតុធ្វើឲ្យ រ.ទ.ស.ភ ទទួលបានការទិញទំនិញមានតម្លៃសមរម្យ គុណភាពអាចទទួលយកបាន។

- **ការគ្រប់គ្រងសាច់ប្រាក់៖** តាមរយៈអត្រាទារប្រាក់ដែលមានកម្រិតខ្ពស់៩៩.៩០% បានធ្វើឲ្យ រ.ទ.ស.ភ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់ដោយទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ក្នុងការគ្រប់គ្រង រ.ទ.ស.ភ បានរក្សាទុកនូវសាច់ប្រាក់សម្រាប់ប្រើប្រាស់ជាទុនបង្វិលក្នុងរយៈពេល ២ទៅ៣ខែ ឯសាច់ប្រាក់ដែលទំនេរពុំមានតម្រូវការប្រើប្រាស់ រ.ទ.ស.ភ បានធ្វើការវិនិយោគរយៈពេលខ្លី ដោយដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេលខ្លីនៅធនាគារពាណិជ្ជជាមួយនឹងការទទួលបាននូវអត្រាការប្រាក់ខ្ពស់ ប៉ុន្តែ រ.ទ.ស.ភ ក៏បានធ្វើការថ្លឹងថ្លែងពីហានិភ័យ និងផលចំណេញពីអត្រាការប្រាក់ខ្ពស់នេះផងដែរ។

- **ការជ្រើសរើសយកនូវអ្នកផ្តល់ហិរញ្ញប្បទានដែលផ្តល់អត្រាការប្រាក់ទាប៖** ដោយសារមានតម្រូវការប្រើប្រាស់ទឹកស្អាត កើនឡើងខ្ពស់ ធ្វើឲ្យ រ.ទ.ស.ភ មានតម្រូវការហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគដូចជាការ សាងសង់រោងចក្រផលិតទឹកស្អាត ការតបណ្តាញមេនាំទឹក និងបណ្តាញចែកចាយ។ រ.ទ.ស.ភ បានស្វែងរកដៃគូអភិវឌ្ឍអន្តរជាតិដូចជាទីភ្នាក់ងារបារាំង សម្រាប់អភិវឌ្ឍន៍(AFD) ដើម្បីទទួលបាននូវហិរញ្ញប្បទាន ដែលមានអត្រាការប្រាក់ទាប។

- **ស្ថានភាពសេដ្ឋកិច្ច៖** ទោះបីជាស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជាក្នុងឆ្នាំ២០២២ ត្រូវបានព្យាករការកើនឡើងក្នុងកម្រិត ៥.៣% ទាបជាងការព្យាករកាលពីដើមឆ្នាំ ដោយសង្គ្រាមរវាងប្រទេសរុស្សី និងអ៊ុយក្រែនបន្តអូសបន្លាយ និងភាពមិនច្បាស់លាស់នៃកំណើនសេដ្ឋកិច្ចប្រទេសចិន ដែលនាំអោយប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោក ក៏ដូចប្រទេសកម្ពុជា ក៏ថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ ពុំមានការប៉ះពាល់ខ្លាំងឡើយ។

## ខ- កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ដោយយោងទៅតាមការសិក្សា នៃតម្រូវការប្រើប្រាស់ទឹកធៀបទៅនឹងកំណើនប្រជាជន នៅក្នុងរាជធានីភ្នំពេញ ដោយសារការពង្រីកតំបន់ជុំវិញរាជធានីភ្នំពេញ រ.ទ.ស.ភ បានកំពុងធ្វើការសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងដំហាន១ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម$^{៣}$/ថ្ងៃ និងគ្រោងដាក់អោយដំណើរការផលិតនៅក្នុងឆ្នាំ២០២៣ និងកំពុងបន្តសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងដំហាន២ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម$^{៣}$/ថ្ងៃ ដូចគ្នា និងរោងចក្រផលិតទឹកស្អាតបឹងធំ ដែលមានសមត្ថភាពផលិត ៥.០០០ម$^{៣}$/ថ្ងៃ ដើម្បីបំពេញតម្រូវការទឹកស្អាតនាបច្ចុប្បន្ន និងពេលអនាគត។

### ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការប្រែប្រួលនៃថ្លៃវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត អាចប៉ះពាល់ដល់ថ្លៃដើមផលិត ប៉ុន្តែមិនមានផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ ដោយសារការចំណាយនេះមានអត្រាមិនលើសពី១០% នៃចំណាយប្រតិបត្តិការ។ ទោះជាយ៉ាងណា ក៏ដោយ រ.ទ.ស.ភ ក៏បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាថ្លៃវត្ថុធាតុដើមសមស្របទៅតាមតម្លៃលើទីផ្សារ ជាក់ស្តែង ហើយនីតិវិធីនេះ ក៏ផ្តល់លទ្ធភាពសម្រាប់ រ.ទ.ស.ភ ទទួលបាននូវតម្លៃប្រកួតប្រជែងដែលមានតម្លៃទាប។

### ៣- ការវិភាគលើពន្ធ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ រ.ទ.ស.ភ មានកាតព្វកិច្ច ត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ រ.ទ.ស.ភ មានកាតព្វកិច្ចបង់ពន្ធអាករ ទៅតាមរបបស្វ័យប្រកាស និង ជាសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

### ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ នេះ គណៈគ្រប់គ្រងយល់ថា រ.ទ.ស.ភ ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ រ.ទ.ស.ភ គឺចំណូលពីការលក់ (ចំណូលលក់ទឹក និងភ្ជាប់បណ្តាញ) ដែលជាតម្រូវការចាំបាច់របស់ប្រជាជននៅក្នុងរាជធានីភ្នំពេញ។ ចំណូលនេះបានចូលរួមចំណែកប្រមាណ ៨៦,៥៨% នៃចំណូលសរុបនៅក្នុងឆ្នាំ២០២២ ហើយ រ.ទ.ស.ភ ក៏ជាអ្នកផ្គត់ផ្គង់ផ្តាច់មុខនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ។ ប្រាក់ចំណូលនេះអាចមានការកើនឡើង អាស្រ័យទៅតាមកំណើននៃចំនួនប្រជាពលរដ្ឋដែលរស់នៅ ក្នុងរាជធានីភ្នំពេញ និងតំបន់ទីក្រុងតាខ្មៅផងដែរ។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ឃ.១- ផលប៉ះពាល់នៃអត្រាប្តូរប្រាក់

រ.ទ.ស.ភ បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ"ប្រាក់រៀល"។ប្រតិបត្តិការជារូបិយប័ណ្ណបរទេសត្រូវបានប្តូរទៅជារូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះការប្តូរទ្រព្យសកម្ម និងបំណុលរូបិយប័ណ្ណបរទេសត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត។ សម្រាប់ឆ្នាំ២០២២ នេះ ការធ្លាក់ចុះថ្លៃអត្រាប្តូរប្រាក់រៀលធៀប និងអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេសបានធ្វើអោយ រ.ទ.ស.ភ ខាតមិនពិតពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចី។ដោយសារការទូទាត់ទំនិញរបស់ រ.ទ.ស.ភ ភាគច្រើនធ្វើឡើងដោយប្រាក់រៀល ដូចនេះពុំមានផលប៉ះពាល់ខ្លាំងដោយអត្រាប្តូរប្រាក់នោះទេ។

### ឃ.២- ផលប៉ះពាល់នៃអត្រាការប្រាក់

#### ឃ.២.១- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណូលការប្រាក់

ដោយសារនៅប្រទេសកម្ពុជាពុំមានទីផ្សាររូបិយប័ណ្ណ ដូច្នេះ រ.ទ.ស.ភ មានលទ្ធភាពត្រឹមតែវិនិយោគរយៈពេលខ្លី លើការដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៣ខែ ទៅ៩ខែ ទៅ១២ខែ នៅធនាគារពាណិជ្ជក្នុងស្រុកតែប៉ុណ្ណោះ។

#### ឃ.២.២- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណាយការប្រាក់

រ.ទ.ស.ភ មានប្រភពហិរញ្ញប្បទានពីរ ដែលមានអត្រាការប្រាក់ថេរ និងប្រែប្រួល។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ ថេរមាន ហិរញ្ញប្បទានដែលទទួលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានកម្រិតអត្រា១,៦៥% និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)មានកម្រិតអត្រា០,៦៦% ក្នុងមួយឆ្នាំ។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ប្រែប្រួលមាន ហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) នៅអត្រា EURIBOR ៦ខែ ដក១,៣៥ពិន្ទុ។ តែអត្រានេះមិនឲ្យទាបជាង០,២៥% និងមិនខ្ពស់ជាង៥,២១% ក្នុងឆ្នាំនោះទេ។

### ឃ.៣- ផលប៉ះពាល់នៃថ្លៃទំនិញ

តាមរយៈដំណើរការកិច្ចលទ្ធកម្មរបស់ រ.ទ.ស.ភ ដែលអនុលោមទៅតាមច្បាប់ និង បញ្ញត្តិជាធរមាន រួមផ្សំនឹងគោលការណ៍ណែនាំផ្សេងៗ ដែលតម្រូវឲ្យ រ.ទ.ស.ភ ធ្វើកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់សម្ភារ និង វត្ថុធាតុដើមទៅតាមតម្លៃប្រកួតប្រជែងឬតម្លៃចរចាររួច។ ការអូសបន្លាយនៃសង្គ្រាមរវាងប្រទេសរុស្សីនិងអ៊ុយក្រែនបានធ្វើអោយតម្លៃសម្ភារវត្ថុធាតុដើមនៅលើទីផ្សារក្នុងស្រុក និង ក្រៅស្រុកមានការកើនឡើងដោយសារៈ ការកើនឡើងតម្លៃប្រេងឥន្ធនៈ ការដឹកជញ្ជូន ព្រមទាំងតម្រូវការ និងការផ្គត់ផ្គង់ពុំមានតុល្យភាព។ ការកើនឡើងនៃតម្លៃសម្ភារ និងវត្ថុធាតុដើម ក៏បានជះឥទ្ធិពលដល់ចំណាយវិនិយោគនិងចំណាយដំណើរការរបស់ រ.ទ.ស.ភ ផងដែរ ។ ប៉ុន្តែទោះបីជាការកើនឡើងនៃតម្លៃសម្ភារ និង វត្ថុធាតុដើមដូចនេះក្តីក៏គណៈគ្រប់គ្រងបានគិតគូរយ៉ាងហ្មត់ចត់លើផែនការ និង តម្រូវការសម្ភារ បរិក្ខា វត្ថុធាតុដើម ដើម្បីធានាអោយការប្រើប្រាស់បានទាន់ពេល និងមានតម្លៃសមរម្យ ដោយអនុវត្តតាមច្បាប់លទ្ធកម្មសាធារណៈជាធរមាន។

## ង- ផលប៉ះពាល់នៃអតិផរណា

រ.ទ.ស.ភ បានរក្សានូវថ្លៃលក់ទឹកថេរមិនប្រែប្រួលចាប់តាំងពីឆ្នាំ២០០១ រហូតដល់ឆ្នាំ២០១៩។ ដើម្បីធ្វើការកែសម្រួលទៅ តាមការប្រែប្រួលនៃអតិផរណា យើងបានធ្វើការកែសម្រួលនូវថ្លៃលក់ទឹកស្អាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់បច្ចុប្បន្ន ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល

ធុរកិច្ចរបស់ រ.ទ.ស.ភ ទទួលការជះឥទ្ធិពលពីគោលនយោបាយមួយចំនួន ដែលកំណត់ដោយរាជរដ្ឋាភិបាលដូចជា៖

- **ការពង្រីកផ្ទៃសេវា៖** ការពង្រីកផ្ទៃសេវាបន្ថែមដើម្បីផ្គត់ផ្គង់ទឹកស្អាត ត្រូវបានរឹតត្បិតដោយបេសកកម្មរបស់ រ.ទ.ស.ភ ដែលអនុញ្ញាតឲ្យផលិត និងចែកចាយទឹកសម្រាប់ការប្រើប្រាស់របស់សាធារណជននៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ការរឹតត្បិតនេះត្រូវបានកំណត់ដោយអនុក្រឹត្យលេខ៥២អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើត រ.ទ.ស.ភ។
- **ការពង្រីករាជធានីភ្នំពេញ៖**រាជរដ្ឋាភិបាលមានគោលនយោបាយពង្រីករាជធានីភ្នំពេញ ដោយបញ្ចូលឃុំ បន្ថែមចំនួន២០ឃុំ ទៀត ទៅក្នុងតំបន់រាជធានីភ្នំពេញដែលធ្វើឲ្យផ្ទៃសេវារបស់ រ.ទ.ស.ភ ក្នុងការផ្គត់ផ្គង់ទឹកស្អាតក៏ត្រូវពង្រីកបន្ថែមដែរ។
- **គោលនយោបាយពន្ធលើអចលនទ្រព្យ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ឲ្យអនុវត្តនូវ ប្រកាសលេខ ៤៩៣សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពី " ការប្រមូលពន្ធលើអចលនទ្រព្យ" ។ អចលនទ្រព្យរបស់ រ.ទ.ស.ភ គឺសម្រាប់បម្រើឲ្យប្រព័ន្ធផលិតកម្មទឹកស្អាត ដែលអចលនទ្រព្យប្រភេទនេះ ត្រូវបានលើកលែងពន្ធតាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ០០៦សហវ. អពដ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១។

# ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

រ.ទ.ស.ភ បាន និងកំពុងខិតខំប្រឹងប្រែងផលិតទឹកស្អាតប្រកបដោយគុណភាព និងមានសុវត្ថិភាពជូនប្រជាពលរដ្ឋដែលប្រើប្រាស់ទឹកស្អាតរបស់ រ.ទ.ស.ភ ។ ដើម្បីទទួលបានទំនុកចិត្តបន្ថែមពីប្រជាពលរដ្ឋ ដែលជាអតិថិជនរបស់ខ្លួន នៅក្នុងឆ្នាំ២០២២ រ.ទ.ស.ភ បានបញ្ជូនទឹកសំណាកនៅរោងចក្រផលិតទឹកស្អាតចំការមន ទៅមន្ទីរពិសោធន៍ទឹកឯករាជ្យ TUY SUD PSB Pts Ltd. នៃប្រទេសសឹង្ហបូរី ដែលមានមុខវិភាគ ១១៦មុខ ដូចខាងក្រោម៖

១. មីក្រូជីវសាស្ត្រ ចំនួន ១ មុខ
២. លក្ខណៈរូប ចំនួន ៦ មុខ
៣. លក្ខណៈគីមី ចំនួន ១០៩ មុខ

ជាលទ្ធផល ទឹកស្អាតដែលផលិតពីរោងចក្រផលិតទឹកស្អាតចំការមនរបស់ រ.ទ.ស.ភ គឺអនុលោមទៅតាមស្តង់ដាររបស់អង្គការសុខភាពពិភពលោក សម្រាប់គុណភាពទឹកផឹក (4th Edition 2011) ដូចមានបង្ហាញលទ្ធផលទាំងស្រុងនៅក្នុងឧបសម្ព័ន្ធ៤ TEST REPORT 7191297902-01-CHM22-PN។

# ហត្ថលេខាអភិបាល
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ថ្ងៃព្រហ ៩រោច ខែផល្គុន ឆ្នាំខាល
ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ឹម ស៊ីថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃព្រហ ៩រោច ខែផល្គុន ឆ្នាំខាល
ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ឡុង ណារ៉ូ**
អភិបាល

ថ្ងៃព្រហ ៩រោច ខែផល្គុន ឆ្នាំខាល
ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**មី វ៉ាន់**
អភិបាល

ថ្ងៃព្រហ ៩រោច ខែផល្គុន ឆ្នាំខាល
ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ទួន ផារ័ត្ន**
អភិបាល

ថ្ងៃព្រហ ៩រោច ខែផល្គុន ឆ្នាំខាល
ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ម៉ា ណូរ៉ាទីន**
អភិបាល

ថ្ងៃព្រហ ៩រោច ខែផល្គុន ឆ្នាំខាល
ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ណាំ ចន្ទ្រី**
អភិបាល

ថ្ងៃព្រហ ៩រោច ខែផល្គុន ឆ្នាំខាល
ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣
បានអាន និងឯកភាព

ហត្ថលេខា
**ស្រេង សំឌិត**
អភិបាល

# ឧបសម្ព័ន្ធ ១

## របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២២

# មាតិកា


ផ្នែកទី១: ភាគហ៊ុនិក ១

ក- រចនាសម្ព័ន្ធភាគហ៊ុនិក ១

ខ- សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក ២

គ- មហាសន្និបាតភាគហ៊ុនិក ២

ឃ- ការបែងចែកភាគលាភ ៣

ផ្នែកទី២: ក្រុមប្រឹក្សាភិបាល ៤

ក- ក្រុមប្រឹក្សាភិបាល ៤

ខ- គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៩

គ- លាភការ ឬប្រាក់បំណាច់ ១១

ឃ- ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ ១១

ង- ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ១២

ផ្នែកទី៣: ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ១៥

ក- គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ១៥

ខ- ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ដោយនិយោជិត (Whistle Blower) ១៨

គ- យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ១៨

ឃ- ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ១៨

ផ្នែកទី៤: ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម ១៩

ក- សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ ១៩

ខ- សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ១៩

គ- ការធ្វើសវនកម្ម ១៩

ផ្នែកទី៥: ភាគីពាក់ព័ន្ធ ២១

ក- បង្ហាញពីគោលនយោបាយ និងសកម្មភាព ២១

ខ- ពិពណ៌នាអំពីទំនួលខុសត្រូវសង្គមរបស់ រ.ទ.ស.ភ ២៣

ផ្នែកទី៦: ការបង្ហាញព័ត៌មាន និងតម្លាភាព ២៤

ក- ការបង្ហាញព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំ ២៤

ខ- យន្តការនៃការបង្ហាញព័ត៌មាន មធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលព័ត៌មាន ២៤

គ- ទំនាក់ទំនងជាមួយវិនិយោគិន ២៥

# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២២
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
# របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ផ្នែកទី១. ភាគហ៊ុនិក

### ក- រចនាសម្ព័ន្ធភាគហ៊ុនិក(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)

### ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣.១៤០ | ៤.៦៩១.១៤៣ | ៥,៣៩៤% |
| | | នីតិបុគ្គល | ៧ | ២.៦១២.៧១៣ | ៣,០០៤% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៥៩០ | ៥.៣៤០.៩៣៣ | ៦,១៤១% |
| | | នីតិបុគ្គល | ៦ | ៤០១.១៨៦ | ០,៤៦១% |
| ចាប់ពី៥% ដល់តិចជាង៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៧៣.៩២៧.១៨៧ | ៨៥% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

### ២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត រ.ទ.ស.ភ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ២ | ២០.២១៦ | ០,០២៣% |
| បុគ្គលិកជាន់ខ្ពស់ | ២០ | ១២៥.៩០០ | ០,១៤៥% |
| និយោជិត | ៣៨៧ | ៧១៨.៥២២ | ០,៨២៦% |
| សរុប | ៤០៩ | ៨៦៤.៦៣៨ | ០,៩៩៤% |

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## ខ- សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាហ៊ុនិក

### ១. សិទ្ធិរបស់ភាគហ៊ុនិក

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ មានសិទ្ធិស្មើៗគ្នា ដែលសិទ្ធិទាំងនោះរួមមាន៖

- សិទ្ធិទទួលបានព័ត៌មានដែលផ្តល់ដោយ រ.ទ.ស.ភ ស្របតាមច្បាប់ និងបញ្ញតិជាធរមាន។
- សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិករបស់ រ.ទ.ស.ភ ដោយត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក ដោយត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិទទួលភាគលាភ ដែលប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ តាមសមាមាត្រភាគហ៊ុនដែលខ្លួនកាន់កាប់។
- សិទ្ធិក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ រ.ទ.ស.ភ នៅពេលមានការរំលាយតាមសមាមាត្រភាគហ៊ុន។
- សិទ្ធិផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងបញ្ញតិជាធរមាន។

### ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនភាគតិច

សិទ្ធិរបស់ភាគហ៊ុនិករបស់ រ.ទ.ស.ភ ត្រូវបានការពារដោយលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ និងតាមរយៈការបង្កើតឱ្យមាននូវ ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

ក្នុងឆ្នាំ២០២២ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១០ ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ដែលភាគហ៊ុនិកទាំងអស់ទទួលបានព័ត៌មានស្មើគ្នា មានសិទ្ធិចូលរួម ដោយគោរពតាមនីតិវិធីនៃការចូលរួមមហាសន្និបាតរបស់ រ.ទ.ស.ភ និងធ្វើការបោះឆ្នោតលើរបៀបវារៈដែលបានលើកឡើង។ រ.ទ.ស.ភ ក៏បានធ្វើការបែងចែកភាគលាភប្រចាំឆ្នាំ២០២១ ជូនដល់ភាគហ៊ុនិក របស់ រ.ទ.ស.ភ ដោយធ្វើការទូទាត់នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅ។

### ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្តក្នុងឆ្នាំ២០២២

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិចរបស់ រ.ទ.ស.ភ ទទួលបានស្មើគ្នានូវការការពារ និងការអនុវត្តដូចទៅនឹងភាគហ៊ុនិកដទៃដូចបានរៀបរាប់ខាងលើ ដោយពុំមានការរិតត្បិតសិទ្ធិណាមួយទេ។

## គ- មហាសន្និបាតភាគហ៊ុនិក

### ១. និតិវិធីនៃការរៀបចំសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

ការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោតត្រូវបានអនុវត្តទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## គ- មហាសន្និបាតភាគហ៊ុនិក (ត)

### ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិកលើកទី១០

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|---|
| ១ | ១៣<br>ឧសភា<br>២០២២ | សាមញ្ញ | ១៣៨នាក់<br>(៧៦.៧៥៤.៦៨០ ភាគហ៊ុន) | ១.របាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ២០២១<br>២.ទិសដៅអាជីវកម្ម២០២២<br>៣.សំនួរ-ចម្លើយ<br>៤.កម្មវិធីបោះឆ្នោតអនុម័តលើ៖<br>➢ ការបោះឆ្នោតអនុម័តគាំទ្របេក្ខភាពអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន<br>➢ ការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ<br>➢ ការបោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២១<br>➢ ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល ឆ្នាំ២០២២ | លទ្ធផលនៃការបោះឆ្នោត៖<br>➢ ឯកភាពគាំទ្រអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន( លោក ណាំ ចន្រ្ទី)<br>➢ ឯកភាពជ្រើសតាំងអភិបាលឯករាជ្យ (លោក ស្រេង សំឌិក)<br>➢ ឯកភាពបែងចែកភាគលាភ៖<br>▪ ចំនួន ៣១០ រៀលក្នុង១ភាគហ៊ុន<br>▪ កាលបរិច្ឆេទកំណត់ទុក: ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២<br>▪ កាលបរិច្ឆេទទូទាត់: ចាប់ពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២<br>➢ ឯកភាពលើលាភការរបស់ក្រុមប្រឹក្សាភិបាល ៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋ ១រូប សម្រាប់ឆ្នាំ ២០២២ ដែលមានទឹកប្រាក់សរុបចំនួន ១.០០៧.២៥៤.០០០រៀល។ |

## ឃ- ការបែងចែកភាគលាភ

### ១- គោលនយោបាយបែងចែកភាគលាភ

ក្រោយពីបានអនុម័តលើគណនី បើពិនិត្យឃើញថាមានចំណេញ ក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ អាចសម្រេចផ្ទេរទឹកប្រាក់ទាំងនោះដើម្បី៖

១.១. ការទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅ

១.២. បន្ទាប់ពីបានទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅរួច ប្រសិនបើមានប្រាក់ចំណេញ នោះប្រាក់ចំណេញនេះត្រូវបែងចែកសម្រាប់៖

ក- ថ្លៃងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិត តាមលក្ខខណ្ឌ៖

- ក្នុងករណីប្រាក់ចំណេញនៅសល់មានចំនួនពី ៥% ដល់ ១០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងមួយខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី ១០% ដល់ ២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងពីរខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និង និយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី ២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងបីខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។

ខ- ចំនួន ២% សម្រាប់ប្រាក់សោធននិវត្ត និងអសមត្ថភាពវិជ្ជាជីវៈ។

គ- បង្កើតភាគបម្រុងតាមច្បាប់ ៥%។

ឃ- បង្កើតភាគបម្រុងសេរីចំនួន ៥%។

ង- មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រតិបត្តិការចំណាយនោះ។

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## ឃ- ការបែងចែកភាគលាភ (ត)

### ១- គោលនយោបាយបែងចែកភាគលាភ (ត)

១.៣. ចំនួនប្រាក់ដែលនៅសល់បន្ទាប់ពីការបែងចែកខាងលើនេះត្រូវ៖

- ក- ដកប្រាក់រក្សាទុកដើម្បីធ្វើការវិនិយោគនាពេលខាងមុខ ដែលចំនួននេះត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។
- ខ- ប្រាក់នៅសល់ក្រោយពីការរក្សាទុកសម្រាប់ធ្វើការវិនិយោគត្រូវធ្វើការបែងចែក ៨៥% ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ១៥% ទៅភាគហ៊ុនិកដែលជាវិនិយោគិនសាធារណៈ។

### ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២១ | ២០២០ | ២០១៩ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ១៣ ឧសភា ២០២២ | ២៦ មីនា ២០២១ | ២៦ មិថុនា ២០២០ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ៣០ ឧសភា ២០២២ | ២១ មេសា ២០២១ | ០២ កក្កដា ២០២០ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ០៨ មិថុនា ២០២២ | ០១ មិថុនា ២០២១ | ១៣ កក្កដា ២០២០ |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល

## ក. ក្រុមប្រឹក្សាភិបាល

### ១. សមាសភាពក្រុមភិបាល

| ល.រ. | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម ស៊ឹម ស៊ីថា * | ប្រធានក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ២ | ឯកឧត្តម ឡុង ណារ៉ូ * | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៣ | ឯកឧត្តម ម៉ី វ៉ាន់ * | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៤ | ឯកឧត្តម នួន ផារ័ត្ន * | សមាជិកក្រុមប្រឹក្សាភិបាល | ០៦/០១/២០២៣ | ០៦/០១/២០២៦ |
| ៥ | លោក ម៉ា ណូវ៉ារីន ** | សមាជិកក្រុមប្រឹក្សាភិបាល | ២៧/០២/២០២៣ | ២៧/០២/២០២៦ |
| ៦ | លោក ស្រេង សំឌិក | អភិបាលឯករាជ្យ | ១៣/០៥/២០២២ | ១៣/០៥/២០២៥ |
| ៧ | លោក ណាំ ចន្ទ្រី | អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន | ១៣/០៥/២០២២ | ១៣/០៥/២០២៥ |

- ឈ្មោះលេខាធិការសហគ្រាសរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ:
  - **លោក ជុំ ផល្លា**
  - **លោក ហួត សុខហេង**

សម្គាល់៖

* យោងតាមអនុក្រឹត្យលេខ ៣១អនក្រ.គត ចុះថ្ងៃសុក្រ ១៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨។

** យោងលក្ខន្តិកៈរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ និងយោងកំណត់ហេតុស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងនិយោជិតអាណត្តិទី៨ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចុះថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣

### ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ

#### - ជីវប្រវត្តិរូបសង្ខេបរបស់ឯកឧត្តម ស៊ឹម ស៊ីថា

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៦១ និងបានទទួលជាវិស្វករសំណង់ស៊ីវិលឧស្សាហកម្ម នៅវិទ្យាស្ថានជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត (រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា) ក្នុងឆ្នាំ ១៩៨៩។ ឯកឧត្តមបានទទួលបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យគ្រប់គ្រប់សេដ្ឋកិច្ច ខេត្តព្រះសីហនុ នៃព្រះរាជាណាចកម្ពុជានៅ ឆ្នាំ២០០៧។ ក្នុងឆ្នាំ២០១៤ ឯកឧត្តម បានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតដោយជោគជ័យ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យ អាស៊ីអ៊ឺរ៉ុប រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៣ ឯកឧត្តមជាអនុប្រធានអង្គភាពរដ្ឋាករទឹកខេត្តព្រះសីហនុ ។ ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០១២ ឯកឧត្តមមានតួនាទីជាប្រធានអង្គភាពរដ្ឋាករទឹកខេត្តព្រះសីហនុ។ ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០២១ ឯកឧត្តមជាអគ្គនាយក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ អាណត្តិទី៥។ ចាប់ពីឆ្នាំ២០២១ **ឯកឧត្តម ស៊ឹម ស៊ីថា** ត្រូវបានតែងតាំងជា រដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ព្រមទាំងបានទទួលការតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលអាណត្តិទី៨ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ រហូតដល់បច្ចុប្បន្ន។

#### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម ម៉ី វ៉ាន់

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៦៩ និងបានទទួលអនុបណ្ឌិតគោលនយោបាយសេដ្ឋកិច្ចនៃសកលវិទ្យាល័យ D'AUVERGNE ប្រទេសបារាំងនៅឆ្នាំ១៩៩៩។ ឯកឧត្តមបានទទួលបណ្ឌិតសេដ្ឋកិច្ចពាណិជ្ជកម្មនៃសកលវិទ្យាល័យ PRESTON សហរដ្ឋអាមេរិក នៅឆ្នាំ២០០៩។ ឯកឧត្តមបានបម្រើការងារឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។ **ឯកឧត្តម ម៉ី វ៉ាន់** ចូលជាសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៥ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

## ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ (ត)

### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម ឡុង ណារ៉ូ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៦។ ឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៨ សិក្សានៅសាលា Engineering School for Plant and Construction " Georgi Dimitroff " Glauchau (East Germany) ដោយទទួលបានសញ្ញាបត្រវិស្វករយន្តសាស្ត្រ។ នៅឆ្នាំ២០០៤ ទទួលបានអនុបណ្ឌិតរដ្ឋបាល ពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Charles Sturt University (Australia University)។ **ឯកឧត្តម ឡុង ណារ៉ូ** បានចូលបម្រើការងារនៅ រ.ទ.ស.ភ នៅឆ្នាំ ១៩៨៩ និង ទទួលបានការតែងតាំងជាប្រធាននាយកដ្ឋានបច្ចេកទេស ផលិតកម្ម និងផ្គត់ផ្គង់ទឹកនៅឆ្នាំ១៩៩៧។ ចាប់ពីឆ្នាំ២០០២ ដល់ ឆ្នាំ២០០៦ ជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានបច្ចេកទេស និង ផលិតកម្ម និងផ្គត់ផ្គង់ទឹក។ ពីឆ្នាំ ២០០៦ ដល់ ឆ្នាំ២០១២ ជាអគ្គនាយករងទទួលបន្ទុកត្រួតពិនិត្យ និងគ្រប់គ្រងគម្រោងសាងសង់រោងចក្រផលិតទឹកស្អាត ជ្រោយចង្វារ និងនិរោធ។ឆ្នាំ២០១២ ដល់ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ ជាអគ្គនាយករងទទួលបន្ទុកសាខាសេវាកម្មទឹកស្អាត និងអនាម័យ និងចាប់ពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ ដល់បច្ចុប្បន្ន ជាអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម នួន ផារ័ត្ន

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨០ និងបានទទួលបរិញ្ញាបត្រច្បាប់ផ្នែកសាធារណៈ និង ផ្នែកឯកជន នៅឆ្នាំ២០០១ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ នៅ Jean Moulin Lyon3 ឯកឧត្តមបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ វិជ្ជាជីវៈតុលាការ និងវិទ្យាសាស្ត្រព្រហ្មទណ្ឌ និងបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ នៅឆ្នាំ២០០៣។ ឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ ឯកឧត្តម ជាជំនួយការនាយិការនៅសាលាភូមិន្ទថៅក្រម។ ឆ្នាំ២០០៥ ដល់ ២០០៦ ឯកឧត្តម ជាមន្ត្រីទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ នៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ ឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ ឯកឧត្តមជាសាស្ត្រាចារ្យច្បាប់នៅចំនួនបីសកលវិទ្យាល័យ។ ឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥ ឯកឧត្តម ជាប្រធានក្រុមអ្នកច្បាប់ នៃការិយាល័យថៅក្រមស៊ើបអង្កេត នៅអង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ឆ្នាំ២០០៧ ដល់បច្ចុប្បន្ន ឯកឧត្តមជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៅទីស្តីការគណៈ រដ្ឋមន្ត្រី។ ចាប់បីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៧ មកដល់បច្ចុប្បន្ន ឯកឧត្តមជាអភិបាលរងនៃសាលារាជធានីភ្នំពេញ។ **ឯកឧត្តម នួន ផារ័ត្ន** ចូលជាសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៦ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ រហូតដល់បច្ចុប្បន្ន។

### - ជីវប្រវត្តិសង្ខេបរបស់លោក ម៉ា ណូរ៉ាវីន

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៣។ នៅឆ្នាំ១៩៩៦ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រលើជំនាញផ្នែកវារីសាស្ត្រនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ បន្ទាប់មក នៅឆ្នាំ២០០៨ លោកទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតជំនាញ Socio-Environmental Engineering នៅប្រទេសជប៉ុន។លោកចូលបម្រើការនៅ រ.ទ.ស.ភ នៅឆ្នាំ ១៩៩៧ និងទទួលការតែងតាំងជាប្រធានការិយាល័យសិក្សាគម្រោង នាឆ្នាំ២០០៣។ នៅឆ្នាំ២០០៨ បានទទួលការតែងតាំងជាអនុប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក និងពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៨ ជាប្រធាននាយកដ្ឋាផលិតកម្ម និងផ្គត់ផ្គង់ទឹក។ ឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២ ជាអគ្គនាយករងទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធផលិតកម្ម។ លោក ម៉ា ណូរ៉ាវីន បានចូលជាសមាជិកក្រុមប្រឹក្សាភិបាលអាណ្ណត្តិទី៧នៃ រ.ទ.ស.ភ ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់បច្ចុប្បន្ន។

### - ជីវប្រវត្តិសង្ខេបរបស់លោក ស្រេង សំឌិក

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៦២ ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែក គ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិពី West Coast University នៃរដ្ឋកាលីហ្វ័រញ៉ា ក្នុងឆ្នាំ១៩៩៤ និងបរិញ្ញាបត្រ វិទ្យាសាស្ត្រផ្នែកវិស្វកម្មអគ្គិសនី California State University of Long Beach ក្នុងឆ្នាំ១៩៨៨ នៃសហរដ្ឋ អាមេរិក។ ចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ លោកជាសមាជិកក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ ។

## ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

### ក. ក្រុមប្រឹក្សាភិបាល (ត)

### ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ (ត)

#### - ជីវប្រវត្តិសង្ខេបរបស់លោក ណាំ ចន្ទ្រី

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៨៦ ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រង អាជីវកម្មឯកទេសគ្រប់គ្រងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុង ឆ្នាំ ២០១៣។ ចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ លោកជាសមាជិកក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ ។

### ៣. ករណីអភិបាលណាម្នាក់ជាអភិបាលជាភាគហ៊ុនិក ឬសហកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សេងទៀត

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញពុំមានព័ត៌មានករណីអភិបាលណាម្នាក់ជាអភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុនផ្សេងទៀតនោះទេ។

### ៤. តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

- កំណត់គម្រោងអភិវឌ្ឍន៍សហគ្រាស ដោយអនុលោមតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល យោងតាមសំណើរបស់អគ្គនាយក
- កំណត់គម្រោងថវិកាប្រចាំឆ្នាំ និង កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបម្រុងសម្រាប់សម្រេច កម្មវិធីវិនិយោគ
- អនុម័តលើរបាយការណ៍គណនេយ្យ(របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលលម្អិត)
- កំណត់នូវរចនាសម្ព័ន្ធចាត់តាំងចំនួនក្របខ័ណ្ឌការបែងចែកមុខងារទូទៅ និង ប្រាក់បៀវត្សរ៍របស់និយោជិតតាមសំណើរបស់អគ្គនាយក
- អនុញ្ញាតឱ្យបើក ឬសម្រេចឱ្យបិទសកម្មភាពរបស់ការិយាល័យភ្នាក់ងារ ឬតំណាង
- អនុញ្ញាតឱ្យទិញអចលនទ្រព្យគ្រប់ប្រភេទ ដោយគោរពតាមប្រកាសលេខ៩៩៧ សហវ.ទរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការគ្រប់គ្រងលទ្ធកម្មនៅសហគ្រាសសាធារណៈ
- ជ្រើសរើសស្នងការគណនី និងកំណត់នូវលាភការជូនចំពោះស្នងការគណនី
- សម្រេចយល់ព្រមលើកិច្ចសន្យា ឬសន្ធិសញ្ញាផ្សេងៗ
- ធ្វើការពិនិត្យក្នុងចន្លោះពេលទៀតទាត់មួយ លើទិសដៅដែលបានកំណត់ឱ្យសហគ្រាស និងលើកឡើងនូវបណ្តាវិធានការកែសម្រួលលើកសំណើសុំកែប្រែលក្ខន្តិកៈ។

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ២១/០១/២០២២ | វិសាមញ្ញ | ▪ ឯកឧត្តម អ៊ុំ សុថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូរ៉ាវីន<br>▪ លោកឧកញ៉ា ចាង យុនហ្វេង<br>▪ លោក អោម សេងបូរ៉ា<br>▪ ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យរដ្ឋ អម រ.ទ.ស.ភ |
| ២ | ១៨/០៣/២០២២ | សាមញ្ញ | ▪ ឯកឧត្តម អ៊ុំ សុថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល (ត)

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ២ | ១៨/០៣/២០២២ | សាមញ្ញ | ▪ លោក ម៉ា ណូរ៉ាវីន<br>▪ លោកឧកញ៉ា ចាង យុនហ្វេង<br>▪ លោក អោម សេងបូរ៉ា<br>▪ ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យរដ្ឋ អម វ.ទ.ស.ភ |
| ៣ | ៣០/០៣/២០២២ | វិសាមញ្ញ | ▪ ឯកឧត្តម អ៊ុំ សុថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូរ៉ាវីន<br>▪ លោកឧកញ៉ា ចាង យុនហ្វេង<br>▪ លោក អោម សេងបូរ៉ា<br>▪ ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យរដ្ឋ អម វ.ទ.ស.ភ |
| ៤ | ២៤/០៦/២០២២ | សាមញ្ញ | ▪ ឯកឧត្តម អ៊ុំ សុថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ លោក ម៉ា ណូរ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យរដ្ឋ អម វ.ទ.ស.ភ |
| ៥ | ២៣/០៩/២០២២ | សាមញ្ញ | ▪ ឯកឧត្តម អ៊ុំ សុថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូរ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យរដ្ឋ អម វ.ទ.ស.ភ |
| ៦ | ២៣/១២/២០២២ | សាមញ្ញ | ▪ ឯកឧត្តម អ៊ុំ សុថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូរ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី មន្ត្រីត្រួតពិនិត្យរដ្ឋ អម វ.ទ.ស.ភ |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១- រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

#### ១-១ គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ស្រេង សំឌិក * | ប្រធានគណៈកម្មាធិការ - អភិបាលឯករាជ្យ | ០៨-កក្កដា-២០២២ | ២ | ២ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកគណៈកម្មាធិការ - អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០៨-កក្កដា-២០២២ | ១ | |
| ៣ | លោក ណាំ ចន្ទ្រី * | សមាជិកគណៈកម្មាធិការ -អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន | ០៨-កក្កដា-២០២២ | ២ | |
| ៤ | ឯកឧត្តម នេត មុន្នី | សមាជិកគណៈកម្មាធិការ - មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ | ០៨-កក្កដា-២០២២ | ២ | |
| ៥ | លោក ម៉ា ណូរ៉ាវីន | សមាជិកគណៈកម្មាធិការ - តំណាងនិយោជិត រ.ទ.ស.ភ | ០៨-កក្កដា-២០២២ | ២ | |

សម្គាល់៖

* យោងសេចក្តីសម្រេចលេខ ០០៣ ក្រ.ប្រ.ភ/ស.ស.រ ចុះថ្ងៃសុក្រ ១០កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ ស្តីពី ការកែសម្រួលសមាសភាពនៃគណៈកម្មាធិការសវនកម្មក្រុមប្រឹក្សាភិបាល អាណត្តិទី៧។

### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម៖

១- ពិនិត្យលើរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

២- ពិនិត្យលើការត្រួតពិនិត្យផ្ទៃក្នុង

៣- ពិនិត្យលើការធ្វើសវនកម្មផ្ទៃក្នុង

៤- ពិនិត្យលើការធ្វើសវនកម្មខាងក្រៅ

៥- ពិនិត្យលើការគ្រប់គ្រងហានិភ័យ ករណីមិនមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ

៦- របាយការណ៍ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាភិបាល

៧- អនុវត្តកិច្ចការផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

### លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម មាន៖

១- អនុសាសន៍ដល់សវនកម្មផ្ទៃក្នុងឱ្យស្វែងរកវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងផ្នែកសវនកម្មផ្ទៃក្នុង ដើម្បីទទួលបានចំណេះដឹង បង្កើនការយល់ដឹង សមត្ថភាព និងអភិវឌ្ឍក្នុងការបំពេញការងារស្របទៅនឹងបរិបទថ្មីៗ ដែលកំពុងកើតមានឡើងនៅក្នុងអង្គភាព ដើម្បីមានវិធានការទប់ស្កាត់ទៅលើហានិភ័យទាំងនោះបានទាន់ពេល

២- ផ្តល់អនុសាសន៍ដល់សវនកម្មផ្ទៃក្នុងឱ្យរៀបចំដំណើរការនីតិវិធីប្រតិបត្តិការការងារសវនកម្មផ្ទៃក្នុង ដោយមានបញ្ចូល (Audit Manual, Audit Framework, and Audit Charter) ដើម្បីងាយស្រួលដល់មន្ត្រី-និយោជិតសវនកម្មទាំងអស់អនុវត្តការងារឱ្យទទួលបាននូវប្រសិទ្ធភាព និងទុកជាឯកសារសម្រាប់មន្ត្រី-និយោជិតជំនាន់ក្រោយដែលមានភាពងាយស្រួលក្នុងការបំពេញការងារ។

៣- បានពិភាក្សា និងឯកភាពទៅលើផែនការសកម្មភាពសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២៣ (ការិយបរិច្ឆេទ ២០២២)។ បន្ថែមពីនេះ គណៈកម្មាធិការសវនកម្ម ស្នើឱ្យមានការរៀបចំ ផែនការធនធានមនុស្ស (Main power plan) និងផែនការអភិវឌ្ឍន៍ធនធានមនុស្ស (Training and Capacity Development Plan) សម្រាប់ឆ្នាំ២០២៣ នេះ

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

### ១- រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

### ១-១ គណៈកម្មាធិការសវនកម្ម (ត)

៤- បានឯកភាព ទៅលើផែនការគ្រោងចំណាយលើថ្លៃសេវាត្រួតពិនិត្យ និងសវនកម្ម សម្រាប់ក្រុមហ៊ុនសវនកម្មឯករាជ្យ និងលក្ខខណ្ឌការងារខាងលើ។ គណៈកម្មាធិការសវនកម្ម ក៏បានឯកភាពក្នុងការជ្រើសរើសសវនកម្មឯករាជ្យក្នុងរយៈពេល ២ឆ្នាំម្តង និងការស្នើសុំឆ្លងយោបល់ពីក្រុមប្រឹក្សាភិបាលក្នុងការងារនេះ។

៥- បានឯកភាពលើលទ្ធផលការងារសវនកម្មផ្ទៃក្នុង និងស្នើឱ្យមានការកែតម្រូវតាមការពិភាក្សា។ គណៈកម្មាធិការសវនកម្ម ស្នើសុំឱ្យសវនកម្មផ្ទៃក្នុង ផ្ញើជូនឡើងវិញនូវផែនការយុទ្ធសាស្ត្រ ៣ឆ្នាំ និងផែនការប្រចាំឆ្នាំ ២០២៣។

៦- បានពិភាក្សា និងឯកភាពទៅលើការជ្រើសរើសសវនករឯករាជ្យសម្រាប់ រយៈពេល១ឆ្នាំ ស្តីពីការផ្តល់សេវាសវនកម្មត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានហិរញ្ញវត្ថុ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ការិយបរិច្ឆេទ ២០២៣។ នឹងស្នើសុំឱ្យមានការអនុវត្តន៍រយៈពេល ២ឆ្នាំ ម្តងចាប់ពីឆ្នាំ ២០២៤ តទៅ។

៧- បានពិភាក្សា និងឯកភាពទៅលើគុណវុឌ្ឍិរបស់ក្រុមហ៊ុន និងការឆ្លើយតបទៅនឹងលក្ខខណ្ឌការងារនៃឯកសារដេញថ្លៃ ក្នុងការជ្រើសរើសសវនករឯករាជ្យ សម្រាប់ផ្តល់សេវាសវនកម្មត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានហិរញ្ញវត្ថុ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

៨- ផ្តល់អនុសាសន៍ដល់សវនកម្មផ្ទៃក្នុងឱ្យរៀបចំវាយតម្លៃ លើលទ្ធផលដែលបានពិនិត្យឃើញ ថាតើមានផលប៉ះពាល់ និងហានិភ័យកម្រិតណា និងវាយតម្លៃផ្តល់ជាចំណាត់ថ្នាក់ដូចជា កម្រិត A, B, C and D និងត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជារួម ដើម្បីរាយការណ៍ពីការវាយតម្លៃតាមបណ្តានាយកដ្ឋាន/អង្គភាពដែលបានធ្វើសវនកម្ម យោងតាមផែនការឆ្នាំ។

### ១.២. គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯកឧត្តម អ៊ុំ សុថា | ប្រធាន | ០៩-កក្កដា-២០២១ | ៣ | ៣ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិក | ០៩-កក្កដា-២០២១ | ៣ | |
| ៣ | ឯកឧត្តម នួន ផារ័ត្ន | សមាជិក | ០៩-កក្កដា-២០២១ | ២ | |
| ៤ | ឯកឧត្តមអគ្គនាយក រ.ទ.ស.ភ | សមាជិក | ០៩-កក្កដា-២០២១ | ៣ | |
| ៥ | លេខាធិការសហគ្រាស | លេខា | ០៩-កក្កដា-២០២១ | ៣ | |

### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំងនិងលាភការ

- ពិនិត្យ និងផ្តល់អនុសាសន៍លើលក្ខខណ្ឌគុណវឌ្ឍិ និងនីតិវិធីការជ្រើសរើសបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់
- វាយតម្លៃបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីដាក់ស្នើទៅក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើយន្តការ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មាធិការនានាយ៉ាងហោចណាស់១(មួយ)ដងក្នុង១ឆ្នាំ
- រៀបចំនីតិវិធីពិនិត្យ និងផ្តល់អនុសាសន៍លើលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
- អនុវត្តកិច្ចការផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

### ១- រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

#### ១.២. គណៈកម្មាធិការតែងតាំង និងលាភការ (ត)

**លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំងនិងលាភការ**

- ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ : បានបើកកិច្ចប្រជុំស្តីពីការតែងតាំងបុគ្គលិកជាន់ខ្ពស់ចំនួន៧រូប លេខាធិការសហគ្រាស១រូប និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន២រូប។
- ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ : បានបើកកិច្ចប្រជុំ ដើម្បីពិនិត្យ-សម្រេចលើបេក្ខភាពអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន។
- ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ : បានបើកកិច្ចប្រជុំ ដើម្បីពិនិត្យ-សម្រេចលើកសំណើសុំពិនិត្យ- សម្រេច ការបន្តអាណត្តិជូនប្រធានសវនកម្មផ្ទៃក្នុង។

### ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

| គណៈកម្មាធិការ | ឈ្មោះ | មូលហេតុ |
|---|---|---|
| គណៈកម្មាធិការសវនកម្ម | ១-លោក ស្រេង សំឌិក<br><br>២-លោក ណាំ ចន្ទ្រី | ១-លោក ស្រេង សំឌិក ត្រូវបានតែងតាំងជាអភិបាលឯករាជ្យជំនួសអោយលោក អោម សេងបូរ៉ា ដែលផុតអាណត្តិជាក្រុមប្រឹក្សាភិបាល<br>២-លោក ណាំ ចន្ទ្រី ត្រូវបានតែងតាំងជាអភិបាលមិនប្រតិបត្តិជំនួសអោយលោក ឧកញ៉ា ចាង យុនហ្វេង ដែលផុតអាណត្តិជាក្រុមប្រឹក្សាភិបាល |

## គ. លាភការ ឬប្រាក់បំណាច់

### ១. បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

| ល.រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការឬប្រាក់បំណាច់ (គិតជាពាន់រៀល) | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ១១៦.៤២៥.០៩៦រៀល | |
| ២ | អភិបាលប្រតិបត្តិ | ៥២.៦០៣.២៦៥រៀល | |
| ៣ | បុគ្គលិកជាន់ខ្ពស់ | ២៩៩.៥១៨.៤៣៣រៀល | |
| ៤ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥រូប | ៩៨.៨៤៧.៨៨៦រៀល | |

## ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២២នេះ រ.ទ.ស.ភ ពុំមានការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗនោះទេ។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | មុខជំនាញ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ▪ ក្នុងប្រទេស: បុគ្គលិកជាន់ខ្ពស់សរុប ១៩រូប (នារី:៣រូប) | | | | |
| ១ | លោក ដេង ប៉ូលីដែន | សិក្ខាសាលាពីឥទ្ធិពលនៃការអភិវឌ្ឍទីផ្សារមូលធននិរន្តរភាពក្នុងតំបន់អាស៊ានសម្រាប់ការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណនិរន្តភាពនៅកម្ពុជា | ២១ ដល់ ២៣/០៧/២០២២ | ខេត្តសៀមរាប |
| ២ | លោក សុខ ណារ៉េត | ACCA (The Association of Chartered Certified Accounting) | ចាប់ផ្ដើមចុងខែកក្កដា (សិក្សា៤ឆ្នាំ) | CamEd Business School |
| ៣ | លោក សុខ ណារ៉េត | កិច្ចលទ្ធកម្ម និងការគ្រប់គ្រង-ការអនុវត្តកិច្ចសន្យា | ១៤ ដល់ ១៧/០៩/២០២២ | ក្រុងព្រះសីហនុ |
| ៤ | - លោក ហួត សុខហេង<br>- លោក សោម សុវណ្ណ | Microsoft Project | ចាប់ផ្តើមពី ២៤/១០/២០២២ | រ.ទ.ស.ភ |
| ៥ | - លោក ហួត សុខហេង<br>- លោក សារុធ វឌ្ឍនា<br>- លោក ហេង សុផាន់ណារ៉ាត<br>- លោកស្រី សេង គាតារា<br>- លោក ឈឹម សេរីវុធ<br>- លោក សោម សុវណ្ណ<br>- លោកស្រី ស៊ឹម វល្លិកា<br>- លោកស្រី ប្រាក់ ចាន់មករា<br>- លោក កែម កានវិចិត្រ<br>- លោក អ៊ូ គុណវឌ្ឍន៍<br>- លោក ទុយ ប៊ុនសេរីរិទ្ធ<br>- លោក កាំង សោភីណា<br>- លោក រស់ បូរិន្ទ<br>- លោក មាស កុសល | ភាសាអង់គ្លេសទូទៅ | ចាប់ផ្តើមពី ២១/១១/២០២២ | វិទ្យាស្ថាន ELT |
| ▪ ក្រៅប្រទេស: បុគ្គលិកជាន់ខ្ពស់សរុប ០៥រូប (នារី:១រូប) | | | | |
| ១ | លោកស្រី រឿន ណារី | ការលើកកម្ពស់ផលិតភាពនិយោជិតនៅកន្លែងធ្វើការឌីជីថល" | ២៣ ដល់ ២៥/០២/២០២២ | (Online) ពីប្រទេសថៃ |
| ២ | - លោក អ៊ូ គុណវឌ្ឍន៍<br>- លោក សុខ ណារ៉េត | អភិបាលកិច្ចវិមជ្ឈការ និងគណនេយ្យភាពសាធារណៈ | ២៣ ដល់ ២៥/០២/២០២២ | (Online) ប្រទេសឥណ្ឌូនេស៊ី |
| ៣ | លោក ហួត សុខហេង | ការអនុវត្តន៍លម្អិតលើការវិភាគចលនាថយដោយប្រើប្រាស់កម្មវិធី SPSS | ២៥/០៦ ដល់ ០៨/០៧/២០២២ | (Online) ប្រទេសអាមេរិក |

| ល.រ | ឈ្មោះ | មុខជំនាញ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ៤ | ឯកឧត្តម ឡុង ណារ៉ូ | ចូលរួមវគ្គបណ្ដុះបណ្ដាលលើមុខជំនាញ | ០២ ដល់ ០៩/១២/ ២០២២ | ប្រទេសបារាំង |
| **ទស្សនៈកិច្ច និងចូលរួមវេទិការផ្សេងៗ: សរុប ៣៦រូប(នារីៈ៤រូប)** | | | | |
| ១ | ឯកឧត្តម ឡុង ណារ៉ូ | ចូលរួមក្នុងសន្និសីទអន្តរជាតិស្ដីពី World Water-TechInnovation Summit(WWTIS) | ១៩ ដល់២៥/០២/ ២០២២ | ប្រទេសអង់គ្លេស |
| ២ | ឯកឧត្តម ឡុង ណារ៉ូ | អញ្ជើញចូលរួមក្នុងកម្មវិធីចំនួន ០២<br>១-កិច្ចប្រជុំកម្រិតបច្ចេកទេសស្ដីពីការពង្រឹងស្ថានភាពប្រាំងទន្លេរបស់ស្ថានីយបូមទឹកល្អក់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង។<br>២-ទស្សនកិច្ច និងចូលរួមពិនិត្យការធ្វើតេស្ត(FAT)លើឧបករណ៍ Electrical Panel នៅរោងចក្រ Desya | ២៣/០៤ ដល់ ០១/០៥/២០២២ | ប្រទេសបារាំង |
| ៣ | លោក អ៊ុ គុណ្ណវឌ្ឍន៍ | ចូលរួមការត្រួតពិនិត្យ និងការធ្វើតេស្តទៅលើសម្ភារមួយចំនួន (Steel Pipes for Intake, Steel Pipes for Sand Filer/Treated Water Pumpin Station/Steel Walkaway son Clarifier) | ២៥ ដល់ ២៨/០៤/ ២០២២ | ប្រទេស វៀតណាម |
| ៤ | - ឯកឧត្តម ឡុង ណារ៉ូ<br>- លោក ផេង ប៉ូលីដែន<br>- លោក កាំង សោភីណា<br>- លោក អ៊ុ គុណ្ណវឌ្ឍន៍ | ចូលរួមចុះត្រួតពិនិត្យ ការធ្វើតេស្តបំពង់ដែក និងសម្ភារតភ្ជាប់ដែក | ០៦ ដល់ ២១/០៩/ ២០២២ | ប្រទេសបារាំង |
| ៥ | - ឯកឧត្តម ឡុង ណារ៉ូ<br>- លោក ផេង ទី | ចូលរួមក្នុងកិច្ចប្រជុំ និងធ្វើទស្សនកិច្ចសិក្សាលើដំណើរ ការគ្រប់គ្រងប្រព័ន្ធចែកចាយទឹកដោយប្រើបច្ចេកវិទ្យាឈ្លាសវៃ (Smart Water Management System) | ០៥ ដល់ ៣០/០៩/ ២០២២ | សាធារណរដ្ឋកូរ៉េ |
| ៦ | - លោក ម៉ាណូរ៉ាវីន<br>- លោក ជូ ផល្លា | ចូលរួមជាវាគ្មិនក្នុងកម្មវិធី "Borneo International Water and Wastewater Exhibition and conference 2022" | ១៦ ដល់ ២០/១០/ ២០២២ | ប្រទេសម៉ាឡេស៊ី |
| ៧ | - ឯកឧត្តម ឡុង ណារ៉ូ<br>- លោក ផេង ទី<br>- លោក សុខ ណារ៉េត<br>- លោក សោម សុវណ្ណ | ទស្សនកិច្ចសិក្សាស្ដីពី "PRV onsite training program" | ០៥ ដល់ ០៩/១១/ ២០២២ | ប្រទេស វៀតណាម |

| ល.រ | ឈ្មោះ | មុខជំនាញ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ៨ | លោក សំរិទ្ធ សុរិទ្យា | ចូលរួមកម្មវិធីពិភាក្សាលើប្រធានបទ ការគ្រប់គ្រងទឹកក្នុងវេទិកា Plant Show Osaka 2022 by UNIDO ប្រទេសជប៉ុន | ០២ ដល់ ១០/១២/ ២០២២ | ប្រទេសជប៉ុន |
| ៩ | - លោក ផេង ទី<br>- លោក ហួត សុខហេង | ចូលរួមក្នុងកម្មវិធី "ASIAWATER 2022" | ០៧ ដល់ ០៩/១២/ ២០២២ | ប្រទេសម៉ាឡេស៊ី |

# ផ្នែកទី៣.- ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត៖

### ការអនុវត្តច្បាប់ និងបទបញ្ញត្តិជាធរមាន

ក្នុងពេលបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវតែអនុវត្ត និងព្យាយាមធ្វើឱ្យ រ.ទ.ស.ភ អនុវត្តតាមច្បាប់ និងបទបញ្ញត្តិជាធរមាន។ ប្រសិនបើអភិបាល ឬ បុគ្គលិកជាន់ខ្ពស់ណាមួយបានដឹងពីព័ត៌មានដែលខ្លួនជឿជាក់ថា រ.ទ.ស.ភ អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតណាមួយបានបំពានច្បាប់ និងបទបញ្ញត្តិជាធរមាន អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ដែលបានដឹងត្រូវផ្តល់ព័ត៌មាននេះជូន អគ្គនាយក ប្រធានក្រុមប្រឹក្សាភិបាល ប្រធានគណៈកម្មាធិការសវនកម្ម ឬ សវនករផ្ទៃក្នុង។

### អំពើទំនាស់ផលប្រយោជន៍

បន្ថែមលើបទបញ្ញត្តិទាំងឡាយនៃមាត្រា ១៣៤ ១៣៥ ១៣៦ និងមាត្រា ១៣៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងនូវរាល់អំពើទំនាស់ផលប្រយោជន៍ដែលអាចកើតមានជាមួយ រ.ទ.ស.ភ។

ជាទូទៅទំនាស់ផលប្រយោជន៍កើតឡើងនៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬ ផលប្រយោជន៍របស់សមាជិកគ្រួសារផ្ទាល់របស់អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ បានជ្រៀតចូលក្នុង ឬ អាចនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់៖

(ក) ផលប្រយោជន៍ទូទៅ ឬអាជីវកម្មរបស់ រ.ទ.ស.ភ ។

(ខ) លទ្ធភាពរបស់អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ផ្សេងទៀតក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ហើយត្រូវធ្វើសេចក្តីអភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវប្រតិបត្តិការ ឬទំនាក់ទំនងណាមួយ ដែលខ្លួនគិតថានឹងនាំឱ្យកើតមាន ទំនាស់ផលប្រយោជន៍ជាមួយ រ.ទ.ស.ភ តាមការកំណត់របស់និយ័តករមូលបត្រកម្ពុជា ឬ ផ្សារមូលបត្រកម្ពុជា។

អភិបាល ឬ បុគ្គលិកជាន់ខ្ពស់របស់ រ.ទ.ស.ភ ត្រូវបង្ហាញនូវផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅ រ.ទ.ស.ភ ឬ ស្នើឱ្យមានសេចក្តីប្រកាស ដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលក្នុងករណីដែល៖

(ក) អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ ជាភាគីនៃកិច្ចសន្យា ឬ ជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយនឹង រ.ទ.ស.ភ ឬ

(ខ) អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ មានផលប្រយោជន៍សំខាន់ជាមួយនឹងបុគ្គល ឬ នីតិបុគ្គលដែលជាភាគីក្នុងកិច្ចសន្យា ឬ ភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយ រ.ទ.ស.ភ ។

ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ណាមួយនៅក្នុង រ.ទ.ស.ភ ដែលធ្វើឱ្យប៉ះពាល់ឯករាជ្យភាពរបស់ខ្លួន និងមិនត្រូវកាន់កាប់ភាគហ៊ុនលើសពីមួយ (១)ភាគរយនៃភាគហ៊ុនសរុបរបស់ រ.ទ.ស.ភ ឡើយ។

### កាលានុវត្តភាពអាជីវកម្ម

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ជាអាទិភាពដល់ផលប្រយោជន៍ស្របច្បាប់របស់ រ.ទ.ស.ភ នៅពេលសមស្រប។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាង៖

(ក) ឆ្លៀតឱកាសធ្វើកិច្ចការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដែលខ្លួនបានដឹងក្នុងពេលអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុង រ.ទ.ស.ភ ។

(ខ) ប្រើប្រាស់ទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ រ.ទ.ស.ភ ឬឋានៈ និងមុខតំណែងរបស់ខ្លួន ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។

(គ) ប្រកួតប្រជែងជាមួយ រ.ទ.ស.ភ ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច (ត)

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

ក្រុមប្រឹក្សាភិបាលនិងកំណត់ពីទង្វើដែលផ្ទុយពីខ្លឹមសារនៃប្រការនេះ ដោយពិចារណាលើអង្គហេតុ និងស្ថានការណ៍ដែលពាក់ព័ន្ធទាំងឡាយនៃទង្វើនោះ។

### ទំនាក់ទំនងដោយស្មើភាព

នៅក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវធ្វើឱ្យមានភាពស្មើគ្នាក្នុងទំនាក់ទំនងរវាងគ្នា និងជាមួយអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង អ្នកម៉ៅការ និងនិយោជិត រ.ទ.ស.ភ ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកប្រយោជន៍ពីបុគ្គលណាម្នាក់ដោយមិនស្មោះត្រង់ ដោយប្រើប្រាស់ឧបាយកល ការលាក់បាំង ការបំភ័ន្តព័ត៌មានសំខាន់ ការបង្ហាញហេតុការណ៍ដែលខុសពីការពិត ឬដោយអំពើមិនស្មោះត្រង់ផ្សេងទៀតក្នុងអាជីវកម្ម។

ការប្រើប្រាស់ ព័ត៌មានអំពីសិទ្ធិព័ត៌មានសម្ងាត់នៃអាជីវកម្មរបស់ រ.ទ.ស.ភ ឬការបញ្ចុះបញ្ចូល អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ រ.ទ.ស.ភ ទាំងអតីត និងបច្ចុប្បន្នឱ្យទម្លាយនូវព័ត៌មានទាំងនោះ ត្រូវបានហាមឃាត់ដាច់ខាត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដោយសុចរិត និងដើម្បីផលប្រយោជន៍របស់ រ.ទ.ស.ភ និងភាគហ៊ុនិកទាំងអស់របស់ រ.ទ.ស.ភ ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មិនត្រូវទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួនជាអភិបាល ឬ ជាបុគ្គលិកជាន់ខ្ពស់ និងមិនត្រូវទទួលអំណោយណាមួយពីតតិយជន ដោយសារមុខតំណែងជាអភិបាល ឬ បុគ្គលិកជាន់ខ្ពស់។

### ការការពារ និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជំរុញឱ្យមានការត្រួតពិនិត្យ និងការប្រើប្រាស់ឱ្យបានត្រឹមត្រូវ ដោយមានការទទួលខុសត្រូវ នូវទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ រួមទាំងទ្រព្យរូបិយ និងទ្រព្យអរូបិយ។

ទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ មានដូចជា ព័ត៌មាន សម្ភារៈ គ្រឿងបរិក្ខារ កម្មសិទ្ធិបញ្ញា ឧបករណ៍ ប្រភពធនធាន ប្រព័ន្ធព័ត៌មានវិទ្យា និងទ្រព្យដទៃទៀត ដែលជាកម្មសិទ្ធិរបស់ រ.ទ.ស.ភ ឬ ទ្រព្យដែល រ.ទ.ស.ភ ជួលពីគេ ឬ ទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ រ.ទ.ស.ភ ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអាជីវកម្មស្របច្បាប់របស់ រ.ទ.ស.ភ តែប៉ុណ្ណោះ។

### បណ្តឹងពាក់ព័ន្ធនឹងគណនេយ្យ

គណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ រ.ទ.ស.ភ ត្រូវទទួលខុសត្រូវក្នុងការរៀបចំនីតិវិធីសមស្របមួយសម្រាប់ទទួលពាក្យបណ្តឹង និងរក្សាទុកនូវពាក្យបណ្តឹង និងពិនិត្យលើពាក្យបណ្តឹងទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យគណនេយ្យផ្ទៃក្នុង ឬបញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងសវនកម្ម។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ អាចដាក់ពាក្យបណ្តឹងពីបញ្ហាខាងលើ ទៅគណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ រ.ទ.ស.ភ។ ការស្នើសុំឱ្យពិនិត្យបណ្តឹងជាសម្ងាត់ អាចធ្វើឡើងបានតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### ការលើកទឹកចិត្តឱ្យរាយការណ៍ពីទង្វើខុសច្បាប់ ឬអសីលធម៌

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវខិតខំជម្រុញឱ្យ រ.ទ.ស.ភ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងលើកទឹកចិត្តនិយោជិតឱ្យរាយការណ៍ពីកស្តុតាងនៃទង្វើខុសច្បាប់ ឬ អសីលធម៌ទៅនាយកដ្ឋាន ឬ បុគ្គលដែលមានសមត្ថកិច្ចនៅក្នុង រ.ទ.ស.ភ ។

### ការជួញដូរផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្ត និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិ ជាធរមានបទបញ្ជាផ្ទៃក្នុង និងគោលនយោបាយរបស់ រ.ទ.ស.ភ ពាក់ព័ន្ធនឹងការលក់-ទិញភាគហ៊ុន របស់ រ.ទ.ស.ភ ។

## ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច (ត)

### ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

#### ការរក្សាការសម្ងាត់

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាការសម្ងាត់នៃព័ត៌មានសម្ងាត់របស់ រ.ទ.ស.ភ ដែលខ្លួនបានដឹងលើកលែងតែក្នុងករណីដែល រ.ទ.ស.ភ អនុញ្ញាតឱ្យផ្តល់ព័ត៌មាន ឬការផ្តល់ព័ត៌មាននេះត្រូវបានតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យថា "ព័ត៌មានសម្ងាត់" រួមមានជាអាទិ៍ ព័ត៌មានមិនមែនសាធារណៈ ដែលអាចត្រូវបានប្រើដោយគូប្រកួតប្រជែងរបស់ រ.ទ.ស.ភ ឬព័ត៌មានមិនមែនសាធារណៈដែលធ្វើឱ្យប៉ះពាល់ដល់ រ.ទ.ស.ភ ឬ អតិថិជនរបស់ រ.ទ.ស.ភ ប្រសិនបើព័ត៌មាននោះត្រូវបានបង្ហាញ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវពិភាក្សាជាមុនជាមួយអគ្គនាយក ឬ ប្រធានក្រុមប្រឹក្សាភិបាល ប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ គិតថាខ្លួនមានកាតព្វកិច្ចតាមច្បាប់ក្នុងការបង្ហាញព័ត៌មានសំងាត់នោះ។

#### ការផ្តល់ព័ត៌មាន

អភិបាល និងបុគ្គលិកជាន់ខ្ពស់តម្រូវឱ្យយល់ច្បាស់ពីនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ដើម្បីឱ្យសេចក្តីប្រកាសជាសាធារណៈ របាយការណ៍ និងឯកសារផ្តល់ព័ត៌មាន ដែលត្រូវចុះបញ្ជីជាមួយអាជ្ញាធរវដ្ឋ រួមបញ្ចូលទាំងនិយ័តករមូលបត្រកម្ពុជា អាចរៀបចំធ្វើឡើងដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន រួមទាំងគោលការណ៍ណែនាំរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។

ម្យ៉ាងវិញទៀត ក្នុងទំហំនៃតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមានអំណាចដឹកនាំ ឬ គ្រប់គ្រងការចុះបញ្ជីឯកសារជាមួយ និយ័តករមូលបត្រកម្ពុជា និង/ឬ ផ្សារមូលបត្រកម្ពុជា ឬ ការជូនដំណឹងជាសាធារណៈផ្សេងទៀតរបស់ រ.ទ.ស.ភ ពាក់ព័ន្ធអាជីវកម្មទូទៅលទ្ធផលលក្ខខណ្ឌ និងលទ្ធភាពហិរញ្ញវត្ថុ ត្រូវពិភាក្សាជាមួយនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ផ្សេងទៀត និងជាមួយនិយោជិតពាក់ព័ន្ធ ហើយចាត់វិធានការសមស្របសម្រាប់នីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មាន ដើម្បីឱ្យការផ្តល់ព័ត៌មានធ្វើបានពេញលេញច្បាស់លាស់ ត្រឹមត្រូវ ទាន់ពេល និងអាចយល់បាន។

ក្នុងទំហំដែលពាក់ព័ន្ធនឹងនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ អភិបាល និងបុគ្គលិកជាន់ខ្ពស់ម្នាក់ៗ៖

- ត្រូវយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវនៃការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ក៏ដូចជាប្រតិបត្តិការអាជីវកម្ម និងហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ។
- មិនត្រូវធ្វើសេចក្តីថ្លែងខុសពីការពិត ឬ ធ្វើឱ្យអ្នកដទៃថ្លែងខុសពីការពិតទាក់ទងអំពីព័ត៌មានរបស់ រ.ទ.ស.ភ ប្រាប់អ្នកដទៃ ទោះបីជាអ្នកនោះនៅក្នុង ឬ នៅក្រៅ រ.ទ.ស.ភ រួមទាំងសវនករឯករាជ្យ និយ័តករ របស់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត។

#### វិសោធនកម្ម និងការលើកលែង

ក្រមសីលធម៌នេះអាចត្រូវបានធ្វើវិសោធនកម្មឬលើកលែងមិនអនុវត្តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាវិធានទូទៅក្រុមប្រឹក្សាភិបាលនឹងមិនផ្តល់ការលើកលែងមិនអនុវត្តប្រការណាមួយនៃក្រមសីលធម៌នេះឡើយ ប្រសិនបើគ្មានមូលហេតុសមស្រប និងចាំបាច់ទេនោះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានកាតព្វកិច្ចយល់ដឹងពីក្រមសីលធម៌នេះ និងស្វែងរកការពន្យល់ និងការផ្តល់ប្រឹក្សាបន្ថែមទាក់ទងនឹងការបកស្រាយខ្លឹមសារ និងលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌នេះជាពិសេសនៅពេលមានហេតុការណ៍ណាមួយដែលអាចមានទំនាស់ជាមួយនឹងក្រមសីលធម៌នេះ។

ក្រុមប្រឹក្សាភិបាលត្រូវបានចាត់វិធានការសមស្រប ក្នុងករណីដែលមានការបំពានក្រមសីលធម៌នេះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់អាចសាកសួរដោយផ្ទាល់ទៅអគ្គនាយក ទាក់ទងនឹងការអនុវត្ត ឬ ការបកស្រាយក្រមសីលធម៌នេះ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច (ត)

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

អានុភាព

ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ និងមានអានុភាពអនុវត្តចាប់ពី រ.ទ.ស.ភ ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ និងមានអានុភាពអនុវត្តចាប់ពី រ.ទ.ស.ភ ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ បានអនុម័តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ដោយត្រូវបានផ្សព្វផ្សាយ និងមានបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំ ជូនដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និយោជិត ភាគហ៊ុនិករបស់ រ.ទ.ស.ភ និងសាធារណជន។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ពុំមាន

## ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១- គោលនយោបាយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | គ្មាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | គ្មាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | គ្មាន |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលប់ | គ្មាន |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | គ្មាន |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | គ្មាន |
| ៧ | ផ្សេងៗ | គ្មាន |

### ២- ប្រតិបត្តិការសំខាន់ៗ ជាមួយភាគីជាប់ពាក់ព័ន្ធ

ពុំមាន

# ផ្នែកទី៤.- គ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

## ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

- ការកំណត់ទំហំមុខកាត់វ៉ានខាងក្នុងបំពង់ ដើម្បីធ្វើការគណនារកបរិមាណទឹកលាងសម្អាតចុងបំពង់ ពុំទាន់មានភាពសមស្របតាមការកំណត់ក្នុងកាតាឡុក។ ការិយាល័យជំនាញ បានធ្វើការកែសម្រួលឡើងវិញ។
- សម្រាប់រូបមន្តគណនាទំហំប្រេះធ្លាយគិតជាសង់ទីម៉ែត្រការ៉េ (Cm²) ជាក់ស្តែងការិយាល័យជំនាញបាន គិតជាមីលីម៉ែត្រ (mm) ដែលអនុវត្តផ្ទុយពីស្តង់ដានីតិវិធីប្រតិបត្តិការការងារកាត់បន្ថយទឹកបាត់បង់។ ការិយាល័យជំនាញ បានធ្វើការកែសម្រួលឡើងវិញឱ្យត្រឹមត្រូវតាមស្តង់ដានីតិវិធីប្រតិបត្តិការការងារ។
- ការគ្រប់គ្រងសន្និធិ (ស្តុកសម្ភារ) ពុំទាន់មានប្រសិទ្ធភាព ដោយសម្ភារមួយចំនួនពុំមានចលនា និងមាន ចលនាយឺត។ ការិយាល័យគណនេយ្យ បានធ្វើការបកស្រាយពីមូលហេតុ ដោយសារមានតម្រូវតិចតួច បំផុត សាមីនាយកដ្ឋាននិងអង្គភាពបញ្ជាទិញខ្លួនឯង និងបានស្នើសុំគ្រប់បណ្តានាយកដ្ឋានពាក់ព័ន្ធ ធ្វើការសហការ ដើម្បីពិនិត្យស្តុកសម្ភារលម្អិត មុននឹងលើកផែនការ ឬទិញសម្ភារប្រើប្រាស់។
- លិខិតជានាប្រាក់កក់លើការអនុវត្តន៍កិច្ចសន្យា មានរយៈពេលខ្លីជាងការប្រគល់-ទទួលទំនិញជាក់ស្តែងដែលអនុវត្តខុសពីកិច្ចសន្យាដែលបានកំណត់ក្នុងប្រការ៧។ អង្គភាពលទ្ធកម្ម បានពង្រឹងបន្ថែមលើការ ពិនិត្យ និងតាមដានក្នុងការអនុវត្តន៍បន្ត។

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការនៃប្រតិបត្តិដោយ ក្រុមប្រឹក្សាភិបាល, គណៈកម្មាធិការសវនកម្ម, សវនកម្មផ្ទៃក្នុង, សវនកម្មខាងក្រៅ, គណៈគ្រប់គ្រង និងបុគ្គលិក ក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាព ភាពត្រឹមត្រូវនៃប្រតិបត្តិការ និងភាពជឿទុកចិត្តលើការរាយការណ៍ព័ត៌មាន អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ក្នុងនោះរក្សាសុវត្ថិភាពទ្រព្យសកម្ម ព្រមទាំងអភិបាលកិច្ចសមស្របរបស់សហគ្រាស។ ដើម្បីឱ្យដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រេចបានត្រូវមានសមាសធាតុដូចជា បរិយាកាសគ្រប់គ្រង, ការវាយតម្លៃហានិភ័យ, ការគ្រប់គ្រងសកម្មភាព, ព័ត៌មាន និងទំនាក់ទំនង និងសកម្មភាពត្រួតពិនិត្យ។

យោងតាមផែនការឆ្នាំ២០២២ លើអនុលោមភាព និងប្រតិបត្តិការ សម្រាប់ការិយបរិច្ឆេទ ២០២១ ដោយមានការឯកភាពពីលោកប្រធានគណៈកម្មាធិការសវនកម្ម ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បានចុះត្រួតពិនិត្យនៅ៖

| | |
|---|---|
| ១-នាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក | (ត្រីមាសទី០១) |
| ២-សាខាសេវាកម្មទឹកស្អាត និងអនាម័យ | (ត្រីមាសទី០២) |
| ៣-មណ្ឌលព័ត៌មានវិទ្យា និងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | (ត្រីមាសទី០៣) |
| ៤-អង្គភាពលទ្ធកម្ម | (ត្រីមាសទី០៤) |

## គ. ការធ្វើសវនកម្ម

## ១- សវនកម្មផ្ទៃក្នុង

### ១-១ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង៖

- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម ៣ឆ្នាំ, ផែនការសវនកម្មប្រចាំឆ្នាំ ដាក់ជូនប្រធានគណៈកម្មាធិការសវនកម្មពិនិត្យ-សម្រេច និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ
- ពិនិត្យឡើងវិញនូវបណ្តាបែបបទ, គោលការណ៍ រួមទាំងបទដ្ឋានបច្ចេកទេស ដែលបានដាក់ចេញឱ្យ អនុវត្ត និងផ្តល់អនុសាសន៍ក្នុងការកែលម្អ។

# ផ្នែកទី៤.- គ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម (ត)

## គ. ការធ្វើសវនកម្ម (ត)

## ១- សវនកម្មផ្ទៃក្នុង (ត)

### ១-១ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង (ត)

- កំណត់ភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អ លើកិច្ចប្រតិបត្តិការរបស់អង្គភាព។
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន លើអនុលោមភាព និងកិច្ចប្រតិបត្តិការ តាមបណ្តានាយកដ្ឋាន/អង្គភាព ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណ វាស់វែង ចំណាត់ថ្នាក់ និងរាយការណ៍ អំពីព័ត៌មានទាំងនោះ។
- ត្រួតពិនិត្យលើការធ្វើសវនកម្មប្រចាំត្រីមាស និងឆ្នាំ ផ្ញើជូនផ្នែកនីមួយៗ របស់អង្គភាពដែលទទួលបន្ទុកកែលម្អតាមអនុសាសន៍ និងដាក់ជូនគណៈកម្មាធិការសវនកម្ម ពិនិត្យ-សម្រេច, រាយការណ៍ជូនក្រុមប្រឹក្សា ភិបាល និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ឬក្រសួងពាក់ព័ន្ធ។
- ត្រួតពិនិត្យឡើងវិញ នូវប្រព័ន្ធដែលកំពុងប្រើប្រាស់ ដើម្បីធានាបានតាមច្បាប់ និងបទបញ្ញត្តិនានា របស់រដ្ឋ និងអង្គភាពលើកិច្ចប្រតិបត្តិការ និងរបាយការណ៍។
- វាយតម្លៃឡើងវិញលើ ការគ្រប់គ្រង, ថែទាំ, ការពារ, ផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិ, វាយតម្លៃភាពសន្សំសំចៃ, ប្រសិទ្ធភាពប្រើប្រាស់ធនធាន, កំណត់កែលម្អលើការអនុវត្តន៍ និងផ្តល់អនុសាសន៍។
- សិក្សា និងវិភាគហានិភ័យ ដាក់ជូនប្រធានគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាល ពិនិត្យ-សម្រេច ដើម្បីរកដំណោះស្រាយតាមស្ថានភាពជាក់ស្តែង។
- រៀបចំផែនការចំណាយការផ្តល់សេវាសវនកម្ម និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។
- សម្របសម្រួលការងារសវនកម្មជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា។
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ១-២ ការតែងតាំង និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

ពុំមាន

### ១-៣ ការតែងតាំងថ្មីប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

ពុំមាន

## ២- សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម (រៀល) | តម្លៃសេវាមិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក | ០៥/ឧសភា/២០២២ | ២១៥.០០០.០០០ | |

មូលហេតុនៃការផ្លាស់ប្តូរ, ការផ្អាក និងការបញ្ឈប់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រគឺពុំមានទេ។

# ផ្នែកទី៥.- នាគីពាក់ព័ន្ធ

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ១ | សុខមាលភាពរបស់អតិថិជន | - ផ្តល់សេវា និងផ្តល់ទឹកស្អាតជូនអតិថិជនដោយធានាគុណភាព ទៅតាមស្តង់ដារជាតិ និងស្តង់ដារអន្តរជាតិ | នៅក្នុងឆ្នាំ២០២២ រ.ទ.ស.ភ បានផ្តល់សេវាជូនអតិថិជនក្នុងរាជធានីភ្នំពេញ ក្រុងតាខ្មៅ និងខេត្តត្បូងឃ្មុំ បានចំនួនសរុប ២៣.៨០០ បណ្តាញ<br>- ផ្តល់សេវាបណ្តាញទឹកជូនអតិថិជនប្រភេទឧបត្ថម្ភធនចំនួន ១.៤៤៧បណ្តាញ ក្នុងនោះ៖<br>• ឧបត្ថម្ភធន ៣០% ចំនួន ២២៨ បណ្តាញ<br>• ឧបត្ថម្ភធន ៥០% ចំនួន ៧០៥ បណ្តាញ<br>• ឧបត្ថម្ភធន ៧០% ចំនួន ២៩៦ បណ្តាញ<br>• ឧបត្ថម្ភធន ១០០% ចំនួន ២១៨ បណ្តាញ<br>- សរុបកំណើនបណ្តាញអតិថិជន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ មានចំនួន ៤៥១.៥៥៤ អតិថិជន(Active)<br>- ធានាគុណភាព ទឹកស្អាតជូនអតិថិជនប្រើប្រាស់ប្រចាំថ្ងៃ និងទទួលស្គាល់ពីថ្នាក់អន្តរជាតិ<br>- ដំណោះស្រាយជូនអតិថិជន ចែកចេញជាពីរផ្នែក៖<br>១.ទទួលព័ត៌មានពីអតិថិជនផ្ទាល់ និងតាមរយៈប្រព័ន្ធទូរស័ព្ទរបស់អង្គភាពសរុប ៣.៣១៣ ករណី<br>២.ទទួលព័ត៌មានគេហទំព័រហ្វេសប៊ុករបស់អង្គភាព សរុប ៤.០៣៤ ករណី |
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ | - អនុវត្តទៅតាមនីតិវិធីលទ្ធកម្ម(ច្បាប់លទ្ធកម្មសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា) | - រៀបចំផែនការលទ្ធកម្ម ស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ដំណាក់កាលនៃការរៀបចំដេញថ្លៃ<br>- ការផ្សព្វផ្សាយ លក់ ទទួលបើកសំណើដេញថ្លៃ<br>- ការវាយតម្លៃលើសំណើដេញថ្លៃ<br>- ការចុះកិច្ចសន្យា<br>ការគ្រប់គ្រង និងការអនុវត្ត កិច្ចសន្យា |

# ផ្នែកទី៥.- ភាគីពាក់ព័ន្ធ

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម (ត)

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ៣ | ការគ្រប់គ្រង និងការពារនិយោជិត | - លក្ខន្តិកៈបុគ្គលិក<br><br>- កិច្ចសន្យាការងារ<br><br>- បទបញ្ជាផ្ទៃក្នុង និងវិន័យ | អនុវត្តបានយ៉ាងខ្ជាប់ខ្ជួននូវបណ្តាចំណុចដែលមានចែង ក្នុងលក្ខន្តិកៈបុគ្គលិកដូចជា ៖<br>១- ការផ្តល់នូវថ្នាក់-កាំបៀវត្សរ៍តាមតួនាទី និងភារកិច្ច និងបើកបៀវត្សរ៍យ៉ាងទៀងទាត់ជូន២ដង ក្នុងមួយខែ<br>២- ផ្តល់នូវប្រាក់ផ្សេងៗដូចជាប្រាក់បំណាច់មុខងារ, ប្រាក់ប៉ះពាល់សុខភាព, ប្រាក់លើសម៉ោង, ប្រាក់បំណាច់អតីតភាពការងារ និងប្រាក់បុព្វលាភប្រចាំឆ្នាំ ជាដើម<br>៣- ផ្តល់ជូននូវសំលៀកបំពាក់ឯកសណ្ឋាន និងសម្ភារៈសុវត្ថិភាពពលកម្ម<br>៤- ធានាសុវត្ថិភាពការងារជូននិយោជិត ដោយអង្គភាពបាន បង់ប្រាក់ទៅបេឡាជាតិរបបសន្តិសុខសង្គម ផ្នែកគ្រោះថ្នាក់ ការងារ, ថែទាំសុខភាព និងផ្នែកសោធន<br>បានចុះកិច្ចសន្យាការងារជាមួយ:<br>• និយោជិតជាប់កិច្ចសន្យា<br>• និយោជិតសាកល្បងការងារ<br>• និយោជិតក្របខណ្ឌពេញសិទ្ធិ<br>និយោជិតគ្រប់រូបគោរពបានតាមបទបញ្ជាផ្ទៃ ក្នុងរបស់អង្គភាពដូចជា:<br>• ពេលវេលាធ្វើការពីម៉ោង៨:០០ព្រឹក ដល់ម៉ោង៤:៣០ ល្ងាច<br>• សំលៀកបំពាក់ឯកសណ្ឋានមាន៤ប្រភេទតាមការកំណត់<br>• គោរពឋានានុក្រមក្នុងការបំពេញការងារ |
| ៤ | ការគាំពារបរិស្ថាន | - ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលជាពិសេសក្រសួងបរិស្ថានលើការគិតគូរ និងគាំពារបរិស្ថាន | ការអនុវត្តគម្រោងពង្រីកប្រព័ន្ធផលិតកម្ម និងប្រព័ន្ធមេនាំទឹករបស់ រ.ទ.ស.ភ គឺចាប់ផ្តើមឡើង ដោយអង្គភាពបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ព្រមទាំងស្នើសុំការឯកភាពពីក្រសួងបរិស្ថាន។<br>ក្រោយពីទទួលបានឯកភាព និងនៅពេលដែលអនុវត្តគម្រោង រ.ទ.ស.ភ តែងតែធ្វើការត្រួតពិនិត្យលើផលប៉ះពាល់បរិស្ថានរបស់គម្រោងជារៀងរាល់ ឆមាស ព្រមទាំងរៀបចំជារបាយការណ៍ជូនម្ចាស់ហិរញ្ញប្បទាន និងក្រសួងបរិស្ថាន។ |
| ៥ | អន្តរកម្មជាមួយសហគមន៍ | - ពង្រីកផ្ទៃសេវាដល់សហគមន៍ទៅតាមលទ្ធភាពជាក់ស្តែង | រ.ទ.ស.ភ បានធ្វើការពង្រីកផ្ទៃសេវា ជូនប្រជាពលរដ្ឋដែលរស់នៅតាមបណ្តាសហគមន៍បានចំនួន ៨ភូមិ។ |
| ៦ | ការការពារសិទ្ធិរបស់ម្ចាស់បំណុល | - មានការធានាពីរាជរដ្ឋាភិបាល | លិខិតធានាផ្លូវច្បាប់ចេញដោយក្រសួងយុត្តិធម៌លេខ ២៥០២MOJ.IRDP/១៩ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ របស់គម្រោងសាងសង់រោងចក្របាក់ខែង។ |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | - អនុវត្តការងារអាជីវកម្មជាមួយអតិថិជនដោយមានតម្លាភាព | ១- ផ្តល់សេវាជូនអតិថិជនទាំងអស់ មិនប្រកាន់វណ្ណៈ ពណ៌សម្បុរ ឬបក្សពួកឡើយ<br>២- គ្រប់បុគ្គលិកជាន់ខ្ពស់ចាប់ពីប្រធាននាយកដ្ឋានឡើង ត្រូវប្រកាសទ្រព្យសម្បត្តិរៀងរាល់២ឆ្នាំម្តង |

# ផ្នែកទី៥.- ភាគីពាក់ព័ន្ធ (ត)

## ខ. ពិពណ៌នាអំពីការទទួលខុសត្រូវសង្គមរបស់ រ.ទ.ស.ភ

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | សកម្មភាព |
|---|---|---|---|
| ១ | សហគមន៍ និងប្រជាជនមានចំណូលទាប | ទឹកប្រាក់ប្រមាណ ៣០៩.៤០៧.៤០០រៀល | -បានអនុវត្តតាមគោលការណ៍ឧបត្ថម្ភធនក្នុងឆ្នាំ២០២២ បានចំនួន១.៤៤៧ប/ណ ដោយប្រើប្រាស់ថវិការមូលនិធិសង្គមរបស់ រ.ទ.ស.ភ |

# ផ្នែកទី៦.- ការបង្ហាញព័ត៌មាន និងតម្លាភាព

## ក. ការបង្ហាញព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/បេសកកម្ម/គោលដៅអាជីវកម្ម | មានបង្ហាញ |
| ២ | សូចនាករហិរញ្ញវត្ថុ | មានបង្ហាញ |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មានបង្ហាញ |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មានបង្ហាញ |
| ៥ | គោលនយោបាយភាគលាភ | មានបង្ហាញ |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មានបង្ហាញ |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មានបង្ហាញ |
| ៨ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មានបង្ហាញ |

## ខ. យន្តការនៃការបង្ហាញព័ត៌មាន មធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

លោក ដេង ប៉ូលីដែន អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច និង លោក ជូ ផល្លា លេខាធិការសហគ្រាស ជាបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ដែលមានការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ជាជំនួយការក្នុងការផ្តល់ព័ត៌មានសាជីវកម្ម។

ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនសុំការអនុម័តពីក្រុមប្រឹក្សាភិបាល រួចផ្ញើជូននិយ័តករមូលបត្រកម្ពុជា (ទម្រង់ PDF) ដើម្បីស្នើសុំការអនុញ្ញាតផ្សព្វផ្សាយរបាយការណ៍ទាំងនេះជាសាធារណៈ បន្ទាប់ពីទទួលបានការត្រួតពិនិត្យរបស់ អនុប្រធាន ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។ ក្រោយពីទទួលបានការអនុញ្ញាតពី និយ័តករមូលបត្រកម្ពុជា លើសំណើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិនត្រូវបញ្ជូនរបាយការណ៍នេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន ផ្តល់ព័ត៌មានពិសេស និងតាមការស្នើសុំជូននិយ័តករមូលបត្រកម្ពុជា បន្ទាប់ពីទទួលបានការត្រួតពិនិត្យរបស់ អនុប្រធាន ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងការអនុញ្ញាតរបស់ ឯកឧត្តមអគ្គនាយក រ.ទ.ស.ភ។ ក្រោយពីបានទទួលការអនុញ្ញាតពី និយ័តករមូលបត្រកម្ពុជា លើព័ត៌មានដែលបានស្នើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិនត្រូវបញ្ជូនព័ត៌មាននេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

ដោយឡែកព័ត៌មានទាន់ពេល និងព័ត៌មានតាមការស្ម័គ្រចិត្តត្រូវបានបញ្ជូនទៅ ផ្សារមូលបត្រកម្ពុជា តាមប្រព័ន្ធ E-Disclosure របស់ផ្សារមូលបត្រកម្ពុជា ដោយការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន បន្ទាប់ពីការត្រួតពិនិត្យរបស់អនុប្រធាន ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។ ក្រោយពីទទួលបានការអនុញ្ញាតរបស់ផ្សារមូលបត្រកម្ពុជា លើព័ត៌មានដែលបានស្នើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិនត្រូវបញ្ជូនព័ត៌មាននេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ នៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

# ផ្នែកទី៦.- ការបង្ហាញព័ត៌មាន និងតម្លាភាព (ត)

## គ. ទំនាក់ទំនងជាមួយវិនិយោគិន

### ១- យន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

រ.ទ.ស.ភ ធ្វើការទំនាក់ទំនងទៅវិនិយោគិន តាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ រ.ទ.ស.ភ ក្នុងការផ្តល់ព័ត៌មានអំពី ការបែងចែកភាគលាភប្រចាំឆ្នាំ និងមហាសន្និបាតភាគហ៊ុនិក។ ចំពោះវិនិយោគិនដែលមានបំណងស្វែងយល់អំពី រ.ទ.ស.ភ ត្រូវដាក់សំណើជាមុនមកកាន់ រ.ទ.ស.ភ ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្ររបស់ខ្លួន ដើម្បីឲ្យ រ.ទ.ស.ភ មានលទ្ធភាពរៀបចំតាមសំណើរបស់វិនិយោគិន។

ក្រៅពីយន្តការទំនាក់ទំនងខាងលើ វិនិយោគិនអាចធ្វើការទំនាក់ទំនងមកកាន់បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និង/ឬ ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុតាមរយៈសារអេឡិចត្រូនិកដូចខាងក្រោម៖

- បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន: Dpolyden@ppwsa.com.kh ឬ cphalla@ppwsa.com.kh
- ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន: Ksokuntheary@ppwsa.com.kh ឬ ir@ppwsa.com.kh

### ២- ទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងឆ្នាំ២០២២

នៅក្នុងឆ្នាំ២០២២ រ.ទ.ស.ភ បានធ្វើការទំនាក់ទំនងជាមួយនឹងវិនិយោគិនតាមរយៈ ធនាគារអេស៊ីលីដា ភីអិលស៊ី ក្នុងការផ្តល់ព័ត៌មានអំពី ការបែងចែកភាគលាភប្រចាំឆ្នាំ២០២១ និងមហាសន្និបាតភាគហ៊ុនលើកទី១០ របស់ រ.ទ.ស.ភ។

# ឧបសម្ព័ន្ធ ២

## របាយការណ៍សវនកម្មផ្ទៃក្នុង

## ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ

**ប្រចាំឆ្នាំ២០២២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការសវនកម្ម**

**សវនកម្មផ្ទៃក្នុង**

លេខ ...០០១......ស.ប.ក

# របាយការណ៍សវនកម្មផ្ទៃក្នុង
# ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ
# ប្រចាំឆ្នាំ២០២២ ការិយបរិច្ឆេទ ២០២១

ការងារត្រួតពិនិត្យផ្ទៃក្នុង គឺជាកត្តាចម្បងដ៏មានសារៈសំខាន់ដែលជួយដល់អង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សម្រាប់អនុវត្តការងារប្រចាំថ្ងៃប្រកបដោយជោគជ័យ និងសម្រេចបាននូវគោលដៅផ្គត់ផ្គង់ទឹកស្អាត ជូនអតិថិជនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ប្រកបដោយសុខុមាលភាព។

ក្នុងឆ្នាំ២០២១ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានមន្ត្រី-និយោជិត សរុបចំនួន ១.២១៩ នាក់ (នារី ២០៦ នាក់) ក្នុងនោះ ៖

- មន្ត្រីក្របខ័ណ្ឌរដ្ឋ ចំនួន ០២ នាក់ គឺអគ្គនាយក និងអគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច
- មន្ត្រី-និយោជិតក្របខ័ណ្ឌសហគ្រាស ចំនួន ១.១៣៣ នាក់ (នារី ១៩៦ នាក់)
- និយោជិតសាកល្បងការងារ ចំនួន ១៦ នាក់ (នារី ០៣ នាក់)
- និយោជិតជាប់កិច្ចសន្យា ចំនួន ៦៨ នាក់ (នារី ០៧ នាក់)

យោងតាមផែនការឆ្នាំ២០២២ លើអនុលោមភាព និងប្រតិបត្តិការ សម្រាប់ការិយបរិច្ឆេទ ២០២១ ដោយមានការឯកភាពពីលោកប្រធានគណៈកម្មាធិការសវនកម្ម ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បានចុះពិនិត្យនៅ៖

១- នាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក ត្រីមាសទី ០១

- យោងសេចក្តីសម្រេច លេខ ០០១ ក្រប្រ.ក/សសរ.គត ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការតែងតាំងបុគ្គលិកជាន់ខ្ពស់ ក្រុមប្រឹក្សាភិបាល អាណត្តិទី៧ នៃ រ.ទ.ស.ភ បច្ចុប្បន្នត្រូវបានចែកចេញជា ០២ គឺនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក។

២- សាខាសេវាកម្មទឹកស្អាត និងអនាម័យ ត្រីមាសទី ០២

៣- មណ្ឌលព័ត៌មានវិទ្យា និង នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ត្រីមាសទី ០៣

៤- អង្គភាពលទ្ធកម្ម ត្រីមាសទី ០៤

## ក- ការអនុវត្តន៍អនុសាសន៍សវនកម្មគ្រាមុន

| អនុសាសន៍សវនកម្ម | ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| I. **នាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក** (**ការិ. ២០១៩**) | | | |
| **១- ក្នុងព្រឹត្តិប័ត្រតាមដានការងារជួសជុលទឹកធ្លាយ ពុំបានបញ្ជាក់ពីពេលវេលាចាប់ផ្តើម និងពេលបញ្ចប់ចុះអនុវត្តការងារ**<br>ក្នុងឆ្នាំ២០១៩ ការិយាល័យស្រាវជ្រាវទឹកបាត់បង់ បានធ្វើការជួសជុលទឹកធ្លាយមើលឃើញ ចំនួន ១.៩៧៤កន្លែង។ សវនករបានពិនិត្យឃើញថា មានចំនួន ១.១៣២ កន្លែង ស្មើនឹង ៥៧,៣៤% ពុំបានបញ្ជាក់ពីពេលវេលាចាប់ផ្តើម និងបញ្ចប់ ក្នុងកំឡុងពេលចុះអនុវត្តការងារជួសជុលទឹកធ្លាយ ក្នុងនោះ៖ | អនុវត្តបានពេញលេញ | | |

| អនុសាសន៍សវនកម្ម | ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| ១- លេចធ្លាយដោយជីកប៉ះ ២៣៦ កន្លែង<br>២- លេចធ្លាយបំពង់ដោយសម្ភារ ៨៧៥ កន្លែង<br>៣- លេចធ្លាយបំពង់ដោយបច្ចេកទេស ២១ កន្លែង<br>ការិយាល័យ ត្រូវធ្វើការកត់ត្រាព័ត៌មានឱ្យបានច្បាស់ស្ដីពីការទទួលព័ត៌មាន, រយៈពេលលេចធ្លាយ និងពេលវេលាជួសជុលទឹកធ្លាយ ដើម្បីឱ្យរបាយការណ៍មានភាពត្រឹមត្រូវ និងពេញលេញ។ | | | |
| **២- ការជ្រើសរើសយកសម្ពាធទឹកក្នុងការគណនាទឹកបាត់បង់ ពុំទាន់មានសុក្រឹតភាព**<br>ក្នុងឆ្នាំ២០១៩ ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក បានធ្វើការកែសម្រួលប្រព័ន្ធចែកចាយទឹក ចំនួន ១.១៤៨ កន្លែង ក្នុងនោះ៖<br>១. ការជីកប៉ះដោយការដ្ឋានអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ចំនួន ១.០១៤ កន្លែង<br>- បំពង់មេនាំទឹក ០៤ កន្លែង<br>- បំពង់ចែកចាយទឹក ១៨៨ កន្លែង<br>- បណ្ដាញចូលផ្ទះ ៨២២ កន្លែង<br>២. ការកែសំរួលប្រព័ន្ធចែកចាយទឹក ១៣៤ កន្លែង<br>- បំពង់ចែកចាយទឹក ១០២ កន្លែង<br>- បណ្ដាញចូលផ្ទះ ៣២ កន្លែង<br>សវនករត្រួតពិនិត្យឃើញថា ក្នុងតារាងរបាយការណ៍ថែទាំប្រព័ន្ធចែកចាយទឹក ការិយាល័យបានកំណត់យកសម្ពាធទឹកថេរ នៅតាមតំបន់នីមួយៗសម្រាប់ធ្វើការគណនាទឹកបាត់បង់។<br>ការិយាល័យ ត្រូវធ្វើការកំណត់សម្ពាធទឹកឱ្យបានត្រឹមត្រូវតាមស្ថានភាពជាក់ស្ដែងនៅក្នុងតំបន់នីមួយៗ ដើម្បីងាយស្រួលក្នុងការគណនាទឹកបាត់បង់ឱ្យបានច្បាស់លាស់។ | អនុវត្តបានពេញលេញ | | |
| **៣- ការងារកើ-រៀបបំពង់មួយចំនួន អនុវត្តពុំទាន់ច្បាស់លើការងារគូសប្លង់ និងពុំបញ្ជាក់ចំនួនសម្ភារដែលបានយកទៅប្រើ**<br>ក្នុងឆ្នាំ២០១៩ ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក អនុវត្តការងារកើ-រៀបបំពង់បានចំនួន ២៩គម្រោង។ សវនករបានពិនិត្យឃើញថា ការិយាល័យអនុវត្តពុំទាន់បានសមស្របក្នុងតារាងព្រឹត្តិប័ត្រតាមដានការងារប្រចាំថ្ងៃ ដូចជា៖<br>១- ការយកសម្ភារទៅប្រើប្រាស់ ពុំមានបញ្ជាក់ក្នុងតារាងបរិយាយ មាន ១១ គម្រោង ស្មើនឹង ៣៧%។<br>២- ការគូសប្លង់ ពុំទាន់មានភាពច្បាស់លាស់ ជាមួយការអនុវត្តន៍ជាក់ស្ដែង មាន ១២គម្រោង ស្មើនឹង ៤១%។<br>ការិយាល័យ ត្រូវបញ្ជាក់ពីចំនួនសម្ភារដែលយកទៅប្រើឱ្យត្រូវជាមួយនឹងគំនូសប្លង់ និងត្រូវធ្វើបច្ចុប្បន្នភាពទៅលើគំនូសប្លង់ឱ្យបានត្រឹមត្រូវ។ | អនុវត្តបានពេញលេញ | | |
| **៤- ការស្នើសុំទូទាត់ចំណាយលើការងារកើ-រៀបបំពង់ ពុំមានការចុះហត្ថលេខាក្រុមកម្មករសេរី**<br>ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក មានក្រុមអនុវត្តការងារកើ-រៀបបំពង់ ចំនួន ០២ក្រុម និងមានគ្រឿងចក្រ ០២គ្រឿង។ ការងារកើ-រៀបបំពង់ ក្នុងឆ្នាំ២០១៩ មានចំនួន ២៩គម្រោង ស្មើនឹង ១០០% បានពិនិត្យឃើញថា សំណើសុំទូទាត់ការងារកើ-រៀបំពង់ អនុវត្តពុំទាន់ច្បាស់លាស់ ទៅលើ៖<br>១. ការចំណាយលើការជីករៀបដោយដៃ<br>២. ការចំណាយលើប្រើប្រាស់គ្រឿងចក្រ | អនុវត្តបានពេញលេញ | | |

| អនុសាសន៍សវនកម្ម | ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| ៣. ការចំណាយលើមេជាង<br>៤. ការចំណាយលើកម្មករជំនាញ<br>សវនករពិនិត្យឃើញថា ការចំណាយរបស់ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក ពុំមានការចុះហត្ថលេខារបស់ក្រុមកម្មករសេរីនៅលើសក្ខីប័ត្រចំណាយ ដោយមានតែប្រធានក្រុមការដ្ឋាន និងប្រធានការិយាល័យ តែប៉ុណ្ណោះ។<br>ការិយាល័យ ត្រូវឱ្យមានការចុះហត្ថលេខារបស់ក្រុមកម្មករសេរីលើប័ណ្ណចំណាយ ឱ្យបានត្រឹមត្រូវ មុននឹងធ្វើការទូទាត់។ | | | |
| **៥- លើព្រឹត្តិប័ត្រតាមដានការងារប្រចាំថ្ងៃ លោកអនុប្រធានការិយាល័យ បានចុះហត្ថលេខាត្រង់ប្រធានផ្នែក អនុវត្តផ្ទុយពីសេចក្តីសម្រេចលេខ ០៧០ ស.ស.រ**<br>ក្នុងឆ្នាំ២០១៩ ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក អនុវត្តការងាររើ-រៀបបំពង់បានចំនួន ២៩គម្រោង។ សវនករពិនិត្យឃើញថា មាន ២២គម្រោង ការទទួលខុសត្រូវទម្រង់ព្រឹត្តិប័ត្រតាមដានការងារប្រចាំថ្ងៃនៃការងាររើ-រៀបបំពង់ ឃើញថា លោកអនុប្រធានការិយាល័យទទួលបន្ទុកថែទាំប្រព័ន្ធចែកចាយទឹក បានចុះហត្ថលេខាត្រង់ការទទួលខុសត្រូវរបស់ប្រធានផ្នែក ដែលអនុវត្តផ្ទុយពីសេចក្តីសម្រេច លេខ ០៧០ ស.ស.រ។<br>មន្ត្រីទទួលបន្ទុក ត្រូវកំណត់អ្នកទទួលខុសត្រូវឱ្យបានច្បាស់លាស់ក្នុងការបំពេញការងារឱ្យសមស្របទៅតាមសេចក្តីសម្រេច និងភារកិច្ចទទួលខុសត្រូវដែលបានកំណត់។ | អនុវត្តបានពេញលេញ | | |
| II. **សាខាសេវាកម្មទឹកស្អាត និងអនាម័យ** (**ការិ. ២០១៩**) | | | |
| **១- ការប្រើប្រាស់សម្ភារក្នុងការអនុវត្តន៍ខុសពីគម្រោងដែលបានលើក និងពុំមានការឯកភាពពីម្ចាស់គម្រោង**<br>ឆ្នាំ២០១៩ សាខាបានទទួលគម្រោង ចំនួន ១.០៧៨ គម្រោង ក្នុងនោះ៖<br>- អនុវត្តគម្រោងបានចំនួន ១.០៤៨ គម្រោង<br>- បង្វិលទៅនាយកដ្ឋានផែនការ និងគម្រោង ចំនួន ២០ គម្រោង (ស្ថិតក្នុងផ្សារតូច សង្កាត់ស្នើសុំដាក់ជាមួយប្រព័ន្ធលូ ឆ្នាំ២០២០, ដីឯកជន, ពុំទាន់ចាក់ដីបំពេញ, កំពុងដាក់លូ និងមន្ទីរសាធារណការក្រុងកំពុងរៀបចំប្រព័ន្ធលូ)<br>- គម្រោងនៅសល់ ចំនួន ១០ គម្រោង<br>សវនករបានពិនិត្យឃើញថា មាន ១៣គម្រោង ស្មើនឹង ១,២% បានបើកសម្ភារយកទៅអនុវត្តខុសពីគម្រោងដែលបានលើក ដោយពុំមានគោលការណ៍ឯកភាពពីនាយកដ្ឋានផែនការ និងគម្រោង។<br>មន្ត្រីទទួលបន្ទុក ត្រូវសហការ និងមានការឯកភាពជាមួយនាយកដ្ឋានដែលទទួលបន្ទុកការងារលើកគម្រោង (នាយកដ្ឋានផែនការ និងគម្រោង) ដើម្បីធានាឱ្យបាននូវការអនុវត្តន៍ឱ្យស្របតាមលក្ខណៈបច្ចេកទេស ក្នុងករណីមានការអនុវត្តន៍ខុសពីគម្រោងដែលបានលើក។ | អនុវត្តបានពេញលេញ | | |
| **២- ការងារទូទាត់គម្រោងដាក់បំពង់នៅខេត្តសៀមរាប ពិនិត្យឃើញថា ពុំទាន់មានឯកសារភ្ជាប់គ្រប់គ្រាន់**<br>សាខាសេវាកម្មទឹកស្អាត និងអនាម័យ អនុវត្តគម្រោងខេត្តសៀមរាប (កញ្ចប់ទី១) ចំនួន ១៤ គម្រោង ក្នុងនោះមាន៖<br>- ដាក់បំពង់ដែក ០៤ គម្រោង<br>- ដំឡើងប្រអប់គ្រប់ប្រភេទ ០៤ គម្រោង<br>- ជីកកាត់ផ្លូវបេទីមមីណឺ ០១ គម្រោង<br>- ចាក់បេតុងអាមេទប់ការពារតំណខ្វែងបំពង់ ០១ គម្រោង<br>- សាកសំពាធ និងសម្លាប់មេរោគក្នុងបំពង់ដែក ០៣ គម្រោង<br>- សាងសង់សរសេរគ្រឹះទំរបំពង់ទឹក និងដំឡើងបំពង់ទឹក ០១ គម្រោង | អនុវត្តបានពេញលេញ | | |

| អនុសាសន៍សវនកម្ម | ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| សវនករបានពិនិត្យឃើញថា ការស្នើសុំទូទាត់ជូនក្រុមហ៊ុន **"ភាគី ខ" ពុំមានភ្ជាប់លិខិតស្នើសុំទូទាត់ និងពុំមានលិខិតបញ្ជាក់ពីលទ្ធផលការងារដែលអនុវត្តបានរបស់ "ភាគី ខ"**។<br>មន្រ្តីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តន៍ការងារឱ្យបានសមស្របទៅតាមកិច្ចសន្យាដែលបានកំណត់ រាល់ការស្នើសុំទូទាត់ត្រូវមានភ្ជាប់លិខិតស្នើសុំទូទាត់ និងលិខិតបញ្ជាក់ពីលទ្ធផលការងារ ដើម្បីឱ្យការទូទាត់មានភាពត្រឹមត្រូវ។ | | | |
| III. **ក- មណ្ឌលព័ត៌មានវិទ្យា** (**ការិ. ២០១៥**) | | | |
| **១ - ការពិនិត្យលើទិន្នន័យក្នុងតារាងសុំកែតម្រូវអតិថិជន**<br>សំណើសុំកែតម្រូវអតិថិជន ដែលមណ្ឌលព័ត៌មានវិទ្យា បានទទួលពីនាយកដ្ឋានអាជីវកម្ម មាន ០៤ខណ្ឌ ដូចជា៖ (ខណ្ឌ៧មករា, ទួលគោក, ដង្កោ និងពោធិ៍សែនជ័យ) មានអតិ. សរុបចំនួន ១៧.៣៣០អតិ. ក្នុងនោះមានការគូសធូតពីលើ (សំណើសុំចេញវិក័យបត្រថ្មី, ប្តូរតម្លៃការប្រើប្រាស់ទឹកពីជីវភាពទៅអាជីវកម្ម, ប្តូរនាឡិកាថ្មី, ប្តូរទីតាំង, ប្តូរឈ្មោះ...។ល។) មានចំនួន ២១៩ ស្មើនឹង ១,២៦% និងកោសលុបលើតួលេខបរិមាណទឹក មានចំនួន ១៣៣ ស្មើនឹង ០,៧៦%។<br>ដើម្បីជៀសវាងការភ័ន្តច្រលំ នៅពេលចេញវិក្កយបត្រវគ្គបន្ទាប់ មណ្ឌលព័ត៌មានវិទ្យា ត្រូវពិនិត្យលើតារាងសំណើសុំកែតម្រូវអតិថិជន មិនត្រូវឱ្យមានការកោសលុបដាច់ខាត ក្នុងករណី មានការគូសលើតួលេខណាមួយដែលខុសត្រូវមានហត្ថលេខាទទួលស្គាល់ពីការិយាល័យទទួលបន្ទុកដែលបានបញ្ជូនមក។ | អនុវត្តបានពេញលេញ | | |
| **២- ការបញ្ចូលទិន្នន័យសម្រាប់ប្រកាសវិក្កយបត្រ**<br>ការប្រកាសវិក្កយបត្រថ្លៃទឹក មានចំនួន ១.៦៧០.០៣៧ វិក្កយបត្រ។ ក្នុងនោះ មណ្ឌលព័ត៌មានវិទ្យា នៅមានចំណុចខ្វះចន្លោះក្នុងការត្រួតពិនិត្យលើឯកសារដែលទទួលបានពីនាយកដ្ឋានអាជីវកម្ម លើការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ មានចំនួន ២១ ស្មើនឹង ០,០០១% ក្នុងនោះមាន៖<br>- ការបញ្ចូល ថ្ងៃ ខែ ខុសវគ្គ មាន ចំនួន ០៥<br>- ការបញ្ចូលលេខអានខុស មាន ចំនួន ១៦<br>មណ្ឌលព័ត៌មានវិទ្យា ត្រូវពិនិត្យឱ្យបានច្បាស់មុនបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ ដើម្បីជៀសវាងការអូសបន្លាយពេលយូរ។ | អនុវត្តបានពេញលេញ | | |
| **៣- ការតាមដានលើការថែទាំប្រព័ន្ធកុំព្យូទ័រ**<br>មណ្ឌលព័ត៌មានវិទ្យា នៅខ្វះចន្លោះក្នុងការតាមដានលើការថែទាំប្រព័ន្ធកុំព្យូទ័រ និងវាយតម្លៃស្ថានភាពនៃបណ្តាបរិក្ខារដែលបានប្រើប្រាស់។<br>មណ្ឌលព័ត៌មានវិទ្យា ត្រូវរៀបចំសៀវភៅសម្រាប់តាមដានលើការថែទាំប្រព័ន្ធកុំព្យូទ័រ ដើម្បីងាយស្រួលតាមដានប្រវត្តិនៃការជួសជុល និងវាយតម្លៃពីគុណភាពនៃបរិក្ខារនីមួយៗ។ | ដោយសារចំនួនឧបករណ៍បរិក្ខារមានចំនួនច្រើន ពិបាកក្នុងការរៀបចំសៀវភៅតាមដាន។ មណ្ឌលព័ត៌មានវិទ្យាកំពុងរៀបចំឱ្យមាន Database ដើម្បីកត់ត្រា គ្រោងបញ្ចប់នៅចុងឆ្នាំ២០២៣។ | ដើម្បីឱ្យការអនុវត្តន៍មានប្រសិទ្ធភាព មណ្ឌលព័ត៌មានវិទ្យា ត្រូវប្រញាប់បញ្ចប់ការងារនេះឱ្យបានឆាប់ | ទាប |
| **៤- ការស្នើសុំប្រើប្រាស់អ៊ិនធើណេត**<br>ការប្រើប្រាស់ប្រព័ន្ធអ៊ិនធើណេតមានចំនួនច្រើន នៅតាមបណ្តានាយកដ្ឋាន/អង្គភាពដែលបានស្នើសុំ។ ក្នុងនោះ ដែលពុំឃើញមានសុំការឯកភាពពី **ឯកឧត្តមអគ្គនាយក** ក្នុងការកំណត់សិទ្ធប្រើប្រាស់អ៊ិនធើណេត និងអ៊ីម៉ែលរបស់មន្ត្រី-និយោជិត។ | អនុវត្តបានពេញលេញ | | |

| អនុសាសន៍សវនកម្ម | ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| ដើម្បីឱ្យមានប្រសិទ្ធភាពការងារ មណ្ឌលព័ត៌មានវិទ្យា ត្រូវអនុវត្តតាមស្តង់ដាការងារ (SOP) ដែលបានកំណត់ (និយោជិតគ្រប់គ្រងប្រព័ន្ធ ត្រូវលើកសំណើជូន **ឯកឧត្តមអគ្គនាយក** ពិនិត្យ-សម្រេច ក្នុងការកំណត់សិទ្ធប្រើប្រាស់អ៊ីនធើណេត និងអ៊ីម៉ែលដល់មន្ត្រី-និយោជិត)។ | | | |
| III **ខ- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ (ការិ. ២០២០)** | | | |
| **១- ការស្នើសុំទូទាត់ចំណាយលើការងារជើ-រៀបបំពង់ របស់ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក ពុំមានការចុះហត្ថលេខាតំណាងក្រុមកម្មករសេរី**<br>ការពិនិត្យលើឯកសារទូទាត់ ចំនួន ០៦ខែ (មេសា, ឧសភា, មិថុនា, កក្កដា, សីហា និងកញ្ញា) មានចំនួន ៨៤៨ សំណើ ក្នុងនោះ ពិនិត្យឃើញថា ការចំណាយទូទាត់លើការងារជើ-រៀបបំពង់ របស់ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក មាន ០៨ សំណើ ស្មើនឹង១០០% ពុំមានការចុះហត្ថលេខារបស់តំណាង ឬក្រុមកម្មករសេរី នៅលើប័ណ្ណចំណាយ ដោយមានតែប្រធានការដ្ឋាន និងប្រធានការិយាល័យ តែប៉ុណ្ណោះ។<br>ការិយាល័យ ត្រូវឱ្យមានការចុះហត្ថលេខារបស់ក្រុមកម្មករសេរី លើប័ណ្ណចំណាយឱ្យបានត្រឹមត្រូវមុននឹងធ្វើការទូទាត់។ | អនុវត្តបានពេញលេញ | | |
| IV **អង្គភាពលទ្ធកម្ម**<br>**ការិយបរិច្ឆេទ ២០១៨** | | | |
| **១- ការអនុវត្តកិច្ចលទ្ធកម្ម មិនស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវ**<br>មន្ត្រីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យបានត្រឹមត្រូវស្របតាមផែនការដែលបានលើកឡើង ដើម្បីឱ្យស្របតាមប្រកាសស្តីពីការអនុវត្តនីតិវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ " **ស្ថាប័នអនុវត្ត លទ្ធកម្ម ត្រូវចាត់ចែងអនុវត្តកិច្ចលទ្ធកម្ម ឱ្យបានទៀងទាត់តាមប្រតិទិនដែល បានកំណត់ក្នុងផែនការប្រចាំឆ្នាំ** "។ | អង្គភាពលទ្ធកម្ម មិនអាចអនុវត្ត បានពេញលេញ ដោយសារៈ<br>- មិនមានតម្រូវការលើមុខទំនិញមួយចំនួន<br>- នាយកដ្ឋានសាមីយកទៅអនុវត្តខ្លួនឯង<br>- មិនអនុវត្តលើគម្រោងមូលនិធិបម្រើផលប្រយោជន៍សង្គម។ | អង្គភាពលទ្ធកម្ម ត្រូវសហការជាមួយន/ជពាក់ព័ន្ធមុននឹងលើកផែនការប្រចាំឆ្នាំ។ | មធ្យម |
| **ការិយបរិច្ឆេទ ២០១៩** | | | |
| **១- ការចរចារតម្លៃ និងវាយតម្លៃប្រគល់កិច្ចសន្យាផ្គត់ផ្គង់ប្រេងឥន្ធនៈ អនុវត្តពុំទាន់បានសមស្រប ដោយអនុវត្តក្នុងថ្ងៃ និងម៉ោងតែមួយ**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការបែងចែកពេលវេលាទៅតាមនីតិវិធីនៃការអនុវត្តន៍ការងារឱ្យបានត្រឹមត្រូវ។ | អនុវត្តបានពេញលេញ | | |
| **២- ការប្រើប្រាស់ស៊ីម៉ង់ត៍ អនុវត្តពុំទាន់សមស្របទៅនឹងកិច្ចសន្យាដែលបានកំណត់**<br>មន្ត្រីទទួលបន្ទុក ត្រូវអនុវត្តការងារឱ្យបានត្រឹមត្រូវស្របតាមកិច្ចសន្យា ស្តីពីការផ្គត់ផ្គង់ស៊ីម៉ង់ត៍ " **កិច្ចសន្យានេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខារហូតអស់បរិមាណទំនិញ** " និងសារាចរណែនាំស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ " **រាល់ការខ្ចីនូវឧបករណ៍សម្ភារសម្រាប់ប្រើប្រាស់មុន ឬការប្រគល់-ទទួលទំនិញ សំណង់ សេវា នៃគម្រោងលទ្ធកម្មណាមួយដោយគ្មានកិច្ចសន្យា ត្រូវហាមឃាត់ដាច់ខាត។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនអនុញ្ញាតឱ្យធ្វើការទូទាត់ជូនឡើយ** "។ | អនុវត្តបានពេញលេញ | | |
| **៣- ការផ្គត់ផ្គង់ប្រេងម៉ាស៊ូត និងការផ្គត់ផ្គង់ខ្សាច់ទន្លេ អនុវត្តពុំទាន់បានសមស្រប ដោយអនុវត្តលើសពីតម្រូវការនៃការប្រើប្រាស់ជាក់ស្តែង**<br>អង្គភាពលទ្ធកម្ម ត្រូវសហការជាមួយនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ និងត្រូវធ្វើការពិនិត្យ-តាមដានស្តុកមុននឹងធ្វើការដេញថ្លៃ។ | អនុវត្តបានពេញលេញ | | |

## ខ- លទ្ធផលការងារសវនកម្ម

### I. នាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក

នាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក បានអនុវត្ត៖

- ការងារជួសជុលទឹកធ្លាយ ចំនួន ២.៦៦៦ កន្លែង ក្នុងនោះ៖
  - ជួសជុលទឹកធ្លាយមើលឃើញ មាន ២.១៩៣ កន្លែង
  - ជួសជុលទឹកធ្លាយមើលមិនឃើញ មាន ៤៧៣ កន្លែង
- ការងារលាងសម្អាត និងថែទាំបំពង់មេ ចំនួន ៣០៨ កន្លែង
- ការងាររើ-រៀបបំពង់អនុវត្តបាន ចំនួន ០៧ គម្រោង
- ការធ្វើសំណើសុំទូទាត់ជួសជុល-ផ្លាស់ប្តូរបរិក្ខាក្នុងប្រព័ន្ធផលិតកម្ម ចំនួន ១៥០ សំណើ

នាយកដ្ឋានអនុវត្តការងារបានរលូន និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយចំនួនដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

#### ១- ការកំណត់យកទំហំមុខកាត់វ៉ាន មកគណនារកបរិមាណទឹកលាងចុងបំពង់សម្រាប់ទំហំ ៦៣ មម ពុំទាន់មានភាពត្រឹមត្រូវ

ក្នុងឆ្នាំ២០២១ ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក បានធ្វើការលាងសម្អាត និងថែទាំបំពង់មេ ចំនួន ៣០៨ កន្លែង ស្មើនឹង ៧៨.៨៥៩,០៣ ម³ ក្នុងនោះសវនកម្មពិនិត្យឃើញថា ការកំណត់មុខកាត់សម្រាប់បង្ហូរលាងដើម្បីយកមកគណនារកបរិមាណទឹកសម្រាប់បង្ហូរលាងសម្អាតចុងបំពង់ ពុំទាន់មានភាពសមស្រប និងត្រឹមត្រូវ ដោយការិយាល័យជំនាញបានយកមុខកាត់របស់វ៉ានមកធ្វើការគណនា ដែលមានលក្ខណៈធំជាងវិជ្ជមាត្រខាងក្នុងបំពង់ មានចំនួន ៦៨ កន្លែង៖

| ការគណនាបរិមាណទឹក បង្ហូរលាងគិតតាមមុខកាត់វ៉ាន | ការគណនាបរិមាណទឹក បង្ហូរលាងតាមវិជ្ជមាត្រខាងក្នុងបំពង់ | លម្អៀងលើស | ភាគរយ |
|---|---|---|---|
| ១ | ២ | ៣ = ១ - ២ | ៤ = ៣ / ១ |
| ៧.៧២៩,៥២ ម³ | ៦.៥៨៦,១០ ម³ | ១.១៤៣,៤២ ម³ | ១៤.៧៩ % |

ប្រការនេះ អនុវត្តពុំទាន់បានសមស្របតាមការកំណត់ក្នុងកាតាឡុក៖

| | | វិជ្ជមាត្រខាងក្នុងបំពង់ | ការបង្ហូរលាងតាមទំហំមុខកាត់វ៉ាន |
|---|---|---|---|
| បំពង់ទំហំ PE | ៦៣ | ៦០ | ៦៥ |

ករណីនេះ នាំឱ្យការគណនារកបរិមាណទឹកដែលអនុញ្ញាតឱ្យប្រើប្រាស់ប្រចាំឆ្នាំពុំបានត្រឹមត្រូវ។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវយកចិត្តទុកដាក់ក្នុងការណែនាំ និងពិនិត្យទៅលើការកំណត់មុខកាត់បង្ហូរលាងចុងបំពង់ឱ្យបានត្រឹមត្រូវ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការគណនា។ **កម្រិតហានិភ័យ មធ្យម។**

***តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន :*** *ការិយាល័យនឹងធ្វើការតាមដានលើការអនុវត្តន៍ការងាររបស់មន្ត្រីទទួលបន្ទុកក្នុងការកំណត់ទំហំមុខកាត់បំពង់ ឬវ៉ាន បានកាន់តែស៊ីជម្រៅ និងលម្អិតលើរង្វាស់មុខកាត់តាមបទដ្ឋានស្តង់ដាឱ្យបានច្បាស់លាស់សម្រាប់ជាមូលដ្ឋានក្នុងការគណនា។*

*ការិយាល័យ នឹងធ្វើការកែសម្រួលបន្ទាប់ពីចេញជារបាយការណ៍។*

#### ២- ការយករូបមន្តសម្រាប់គណនាទំហំប្រេះធ្លាយលើការងារជួសជុលទឹកធ្លាយ អនុវត្តពុំទាន់មានភាពត្រឹមត្រូវ

ក្នុងឆ្នាំ២០២១ ការិយាល័យស្រាវជ្រាវទឹកបាត់បង់ បានធ្វើការជួសជុលទឹកធ្លាយក្នុងផ្ទៃសេវា ចំនួន ២.៦៦៦ កន្លែង ក្នុងនោះ៖

- ជួសជុលទឹកធ្លាយមើលឃើញ មានចំនួន ២.១៩៣ កន្លែង
- ជួសជុលទឹកធ្លាយមើលមិនឃើញ មានចំនួន ៤៧៣ កន្លែង

ការិយាល័យជំនាញបានគណនាទំហំប្រេះធ្លាយ គិតជាមីលីម៉ែត្រ (mm) មាន ១.៩៥២ កន្លែង ដែលអនុវត្ត ខុសពីការកំណត់រូបមន្តក្នុងស្តង់ដានីតិវិធីប្រតិបត្តិការការងារកាត់បន្ថយទឹកបាត់បង់ ដែលបានកំណត់ជា ($Cm^2$) ៖

- ជួសជុលទឹកធ្លាយមើលឃើញ មានចំនួន ៩០៦ កន្លែង ស្មើនឹង ៤១,៣១ %
- ជួសជុលទឹកធ្លាយមើលមិនឃើញ មានចំនួន ២៤៦ កន្លែង ស្មើនឹង ៥២ %

ប្រការនេះ អនុវត្តពុំទាន់បានសមស្របតាមស្តង់ដានីតិវិធីប្រតិបត្តិការការងារកាត់បន្ថយទឹកបាត់បង់ ត្រង់ចំណុច ៤.៣ **ការត្រួតពិនិត្យឡើងវិញនូវអត្រាទឹកបាត់បង់**

**រូបមន្តសម្រាប់គណនាទឹកធ្លាយ**

- ករណីដាច់បំពង់ ឬរន្ធធ្លាយ ទំហំនៃការលេចធ្លាយ ត្រូវគិតជា (មម) : **$0.003755 * D^2 (mm) * H^{0.5} (m)$**
- ករណីដាច់បំពង់បែក ឬប្រេះធ្លាយទំហំនៃការលេចធ្លាយ ត្រូវគិតជា (សម២) : **$0.478136 * A (cm^2) * H^{0.5} (m)$**

ករណីនេះ នាំឱ្យការគណនាអត្រាទឹកបាត់បង់ ពុំសមស្របទៅតាមរូបមន្តដែលបានកំណត់។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវធ្វើការកំណត់ព័ត៌មានឱ្យបានច្បាស់ និងត្រឹមត្រូវ មុនធ្វើការគណនា។ **កម្រិតហានិភ័យ មធ្យម។**

***តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន : យើងខ្ញុំទទួលយកអនុសាសន៍របស់សវនករ ដោយយើងខ្ញុំនឹងពង្រឹងបន្ថែមដល់និយោជិតអនុវត្តការងារខាងលើ និងខិតខំកែលម្អនូវកង្វះខាតនេះឱ្យបានជាអតិបរមា។***

***ការិយាល័យ នឹងចាប់ផ្តើមកែតម្រូវពីខែមេសា ឆ្នាំ២០២២ នេះតទៅ។***

## ៣- ការបំពេញព័ត៌មានក្នុងព្រឹត្តិប័ត្រតាមដានការងារជួសជុលទឹកធ្លាយ ពុំទាន់គ្រប់គ្រាន់

ក្នុងឆ្នាំ២០២១ ការិយាល័យស្រាវជ្រាវទឹកបាត់បង់ បានធ្វើការជួសជុលទឹកធ្លាយបាន ចំនួន ២.៦៦៦ កន្លែង ក្នុងនោះសវនករបានពិនិត្យឃើញ មានចំនួន ១.១៧១ កន្លែង ស្មើនឹង ៤៣,៩២ % ពុំទាន់បានបំពេញព័ត៌មានស្តីពីការលេចធ្លាយបានគ្រប់គ្រាន់។

ប្រការនេះ អនុវត្តពុំទាន់សមស្របតាមបែបបទរដ្ឋបាល។

ករណីនេះ នាំឱ្យពិបាកក្នុងការរកទីតាំងលេចធ្លាយនាពេលអនាគត។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការកត់ត្រាព័ត៌មានឱ្យបានច្បាស់ព័ត៌មានស្តីពីការលេចធ្លាយ ដើម្បីឱ្យរបាយការណ៍មានភាពត្រឹមត្រូវ ពេញលេញ និងស្របតាមស្តង់ដានីតិវិធីប្រតិបត្តិការការងារដែលបានកំណត់។ **កម្រិតហានិភ័យ ទាប។**

***តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន : យើងខ្ញុំនឹងខិតខំពង្រឹងបន្ថែម និងបណ្តុះបណ្តាលដល់និយោជិតទទួលបន្ទុកការងារខាងលើក្នុងការអនុវត្តន៍ការងារឱ្យកាន់តែមានប្រសិទ្ធភាព។***

***ការិយាល័យ នឹងចាប់ផ្តើមកែតម្រូវពីខែមេសា ឆ្នាំ២០២២ នេះតទៅ។***

## ៤- របាយការណ៍ជួសជុលទឹកធ្លាយ កត់ត្រាពុំទាន់ត្រឹមត្រូវជាមួយនឹងព្រឹត្តិប័ត្រតាមដានការងារប្រចាំថ្ងៃ

ក្នុងឆ្នាំ២០២១ ការិយាល័យស្រាវជ្រាវទឹកបាត់បង់ អនុវត្តការងារជួសជុលទឹកធ្លាយ បានចំនួន ២.៦៦៦ កន្លែង សវនករបានជ្រើសរើសយករបាយការណ៍ ០៤ខែ (មករា, តុលា, វិច្ឆិកា និងធ្នូ) ស្មើនឹង ១.០៣៩ កន្លែង មកធ្វើការពិនិត្យឃើញថា ការកត់ត្រាក្នុងតារាងព្រឹត្តិប័ត្រតាមដានការងារជួសជុលទឹកធ្លាយប្រចាំថ្ងៃ និងរបាយការណ៍ជួសជុលទឹកធ្លាយ មានភាពខុសគ្នា ចំនួន ១១២ ករណី ស្មើនឹង ១០,៧៨% ក្នុងនោះ៖

១- ការកំណត់ទំហំមុខកាត់ មាន ៣៨ ករណី

២- ការកត់ត្រាសម្ភារប្រើប្រាស់ មាន ៣៥ ករណី

៣- ការបញ្ជាក់មូលហេតុនៃការលេចធ្លាយ មាន ៣០ ករណី

៤- ការបញ្ជាក់មូលហេតុនៃការលេចធ្លាយ និងសម្ភារប្រើប្រាស់ មាន ០១ ករណី

៥- ការកំណត់ទំហំមុខកាត់ និងសម្ភារប្រើប្រាស់ មាន ០២ ករណី

៦- ការកំណត់ទំហំមុខកាត់ និងការបញ្ជាក់មូលហេតុនៃការលេចធ្លាយ មាន ០៦ ករណី

ប្រការនេះ អនុវត្តពុំទាន់សមស្របតាមបែបបទរដ្ឋបាល។

ករណីនេះ នាំឱ្យការរៀបចំរបាយការណ៍ពុំទាន់មានភាពច្បាស់លាស់។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ មុនបញ្ចូលទិន្នន័យទៅក្នុងរបាយការណ៍ជួសជុលទឹកធ្លាយ។ **កម្រិតហានិភ័យ ទាប**។

*តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន : យើងខ្ញុំនឹងខិតខំពង្រឹងបន្ថែមដល់និយោជិតទទួលបន្ទុកការងារខាងលើ ដើម្បីកែលម្អនូវកង្វះខាតនេះឱ្យបានជាអតិបរមា។*

*ការិយាល័យ នឹងចាប់ផ្តើមកែតម្រូវពីខែមេសា ឆ្នាំ២០២២ នេះតទៅ។*

**៥- ការធ្វើរបាយការណ៍អនុវត្តការងារលើសម៉ោងប្រចាំសប្តាហ៍ របស់និយោជិតនៅរោងចក្រទាំង ០៤ អនុវត្តពុំទាន់សមស្របតាមលក្ខន្តិកៈបុគ្គលិក**

នាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក មានបេសកកម្មផ្គត់ផ្គង់ទឹកស្អាត ២៤/២៤ម៉ោង តម្រូវឱ្យនិយោជិតបំពេញការងារនៅពេលយប់, ថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក តាមការចាត់តាំង។ សវនកម្មផ្ទៃក្នុង ពិនិត្យឃើញថា ក្នុងតារាងរបាយការណ៍ប្រចាំសប្តាហ៍របស់និយោជិតប្រចាំការនៅរោងចក្រទាំង ០៤ កត់ត្រាពុំទាន់បានត្រឹមត្រូវ ដោយអនុវត្តការងារស្នូលប្រចាំថ្ងៃបានត្រឹមតែ ៣៨ម៉ោង/មួយសប្តាហ៍ ក្នុងករណីមានការអនុវត្តន៍ការងារលើសម៉ោងបន្ថែម មន្ត្រីជំនាញពុំបានដក ២ម៉ោង មកបង្គ្រប់ក្នុងម៉ោងការងារស្នូល។

ប្រការនេះ អនុវត្តពុំទាន់បានសមស្របនឹងលក្ខន្តិកៈបុគ្គលិកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រង់៖**ផ្នែកទី២ " ពេលវេលាធ្វើការ " ប្រការ៥** : មន្ត្រី-និយោជិតទាំងអស់ នៃ រ.ទ.ស.ភ ត្រូវបំពេញការងារប្រាំបី (០៨) ម៉ោង ក្នុងមួយថ្ងៃត្រូវនឹងសែសិប (៤០) ម៉ោង ក្នុងមួយសប្តាហ៍តាមពេលវេលាកំណត់។

ករណីនេះ អាចនាំឱ្យការស្នើសុំទូទាត់ប្រាក់បុព្វលាភម៉ោងបន្ថែមរបស់និយោជិត ពុំទាន់មានភាពច្បាស់លាស់។

មន្ត្រីទទួលបន្ទុក ត្រូវសហការជាមួយនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស ក្នុងការរៀបចំរបាយការណ៍អនុវត្តការងារលើសម៉ោងប្រចាំសប្តាហ៍របស់និយោជិតរោងចក្រឱ្យស្របតាមលក្ខន្តិកៈបុគ្គលិក ដើម្បីងាយស្រួលក្នុងការតាមដាន។ **កម្រិតហានិភ័យ ទាប**។

*តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន : កន្លងមកការធ្វើរបាយការណ៍ការងារប្រចាំសប្តាហ៍របស់រោងចក្រទាំង ០៤ ចំពោះករណីនិយោជិតបំពេញការងារក្នុងមួយសប្តាហ៍បានតែ ៣៨ម៉ោង និងមានម៉ោងបន្ថែមបំពេញការងារក្រៅម៉ោងស្នូលបានបញ្ចូលក្នុង column ផ្សេងគ្នា មិនបានដក ០២ម៉ោង ពីម៉ោងបន្ថែមមកដាក់បង្គ្រប់ឱ្យគ្រប់ ៤០ម៉ោងទេ ប៉ុន្តែនៅពេលរបាយការណ៍នេះបញ្ជូនទៅដល់នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស ខាងការិយាល័យធនធានមនុស្ស តែងតែកាត់ពីម៉ោងបន្ថែមយកមកបង្គ្រប់ជានិច្ច និងក្នុងករណីមិនមានម៉ោងបន្ថែមក្រៅម៉ោងស្នូលគាត់តែងតែសរសេរខ្មៅដៃដាក់នៅក្នុងតារាង -២ មានន័យថានៅខ្វះ ០២ម៉ោង ខាងគាត់នឹងធ្វើការកាត់នៅសប្តាហ៍បន្ទាប់ ដែលមានម៉ោងលើស ឬបន្ថែម ក្រោយពីបានជួបពិភាក្សាជាមួយមន្ត្រីជំនាញការិយាល័យធនធានមនុស្សនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស យើងខ្ញុំនឹងធ្វើការកែសម្រួលរបាយការណ៍ការងារប្រចាំសប្តាហ៍ របស់និយោជិតរោងចក្រទាំង ០៤ តាមអនុសាសន៍ណែនាំ គឺចំពោះករណីមានម៉ោងបន្ថែមយើងខ្ញុំនឹងដក ០២ម៉ោង មកបង្គ្រប់ និងបើសិនមិនមានម៉ោងបន្ថែមទេយើងខ្ញុំនឹងសរសេរកំណត់សម្គាល់បញ្ជាក់ថាខ្វះ ០២ម៉ោង ។*

*ការិយាល័យនឹងធ្វើការកែសម្រួល បន្ទាប់ពីចេញជារបាយការណ៍។*

*សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានធ្វើរបាយការណ៍កែលម្អ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២។*

## II. សាខាសេវាកម្មទឹកស្អាត និងអនាម័យ

សាខាសេវាកម្មទឹកស្អាត និងអនាម័យ បានអនុវត្តការងារដាក់បំពង់ទឹកស្អាត សរុបបានប្រវែង ២៩៧.០៣០,៣៨ ម៉ែត្រ (រាជធានីភ្នំពេញ ប្រវែង ២៦៩.៤៧៦,៧៨ ម៉ែត្រ, ត្បូងឃ្មុំ ប្រវែង ២៧.៥៥៣,៦០ ម៉ែត្រ) ធៀបនឹងផែនការប្រវែង ២៨០.០០០ ម៉ែត្រ ស្មើនឹង ១០៦.០៨%។

- **ការងារទទួលគម្រោង និងបង្វិលគម្រោង មាន ១.០៧២ គម្រោង ក្នុងនោះ៖**
  - ការងារទទួលគម្រោង មាន ១.១៧៩ គម្រោង
  - ការងារដាក់លូ មាន ០២ គម្រោង
  - ការបង្វិលគម្រោង មាន (១១០) គម្រោង
  - ទទួលគម្រោងមកវិញ (បន្ទាប់ពីបង្វិល) មាន ០១ គម្រោង
- **ការងារអនុវត្តគម្រោង មាន ៨៥៧ គម្រោង ក្នុងនោះ៖**
  - បានអនុវត្តចប់ មាន ៨០១ គម្រោង
  - ការងារដាក់លូចប់ មាន ០២ គម្រោង
  - កំពុងអនុវត្ត មាន ៥៤ គម្រោង
- **ការងារទូទាត់គម្រោង មាន ៨០៣ គម្រោង ក្នុងនោះ៖**
  - បានរៀបចំសំណើសុំទូទាត់ ចំនួន ៤៤៥ គម្រោង
  - កំពុងរៀបចំធ្វើការទូទាត់ ចំនួន ៧៨ គម្រោង
  - គម្រោងមិនទាន់បានរៀបចំទូទាត់ ចំនួន ២៨០ គម្រោង

សាខាសេវាកម្មទឹកស្អាត និងអនាម័យ អនុវត្តការងារបានល្អ និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយ ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

### វិក្កយបត្រខ្សាច់ ស្ទួនលេខគ្នា និងសរសេរត្រួតលើគ្នា

សាខាសេវាកម្មទឹកស្អាត និងអនាម័យ អនុវត្តការងារដាក់បំពង់បាន ចំនួន ៨៥៧ គម្រោង (បានអនុវត្តបញ្ចប់ ៨០៣ គម្រោង និងកំពុងអនុវត្ត ៥៤ គម្រោង) ក្នុងនោះ៖

- បានរៀបចំសំណើសុំទូទាត់ ចំនួន ៤៤៥ គម្រោង
- កំពុងរៀបចំធ្វើការទូទាត់ ចំនួន ៧៨ គម្រោង
- គម្រោងមិនទាន់បានរៀបចំទូទាត់ ចំនួន ២៨០ គម្រោង

សវនកម្មផ្ទៃក្នុង បានជ្រើសរើសការងារស្នើសុំទូទាត់មកពិនិត្យ ចំនួន ២៥៩ គម្រោង ឃើញថា វិក្កយបត្រទទួលខ្សាច់ពុំទាន់មានភាពត្រឹមត្រូវ៖

**ក-** វិក្កយបត្រខ្សាច់ស្ទួនលេខគ្នា ចំនួន ០៧ គម្រោង

**ខ-** វិក្កយបត្រខ្សាច់សរសេរត្រួតលើគ្នា ចំនួន ១៧១ គម្រោង

**គ-** វិក្កយបត្រខ្សាច់សរសេរត្រួតលើគ្នា និងការប្រគល់-ទទួល មុនថ្ងៃអនុវត្ត (១៨ ថ្ងៃ - ១១៥ ថ្ងៃ) និងក្រោយថ្ងៃអនុវត្ត (០១ ថ្ងៃ - ១៧២ ថ្ងៃ) ស្មើ ១៧ គម្រោង

**ឃ-** វិក្កយបត្រខ្សាច់សរសេរត្រួតលើគ្នា និងរបាយការណ៍អនុវត្តគម្រោង ចេញមុនថ្ងៃអនុវត្តជាក់ស្តែង (១៩ ថ្ងៃ - ៨១ ថ្ងៃ) ចំនួន ០៧ គម្រោង

**ង-** ការរៀបចំវិក្កយបត្រទូទាត់ខ្សាច់ ខុសពីការអនុវត្តន៍ជាក់ស្តែង ស្មើ ៥៧ គម្រោង។

**ឧទាហរណ៍៖**

| លេខកូដគម្រោង | ថ្ងៃចាប់ផ្តើមអនុវត្ត | ថ្ងៃអនុវត្តបញ្ចប់ | ថ្ងៃទទួលខ្សាច់ | បរិមាណ (ម៉$^3$) |
|---|---|---|---|---|
| • P21-11-06-H-110-017 | 07/09/2021 | 01/10/2021 | 07-08/09/2021 | 132 |
| • P21-09-04-H-110-005 | 15/06/2021 | 26/06/2021 | 15-16/06/2021 | 298 |
| • P21-11-08-H-225-002 | 26/03/2021 | 06/04/2021 | 25-26/03/2021 | 428 |

ប្រការនេះ អនុវត្តពុំទាន់សមស្របតាមបែបបទរដ្ឋបាល។

ករណីនេះ នាំឱ្យប៉ះពាល់ដល់ការរៀបចំរបាយការណ៍ និងពុំទាន់មានភាពច្បាស់លាស់។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការពិនិត្យ និងកត់ត្រាឱ្យបានត្រឹមត្រូវ។ **កម្រិតហានិភ័យ ទាប**។

*តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន : ករណីវិក្កយបត្រខ្វាច់ដូចបានពិនិត្យឃើញ ពិតជាត្រឹមត្រូវ។ សាខានឹងត្រួតពិនិត្យកែតម្រូវឡើងវិញ មុននឹងរៀបចំឯកសារទូទាត់។*

*សាខា នឹងខិតខំកែលម្អឡើងវិញនៅដំណាច់ ខែកក្កដា ឆ្នាំ២០២២។*

*សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានផ្ញើរបាយការណ៍កែលម្អ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។*

### III. ក- មណ្ឌលព័ត៌មានវិទ្យា

- ទទួលលិខិតស្នើសុំចេញ Non- Invoice for Spot Billing ចំនួន ១.៦១៨ ច្បាប់។
- ទទួលការផ្គត់ផ្គង់អាជ្ញាប័ណ្ណបន្តសម្រាប់អនុវត្ត មានចំនួន ៣ ៖
  - Microsoft Office ៣៦៥
  - Architecture Engineering & Construction
  - Antivirus

មណ្ឌលព័ត៌មានវិទ្យា អនុវត្តការងារបានរលូន និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

**នីតិវិធីប្រតិបត្តិការការងារ** (SOP) **ពុំទាន់បានធ្វើបច្ចុប្បន្នភាព**

មណ្ឌលព័ត៌មានវិទ្យា បានរៀបចំចងក្រងនីតិវិធីប្រតិបត្តិការការងារ (SOP) ដើម្បីឱ្យនិយោជិតនៅមណ្ឌលព័ត៌មានវិទ្យាអនុវត្តតាម ដែលបានរៀបរៀងលើកទី១ នៅខែមករា ឆ្នាំ២០១៥ ក្នុងនោះ៖

- ស្តង់ដានីតិវិធីប្រតិបត្តិការការងារគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា
- ស្តង់ដានីតិវិធីប្រតិបត្តិការការងារបោះពុម្ពវិក្កយបត្រ

បច្ចុប្បន្ននេះមានការកែសម្រួលមួយចំនួន ទៅលើប្រព័ន្ធបច្ចេកវិទ្យាដោយពិនិត្យឃើញថា នីតិវិធីប្រតិបត្តិការការងារ (SOP) របស់មណ្ឌលព័ត៌មានវិទ្យា ពុំទាន់បានធ្វើបច្ចុប្បន្នភាពនៅឡើយ។

ប្រការនេះ អនុវត្តពុំទាន់សមស្របតាមការអនុវត្តន៍ការងារជាក់ស្តែង។

ករណីនេះ នាំឱ្យការអនុវត្តន៍ការងាររបស់មន្ត្រី-និយោជិតជាក់ស្តែង ពុំទាន់បានធ្វើការបែងចែងការងារបានត្រឹមត្រូវ។

មណ្ឌលព័ត៌មានវិទ្យា ត្រូវធ្វើបច្ចុប្បន្នភាពទៅលើនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន ឱ្យមានលក្ខណៈស្របតាមសម័យកាលនៃបច្ចេកវិទ្យា។ **កម្រិតហានិភ័យ ទាប**។

*តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន : មណ្ឌលព័ត៌មានវិទ្យា បាននឹងកំពុងធ្វើបច្ចុប្បន្នភាពលើនីតិវិធីប្រតិបត្តិការការងារទៅលើការងារគ្រប់ផ្នែកទាំងអស់។ ការងារនេះគ្រោងនឹងបញ្ចប់នៅខែធ្នូ ឆ្នាំ២០២២។*

*សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានផ្ញើរបាយការណ៍កែលម្អ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣។*

### III. ខ- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

- ការងារទូទាត់ចំណាយផ្សេងៗ សម្រាប់រយៈពេល ០៦ខែ ( មករា, កុម្ភៈ, ឧសភា, មិថុនា, វិច្ឆិកា និងធ្នូ) មានចំនួន ១.៤៧៩ សំណើ៖
  - ការទូទាត់ចំណាយគិតជាលុយរៀល មាន ៩៤០ សំណើ
  - ការទូទាត់ចំណាយគិតជាលុយដុល្លា មាន ៥៣៩ សំណើ

- ការងារទូទាត់ថវិកា និងជម្រះបំណុល សម្រាប់គម្រោងដាក់បំពង់ទឹក ចាប់ពីឆ្នាំ ២០១៦-២០២០ មានចំនួន ១.២៥៧ គម្រោង។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ អនុវត្តការងារបានរលូន និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយ ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

**ការគ្រប់គ្រងស្តុកសម្ភារ ពុំទាន់មានភាពត្រឹមត្រូវ**

គិតត្រឹមថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ សវនកម្មផ្ទៃក្នុងបានពិនិត្យលើរបាយការណ៍សន្និធិ (ស្តុកសម្ភារ) ឃើញថា សម្ភារចំនួន ២៦៧ មុខ ពុំមានចលនា និងមានចលនាយឺត។

ប្រការនេះ នាំឱ្យប៉ះពាល់ដល់គុណភាពរបស់សម្ភារ។

ករណីនេះ នាំឱ្យការគ្រប់គ្រងស្តុក ពុំទាន់មានប្រសិទ្ធភាព។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីពិនិត្យតាមដាន និងកត់ត្រាឱ្យបានត្រឹមត្រូវលើសម្ភារមុននឹងបញ្ជាទិញ ដើម្បីចៀសវាងការកកស្ទះសម្ភារក្នុងឃ្លាំង។ **កម្រិតហានិភ័យ មធ្យម។**

*តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន :*

- *សម្ភារចំនួន ២៦៧ មុខ ជាសម្ភារដែលមានចលនាយឺត ដោយសារមានតម្រូវការប្រើប្រាស់តិចតួចបំផុត ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពសម្ភារក្នុងការរក្សាទុកយូរ។*
- *ផ្នែកឃ្លាំងសម្ភារនៃការិយាល័យគណនេយ្យ តែងតែសហការផ្តល់សមតុល្យស្តុកចុងគ្រានៃរាល់បណ្តាសម្ភារដែលមានក្នុងបញ្ជីស្តុកជូនទៅកាន់សាមីនាយកដ្ឋាន ការិយាល័យប្រើប្រាស់នៅពេលមានតម្រូវការទិន្នន័យស្តុកនានា។*
- *ចំពោះការបញ្ជាទិញសម្ភារបន្ថែមជារៀងរាល់ឆ្នាំ គឺសាមីនាយកដ្ឋាន និងអង្គភាព ប្រើប្រាស់គឺជាអ្នកបញ្ជាទិញ ផ្អែកតាមតម្រូវការប្រើប្រាស់រៀងៗខ្លួន។*
- *យោងអនុសាសន៍នេះ ផ្នែកឃ្លាំងសម្ភារស្នើសុំដល់គ្រប់នាយកដ្ឋាន និងការិយាល័យពាក់ព័ន្ធស្នើសុំសហការពិនិត្យស្ថានភាពស្តុកសម្ភារលម្អិតមុននឹងលើកផែនការទិញ ឬទិញសម្ភារទាំងនោះយកមកប្រើប្រាស់ ដើម្បីធានាបានការប្រើប្រាស់សមស្រប និងមិនមានសម្ភារកកស្ទះពុំមានចលនា ឬមានចលនាយឺត។ ការអនុវត្តន៍ការត្រួតពិនិត្យសមតុល្យស្តុកសម្ភារមុននឹងទិញថ្មីបន្ថែមគឺបានអនុវត្តខ្ជាប់ខ្ជួន។*

*នៅពេលលើកផែនការលទ្ធកម្មប្រចាំនាបណ្តាឆ្នាំកន្លងមកក៏ដូចឆ្នាំ២០២២ និងបណ្តាឆ្នាំខាងមុខ។*

*សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានផ្ញើរបាយការណ៍កែលម្អ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣។*

## IV. អង្គភាពលទ្ធកម្ម

ក្នុងឆ្នាំ២០២១ អង្គភាពលទ្ធកម្ម បានអនុវត្ត ៤៨ កិច្ចសន្យា ក្នុងនោះ៖

- កិច្ចសន្យាសម្រាប់ទំនិញ មាន ៤២ កិច្ចសន្យា
- កិច្ចសន្យាសំណង់ មាន ០១ កិច្ចសន្យា
- កិច្ចសន្យាលើសេវាកម្ម មាន ០៥ កិច្ចសន្យា

អង្គភាពលទ្ធកម្ម អនុវត្តការងារបានរលូន និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយចំនួន ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

**១- លិខិតធានាប្រាក់កក់លើការអនុវត្តន៍កិច្ចសន្យា ពុំសមស្របនឹងការអនុវត្តន៍ជាក់ស្តែង**

អង្គភាពលទ្ធកម្ម បានចុះកិច្ចសន្យាលេខ ៣៨-PPWSA-២១ ស្តីពីការផ្គត់ផ្គង់កាមេរ៉ាសុវត្ថិភាព (ផែនការកែតម្រូវ-ឆ្នាំ២០២១) ជាមួយក្រុមហ៊ុន **ផូស៊ីត្រុន ម៉ាល់ធីវើស ឯ.ក** ដែលមានទឹកប្រាក់ ចំនួន ៧៩,០០០,០០០៛ (ចិតសិបប្រាំបួនលានរៀលគត់) និងប្រាក់កក់ធានាការអនុវត្តន៍កិច្ចសន្យា ១០% ស្មើ ៨,០០០,០០០៛ (ប្រាំបី

លានរៀលគត់) ដែលលិខិតនេះមានសុពលភាពចាប់ពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ រហូតដល់ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២។ សវនកម្មពិនិត្យឃើញថា លិខិតធានាប្រាក់កក់ដែលធានាលើការអនុវត្តកិច្ចសន្យា មានរយៈពេលតិចជាងការប្រគល់-ទទួលទំនិញជាក់ស្តែង ក្នុងនោះ ៖

ការប្រគល់-ទទួលទំនិញ

- លើកទី១ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ (ក្រុមហ៊ុនបានស្នើសុំពន្យាពេលផ្គត់ផ្គង់ រហូតដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២)
- លើកទី២ (សេវាកម្មតំឡើង) នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២។

ប្រការនេះ អនុវត្តពុំទាន់សមស្របតាមកិច្ចសន្យា ត្រង់ **ប្រការ៧ : ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា " ប្រាក់កក់នេះត្រូវប្រគល់ជូន ភាគី "ខ" វិញ យ៉ាងយូរក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពេលប្រគល់-ទទួលទំនិញ ចប់ជាស្ថាពរ ឬក្រោយពេលផុតរយៈពេលធានាគុណភាពទំនិញ "** ។

ករណីនេះ ធ្វើឱ្យលិខិតធានាការអនុវត្តន៍កិច្ចសន្យាពុំមានប្រសិទ្ធភាព។

អង្គភាពលទ្ធកម្ម ត្រូវពិនិត្យលើសុពលភាពលិខិតធានាប្រាក់កក់ដែលធានាលើការអនុវត្តកិច្ចសន្យាឱ្យបានត្រឹមត្រូវ មុននឹងធ្វើការទូទាត់។ **កម្រិតហានិភ័យ មធ្យម។**

*តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន : ក្រុមហ៊ុនបានស្នើសុំពន្យាពេលផ្គត់ផ្គង់ រហូតដល់ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ ប៉ុន្តែក្រុមហ៊ុនពុំបានពន្យាពេលលើលិខិតធានាប្រាក់កក់ដែលធានាលើការអនុវត្តកិច្ចសន្យា អង្គភាពលទ្ធកម្ម សូមទទួលយកចំនុចខ្វះចន្លោះក្នុងការពិនិត្យ និងតាមដាននេះ។*

***អង្គភាពលទ្ធកម្ម នឹងពង្រឹងបន្ថែមលើការពិនិត្យ និងតាមដានការអនុវត្តបន្ត ចាប់ពីខែមករា ឆ្នាំ២០២៣ នេះតទៅ។***

## ២- ការយកសម្ភារមកប្រើប្រាស់ មុនការឯកភាពប្រគល់កិច្ចសន្យា ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កិច្ចសន្យាលេខ ១៨-PPWSA-២១ ស្តីពីការផ្គត់ផ្គង់ថ្ម ១x២ និងថ្មM៣០ ជាមួយសហគ្រាស ហៃ សុខហ៊ួរ ទទួលបានការឯកភាព ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ សវនកម្មពិនិត្យឃើញថា សាខាសេវាកម្មទឹកស្អាត និងអនាម័យ បានយកថ្ម Mix មកប្រើប្រាស់សម្រាប់ ខែមិថុនា ឆ្នាំ២០២១៖

- ការប្រើប្រាស់ មុនមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១.៥០០,៣០ ម³ (យោងតាមរបាយការណ៍ប្រើប្រាស់សម្ភារសំណង់ការដ្ឋានដាក់បំពង់ ពីថ្ងៃទី០១ ដល់ ៣០ ខែមិថុនា ឆ្នាំ២០២១)។
- បរិមាណក្នុងកំណត់ហេតុប្រគល់-ទទួល ខុសពីតារាងប្រើប្រាស់របស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ៖

| **កំណត់ហេតុប្រគល់-ទទួល** | **តារាងប្រើប្រាស់របស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ** |
|---|---|
| ១.៥០០,៣០ ម³ | ១.៦៧២ ម³ |

ប្រការនេះ អនុវត្តពុំស្របតាមកិច្ចសន្យា ត្រង់ **ប្រការ៥ : ការប្រគល់-ទទួល** " ភាគី "ខ" ត្រូវប្រគល់ទំនិញជូនភាគី "ក" តាមការកំណត់ ជាដំណាក់ៗ តាមតម្រូវការរបស់ភាគី "ក" ក្រោយពីកិច្ចសន្យាចូលជាធរមាន និងមិនលើសពី១២ ម៉ោង (ដប់ពីរម៉ោង) បន្ទាប់ពីបានទទួលលិខិតបញ្ជាឱ្យប្រគល់ទទួល " ។

ករណីនេះ ធ្វើឱ្យការបើកសម្ភារយកទៅប្រើប្រាស់ពុំសមស្របតាមកិច្ចសន្យា។

អង្គភាពលទ្ធកម្ម ត្រូវសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់លើការបើកសម្ភារយកទៅប្រើប្រាស់ឱ្យត្រឹមត្រូវតាមកិច្ចសន្យាដែលបានកំណត់។ **កម្រិតហានិភ័យ ទាប។**

*តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន :*

- *កិច្ចសន្យាលេខ ១៨-PPWSA-២១ ចុះនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ រវាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងសហគ្រាស ហៃ សុខហ្វ៊ីរ ដោយមានតម្រូវការចាំបាច់ក្នុងការប្រើប្រាស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានដកប្រើមុនទទួលបានការឯកភាពលើកិច្ចសន្យា ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។*
- *តារាងប្រើប្រាស់របស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ ចំនួន ១.៦៧២ ម៉ែ កំណត់ហេតុប្រគល់-ទទួល ចំនួន ១.៥០០,៣០ ម៉ែ នៅសល់ ១៧១,៧០ ម៉ែ ទូទាត់ជាមួយកិច្ចសន្យា ០៧-PPWSA-២០។*
- *អង្គភាពលទ្ធកម្ម នឹងធ្វើការស្នើសុំប្រគល់-ទទួលលើកិច្ចសន្យា ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងធ្វើការផ្តត់ផ្គង់ជាក់ស្តែង។*

*អង្គភាពលទ្ធកម្ម នឹងខិតខំកែលម្អឡើងវិញនៅកិច្ចសន្យា ចាប់ពីខែមករា ឆ្នាំ២០២៣ នេះតទៅ។*

## គ- សន្និដ្ឋាន

ការធ្វើសវនកម្មដែលបានធ្វើឡើងខាងលើ នេះបង្ហាញថាដំណើរការនៃប្រតិបត្តិការខាងលើអនុវត្តបានល្អអនុលោមតាមសេចក្តីកំណត់ស្តង់ដាការងារ ព្រមទាំងបទដ្ឋានគតិយុត្តិនានា។ មន្ត្រី-និយោជិត នៅតាមបណ្តានាយកដ្ឋាន/អង្គភាព បានខិតខំប្រឹងប្រែងសហការអនុវត្តការងារតាមតួនាទី-ភារកិច្ច និងសម្រេចបានលទ្ធផលល្អ។ សវនដ្ឋាន មានការឯកភាព និងកែលម្អតាមអនុសាសន៍ណែនាំនូវរាល់ចំណុចខ្វះចន្លោះខាងលើ ព្រមទាំងធ្វើរបាយការណ៍បំភ្លឺតបចំណុចដែលបានកែលម្អ និងពុំទាន់បានធ្វើការកែលម្អ ក្នុងរយៈពេល **០៣ខែ** បន្ទាប់ពីចេញរបាយការណ៍។

សវនកម្មផ្ទៃក្នុង នឹងធ្វើការតាមដានរាល់អនុសាសន៍ដែលបានពិនិត្យឃើញ នូវបណ្តាចំណុចខ្វះចន្លោះរបស់សវនដ្ឋានក្នុងកំឡុងពេលចុះត្រួតពិនិត្យតាមការកំណត់ក្នុងផែនការប្រចាំឆ្នាំ។

ថ្ងៃ សុក្រ ១៥កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២៣
**សវនកម្មផ្ទៃក្នុង**

សេង គាតារា

**បានអាន និងឯកភាព**
ថ្ងៃ សុក្រ ១៥កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២៣
**ជ. គណៈកម្មាធិការសវនកម្ម**
**ប្រធាន**

**ស្រេង សំអិត**

# ឧបសម្ព័ន្ធ ៣

## របាយការណ៍ក្រុមប្រឹក្សាភិបាល

## និង

## របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(Co.០៨៣៩ Et/២០១២)

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

# របាយការណ៍ក្រុមប្រឹក្សាភិបាល

# និង

# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

**មាតិកា** ទំព័រ


| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១-៦ |
| របាយការណ៍ហិរញ្ញវត្ថុ | |
|     របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៧-៨ |
|     របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ | ៩-១០ |
|     របាយការណ៍បម្រែបម្រួលមូលធន | ១១-១២ |
|     របាយការណ៍លំហូរសាច់ប្រាក់ | ១៣-១៦ |
|     កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ១៧-៨១ |
| របាយការណ៍សវនករឯករាជ្យ | ៨២-៩៣ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតាមបណ្តាទីតាំងនានាដែលនៅជុំវិញទីក្រុង រួមទាំងក្រុងតាខ្មៅ និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងសេវាកម្មនេះ។ កម្មវត្ថុអាជីវកម្មរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែរក្សាមធ្យោបាយសម្រាប់ផលិតប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក និងកែលម្អសេវាកម្ម និងគុណភាពទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចដែលពាក់ព័ន្ធនឹងវិស័យទឹកស្អាត ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រដ្ឋាភិបាល និង
- ធានាឱ្យបាននូវចិរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ សម្រាប់ផលប្រយោជន៍សាធារណៈ។

នៅក្នុងអំឡុងការិយបរិច្ឆេទនេះ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពអាជីវកម្មចម្បងទាំងនេះទេ។

## លទ្ធផលប្រតិបត្តិការ

| | **ពាន់រៀល** |
|---|---:|
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ១០៨.១៨៥.៨៦៥ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

## ភាគលាភ

ចំនួនភាគលាភដែលបានប្រកាសដោយ រ.ទ.ស.ភ តាំងពីចុងការិយបរិច្ឆេទមុន មានដូចខាងក្រោម និងព័ត៌មានលម្អិតត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២៩ នៃរបាយការណ៍ហិរញ្ញវត្ថុ៖

| | ពាន់រៀល |
|---|---|
| តម្លៃ ៣១០រៀល ក្នុងមួយភាគហ៊ុនធម្មតានៃភាគលាភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ បានប្រកាសនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ | ៤.០៤៤.២៥២ |

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង ឬសំវិធានធនក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ក្រៅពីអ្វីដែលបានដាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលបំណុលពិបាកទារ និងការធ្វើសំវិធានធនលើបំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា ពុំមានបំណុលពិបាកទារទេ និងមិនតម្រូវឱ្យធ្វើសំវិធានធនលើបំណុលដែលជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលនាំឱ្យមានភាពចាំបាច់ដើម្បីលុបបំបាត់ចោលបំណុលពិបាកទារ និងធ្វើសំវិធានធនចំពោះបំណុលជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឡើយ។

## ទ្រព្យសកម្មរយៈពេលខ្លី

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ក្រុមប្រឹក្សាភិបាល បានចាត់វិធានការដែលមានមូលដ្ឋានសមស្របដើម្បីធានាថា ទ្រព្យសកម្មរយៈពេលខ្លីដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ រ.ទ.ស.ភ ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលបានរំពឹងថានឹងអាចលក់បានលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ថាមានភាពមិនត្រឹមត្រូវឡើយ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

## វិធីសាស្ត្រក្នុងការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល មិនបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រ ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម ឬបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) ការទាមទារទ្រព្យសកម្មណាមួយរបស់ រ.ទ.ស.ភ ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទ ដើម្បីធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

(២) បំណុលយថាហេតុណាមួយ ដែលកើតមានឡើងចំពោះ រ.ទ.ស.ភ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទឡើយ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ រ.ទ.ស.ភ ដែលត្រូវទាមទារឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទដែលនឹង ឬអាចធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធភាពរបស់ រ.ទ.ស.ភ ក្នុងការសងបំណុលនៅថ្ងៃកំណត់សងនោះទេ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានបញ្ចូលនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដែលបណ្តាលឱ្យតួលេខនៃចំនួនណាមួយដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ មានភាពមិនត្រឹមត្រូវនោះទេ។

## កត្តាជាសារវន្ត និងមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល៖

(១) លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ រ.ទ.ស.ភ ក្នុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដោយកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ និង

(២) ពុំមានកត្តា ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ក្នុងចន្លោះពេលរវាងចុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលអាចនាំឱ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលប្រតិបត្តិការរបស់ រ.ទ.ស.ភ ក្នុងការិយបរិច្ឆេទដែលបានរៀបចំរបាយការណ៍នេះទេ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

## ការបោះផ្សាយភាគហ៊ុន និងប័ណ្ណបំណុល

នៅក្នុងអំឡុងការិយបរិច្ឆេទនេះ រ.ទ.ស.ភ ពុំបានបោះផ្សាយភាគហ៊ុន ឬប័ណ្ណបំណុលថ្មី ក្រៅពីបង្ហាញនៅកំណត់សម្គាល់ ១៣(គ) នៃរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបម្រើការងារក្នុងអំឡុងការិយបរិច្ឆេទ និងអំឡុងពេលចាប់ពីចុងការិយបរិច្ឆេទដល់កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ រួមមាន៖

| | |
|---|---|
| ឯកឧត្តម អ៊ុំ សុថា | (បញ្ចប់អាណត្តិនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣) |
| ឯកឧត្តម ស៊ឹម ស៊ីថា | (ត្រូវបានតែងតាំងនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣) |
| ឯកឧត្តម ម៉ី វ៉ាន់ | |
| ឯកឧត្តម ឡុង ណារ៉ូ | |
| ឯកឧត្តម នួន ផារ័ត្ន | |
| លោក ម៉ា ណូវ៉ាវីន | |
| លោក អោម សេង បូរ៉ា | (បញ្ចប់អាណត្តិនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២) |
| លោក ចាង យុនហ្វេង | (បញ្ចប់អាណត្តិនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២) |
| លោក ណាំ ចន្ទ្រី | (ត្រូវបានតែងតាំងនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២) |
| លោក ស្រេង សំឱក | (ត្រូវបានតែងតាំងនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២) |

## ព្រឹត្តិការណ៍សំខាន់បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ

ព័ត៌មានលំអិតអំពីព្រឹត្តិការណ៍សំខាន់បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៣៦នៃរបាយការណ៍ហិរញ្ញវត្ថុ។

## សវនករ

សវនករ Messrs. បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក បានបង្ហាញពីឆន្ទៈដើម្បីបន្តការងារនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ទទួលខុសត្រូវលើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំង លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ត្រូវ៖

១) អនុវត្តគោលនយោបាយគណនេយ្យ ដែលសមស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយ ធ្វើការអនុវត្តតាមគោលការណ៍នោះប្រកបដោយសង្គតិភាព។

២) អនុលោមតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន ដែលអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃ កម្ពុជា ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣) រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យ រ.ទ.ស.ភ អាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោម ទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព។

៤) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកតាមមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានភាពមិន ត្រឹមត្រូវក្នុងការសន្មតថា រ.ទ.ស.ភ នឹងបន្តកិច្ចប្រតិបត្តិការរបស់ខ្លួននាពេលអនាគត និង

៥) គ្រប់គ្រង និងដឹកនាំ រ.ទ.ស.ភ ឱ្យមានប្រសិទ្ធិភាពតាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ ដែលអាច ប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលរបស់ រ.ទ.ស.ភ ហើយត្រូវប្រាកដថា ផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះ បញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា រ.ទ.ស.ភ បានអនុវត្តតាមគ្រប់តម្រូវការខាងលើនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ របស់ខ្លួន។

លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

### របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ ឯកឧត្តម ស៊ឹម ស៊ីថា ឯកឧត្តម ឡុង ណារ៉ូ និង លោក ដេង ប៉ូលីដែន ជាអភិបាល និងមន្ត្រី នៅក្នុង រ.ទ.ស.ភ សូមបញ្ជាក់ថាតាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល

**ឡុង ណារ៉ូ**
អគ្គនាយក

**ដេង ប៉ូលីដែន**
អគ្គនាយករង ទទួលបន្ទុកហិរញ្ញកិច្ច

**ស៊ឹម ស៊ីថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃ..ពុធ....៩រោច... ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី..១៥..... ខែមីនា ឆ្នាំ២០២៣

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ២.២០៣.០៤១.៩១៤ | ១.៨៩៣.៨៦៤.៦១៩ |
| ទ្រព្យសកម្មអរូបី | ៦ | ១២.០៨៩.៥៨៧ | ១២.៥៣០.២៧៨ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | ២.២១៥.១៣១.៥០១ | ១.៩០៦.៣៩៤.៨៩៧ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ៧ | ១៥២.៧៣៧.០៧៨ | ១៤៣.៧៣១.៥០៨ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ៨ | ២៨.២៦៤.៩៤០ | ២៤.៨៧៥.១៦៧ |
| ទ្រព្យសកម្មកិច្ចសន្យា | ៩ | ៩២.៧៦៨.៣៧៤ | ៦៦.០២៤.៥៨០ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | ១០ | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| ការវិនិយោគរយៈពេលខ្លី | ១១ | ១២៦.១១៨.៤១៦ | ៦៨.១៦៣.៨៣៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១២ | ៦១.១៥៨.៩១៥ | ៨៩.៦៥៩.៥៣៨ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | ៤៦៩.០០៤.៣៧៤ | ៤០០.៤១១.២៧៧ |
| **ទ្រព្យសកម្មសរុប** | | ២.៦៨៤.១៣៥.៨៧៥ | ២.៣០៦.៨០៦.១៧៤ |
| **មូលធន និងបំណុល** | | | |
| **មូលធនរបស់ភាគហ៊ុនិករបស់ រ.ទ.ស.ភ** | | | |
| ដើមទុន និងបុព្វលាភភាគហ៊ុន | ១៣ | ៦២០.៧៥៩.១០៧ | ៦១៩.៣១៥.៨៨៦ |
| ទុនបម្រុង | ១៤ | ៥៤៣.២៦៨.០៧៥ | ៤១៨.០៣៨.៤១០ |
| ចំណេញរក្សាទុក | | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ |
| **មូលធនសរុប** | | ១.២៧២.២១៣.០៤៧ | ១.១៦៦.៦២៨.២១៣ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៥ | ៩៨៦.៤៩៥.៧១៧ | ៧៩០.៣៥៩.៧៥០ |
| ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៦ | ៦៩.២៣៨.៤៧៧ | ១៦.៨១២.១៨៦ |
| បំណុលពន្ធពន្យារ | ១៧ | ៧៧.០១៦.៧១៦ | ៧២.៣០៧.២៩៩ |
| គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១៨ | ៧៦.៨០១.៧០៥ | ៦៩.៤៤៦.០៧៣ |
| **បំណុលរយៈពេលវែងសរុប** | | ១.២០៩.៥៥២.៦១៥ | ៩៤៨.៩២៥.៣០៨ |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ | ១៨ | ១៥៤.៦៦១.១៥២ | ១៤១.៩៦៩.៥៤៥ |
| ប្រាក់កម្ចី | ១៥ | ២៣.៤៩៩.១៥៨ | ២៣.១២៨.៥១៨ |
| បំណុលកិច្ចសន្យា | ៩ | ៤.៤៥៦.៧៥៦ | ១.៧៨៨.៨៩៤ |
| បំណុលពន្ធលើប្រាក់ចំណូល | | ១៩.៧៥៣.១៤៧ | ២៤.៣៦៥.៦៩៦ |
| **បំណុលរយៈពេលខ្លីសរុប** | | ២០២.៣៧០.២១៣ | ១៩១.២៥២.៦៥៣ |
| **បំណុលសរុប** | | ១.៤១១.៩២២.៨២៨ | ១.១៤០.១៧៧.៩៦១ |
| **មូលធន និងបំណុលសរុប** | | ២.៦៨៤.១៣៥.៨៧៥ | ២.៣០៦.៨០៦.១៧៤ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **ចំណូល៖** | | | |
| ចំណូលពីការលក់ | ១៩ | ២៩៩.៧២៣.៥០៧ | ២៨២.៣៦៩.៧៩៧ |
| កម្រៃពីការសាងសង់ | | ២៤.៩៧៦.៣១៦ | ២៦.២៤១.៩៨៩ |
| ចំណេញពីការប្តូររូបិយប័ណ្ណ - សុទ្ធ | ២០ | - | ២.២៧៣.៩៨៤ |
| ចំណូលផ្សេងៗ | ២១ | ២១.៤៧៨.៣៣៣ | ៥៨.២៥៩.៤៨៧ |
| | | ៣៤៦.១៧៨.១៥៦ | ៣៦៩.១៤៥.២៥៧ |
| **ចំណាយ៖** | | | |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | | (៥៩.៤៥៥.០៧៤) | (៥៥.១៩៤.៤១២) |
| ចំណាយថ្លៃភ្លើង | | (៣៥.២១៨.៧៤៣) | (៣៥.៧៩១.៩៨៣) |
| ចំណាយលើអត្ថប្រយោជន៍និយោជិត | ២២ | (៧០.១៧៥.៤២២) | (៦៣.៦៣១.២៣៧) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | ២៣ | (១២.១៤០.៧៤០) | (៩.៥៤១.៩៨២) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្តាញទឹកតាមគេហដ្ឋាន | ២៤ | (៤.៩៥៣.៣៧១) | (៣.១៦៣.៧៦៨) |
| ចំណាយជួសជុល និងថែទាំ | | (៨.០០៩.៣៥៨) | (៧.០៥០.៨៥៥) |
| ចំណាយសេវាសាងសង់ | | (១៦.៦១៨.០២៤) | (២២.៤៤៨.២១៣) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (១១.២៤៣.៤១៦) | (១៥.២២៦.៥០៦) |
| ខាតពីការប្តូររូបិយប័ណ្ណ - សុទ្ធ | ២០ | (៣.៤៨១.១៦៦) | - |
| | | (២២១.២៩៥.៣១៤) | (២១២.០៤៨.៩៥៦) |
| **ចំណេញប្រតិបត្តិការ** | | **១២៤.៨៨២.៨៤២** | **១៥៧.០៩៦.៣០១** |
| ចំណូលការប្រាក់ | ២៥ | ១៧.៧៣៧.៧៤៦ | ១៣.៥៥៥.០៦៤ |
| ចំណាយការប្រាក់ | ២៦ | (១២.១០៤.៦៩៦) | (៤.៧៩៤.៧៧៩) |
| **ចំណេញមុនបង់ពន្ធ** | | **១៣០.៥១៥.៨៩២** | **១៦៥.៨៥៦.៥៨៦** |
| ពន្ធលើប្រាក់ចំណូល | ២៧ | (២២.៣៣០.០២៧) | (៣៦.៥៨២.៦៦៩) |
| **ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា** | | **១០៨.១៨៥.៨៦៥** | **១២៩.២៧៣.៩១៧** |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | ២០២២ | ២០២១ |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិក | | | |
| ចំណេញក្នុងមួយភាគហ៊ុនគោល (គិតជាប្រាក់រៀល) | ២៨ | ១.២៤៣,៩០ | ១.៤៨៦,៣៧ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (គិតជាប្រាក់រៀល) | ២៨ | ១.២៤៣,៩០ | ១.៤៨៦,៣៧ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ដើមទុន និង បុព្វលាភភាគហ៊ុន គិតជាពាន់រៀល | ទុនបម្រុង គិតជាពាន់រៀល | ចំណេញរក្សាទុក គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | | **៥៤១.២២៧.២៨២** | **៣៥២.៤៧៣.៥៣០** | **៨៨.៣៥១.៨៤៥** | **៩៨២.០៥២.៦៥៧** |
| ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា | | - | - | ១២៩.២៧៣.៩១៧ | ១២៩.២៧៣.៩១៧ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក រ.ទ.ស.ភ** | | | | | |
| ការបន្ថែមដើមទុន | ១៣ | ៧៨.០៨៨.៦០៤ | - | - | ៧៨.០៨៨.៦០៤ |
| ការផ្ទេរទៅគណនីទុនបម្រុង | ១៤ | - | ៦៥.៥៦៤.៨៨០ | (៦៥.៥៦៤.៨៨០) | - |
| ភាគលាភ | ២៩ | - | - | (២២.៧៨៦.៩៦៥) | (២២.៧៨៦.៩៦៥) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | **៧៨.០៨៨.៦០៤** | **៦៥.៥៦៤.៨៨០** | **(៨៨.៣៥១.៨៤៥)** | **៥៥.៣០១.៦៣៩** |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | | **៦១៩.៣១៥.៨៨៦** | **៤១៨.០៣៨.៤១០** | **១២៩.២៧៣.៩១៧** | **១.១៦៦.៦២៨.២១៣** |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | ដើមទុន និង បុព្វលាភភាគហ៊ុន គិតជាពាន់រៀល | ទុនបម្រុង គិតជាពាន់រៀល | ចំណេញរក្សាទុក គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | | **៦១៩.៣១៥.៨៨៦** | **៤១៨.០៣៨.៤១០** | **១២៩.២៧៣.៩១៧** | **១.១៦៦.៦២៨.២១៣** |
| ចំណេញក្នុងគ្រា តំណាងឱ្យលទ្ធផលលម្អិតផ្សេងៗក្នុងគ្រា | | - | - | ១០៨.១៨៥.៨៦៥ | ១០៨.១៨៥.៨៦៥ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | |
| ការបន្ថែមដើមទុន | ១៣ | ១.៤៤៣.២២១ | - | - | ១.៤៤៣.២២១ |
| ការផ្ទេរទៅគណនីទុនបម្រុង | ១៤ | - | ១២៥.២២៩.៦៦៥ | (១២៥.២២៩.៦៦៥) | - |
| ភាគលាភ | ២៩ | - | - | (៤.០៤៤.២៥២) | (៤.០៤៤.២៥២) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | **១.៤៤៣.២២១** | **១២៥.២២៩.៦៦៥** | **(១២៩.២៧៣.៩១៧)** | **(២.៦០១.០៣១)** |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | **៦២០.៧៥៩.១០៧** | **៥៤៣.២៦៨.០៧៥** | **១០៨.១៨៥.៨៦៥** | **១.២៧២.២១៣.០៤៧** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ** | | | |
| **ចំណេញមុនបង់ពន្ធ** | | **១៣០.៥១៥.៨៩២** | **១៦៥.៨៥៦.៥៨៦** |
| និយ័តកម្មលើ៖ | | | |
| រំលស់ទ្រព្យសកម្មអរូបី | ៦ | ១.៩៩៤.១៤៧ | ១.៧០២.៤១៩ |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ៥៧.៤៦០.៩២៧ | ៥៣.៤៩១.៩៩៣ |
| រំលស់ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៦ | (២.០០៩.៩០៨) | (២.០០៩.៩០៧) |
| ការលុបចោលភាគលាភដែលត្រូវបង់ | ២១ | - | (៣៦.៣៧២.១៧៧) |
| ការជម្រះបញ្ជីនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ១៣៦.៨៣៩ | ៥.៧៤៩.១៧៦ |
| ចំណូលការប្រាក់ | ២៥ | (៤.៦៥៦.៦១៨) | (២.៧០៦.០៤៤) |
| ចំណាយការប្រាក់ | ២៥ | ៩.១១៥.៥៣០ | ៦.៤៣៦.៦៧៧ |
| ខាត/(ចំណេញ)សុទ្ធមិនពិតពីការប្តូររូបិយប័ណ្ណ | | ១.៥៥៣.៧៤០ | (១០.៩២៨.២៤៨) |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **១៩៤.១១០.៥៤៩** | **១៨១.២២០.៤៧៥** |
| កើនឡើងសន្និធិ | | (៨៩.៨១៩.២០១) | (៧២.៣៣១.០៦៦) |
| កើនឡើង/ថយចុះគណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | (១.៦៦៨.០៤៩) | ១.៣៧៦.០០២ |
| កើនឡើងគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ | | ៨.៥០៩.៦៩៤ | ៥.១៨៤.៦៥៥ |
| កើនឡើងទ្រព្យសកម្មកិច្ចសន្យា | | (២៦.៧៤៣.៧៩៤) | (២៣.១០២.០៣៣) |
| កើនឡើង/(ថយចុះ)បំណុលកិច្ចសន្យា | | ២.៦៦៧.៨៦២ | (១.៨២៧.៦៧២) |
| កើនឡើងប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | | ៧.៣៥៥.៦៣២ | ៤.២៥០.២៣៧ |
| **សាច់ប្រាក់សុទ្ធបានពីប្រតិបត្តិការ** | | **៩៤.៤១២.៦៩៣** | **៩៤.៧៧០.៥៩៨** |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (២២.២៣៣.១៥៧) | (២៥.៤៧៣.៩១៩) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | **៧២.១៧៩.៥៣៦** | **៦៩.២៩៦.៦៧៩** |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | (២៨១.៦១៩.៧១៦) | (២៨៩.៧១៦.៩៤៥) |
| ការទិញទ្រព្យសកម្មអរូបី | ៦ | (៣៩០.០៧៥) | (១.១៣៣.០៦២) |
| កើនឡើងការវិនិយោគរយៈពេលខ្លី | | (៥៧.៩៥៤.៥៨៣) | (៤៩.៧១៩.១១៩) |
| ការប្រាក់ដែលបានធ្វើមូលធនកម្មលើទ្រព្យសកម្មដែលមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ | | (៥.៥០៥.០៩៦) | (៤.៣៩៨.៤៦៩) |
| ការប្រាក់បានទទួល | | ២.៩៣៤.៨៩៤ | ២.១០៩.០៤៥ |
| ជំនួយទទួលបានពីសហភាពអឺរ៉ុប | ១៦ | ៥៤.៤៣៦.១៩៩ | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(២៨៨.០៩៨.៣៧៧)** | **(៣៤២.៨៥៨.៥៥០)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| ការបន្ថែមដើមទុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សុទ្ធ | | ១.៤៤៣.២២១ | (១០៣.៦៥៦) |
| ភាគលាភបានបង់ | | (៤.០៤៤.២៥២) | (៣.៤១៨.០៤២) |
| សាច់ប្រាក់ទទួលបានពីកម្ចី | | ២១៨.២៨០.៤៣៩ | ៣០៣.១៨៥.២៩២ |
| ការប្រាក់បានបង់ | | (៧.៤៩១.៨០៤) | (៧.៥៥៦.៣៨៣) |
| ការបង់សងប្រាក់កម្ចី | | (២០.៧៦៩.៣៨៦) | (២៨.៥៩៦.៣០៧) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន** | | **១៨៧.៤១៨.២១៨** | **២៦៣.៥១០.៩០៤** |
| **តំហយសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (២៨.៥០០.៦២៣) | (១០.០៥០.៩៦៧) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមគ្រា** | | ៨៩.៦៥៩.៥៣៨ | ៩៩.៧១០.៥០៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងគ្រា** | ១២ | **៦១.១៥៨.៩១៥** | **៨៩.៦៥៩.៥៣៨** |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)

(ក) ការផ្ទៀងផ្ទាត់បំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន៖

| | ប្រាក់កម្ចី<br>គិតជាពាន់រៀល | ភាគលាភ<br>ដែលត្រូវបង់<br>គិតជាពាន់រៀល | ដើមទុន និង<br>បុព្វលាភភាគហ៊ុន<br>គិតជាពាន់រៀល | សរុប<br>គិតជាពាន់រៀល |
|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ៨១៣.៤៨៨.២៦៨ | - | ៦១៩.៣១៥.៨៨៦ | ១.៤៣២.៨០៤.១៥៤ |
| **សកម្មភាពហិរញ្ញប្បទាន** | | | | |
| ការបន្ថែមដើមទុនពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សុទ្ធ | - | - | ១.៤៤៣.២២១ | ១.៤៤៣.២២១ |
| ភាគលាភបានបង់ | - | (៤.០៤៤.២៥២) | - | (៤.០៤៤.២៥២) |
| សាច់ប្រាក់ទទួលបានពីកម្ចី | ២១៨.២៨០.៤៣៩ | - | - | ២១៨.២៨០.៤៣៩ |
| ការប្រាក់បានបង់ | (៧.៤៩១.៨០៤) | - | - | (៧.៤៩១.៨០៤) |
| ការបង់សងប្រាក់កម្ចី | (២០.៧៦៩.៣៨៦) | - | - | (២០.៧៦៩.៣៨៦) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាព ហិរញ្ញប្បទាន** | ១៩០.០១៩.២៤៩ | (៤.០៤៤.២៥២) | ១.៤៤៣.២២១ | ១៨៧.៤១៨.២១៨ |
| **បំណុលដែលពាក់ព័ន្ធនឹងការប្រែប្រួលផ្សេងៗ** | | | | |
| ភាគលាភ | - | ៤.០៤៤.២៥២ | - | ៤.០៤៤.២៥២ |
| ការប្រាក់បង្គរលើប្រាក់កម្ចី | ៩.១១៥.៥៣០ | - | - | ៩.១១៥.៥៣០ |
| ចំណេញពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចី | (២.៦២៨.១៧២) | - | - | (២.៦២៨.១៧២) |
| **បំណុលដែលពាក់ព័ន្ធនឹងការប្រែប្រួល ផ្សេងៗសរុប** | ៦.៤៨៧.៣៥៨ | ៤.០៤៤.២៥២ | - | ១០.៥៣១.៦១០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ១.០០៩.៩៩៤.៨៧៥ | - | ៦២០.៧៥៩.១០៧ | ១.៦៣០.៧៥៣.៩៨២ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ត)

(ក) ការផ្ទៀងផ្ទាត់បំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន៖ (ត)

| | ប្រាក់កម្ចី គិតជាពាន់រៀល | ភាគលាភ ដែលត្រូវបង់ គិតជាពាន់រៀល | ដើមទុន និង បុព្វលាភភាគហ៊ុន គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | ៥៤៨.១៣៥.៥៧៦ | ១៧.០០៣.២៥៤ | ៥៤១.២២៧.២៨២ | ១.១០៦.៣៦៦.១១២ |
| **សកម្មភាពហិរញ្ញប្បទាន** | | | | |
| ការបន្ថែមដើមទុនពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សុទ្ធ | - | - | (១០៣.៦៥៦) | (១០៣.៦៥៦) |
| ភាគលាភបានបង់ | - | (៣.៤១៨.០៤២) | - | (៣.៤១៨.០៤២) |
| សាច់ប្រាក់ទទួលបានពីកម្ចី | ៣០៣.១៨៥.២៩២ | - | - | ៣០៣.១៨៥.២៩២ |
| ការប្រាក់បានបង់ | (៧.៥៥៦.៣៨៣) | - | - | (៧.៥៥៦.៣៨៣) |
| ការបង់សងប្រាក់កម្ចី | (២៨.៥៩៦.៣០៧) | - | - | (២៨.៥៩៦.៣០៧) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាព ហិរញ្ញប្បទាន** | ២៦៧.០៣២.៦០២ | (៣.៤១៨.០៤២) | (១០៣.៦៥៦) | ២៦៣.៥១០.៩០៤ |
| **បំណុលដែលពាក់ព័ន្ធនឹងការប្រែប្រួលផ្សេងៗ** | | | | |
| ភាគលាភ | - | ២២.៧៨៦.៩៦៥ | - | ២២.៧៨៦.៩៦៥ |
| ការប្រាក់បង្គរលើប្រាក់កម្ចី | ៦.៤៣៦.៦៧៧ | - | - | ៦.៤៣៦.៦៧៧ |
| ចំណេញពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចី | (៨.១១៦.៥៨៧) | - | - | (៨.១១៦.៥៨៧) |
| ការលុបចោលភាគលាភដែលត្រូវបង់ | - | (៣៦.៣៧២.១៧៧) | - | (៣៦.៣៧២.១៧៧) |
| **បំណុលដែលពាក់ព័ន្ធនឹងការប្រែប្រួល ផ្សេងៗសរុប** | (១.៦៧៩.៩១០) | (១៣.៥៨៥.២១២) | - | (១៥.២៦៥.១២២) |
| **មូលធនដែលពាក់ព័ន្ធនឹងការប្រែប្រួលផ្សេងៗ** | | | | |
| ការទិញដោយការបន្ថែមដើមទុន | - | - | ៧៨.១៩២.២៦០ | ៧៨.១៩២.២៦០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ៨១៣.៤៨៨.២៦៨ | - | ៦១៩.៣១៥.៨៨៦ | ១.៤៣២.៨០៤.១៥៤ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## ១. ព័ត៌មានអំពី រ.ទ.ស.ភ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេស របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("MoEF") ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ថាមានលក្ខណៈសេដ្ឋកិច្ចជាសហគ្រាសសាធារណៈ ដែលមានលេខចុះបញ្ជីពាណិជ្ជកម្ម Co.០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពអាជីវកម្មចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតាមបណ្តាទីតាំងនានាដែលនៅជុំវិញទីក្រុង រួមទាំងក្រុងតាខ្មៅ និងសកម្មភាព ផ្សេងៗដែលពាក់ព័ន្ធនឹងសេវាកម្មនេះ។ កម្មវត្ថុអាជីវកម្មរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែរក្សាមធ្យោបាយសម្រាប់ផលិតប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ។
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក និងកែលម្អសេវាកម្ម និងគុណភាពទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់។
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចដែលពាក់ព័ន្ធនឹងវិស័យទឹកស្អាត ស្របតាមការសម្រេចរបស់ ក្រុមប្រឹក្សាភិបាល និងអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រដ្ឋាភិបាល និង
- ធានាឱ្យបាននូវចិរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ សម្រាប់ផលប្រយោជន៍សាធារណៈ។

## ២. មូលដ្ឋាននៃការរៀបចំ

### ២.១ របាយការណ៍អនុលោមភាព

ព័ត៌មានហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក")។

## ២. មូលដ្ឋាននៃការរៀបចំ

### ២.២ ការធ្វើវិសោធនកម្ម ឬកែសម្រួលស្តង់ដារ ("ស.រ.ហ.អ.ក")

រ.ទ.ស.ភ បានអនុវត្តដោយវិសោធនកម្ម/ការកែសម្រួលស្តង់ដារ ("ស.រ.ហ.អ.ក") សម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុដើមគ្រានាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ មានដូចខាងក្រោម៖

<u>វិសោធនកម្ម/ការកែលម្អស្តង់ដារ ស.រ.ហ.អ.ក</u>

| | |
|---|---|
| ស.រ.ហ.អ.ក ១៦ | កូវីត-១៩ ទាក់ទងនឹងការជួលសម្បទានក្រោយថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១-វិសោធនកម្មលើ ស.រ.ហ.អ.ក ១៦ |
| ស.គ.អ.ក ១៦ | ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ |
| ស.គ.អ.ក ៣៧ | សំវិធានធន បំណុលជាយថាហេតុ និងទ្រព្យសកម្មជាយថាហេតុ |
| ស.គ.អ.ក ៤១ | កសិកម្ម |
| ស.រ.ហ.អ.ក ១ | ការអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលើកដំបូង |
| ស.រ.ហ.អ.ក ៣ | ការរួមបញ្ចូលគ្នានៃអាជីវកម្មតែមួយ |

ការអនុវត្តវិសោធនកម្ម ឬការកែសម្រួលស្តង់ដារ ("ស.រ.ហ.អ.ក") ដែលបានពិពណ៌នាខាងលើ មិនមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ នោះទេ។

### ២.៣ ស្តង់ដារ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន

រ.ទ.ស.ភ ពុំទាន់បានអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន មានដូចខាងក្រោម៖

| | | **ថ្ងៃចូលជាធរមាន ក្នុងអំឡុងការិយបរិច្ឆេទចាប់ផ្តើម ឬការិយបរិច្ឆេទបន្ទាប់** |
|---|---|---|
| <u>ស្តង់ដារគណនេយ្យថ្មី</u> | | |
| ស.រ.ហ.អ.ក ១៧ | កិច្ចសន្យាធានារ៉ាប់រង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ |
| <u>វិសោធនកម្ម ឬការកែសម្រួល</u> | | |
| ស.រ.ហ.អ.ក ១ | ការអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាលើកដំបូង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ** (ត)

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### ២.៣ ស្តង់ដារ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន (ត)

រ.ទ.ស.ភ ពុំទាន់បានអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន មានដូចខាងក្រោម៖ (ត)

| | | ថ្ងៃចូលជាធរមាន ក្នុងអំឡុងការិយបរិច្ឆេទចាប់ផ្តើម ឬការិយបរិច្ឆេទបន្ទាប់ |
|---|---|---|
| <u>វិសោធនកម្ម ឬការកែសម្រួល (ត)</u> | | |
| ស.រ.ហ.អ.ក ៣ | ការរួមបញ្ចូលគ្នានៃអាជីវកម្មតែមួយ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.រ.ហ.អ.ក ៥ | ទ្រព្យសកម្មរយៈពេលវែងរក្សាទុក សម្រាប់លក់ និងកិច្ចប្រតិបត្តិការមិនបន្ត | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.រ.ហ.អ.ក ៧ | ឧបករណ៍ហិរញ្ញវត្ថុ៖ ការបង្ហាញ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.រ.ហ.អ.ក ៩ | ឧបករណ៍ហិរញ្ញវត្ថុ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.រ.ហ.អ.ក ១០ | របាយការណ៍ហិរញ្ញវត្ថុរួម | ពន្យា |
| ស.រ.ហ.អ.ក ១៥ | ចំណូលបានមកពីអតិថិជនជាប់កិច្ចសន្យា | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.រ.ហ.អ.ក ១៦ | ភតិសន្យា | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.រ.ហ.អ.ក ១៧ | កិច្ចសន្យាធានារ៉ាប់រង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ |
| ស.គ.អ.ក ១ | ការបង្ហាញនៃឧបករណ៍ហិរញ្ញវត្ថុ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣#/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ៧ | របាយការណ៍លំហូរសាច់ប្រាក់ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.គ.អ.ក ៨ | គោលនយោបាយគណនេយ្យ ការកែប្រែគណនេយ្យលើការប៉ាន់ស្មាន និងកំហុសឆ្គង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ |
| ស.គ.អ.ក ១២ | ពន្ធលើប្រាក់ចំណូល | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ |
| ស.គ.អ.ក ១៦ | ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |

**២. មូលដ្ឋាននៃការរៀបចំ (ត)**

**២.៣ ស្តង់ដារ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន (ត)**

រ.ទ.ស.ភ ពុំទាន់បានអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន មានដូចខាងក្រោម៖ (ត)

| | | ថ្ងៃចូលជាធរមាន ក្នុងអំឡុងការិយបរិច្ឆេទចាប់ផ្តើម ឬការិយបរិច្ឆេទបន្ទាប់ |
|---|---|---|
| <u>វិសោធនកម្ម ឬការកែសម្រួល (ត)</u> | | |
| ស.គ.អ.ក ១៩ | អត្ថប្រយោជន៍និយោជិត | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.គ.អ.ក ២៨ | ការវិនិយោគនៅក្នុងសមាគត | ពន្យា/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.គ.អ.ក ៣២ | ឧបករណ៍ហិរញ្ញវត្ថុ៖ ការបង្ហាញ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.គ.អ.ក ៣៦ | ឱនភាពនៃទ្រព្យសកម្ម | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.គ.អ.ក ៣៧ | សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.គ.អ.ក ៣៨ | ទ្រព្យអរូបី | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |
| ស.គ.អ.ក ៤០ | ទ្រព្យវិនិយោគ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣# |

# វិសោធនកម្មនេះជាលទ្ធផលនៃ ស.រ.ហ.អ.ក ១៧ កិច្ចសន្យាធានារ៉ាប់រងដែលចូលជាធរមាន

រ.ទ.ស.ភ គ្រោងនឹងអនុវត្តស្តង់ដារគណនេយ្យ ដែលអាចអនុវត្តបានដូចបានបង្ហាញខាងលើ និងវិសោធនកម្ម ឬការកែសម្រួល នៅពេលតែស្តង់ដារគណនេយ្យបានចូលជាធរមាន។ ការពិភាក្សាសង្ខេបអំពីស្តង់ដារគណនេយ្យសំខាន់ៗខាងលើ និងវិសោធនកម្ម ឬការកែសម្រួល ដែលអាចអនុវត្តបានលើ រ.ទ.ស.ភ ត្រូវបានសង្ខេបដូចខាងក្រោម។

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### ២.៣ ស្តង់ដារ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន (ត)

***វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ ការរួមបញ្ចូលគ្នានៃអាជីវកម្មតែមួយ***

វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ ដោយជំនួសឯកសារយោងទៅកំណែចាស់នៃក្របខ័ណ្ឌទស្សទាន សម្រាប់របាយការណ៍រាយការណ៍ ជាមួយសេចក្តីយោងទៅកំណែថ្មី។

***វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ របាយការណ៍ហិរញ្ញវត្ថុរួម ស.រ.ហ.អ.ក ២៨ ការវិនិយោគនៅក្នុង សមាគត និងការបណ្តាក់ទុនរួមគ្នា***

វិសោធនកម្មទាំងនេះ ដោះស្រាយភាពមិនស៊ីសង្វាក់គ្នា ដែលត្រូវបានទទួលស្គាល់រវាងតម្រូវការតាម ស.រ.ហ.អ.ក ១០ និងស.គ.អ.ក ២៨ ក្នុងការដោះស្រាយជាមួយនឹងការលក់ ឬការរួមចំណែកនៃទ្រព្យសកម្មរវាងអ្នកវិនិយោគ និង សមាគត ឬការបណ្តាក់ទុនរួមគ្នា។

លទ្ធផលចម្បងនៃការធ្វើវិសោធនកម្ម គឺចំណេញ ឬខាតត្រូវបានទទួលស្គាល់ នៅពេលដែលប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្ម ដូចដែលបានកំណត់ក្នុង ស.រ.ហ.អ.ក ១៣។ ចំណេញ ឬខាតមួយផ្នែក គឺត្រូវបានទទួលស្គាល់ នៅពេលដែលប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្ម ដែលមិនមែនជាអាជីវកម្ម។

***វិសោធនកម្មលើ ស.គ.អ.ក ១ ការបង្ហាញនៃឧបករណ៍ហិរញ្ញវត្ថុ***

វិសោធនកម្មរួមបញ្ចូលការបញ្ជាក់ថា សិទ្ធិរបស់អង្គភាពក្នុងការពន្យារពេលទូទាត់បំណុលយ៉ាងហោចណាស់ដប់ពីរខែ បន្ទាប់ពីរយៈពេលរាយការណ៍ ត្រូវតែមានខ្លឹមសារ និងត្រូវតែកើតមាននៅចុងបញ្ចប់នៃការិយបរិច្ឆេទរាយការណ៍។ ការបញ្ជាក់អំពីការចាត់ថ្នាក់បំណុល គឺមិនប៉ះពាល់ដល់លទ្ធភាពនៃអង្គភាពក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការពន្យាពេលការទូទាត់បំណុលយ៉ាងហោចណាស់ដប់ពីរខែ បន្ទាប់ពីការិយបរិច្ឆេទនៃការរាយការណ៍។ ការបញ្ជាក់អំពីលក្ខខណ្ឌនៃការខ្ចី ដែលប៉ះពាល់លើការចាត់ថ្នាក់នៃបំណុល និងការបញ្ជាក់អំពីតម្រូវការ សម្រាប់ចាត់ថ្នាក់បំណុល ដែលអង្គភាពនឹង ឬអាចទូទាត់ដោយការបោះផ្សាយឧបករណ៍មូលធនរបស់ខ្លួន។

វិសោធនកម្មតម្រូវឱ្យអង្គភាព បង្ហាញព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត ជាងគោលនយោបាយគណនេយ្យសំខាន់ៗ។ វិសោធនកម្ម ក្នុងចំណោមវិសោធនកម្មផ្សេងទៀត ក៏រួមបញ្ចូលឧទាហរណ៍នៃកាលៈទេសៈ ដែលអង្គភាពគួរតែពិចារណាព័ត៌មានអំពីគោលនយោបាយគណនេយ្យជាសារវន្តសម្រាប់របាយការណ៍ហិរញ្ញវត្ថុ។ ដើម្បីគាំទ្រដល់វិសោធនកម្មនេះ ស.រ.ហ.អ.ក សេចក្តីថ្លែងការណ៍អនុវត្ត ២ ក៏ត្រូវបានកែសម្រួល ដើម្បីផ្តល់ការណែនាំអំពីរបៀបអនុវត្តគំនិតនៃការបង្ហាញព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)**

**២. មូលដ្ឋាននៃការរៀបចំ (ត)**

**២.៣ ស្តង់ដារ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន (ត)**

***វិសោធនកម្មលើ ស.គ.អ.ក ១ ការបង្ហាញនៃឧបករណ៍ហិរញ្ញវត្ថុ (ត)***

ការណែនាំ និងឧទាហរណ៍ដែលមាននៅក្នុង ស.រ.ហ.អ.ក សេចក្តីថ្លែងការណ៍អនុវត្ត ២ បញ្ជាក់ពីតម្រូវការក្នុងការផ្តោតព័ត៌មានជាក់លាក់របស់អង្គភាព និងបង្ហាញពីរបៀបដំណើរការទាំងបួនដំណាក់ការជាសារវន្តដែលអាចចង្អុលបង្ហាញពីស្តង់ដារព័ត៌មាន និងភាពស្មុគស្មាញនៃតម្រូវការនៃស.រ.ហ.អ.ក នៅក្នុងការបង្ហាញគោលនយោបាយគណនេយ្យ។

***វិសោធនកម្មលើ ស.គ.អ.ក ៨ គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរក្នុងការប៉ាន់ស្មានគណនេយ្យ និងការកំហុស***

វិសោធនកម្មកែប្រែនិយមន័យការប៉ាន់ស្មានគណនេយ្យ ដើម្បីបញ្ជាក់របៀបដែលអង្គភាពគួរបែងចែកភាពខុសគ្នារវាងការផ្លាស់ប្តូរគោលនយោបាយគណនេយ្យពីការប៉ាន់ស្មានគណនេយ្យ។ ភាពខុសគ្នា គឺមានសារៈសំខាន់ ពីព្រោះការផ្លាស់ប្តូរក្នុងការប៉ាន់ស្មានគណនេយ្យ ត្រូវអនុវត្តទៅលើប្រតិបត្តិការព្រឹត្តិការណ៍ ឬស្ថានភាពផ្សេងៗ ចាប់ពីកាលបរិច្ឆេទនៃការផ្លាស់ប្តូរនាពេលអនាគត។ ប៉ុន្តែការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ជាទូទៅត្រូវអនុវត្តទៅលើប្រតិបត្តិការណ៍ និងព្រឹត្តិការណ៍នៅក្នុងអតីតកាល។

***វិសោធនកម្មលើ ស.គ.អ.ក ១២ ពន្ធលើប្រាក់ចំណូល***

វិសោធនកម្មនេះបញ្ជាក់អំពីរបៀបដែលអង្គភាពត្រូវគិតពន្ធពន្យារលើប្រតិបត្តិការ ដូចជាភតិសន្យា និងកាតព្វកិច្ចរំលាយ។

ក្នុងកាលៈទេសៈដែលច្បាស់លាស់ ស.គ.អ.ក ១២ លើកលែង និងអង្គភាពពីការទទួលស្គាល់ពន្ធពន្យានៅពេលដែលទទួលស្គាល់ទ្រព្យសកម្ម ឬបំណុលជាលើកដំបូង។ ទាំងនេះនឹងអាចមានភាពមិនច្បាស់លាស់មួយចំនួនអំពីថាតើ ការលើកលែងពីការទទួលស្គាល់ពន្ធពន្យា ត្រូវបានអនុវត្តលើប្រតិបត្តិការដូចជាភតិសន្យា និងកាតព្វកិច្ចរំលាយប្រតិបត្តិការដែលអង្គភាពទទួលស្គាល់ទាំងទ្រព្យសកម្ម ឬបំណុល។ វិសោធនកម្មបញ្ជាក់ថា ការលើកលែងមិនត្រូវបានអនុវត្ត និងអង្គភាពនោះត្រូវបានតម្រូវឱ្យទទួលស្គាល់ពន្ធពន្យារលើប្រតិបត្តិការទាំងនេះ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ** (ត)

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### ២.៣ ស្តង់ដារ និងវិសោធនកម្ម ឬកែសម្រួលដែលបានបោះផ្សាយ តែមិនទាន់ចូលជាធរមាន (ត)

***វិសោធនកម្មលើ ស.គ.អ.ក ១៦ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ***

វិសោធនកម្មហាមឃាត់អង្គភាព ពីការដកចេញនៃថ្លៃដើមនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដែលបានទទួលពីការលក់ទំនិញដែលបានផលិត ខណៈដែលអង្គភាពកំពុងរៀបចំទ្រព្យសកម្មសម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក។ ផ្ទុយទៅវិញ អង្គភាពត្រូវទទួលស្គាល់សាច់ប្រាក់បានមកពីការលក់ និងថ្លៃដើមដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ចំណេញ ឬខាត។

***វិសោធនកម្មលើ ស.គ.អ.ក ៣៧ សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ***

វិសោធនកម្មបញ្ជាក់អំពីថ្លៃដើមដែលអង្គភាព បូកបញ្ចូលក្នុងការកំណត់ថ្លៃដើមនៃការបំពេញកិច្ចសន្យាក្នុងគោលបំណងវាយតម្លៃថា តើកិច្ចសន្យានេះគឺនាំឱ្យមានការខាតបង់ ឬទេ។

### ២.៤ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

របាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានបង្ហាញជាប្រាក់រៀល ដែលជារូបិយប័ណ្ណមុខងាររបស់ រ.ទ.ស.ភ ហើយត្រូវបានបង្គត់ទៅខ្ទង់ពាន់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.៥ មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ បានរៀបចំតាមវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានបង្ហាញផ្សេងពីនេះនៅក្នុងកំណត់សម្គាល់ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ២.៦ ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាម ស.រ.ហ.អ.ក តម្រូវឱ្យប្រើការប៉ាន់ស្មាន និងការសន្មតគណនេយ្យជាក់លាក់មួយចំនួន ដែលជះឥទ្ធិពលដល់ចំនួនទឹកប្រាក់ដែលត្រូវបានរាយការណ៍នៃទ្រព្យសកម្ម និងបំណុល និងការបង្ហាញពីទ្រព្យសកម្ម និងបំណុលយថាហេតុនាកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងទឹកប្រាក់ដែលត្រូវបានរាយការណ៍នៃចំណូល និងចំណាយរាយការណ៍ក្នុងគ្រា។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការ វិនិច្ឆ័យក្នុងការអនុវត្តគោលនយោបាយគណនេយ្យនេះផងដែរ។ ទោះបីជាការប៉ាន់ស្មាន និងការវិនិច្ឆ័យដោយផ្អែកលើចំណេះដឹង និងព្រឹត្តិការណ៍នាពេលបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលក៏ដោយ ក៏លទ្ធផលជាក់ស្តែងអាចនឹងមានខុសគ្នា។

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### ២.៦ ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

ផ្នែកដែលទាក់ទងទៅនឹងការវិនិច្ឆ័យ ឬមានភាពភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៤ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ

លើកលែងតែមានការចែងផ្សេងពីនេះ គោលនយោបាយគណនេយ្យខាងក្រោមត្រូវបានអនុវត្តដោយសង្គតិភាពសម្រាប់ឆ្នាំហិរញ្ញវត្ថុទាំងអស់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ។

### ៣.១ ការប្តូររូបិយប័ណ្ណបរទេស

ការប្តូររូបិយប័ណ្ណបរទេសនៅក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានប្តូរតាមអត្រាប្តូរប្រាក់បរទេសនៅថ្ងៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលមិនមែនរូបិយវត្ថុ ត្រូវបានកំណត់ជារូបិយប័ណ្ណបរទេស ដោយប្តូរតាមអត្រាប្តូរប្រាក់បរទេសតាមចុងការិយបរិច្ឆេទរាយការណ៍។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។

ទ្រព្យសកម្ម និងបំណុលមិនមែនរូបិយវត្ថុ ត្រូវបានវាស់វែងតាមថ្លៃវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេស ដែលត្រូវបានប្តូរតាមអត្រាប្តូរប្រាក់បរទេសនៅថ្ងៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុល មិនមែនរូបិយវត្ថុ ត្រូវបានកំណត់ជារូបិយប័ណ្ណបរទេស ដែលត្រូវបានវាស់វែងនៅតម្លៃសមស្រប ត្រូវបាន បកប្រែតាមអត្រាប្តូរប្រាក់បរទេសនៅថ្ងៃកំណត់តម្លៃសមស្រប។

### ៣.២ ឧបករណ៍ហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលដែល រ.ទ.ស.ភ ក្លាយជាភាគីក្នុងការធ្វើសំវិធានធនកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។

លើកលែងគណនីអតិថិជនពាណិជ្ជកម្ម ដែលមិនមានធាតុជាហិរញ្ញប្បទានគួរឱ្យកត់សម្គាល់ ឬ រ.ទ.ស.ភ បានអនុវត្តជាក់ស្តែង ឧបករណ៍ហិរញ្ញវត្ថុ គឺត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃសមស្រប បូក ឬដក ក្នុងករណីទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុមិនបានកត់ត្រាតាមតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬខាតទេ នោះថ្លៃដើមប្រតិបត្តិការដែលត្រូវបានបង្កឡើងដោយផ្ទាល់ទៅនឹងការទិញ ឬបោះផ្សាយនៃទ្រព្យសម្បត្តិ និងបំណុលហិរញ្ញវត្ថុ។

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.២ ឧបករណ៍ហិរញ្ញវត្ថុ (ត)

ថ្លៃដើមប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុយោងមក តាមតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬខាតត្រូវបានចំណាយនៅក្នុងប្រាក់ចំណេញ ឬខាត។ គណនីអតិថិជនពាណិជ្ជកម្ម ដែលមិនមានសមាសធាតុហិរញ្ញប្បទានគួរឱ្យកត់សម្គាល់ ឬដែល រ.ទ.ស.ភ បានអនុវត្តការអនុវត្តន៍ជាក់ស្តែង ត្រូវបានវាស់វែងតាមតម្លៃប្រតិបត្តិការដែលបានកំណត់ក្រោម រ.ទ.ស.ភ ១៥។

**(ក) ការវាស់វែងជាបន្តបន្ទាប់**

រ.ទ.ស.ភ បានចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

**(១) ទ្រព្យសកម្មហិរញ្ញវត្ថុ**

ការវាស់វែងជាបន្តបន្ទាប់នៃឧបករណ៍បំណុលអាស្រ័យលើ គំរូអាជីវកម្មរបស់ រ.ទ.ស.ភ សម្រាប់ការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈលំហូរសាច់ប្រាក់នៃទ្រព្យសកម្មនោះ។ រ.ទ.ស.ភ បានចាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួនជាទ្រព្យសកម្មហិរញ្ញវត្ថុដោយវិធីសាស្ត្ររំលស់ថ្លៃដើម។

<u>ទ្រព្យសកម្មហិរញ្ញវត្ថុក្នុងវិធីសាស្ត្ររំលស់ថ្លៃដើម</u>
ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ប្រមូលលំហូរសាច់ប្រាក់ពីកិច្ចសន្យា ហើយលំហូរសាច់ប្រាក់ទាំងនោះបង្ហាញពីការទូទាត់នៃប្រាក់ដើម និងការប្រាក់ទាំងស្រុងត្រូវបានវាស់វែងនៅថ្លៃដើមរំលស់។ ទ្រព្យសកម្មហិរញ្ញវត្ថុនៅថ្លៃដើមរំលស់ត្រូវបានវាស់វែងបន្ទាប់ ដោយបានប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព ហើយដែលជាកម្មវត្ថុនៃការថយចុះតម្លៃ។ គោលនយោបាយសម្រាប់ការទទួលស្គាល់ និងការវាស់វែងការថយចុះតម្លៃគឺស្របតាមកំណត់សម្គាល់លេខ ៣.៨(ក) នៃរបាយការណ៍ហិរញ្ញវត្ថុ។ ចំណេញ ឬខាតត្រូវទទួលស្គាល់ក្នុងចំណេញ ឬខាត នៅពេលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ កែតម្រូវ ឬមានឱនភាពតម្លៃ។

**(២) បំណុលហិរញ្ញវត្ថុ**

រ.ទ.ស.ភ បានចាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួន ជាបំណុលហិរញ្ញវត្ថុក្នុងវិធីសាស្ត្ររំលស់ថ្លៃដើម។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)**

**៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)**

**៣.២ ឧបករណ៍ហិរញ្ញវត្ថុ (ត)**

**(ក) ការវាស់វែងជាបន្តបន្ទាប់ (ត)**

**(២) បំណុលហិរញ្ញវត្ថុ (ត)**

<u>បំណុលហិរញ្ញវត្ថុក្នុងវិធីសាស្ត្ររំលស់ថ្លៃដើម</u>

បន្ទាប់ពីការទទួលស្គាល់ជាដំបូង បំណុលហិរញ្ញវត្ថុផ្សេងៗត្រូវបានវាស់វែងតាមវិធីសាស្ត្ររំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។ ចំណេញ និងខាតត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត នៅពេលដែលបំណុលហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ និងតាមរយៈដំណើរការរំលស់។

**(ខ) ការឈប់ទទួលស្គាល់**

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬផ្នែកណាមួយត្រូវបានឈប់ទទួលស្គាល់នៅពេល៖

(១) សិទ្ធិក្នុងកិច្ចសន្យា ដើម្បីទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុនោះផុតកំណត់ ឬ

(២) រ.ទ.ស.ភ បានផ្ទេរសិទ្ធិក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មរបស់ខ្លួន ឬបានសន្មតថាមានកាតព្វកិច្ចត្រូវបង់លំហូរសាច់ប្រាក់ ដែលត្រូវទទួលបានក្នុងចំនួនពេញលេញ ដោយគ្មានការពន្យាជាសារវន្តដល់តតិយជន និង (ក) រ.ទ.ស.ភ ក្រុមហ៊ុនបានផ្ទេរនូវរាល់ហានិភ័យ និងរង្វាន់នៃទ្រព្យសកម្មនោះ ឬ (ខ) រ.ទ.ស.ភ មិនបានផ្ទេរឬរក្សាទុកនូវរាល់ហានិភ័យ និងអត្ថប្រយោជន៍នៃទ្រព្យសកម្មទេ ប៉ុន្តែបានផ្ទេរការគ្រប់គ្រងទ្រព្យសកម្មនោះវិញ។

រ.ទ.ស.ភ បានវាយតម្លៃ ប្រសិនបើ និងនៅកម្រិតណាដែលវាបានរក្សាទុកនូវហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិ។ នៅពេលដែលវាមិនបានផ្ទេរ ឬរក្សាទុកនូវហានិភ័យ និងអត្ថប្រយោជន៍ទាំងអស់នៃទ្រព្យសកម្មនោះ ហើយក៏មិនបានផ្ទេរការគ្រប់គ្រងនៃទ្រព្យសកម្មនោះទេ រ.ទ.ស.ភ នៅតែបន្តទទួលស្គាល់ទ្រព្យសកម្មដែលបានផ្ទេរក្នុងទំហំនៃការចូលរួមរបស់វា។ ក្នុងករណីនោះ រ.ទ.ស.ភ ក៏ទទួលស្គាល់បំណុលដែរពាក់ព័ន្ធ។ ទ្រព្យសកម្មដែលបានផ្ទេរ និងបំណុលដែលបានពាក់ព័ន្ធត្រូវបានវាស់ផ្អែកលើមូលដ្ឋាន ដែលបានឆ្លុះបញ្ចាំងពីសិទ្ធិ និងកាតព្វកិច្ចដែល រ.ទ.ស.ភ បានរក្សាទុក។

ការបន្តជាប់ទាក់ទង ដែលមានទម្រង់ជាការធានាលើទ្រព្យសកម្មដែលបានផ្ទេរ ត្រូវបានវាស់វែងតាមតម្លៃទាបជាងតម្លៃយោងដើមនៃទ្រព្យសកម្ម និងតម្លៃអតិបរមានៃអត្ថប្រយោជន៍ដែល រ.ទ.ស.ភ អាចតម្រូវឱ្យទូទាត់។

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.២ ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### (ខ) ការឈប់ទទួលស្គាល់ (ត)

ក្នុងការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោង (វាស់វែងនៅកាលបរិច្ឆេទដែលឈប់ទទួលស្គាល់) និងអត្ថប្រយោជន៍ដែលទទួលបាន (រួមទាំងទ្រព្យសកម្មថ្មីណាមួយដែលទទួលបាន ដកបំណុលថ្មីដែលមាន) ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

បំណុលហិរញ្ញវត្ថុមួយ ឬផ្នែកណាមួយរបស់វាត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលកាតព្វកិច្ចដែលបានកំណត់នៅក្នុងកិច្ចសន្យាត្រូវបានបំពេញ លុបចោល ឬផុតកំណត់។ ក្នុងការឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ ផលសងរវាងតម្លៃយោង និងអត្ថប្រយោជន៍ដែលបានបង់រួមទាំងទ្រព្យសកម្មមិនមែនជាសាច់ប្រាក់ដែលបានផ្ទេរ ឬបំណុល ដែលមានត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

#### (គ) ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់ដែលនៅសល់ត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ប្រសិនបើមានសិទ្ធិស្របច្បាប់ដែលអាចអនុវត្តបាននាពេលបច្ចុប្បន្នក្នុងការកាត់កងនូវចំនួនទឹកប្រាក់ ដែលត្រូវបានទទួលស្គាល់ហើយមានបំណងទូទាត់លើប្រាក់ដែលនៅសល់ពីការលក់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

នៅក្នុងកត់ត្រាការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការឈប់ទទួលស្គាល់ អង្គភាពមិនត្រូវកាត់កងទ្រព្យសកម្មដែលបានផ្ទេរ និងបំណុលដែលពាក់ព័ន្ធនោះទេ។

### ៣.៣ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

#### (ក) ការទទួលស្គាល់ និង ការវាស់វែង

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានវាស់វែងតាមថ្លៃដើម ដករំលស់បង្គរ និងឱនភាពតម្លៃបង្គរ។ គោលនយោបាយសម្រាប់ការទទួលស្គាល់ និងវាស់វែងការខាតបង់លើឱនភាពតម្លៃ គឺអនុលោមតាមកំណត់សម្គាល់ ៣.៨(ខ) នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.៣ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

#### (ក) ការទទួលស្គាល់ និង ការវាស់វែង (ត)

ថ្លៃដើមនៃទ្រព្យសកម្ម រួមបញ្ចូលទាំងថ្លៃប្រតិបត្តិការដែលត្រូវបានពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការទិញទ្រព្យសកម្ម និងចំណាយផ្សេងទៀតដែលត្រូវបានពាក់ព័ន្ធដោយផ្ទាល់ដើម្បីនាំយកទ្រព្យសកម្មនោះមកកាន់លក្ខខណ្ឌនៃការប្រើប្រាស់ដែលបានគ្រោងទុក។ ថ្លៃដើមនៃការសាងសង់ទ្រព្យសកម្មផ្ទាល់ រាប់បញ្ចូលទាំងថ្លៃដើមនៃសម្ភារៈ កម្លាំងពលកម្មផ្ទាល់ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ប៉ុន្តែមិនរាប់បញ្ចូលប្រាក់ចំណេញផ្ទៃក្នុងទេ។ សម្រាប់ទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បន្ទុកលើប្រាក់កម្ចី ត្រូវធ្វើមូលធន អនុលោមតាមគោលនយោបាយគណនេយ្យនៃបន្ទុកលើប្រាក់កម្ចី ក្នុងកំណត់សម្គាល់ ៣.១៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

នៅពេលផ្នែកសំខាន់ៗនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ផ្សេងៗគ្នា ពួកវាត្រូវបានកត់ត្រាជាទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដាច់ដោយឡែកពីគ្នា។

#### (ខ) ចំណាយបន្ទាប់

ចំណាយលើការផ្លាស់ប្តូរសមាសធាតុមួយនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានរួមបញ្ចូលនៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម ប្រសិនបើច្បាស់ថាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតនឹងហូរចូលរ.ទ.ស.ភ ហើយចំណាយនោះអាចត្រូវបានវាស់វែងដោយជឿទុកចិត្ត។ តម្លៃយោងនៃចំណែកដែលបានផ្លាស់ប្តូរត្រូវបានឈប់ទទួលស្គាល់។ ចំណាយក្នុងការជួសជុល និងថែទាំទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត នៅពេលកើតមាន។

#### (គ) រំលស់

ដីធ្លីមានអាយុកាលប្រើប្រាស់មិនកំណត់ ដូច្នេះមិនត្រូវបានធ្វើការរំលស់ទេ។ ទ្រព្យសកម្មស្ថិតក្រោមការសាងសង់ ដែលរួមបញ្ចូលក្នុងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារក៏មិនត្រូវបានរំលស់ដែរ ដោយសារតែ ទ្រព្យសកម្មទាំងនោះមិនទាន់អាចប្រើប្រាស់បាននៅឡើយ។

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.៣ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

**(គ) រំលស់ (ត)**

រាល់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដ៏ទៃទៀតត្រូវបានរំលស់ដោយវិធីសាស្រ្តរំលស់ថេរ ដោយបែងចែកតម្លៃដែលអាចរំលស់បានតាមអាយុកាលប្រើប្រាស់ដែលនៅសល់។

| | អាយុកាលប្រើប្រាស់ (ឆ្នាំ) |
|---|---|
| អគារ | ៣ - ៥០ |
| គ្រឿងម៉ាស៊ីន | ៣ - ២០ |
| បំពង់បង្ហូរទឹក | ៦ - ៥០ |
| បរិក្ខារមន្ទីរពិសោធន៍ | ៦ - ៧ |
| គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ | ២ - ៧ |
| បរិក្ខារអគ្គិសនី | ២ - ២០ |
| យានយន្ត | ២ - ៧ |
| វ៉ាន និងឧបករណ៍ | ៣ - ៣៥ |
| នាឡិកាទឹក | ៥ - ២០ |
| ការតភ្ជាប់បណ្តាញចូលផ្ទះ | ១២ |

តម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្រ្តរំលស់ ត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់ចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ និងធ្វើនិយ័តកម្មតាមការគួរ។

**(ឃ) ការឈប់ទទួលស្គាល់**

ផ្នែកនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានឈប់ទទួលស្គាល់នៅពេលលក់ ឬនៅពេលដែលគ្មានការរំពឹងថានឹងទទួលបានផលប្រយោជន៍សេដ្ឋកិច្ចពីការប្រើប្រាស់ ឬលក់។ ចំណេញ ឬខាតដែលកើតឡើង ដោយសារការឈប់ទទួលស្គាល់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

**៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)**

**៣.៤ ទ្រព្យសកម្មអរូបី**

ទ្រព្យសកម្មអរូបីរួមមាន កម្មវិធីគណនេយ្យ និងកម្មវិធីបណ្តាញ ដែលត្រូវបានប្រើប្រាស់ដោយ រ.ទ.ស.ភ ដែលមានអាយុកាលច្បាស់លាស់ ត្រូវបានវាស់វែងនូវថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពតម្លៃបង្គរ។ គោលនយោបាយនៃការទទួលស្គាល់ និងការវាស់វែងនៃការខាតបង់ឱនភាពតម្លៃ គឺអនុលោមតាមកំណត់សម្គាល់ ៣.៨(ខ)។

វិធីសាស្ត្ររំលស់ និងការប៉ាន់ស្មានអាយុកាលប្រើប្រាស់ត្រូវបានបង្ហាញដូចខាងក្រោម៖

| | **វិធីសាស្ត្រ** | **អាយុកាលប្រើប្រាស់ (ឆ្នាំ)** |
|---|---|---|
| កម្មវិធីគណនេយ្យ និងបណ្តាញ | រំលស់ថេរ | ១ - ៧ |

**៣.៥ សន្និធិ**

សន្និធិត្រូវបានវាស់វែងតាមតម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃដែលអាចទទួលបានមកវិញ។

ថ្លៃដើមត្រូវបានកំណត់ដោយមូលដ្ឋានថ្លៃដើមជាមធ្យម។ ថ្លៃដើមរួមបញ្ចូល ថ្លៃទិញ បូកបញ្ចូលនឹងចំណាយផ្សេងៗ ដែលកើតឡើងក្នុងការនាំសន្និធិនោះមកកាន់ទីតាំង និងមានលក្ខណៈបច្ចុប្បន្ន។ សន្និធិរួមបញ្ចូលទាំងវត្ថុធាតុដើម វត្ថុប្រើប្រាស់ គ្រឿងបន្លាស់ និងសន្និធិដ៏ទៃទៀតដែលទាក់ទងនឹងការផ្គត់ផ្គង់ទឹក ហើយត្រូវកំណត់តម្លៃទៅតាមថ្លៃដើមពិតប្រាកដ ក្នុងការនាំយកសន្និធិដកនឹងប្រាក់សម្រាប់ការខូចខាត ហួសសម័យ និងមានចលនាយឺត ដោយមានការប្រើមូលដ្ឋានថ្លៃដើមជាមធ្យម។ គ្រឿងបន្លាស់ និងសន្និធិដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹក ដែលមានអាយុកាលច្រើនជាងមួយឆ្នាំត្រូវទទួលស្គាល់ជាទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ នៅពេលដាក់ចូលទៅក្នុងការប្រើប្រាស់។

តម្លៃដែលអាចទទួលបានមកវិញ គឺជាតម្លៃលក់ប៉ាន់ស្មានតាមប្រតិបត្តិការអាជីវកម្មធម្មតាដកនឹងថ្លៃដើមប៉ាន់ស្មាននៃការសម្រេចឱ្យបានផលិតផល និងចំណាយប៉ាន់ស្មានចាំបាច់ក្នុងការលក់។

**៣.៦ កិច្ចសន្យាទ្រព្យសកម្ម/(បំណុល)**

ទ្រព្យសកម្មកិច្ចសន្យា គឺជាសិទ្ធិក្នុងការទទួលបានផលប្រយោជន៍ជាថ្នូរនឹងការផ្ទេរទំនិញឬសេវាកម្មទៅឱ្យអតិថិជននៅពេលដែល សិទ្ធិនោះមានលក្ខខណ្ឌលើអ្វីមួយជាជាងពេលវេលា ដែលបានកន្លងផុតទៅ (ឧទាហរណ៍៖ ការអនុវត្តនាពេលអនាគតរបស់ រ.ទ.ស.ភ)។ គោលនយោបាយក្នុងការទទួលស្គាល់ និងវាស់វែងលើការខាតបង់ឱនភាពតម្លៃគឺអនុលោមតាមកំណត់សំគាល់ ៣.៨(ក)។

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.៦ កិច្ចសន្យាទ្រព្យសកម្ម/(បំណុល) (ត)

កិច្ចសន្យាបំណុល គឺជាកាតព្វកិច្ចផ្ទេរទំនិញ ឬសេវាកម្មទៅឱ្យអតិថិជននៅពេលដែល រ.ទ.ស.ភ បានទទួលផលប្រយោជន៍ ឬបានចេញវិក័យបត្រជូនអតិថិជន។

### ៣.៧ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យធនាគារ និងសាច់ប្រាក់ដែលត្រូវបានតម្កល់ និងគ្រប់គ្រងដោយអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានីភ្នំពេញ រតនាគាខេត្តត្បូងឃ្មុំ រតនាគាខេត្តកណ្តាលដែលងាយបម្លែងជាសាច់ប្រាក់ និងដែលអាចប្រឈមនឹងហានិភ័យតិចតួចនៃការផ្លាស់ប្តូរតម្លៃ។

### ៣.៨ ឱនភាពតម្លៃនៃទ្រព្យសកម្ម

#### (ក) ឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

រ.ទ.ស.ភ វាយតម្លៃតាមព័ត៌មាននាពេលអនាគត លើមូលដ្ឋានការប៉ាន់ស្មានការខាតបង់ឥណទានរំពឹងទុកនឹងទ្រព្យសកម្មហិរញ្ញវត្ថុបំណុលតាមថ្លៃដើមរំលស់។ វិធីសាស្ត្រការនៃឱនភាពនៃតម្លៃគឺត្រូវបានបង្ហាញនៅកំណត់សម្គាល់ ៣១(ខ) នៃរបាយការណ៍ហិរញ្ញវត្ថុ។

#### (ខ) ឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យឡើងវិញនៅចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានការចង្អុលបង្ហាញពីឱនភាពតម្លៃដែរ ឬទេ។ ប្រសិនបើមានការចង្អុលបង្ហាញកើតឡើង រ.ទ.ស.ភនឹងធ្វើការប៉ាន់ស្មាននូវចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញនៃទ្រព្យសកម្មនោះ។
ក្នុងគោលបំណងធ្វើតេស្តឱនភាពតម្លៃ ទ្រព្យសកម្មត្រូវបានដាក់ជាក្រុមតូចបំផុតដែលអាចបង្កើតលំហូរសាច់ប្រាក់ចូលពីការបន្តប្រើប្រាស់ ដែលឯករាជ្យពីលំហូរសាច់ប្រាក់ចូលនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ឬ អង្គភាពបង្កើតសាច់ប្រាក់ ("CGUs")។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ** (ត)

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.៨ ឱនភាពតម្លៃនៃទ្រព្យសកម្ម (ត)

#### (ខ) ឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញពីទ្រព្យសកម្ម ឬ អង្គភាពបង្កើតសាច់ប្រាក់ គឺជាតម្លៃខ្ពស់ជាងរវាងតម្លៃសមស្របដកចំណាយក្នុងការលក់ និងតម្លៃប្រើប្រាស់។ ក្នុងការវាយតម្លៃតម្លៃប្រើប្រាស់លំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគតត្រូវបានគេបំលែងទៅជាតម្លៃបច្ចុប្បន្នដោយប្រើប្រាស់អត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្នទៅលើតម្លៃនៃសាច់ប្រាក់តាមពេលវេលា និងហានិភ័យជាក់លាក់នៃទ្រព្យសកម្ម ឬ អង្គភាពបង្កើតសាច់ប្រាក់។ ក្នុងការកំណត់តម្លៃសមស្របដកចំណាយក្នុងការលក់ ប្រតិបត្តិការទីផ្សារថ្មីៗត្រូវបានគេយកមកពិចារណា។ ប្រសិនបើគ្មានប្រតិបត្តិការបែបនោះត្រូវបានសម្គាល់ឃើញគំរូវាយតម្លៃសមស្របនឹងត្រូវប្រើប្រាស់។

នៅពេលដែលតម្លៃយោងនៃទ្រព្យសកម្មលើសពីទឹកប្រាក់ ដែលអាចប្រមូលបានមកវិញ តម្លៃយោងនៃទ្រព្យសកម្មត្រូវបានកាត់បន្ថយមកត្រឹមទឹកប្រាក់ដែលអាចប្រមូលបានមកវិញ។

ការខាតបង់ឱនភាពតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

ការវាយតម្លៃត្រូវបានធ្វើឡើងនៅចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ ថាតើមានការចង្អុលបង្ហាញណាមួយដែលថាការខាតបង់លើឱនភាពនៃតម្លៃ ដែលទទួលស្គាល់ពីមុនអាចលែងកើតមាន ឬអាចថយចុះ។ ការខាតបង់ឱនភាពតម្លៃត្រូវកត់ត្រឡប់មកវិញ ប្រសិនបើមានការផ្លាស់ប្តូរការប៉ាន់ស្មានដែលប្រើប្រាស់ដើម្បីកំណត់ទឹកប្រាក់ដែលអាចប្រមូលបានមកវិញពីទ្រព្យសកម្មនោះ ចាប់តាំងពីការខាតបង់លើឱនភាពតម្លៃចុងក្រោយ ត្រូវបានទទួលស្គាល់។

ការខាតបង់ឱនភាពតម្លៃត្រូវកត់បញ្ច្រាស់មកវិញ ត្រូវកំណត់នៅត្រឹមកម្រិតនៃតម្លៃយោងនៃទ្រព្យសកម្ម មិនលើសតម្លៃយោងដែលត្រូវបានកំណត់ ក្រោយរំលស់ ប្រសិនបើមិនមានការទទួលស្គាល់ការខាតបង់ឱនភាពតម្លៃក្នុងការិយបរិច្ឆេទមុន។ ការកត់បញ្ច្រាស់មកវិញនេះ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត លុះត្រាតែទ្រព្យសកម្ម ត្រូវបានវាស់វែងតម្លៃឡើងវិញ ក្នុងករណីដែលការកត់ត្រាបញ្ច្រាស់ ត្រូវបានចាត់ទុកជាការកើនឡើងនៃការវាយតម្លៃឡើងវិញ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.៩ ដើមទុន

#### (ក) ភាគហ៊ុនធម្មតា

ភាគហ៊ុនធម្មតា ជាឧបករណ៍មូលបត្រកម្មសិទ្ធិ។ ឧបករណ៍មូលបត្រកម្មសិទ្ធិ ជាកិច្ចសន្យាមួយ ដែលបង្ហាញពីភស្តុតាងលើភាគកម្មដែលនៅសល់ក្នុងទ្រព្យសកម្មរបស់រ.ទ.ស.ភ បន្ទាប់ពីកាត់កងបំណុលទាំងអស់។ ភាគហ៊ុនធម្មតាត្រូវបានកត់ត្រានៅពេលទទួលបានសាច់ប្រាក់ ដោយដកចំណាយប្រតិបត្តិការ ដែលពាក់ព័ន្ធ ផ្ទាល់។ ភាគលាភលើភាគហ៊ុនធម្មតា ត្រូវបានកត់ត្រាក្នុងមូលធនពេលដែលភាគលាភត្រូវបានប្រកាស។

#### (ខ) បុព្វលាភភាគហ៊ុន

បុព្វលាភភាគហ៊ុន ត្រូវបានចាត់ថ្នាក់ជាមូលធន ប្រសិនបើមិនអាចហៅមកវិញបាន ឬអាចហៅមកវិញបាន ប៉ុន្តែជាជម្រើសតែមួយគត់របស់ រ.ទ.ស.ភ និងការទូទាត់ភាគលាភណាមួយគឺជាការសម្រេចចិត្ត។ ភាគលាភត្រូវបានទទួលស្គាល់ជាការបែងចែកនៅក្នុងមូលធន។
បុព្វលាភភាគហ៊ុន ត្រូវបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុ ប្រសិនបើអាចហៅមកវិញបាននៅកាលបរិច្ឆេទជាក់លាក់ ឬជាជម្រើសរបស់ម្ចាស់កាន់កាប់មូលធន ប្រសិនបើការទូទាត់ភាគលាភណាមួយគឺជាការមិនសម្រេចចិត្ត។ ភាគលាភត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់នៅពេលកើតឡើង ក្នុងរបាយការណ៍ចំណេញ ឬខាត។

#### (គ) ការបន្ថែមដើមទុន

ការបន្ថែមមិនទៅវិញទៅមកពីម្ចាស់ គឺជាមូលធន និងត្រូវបានកត់ត្រាជាការបន្ថែមដើមទុន។ ទ្រព្យសកម្មសុទ្ធដែលកើតចេញពីកាបន្ថែមដើមទុន គឺត្រូវបានវាស់វែងតាមតម្លៃសមស្រប គិតត្រឹមកាលបរិច្ឆេទនៃការបន្ថែមដើមទុន និងត្រូវបានកត់ត្រាដោយផ្អែកលើលក្ខណៈនៃទ្រព្យសកម្មដែលបន្ថែមដោយម្ចាស់ដើមទុន។

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.១០ អត្ថប្រយោជន៍បុគ្គលិក

កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីពាក់ព័ន្ធនឹង ប្រាក់ឈ្នួល ប្រាក់ខែ វិភាគទានសន្តិសុខសង្គម ប្រាក់រង្វាន់ប្រចាំឆ្នាំ ការឈប់សម្រាកប្រចាំឆ្នាំ ការឈប់សម្រាកឈឺ និងអត្ថប្រយោជន៍មិនមែនរូបិយវត្ថុ ត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងឆ្នាំហិរញ្ញវត្ថុដែលនិយោជិតបានផ្តល់សេវាកម្មដល់ រ.ទ.ស.ភ។

### ៣.១១ ចំណូល និងចំណូលផ្សេងៗ

រ.ទ.ស.ភ ទទួលស្គាល់ចំណូលនៅពេលដែលទំនិញ ឬសេវាត្រូវបានផ្ទេរទៅអតិថិជនក្នុងទឹកប្រាក់ដែលឆ្លុះបញ្ចាំងការតបស្នង ដែល រ.ទ.ស.ភ រំពឹងថានឹងទទួលបានក្នុងការដោះដូរទំនិញ ឬសេវានោះ។

ការទទួលស្គាល់ចំណូលរបស់ រ.ទ.ស.ភ ត្រូវបានអនុវត្តសម្រាប់កិច្ចសន្យានីមួយៗ ជាមួយនឹងអតិថិជន ឬការបញ្ចូលគ្នានៃកិច្ចសន្យាជាមួយនឹងអតិថិជនដូចគ្នា (ឬភាគីពាក់ព័ន្ធរបស់អតិថិជន)។ ជាការអនុវត្តជាក់ស្តែង រ.ទ.ស.ភ បានអនុវត្តការទទួលស្គាល់ចំណូលចំពោះផលប័ត្រនៃកិច្ចសន្យា (ឬកាតព្វកិច្ចដែលត្រូវអនុវត្ត) ជាមួយនឹងលក្ខណៈស្រដៀងគ្នា ប្រសិនរ.ទ.ស.ភរំពឹងថា ផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុ មិនខុសគ្នាខ្លាំងពីការទទួលស្គាល់ចំណូលលើកិច្ចសន្យានីមួយៗ (ឬកាតព្វកិច្ចដែលត្រូវអនុវត្ត) ជាមួយនឹងផលប័ត្រនោះ។

រ.ទ.ស.ភ វាស់វែងចំណូលពីការលក់ទំនិញ ឬផ្ទេរសេវាកម្មនៅថ្លៃប្រតិបត្តិការ គឺជាការតបស្នង ដែល រ.ទ.ស.ភ រំពឹងទុកថានឹងទទួលបាននៅពេលដោះដូរសម្រាប់ការផ្ទេរទំនិញ ឬសេវា ដែលបានសន្យាទៅអតិថិជន ដែលមិនរាប់បញ្ចូលទឹកប្រាក់ដែលប្រមូលបានក្នុងនាមជាភាគីទី៣ ដូចជាសេវាកម្មលើសេវាកម្មពន្ធដារជាដើមត្រូវបានកែតម្រូវសម្រាប់ផលប៉ះពាល់ការតបស្នង ការប៉ាន់ស្មានការតបស្នងអថេរ ធាតុហិរញ្ញប្បទានសំខាន់ៗ ការតបស្នងលើធាតុមិនមែនសាច់ប្រាក់ និងតម្លៃតបស្នងត្រូវសងដល់អតិថិជន។ ប្រសិនបើថ្លៃប្រតិបត្តិការ រួមទាំងការតបស្នងអថេរ រ.ទ.ស.ភ ប្រើប្រាស់វិធីសាស្ត្រតម្លៃរំពឹងទុក ដោយការប៉ាន់ស្មានការបូកបញ្ចូលគ្នានៃចំនួនមធ្យមប្រូបាបតាមចន្លោះ ឬចំនួនទឹកប្រាក់តបស្នង ឬតាមវិធីសាស្ត្រលទ្ធផលដោយផ្អែកលើវិធីសាស្ត្រណាដែល រ.ទ.ស.ភ រំពឹងទុកថាការព្យាករណ៍ទឹកប្រាក់តបស្នងដែលល្អប្រសើរនឹងត្រូវបានទទួល។

សម្រាប់កិច្ចសន្យាដែលបែងចែកកាតព្វកិច្ចត្រូវអនុវត្ត ថ្លៃប្រតិបត្តិការត្រូវធ្វើបានធ្វើការបែងចែកដោយឡែកទៅតាមការបែងចែកកាតព្វកិច្ចត្រូវអនុវត្តនោះដោយផ្អែកលើមូលដ្ឋានថ្លៃលក់ទោល។ ប្រសិនបើថ្លៃលក់ទោលនោះ មិនអាចអង្កេតដោយផ្ទាល់បាន រ.ទ.ស.ភ ត្រូវធ្វើការប៉ាន់ស្មានដោយប្រើប្រាស់ថ្លៃដើមរំពឹងទុកបូកនឹងគំលាតចំណេញ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.១១ ចំណូល និងចំណូលផ្សេងៗ (ត)

ចំណូលពីកិច្ចសន្យាជាមួយអតិថិជន ត្រូវបានទទួលស្គាល់ដោយយោងតាមកាតព្វកិច្ចខុសៗគ្នានីមួយៗត្រូវអនុវត្តផ្សេងគ្នាក្នុងកិច្ចសន្យាជាមួយអតិថិជន ឧទាហរណ៍ នៅពេលកាតព្វកិច្ចត្រូវអនុវត្តក្នុងកិច្ចសន្យាជាមួយអតិថិជនត្រូវបានពេញចិត្ត។ កាព្វកិច្ចត្រូវអនុវត្ត ត្រូវបានពេញចិត្តនៅពេលដែលអតិថិជនទទួលបានបានការគ្រប់គ្រងទំនិញ ឬសេវានោះ ក្រោមកាតព្វកិច្ចត្រូវអនុវត្តជាក់លាក់ ដែលកាតព្វកិច្ចត្រូវអនុវត្តជាក់លាក់នោះអាចត្រូវបានបំពេញនៅពេលជាក់លាក់ណាមួយ ឬតាមពេល។

ការកែប្រែកិច្ចសន្យា ជាការផ្លាស់ប្តូរនៅវិសាលភាព ឬថ្លៃ (ឬទាំងពីរ) នៃកិច្ចសន្យាដែលត្រូវបានអនុម័តដោយភាគីនៅក្នុងកិច្ចសន្យា។ ការកែប្រែកើតមាននៅពេលដែលមានការផ្លាស់ប្តូរថ្មី ឬការផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីក្នុងកិច្ចសន្យា។ រ.ទ.ស.ភបានវាយតម្លៃប្រភេទនៃការកែប្រែ និងអាចបង្កើតទាំងកិច្ចសន្យាថ្មីដាច់ដោយឡែក បញ្ចប់កិច្ចសន្យាដែលមានស្រាប់ និងបង្កើតកិច្ចសន្យាថ្មី ឬរៀបចំផ្នែកណាមួយនៃកិច្ចសន្យាដែលមានស្រាប់។

#### (ក) ចំណូលបានមកពីការផ្គត់ផ្គង់ទឹក

ចំណូលពីការផ្គត់ផ្គង់ទឹក ត្រូវបានទទួលស្គាល់ក្នុងពេលជាក់លាក់មួយ នៅពេលដែល រ.ទ.ស.ភ បំពេញកាតព្វកិច្ចអនុវត្ត ដោយផ្អែកលើការប្រើប្រាស់ទឹករបស់អតិថិជន និងនៅពេលដែលទឹកត្រូវបានផ្គត់ផ្គង់ដោយ រ.ទ.ស.ភ។

#### (ខ) ចំណូលបានមកពីតភ្ជាប់បណ្តាញទឹក

ចំណូលបានពីការតភ្ជាប់បណ្តាញទឹក ត្រូវបានទទួលស្គាល់ក្នុងពេលជាក់លាក់មួយនៅពេលដែលការតភ្ជាប់បណ្តាញទឹកត្រូវបានបញ្ចប់រួចរាល់។

#### (គ) ការផ្លាស់ប្តូរនាឡិកាទឹក

ចំណូលបានពីការផ្លាស់ប្តូរនាឡិកាទឹក ត្រូវបានទទួលស្គាល់ក្នុងពេលជាក់លាក់មួយដោយផ្អែកលើការចេញវិក្កយបត្រដោយគិតថ្លៃ ៥០រៀល ក្នុង១មីលីម៉ែត្រក្នុងមួយខែនៃទំហំនាឡិកាទឹក។

#### (ឃ) ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់លើមូលដ្ឋានបង្គរ ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.១១ ចំណូល និងចំណូលផ្សេងៗ (ត)

#### (ង) កម្រៃពីសេវាសាងសង់

កម្រៃពីសេវាសាងសង់តំណាងឱ្យកម្រៃ ដែលបានមកពីថ្លៃឈ្នួលនៃសេវាកម្មសំណង់ដែលទាក់ទងនឹង ការពង្រីកប្រព័ន្ធចែកចាយទឹកទៅកាន់អ្នកចែកចាយទឹកនៅតាមបណ្តាខេត្តនានា។

ចំណូលពីកិច្ចសន្យាសាងសង់ ត្រូវបានវាស់វែងតាមតម្លៃប្រតិបត្តិការថេរដែលបានយល់ព្រមក្រោមកិច្ចព្រមព្រៀង។

ចំណូលត្រូវបានទទួលស្គាល់ក្នុងកំឡុងពេលនៃកិច្ចសន្យា ដោយយោងទៅតាមដំណើរការបញ្ចប់នៃកិច្ចសន្យាកាតព្វកិច្ច។ ដំណើរការបញ្ចប់នៃកិច្ចសន្យាកាតព្វកិច្ច ត្រូវកំណត់ដោយការប៉ាន់ស្មានផលចំណេញពីមុន។ រ.ទ.ស.ភ ក៏បានប៉ាន់ប្រមាណនូវតម្លៃកិច្ចសន្យាក្នុងការអនុវត្តវិធីសាស្ត្រធាតុចូលដើម្បីទទួលបានប្រាក់ចំណូលតាមពេលវេលាផងដែរ។

### ៣.១២ ជំនួយពន្យាពីរដ្ឋាភិបាល

ជំនួយពន្យាពីរដ្ឋាភិបាល និងភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀតត្រូវបានទទួលស្គាល់នៅពេលដែលមានការធានាសមហេតុផលថាជំនួយនឹងត្រូវទទួលបាន ហើយ រ.ទ.ស.ភ នឹងអនុវត្តទៅតាមលក្ខខណ្ឌទាំងអស់ដែលមានភ្ជាប់នឹងជំនួយនោះ។ ជំនួយនឹងត្រូវបានពន្យា និងទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត និងរបាយការណ៍លម្អិតផ្សេងៗក្នុងការិយបរិច្ឆេទចាំបាច់ ដើម្បីធ្វើឱ្យមានសមាមាត្រទៅនឹងថ្លៃដើមដែលត្រូវបានទូទាត់។

ជំនួយពន្យាដែលទាក់ទងនឹងថ្លៃដើមរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ផ្តល់ដោយម្ចាស់ជំនួយត្រូវបានទទួលស្គាល់តាមថ្លៃដើមដែលទទួលបាន។ ជំនួយពន្យា ត្រូវបានចាត់ថ្នាក់ជាបំណុលរយៈវែង និងត្រូវកត់ត្រាជាចំណូល នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងរបាយការណ៍លម្អិតផ្សេងៗ តាមវិធីរំលស់ថេរ ដើម្បីផ្គូរផ្គង់នឹងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មនោះ។

អត្ថប្រយោជន៍នៃឥណទានរបស់រដ្ឋាភិបាល តាមអត្រាប្តូររូបិយប័ណ្ណក្រោមតម្លៃទីផ្សារ ឧទាហរណ៍បម្រែបម្រួលរវាងតម្លៃរូបិយប័ណ្ណរបស់ឥណទាន (Special Drawing Right) និងរូបិយប័ណ្ណនៃការទូទាត់សងរបស់ រ.ទ.ស.ភ ("រៀល") ត្រូវបានចាត់ទុកជាជំនួយពន្យារបស់រដ្ឋាភិបាល។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.១៣ បន្ទុកលើប្រាក់កម្ចី

បន្ទុកលើប្រាក់កម្ចី គឺជាការប្រាក់ និងថ្លៃដើមផ្សេងទៀតដែល រ.ទ.ស.ភ មួយកើតឡើង ដែលជាប់ទាក់ទិននិងការខ្ចីមូលនិធិ។

បន្ទុកលើប្រាក់កម្ចីដែលមិនចូលរួមដោយផ្ទាល់ក្នុងការទិញ ការសាងសង់ ឬការផលិតនៃទ្រព្យសកម្មមិនទាន់ពេញលក្ខណៈ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

បន្ទុកលើប្រាក់កម្ចីដែលមិនចូលរួមដោយផ្ទាល់ក្នុងការទិញ ការសាងសង់ ឬការផលិតនៃទ្រព្យសកម្មមិនទាន់ពេញលក្ខណៈ គឺទ្រព្យសកម្មដែលត្រូវការពេលវេលាច្រើនជាចាំបាច់ ដើម្បីត្រៀមខ្លួនរួចរាល់សម្រាប់ប្រើប្រាស់ ឬលក់ ត្រូវធ្វើមូលធនកម្មបន្ទុក ដែលជាផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មនោះរហូតដល់ពេលដែលទ្រព្យសកម្មនោះរួចរាល់ សម្រាប់គោលបំណងប្រើប្រាស់ ឬការលក់។

រ.ទ.ស.ភ ត្រូវចាប់ផ្តើមធ្វើមូលធនកម្មបន្ទុកលើប្រាក់កម្ចី នៅពេលដែល រ.ទ.ស.ភ កើតមានចំណាយសម្រាប់ទ្រព្យសកម្ម កើតឡើងបន្ទុកលើប្រាក់កម្ចី និងអនុវត្តសកម្មទាំងឡាយដែលចាំបាច់ ដើម្បីរៀបចំទ្រព្យសកម្ម សម្រាប់គោលបំណងប្រើប្រាស់ ឬការលក់។

### ៣.១៤ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលក្នុងរបាយការណ៍ចំណេញ ឬខាត រួមមានពន្ធក្នុងគ្រា និងពន្ធពន្យារ។ ពន្ធក្នុងគ្រា និងពន្ធពន្យារ ត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែវាទាក់ទងនឹងការរួមបញ្ចូលអាជីវកម្ម ឬធាតុដែលទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬរបាយការណ៍លទ្ធផលលំអិតផ្សេងៗ។

#### (ក) ពន្ធក្នុងគ្រា

ពន្ធក្នុងគ្រា គឺជាពន្ធដែលរំពឹងទុកដែលត្រូវបង់ ឬអាចទទួលបានលើប្រាក់ចំណេញពន្ធ ឬខាតពន្ធ សម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុដោយប្រើប្រាស់អត្រាពន្ធដែលត្រូវបានអនុម័ត ឬត្រូវបានអនុម័តនៅចុងគ្រារាយការណ៍ និងការធ្វើនិយ័តកម្មពន្ធដែលត្រូវបង់នៅឆ្នាំហិរញ្ញវត្ថុមុន។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ** (**ត**)

៣. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (**ត**)

៣.១៤ **ពន្ធលើប្រាក់ចំណូល (ត)**

(ខ) **ពន្ធពន្យា**

ពន្ធពន្យារត្រូវបានទទួលស្គាល់ ដោយប្រើវិធីសាស្ត្របំណុលលើភាពខុសគ្នាបណ្តោះអាសន្ន នៅចុងការិយបរិច្ឆេទនៃការរាយការណ៍រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និង តម្លៃយោងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ បំណុលពន្ធពន្យារត្រូវបានទទួល ស្គាល់ជាទូទៅចំពោះភាពខុសគ្នាបណ្តោះអាសន្នដែលជាប់ពន្ធ។ ទ្រព្យសកម្មពន្ធពន្យារ ត្រូវ បានទទួលស្គាល់ជាទូទៅរាល់ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន ការខាត បង់ពន្ធដែលមិនទាន់បានប្រើប្រាស់ និងឥណទានពន្ធដែលមិនទាន់បានប្រើប្រាស់ក្នុង កម្រិត ដែលអាចនឹងទទួលបានការកាត់កងប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។

ពន្ធពន្យារមិនត្រូវបានទទួលស្គាល់ទេ ប្រសិនបើភាពខុសគ្នាបណ្តោះអាសន្នកើតឡើងពីការ ទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម និងបំណុល នៅក្នុងប្រតិបត្តិការដែលមិនមែនជាការរួម បញ្ចូលអាជីវកម្ម និងមិនប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធ និងប្រាក់ចំណេញ គណនេយ្យ។ លើសពីនេះទៀត បំណុលពន្ធពន្យារមិនត្រូវបានទទួលស្គាល់ទេ ប្រសិនបើ ភាពខុសគ្នាបណ្តោះអាសន្នកើតឡើងពីការទទួលស្គាល់ដំបូងនៃមូលនិធិពាណិជ្ជកម្ម។

តម្លៃយោងនៃទ្រព្យសកម្មពន្ធពន្យារ ត្រូវបានត្រួតពិនិត្យឡើងវិញរាល់គ្រារាយការណ៍ នីមួយៗ និងកាត់បន្ថយនៅកម្រិតដែលអាចទៅរួច ដែលថាប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ នឹងអាចមានដើម្បីអោយអត្ថប្រយោជន៍មួយផ្នែក ឬទាំងអស់នៃទ្រព្យសកម្មពន្ធពន្យារអាច ត្រូវបានប្រើប្រាស់។ ទ្រព្យសកម្មពន្ធពន្យារដែលត្រូវបានឈប់ទទួលស្គាល់ត្រូវវាយតម្លៃ ឡើងវិញ នៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ និងត្រូវទទួលស្គាល់ក្នុងកម្រិតដែល ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលនឹងអនុញ្ញាតឱ្យទ្រព្យសកម្មពន្ធពន្យារត្រូវបាន ប្រើប្រាស់។

ពន្ធពន្យារត្រូវបានវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវអនុវត្តក្នុងរយៈពេលដែល ទ្រព្យសកម្ម ត្រូវបានលក់ ឬបំណុលត្រូវបានទូទាត់ផ្អែកលើអត្រាពន្ធ និងច្បាប់ពន្ធដែលត្រូវ បាន អនុម័ត ឬ ត្រូវបានអនុម័តជាក់ស្តែងនាគ្រារាយការណ៍។

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.១៤ ពន្ធលើប្រាក់ចំណូល (ត)

#### (ខ) ពន្ធពន្យា (ត)

ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារត្រូវកាត់កង ប្រសិនបើមានសិទ្ធិអនុវត្តតាមច្បាប់ក្នុងការកាត់កងទ្រព្យសកម្មពន្ធពន្យារបច្ចុប្បន្នជាមួយនឹងបំណុលពន្ធបច្ចុប្បន្ន និងនៅពេលពួកវាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ដែលកំណត់ដោយអាជ្ញាធរពន្ធតែមួយលើអង្គភាពជាប់ពន្ធតែមួយ ឬលើអង្គភាពពន្ធផ្សេងៗប៉ុន្តែពួកគេមានគោលបំណងទូទាត់ពន្ធលើប្រាក់ចំណូលដែលត្រូវទទួល និងពន្ធលើប្រាក់ចំណូលដែលត្រូវបង់ ផ្អែកលើមូលដ្ឋានសុទ្ធ ឬទ្រព្យសកម្ម និងបំណុល ជាប់ពន្ធ នឹងត្រូវបានទទួលស្គាល់ក្នុងពេលដំណាលគ្នា។

### ៣.១៥ ចំណេញក្នុងមួយភាគហ៊ុន

រ.ទ.ស.ភ បានបង្ហាញគោល និងថយចុះចំណេញក្នុងមួយភាគហ៊ុន សម្រាប់ភាគហ៊ុនធម្មតា។ មូលដ្ឋានចំណេញក្នុងមួយភាគហ៊ុន ត្រូវបានគិតដោយបែងចែកប្រាក់ចំណេញ ឬខាត ដែលផ្តល់ទៅម្ចាស់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ តាមវិធីសាស្ត្រមធ្យមនៃចំនួនភាគហ៊ុនធម្មតាដែលមានក្នុងអំឡុងការិយបរិច្ឆេទ ដោយកែសម្រួលភាគហ៊ុនផ្ទាល់ខ្លួនដែលកាន់កាប់។
ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានកំណត់ដោយការកែតម្រូវលើចំណេញ ឬខាតដែលកំណត់ឱ្យភាគហ៊ុនិកធម្មតា និងវិធីសាស្ត្រមធ្យមនៃចំនួនភាគហ៊ុនធម្មតាដែលមាន ត្រូវកែតម្រូវសម្រាប់ភាគហ៊ុនរបស់ខ្លួន សម្រាប់ផលប៉ះពាល់ភាគហ៊ុនធម្មតាថយចុះដែលមានសក្តានុពល។

### ៣.១៦ ចំណែកនៃប្រតិបត្តិការ

ចំណែកនៃប្រតិបត្តិការត្រូវបានរាយការណ៍ក្នុងលក្ខណៈមួយ ដែលស្របជាមួយនឹងរបាយការណ៍ផ្ទៃក្នុងដែលបានផ្តល់ដោយប្រធានផ្នែកប្រតិបត្តិការ។ អគ្គនាយក រ.ទ.ស.ភ ដែលជាអ្នកទទួលខុសត្រូវក្នុងការបែងចែកធនធាន និងវាយតម្លៃការអនុវត្តនៃចំណែកនៃប្រតិបត្តិការ ត្រូវបានគេកំណត់ថាជាអ្នកធ្វើការសម្រេចចិត្តលើប្រតិបត្តិការយុទ្ធសាស្ត្រនានា។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ** (ត)

## ៣. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៣.១៧ ការវាស់វែងតម្លៃសមស្រប

តម្លៃសមហេតុផលនៃទ្រព្យ ឬបំណុលលើកលែងតែប្រតិបត្តិការភតិសន្យាត្រូវបានកំណត់ជាថ្លៃដែលនឹងត្រូវទទួលដើម្បីលក់ទ្រព្យសម្បត្តិ ឬបង់ដើម្បីផ្ទេរបំណុលក្នុងប្រតិបត្តិការដែលមានសណ្តាប់ធ្នាប់រវាងអ្នកចូលរួមទីផ្សារនៅកាលបរិច្ឆេទវាស់វែង។ ការវាស់វែងនេះ សន្មតថា ប្រតិបត្តិការដើម្បីលក់ទ្រព្យសម្បត្តិ ឬផ្ទេរការទទួលខុសត្រូវកើតឡើងទាំងនៅក្នុងទីផ្សារគោល ឬក្នុងករណីគ្មានទីផ្សារសំខាន់នៅក្នុងទីផ្សារដែលមានគុណសម្បត្តិច្រើនបំផុត។

ចំពោះទ្រព្យសម្បត្តិមិនមែនហិរញ្ញវត្ថុ ការវាស់តម្លៃសមស្របត្រូវគិតគូរពីសមត្ថភាពរបស់អ្នកចូលរួមក្នុងទីផ្សារក្នុងការបង្កើតអត្ថប្រយោជន៍សេដ្ឋកិច្ចដោយប្រើទ្រព្យនោះក្នុងការប្រើប្រាស់ខ្ពស់បំផុត និងល្អបំផុត ឬដោយលក់វាទៅអ្នកចូលរួមទីផ្សារផ្សេងទៀតដែលប្រើទ្រព្យសម្បត្តិនោះខ្ពស់បំផុត និងល្អបំផុត។

នៅពេលវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល រ.ទ.ស.ភត្រូវប្រើទិន្នន័យអង្កេតទីផ្សារដែលមាន។ តម្លៃសមស្រប ត្រូវបានចាត់ថ្នាក់ទៅតាមកម្រិតខុសគ្នាតាមឋានុក្រមតម្លៃសមស្របដោយផ្អែកលើការប្រើប្រាស់បច្ចេកទេសវាយតម្លៃដូចខាងក្រោម៖

កម្រិត ១៖ ការស្រង់ថ្លៃ (មិនបានកែតម្រូវ) ក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែល រ.ទ.ស.ភអាចទទួលបាននៅការិយបរិច្ឆេទវាស់វែង។

កម្រិត ២៖ ធាតុចូលជាជាងការស្រង់ថ្លៃមានក្នុងកម្រិត ១ ដែលត្រូវបានអង្កេតសម្រាប់ទ្រព្យសកម្ម ឬបំណុលទាំងផ្ទាល់ ឬមិនផ្ទាល់។

កម្រិត ៣៖ ធាតុចូលមិនអាចអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល។

រ.ទ.ស.ភទទួលស្គាល់ការផ្ទេររវាងតាមកម្រិតខុសគ្នា តាមឋានុក្រមតម្លៃសមស្របការិយបរិច្ឆេទនៃព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរស្ថានភាពដែលបណ្តាលឱ្យមានការផ្ទេរ។

## ៤. ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត គណនេយ្យសំខាន់ៗ

ចំនុចសំខាន់នៃការប៉ាន់ស្មាន ភាពមិនច្បាស់លាស់ និងការវិនិច្ឆ័យសំខាន់ក្នុងការអនុវត្តតាមគោលនយោបាយគណនេយ្យដែលមានផលប៉ះពាល់ខ្លាំងក្នុងការកំណត់ចំនួន ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

### ៤.១ ការកំណត់រូបិយប័ណ្ណមុខងារ

រ.ទ.ស.ភ ប្រតិបត្តិការក្នុងប្រទេសកម្ពុជា និងធ្វើប្រតិបត្តិការទិញ និងប្រតិបត្តិការផ្សេងៗជារូបិយប័ណ្ណជាច្រើន។ ការវិនិច្ឆ័យត្រូវបានអនុវត្តក្នុងការកំណត់រូបិយប័ណ្ណមុខងារ នៅពេលដែលមានសូចនាករជារួម។ រ.ទ.ស.ភ ប្រើឋានុក្រម សូចនាករនៃការលក់ ដែលជាមូលដ្ឋានចម្បង បន្ទាប់មកដោយការទិញ និងសូចនាករនៃចំណាយប្រតិបត្តិការ និងករណីដែលសូចនាករទាំងនោះ មិនមានការសន្និដ្ឋានលើរូបិយប័ណ្ណកម្ម៏ និងមូលនិធិផ្សេងទៀតត្រូវបានលើកឡើងសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការ។

### ៤.២ រំលស់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

ដូចមានបង្ហាញក្នុងកំណត់សម្គាល់ ៣.៣ រ.ទ.ស.ភបានពិនិត្យតម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់នៅចុងគ្រារាយការណ៍នីមួយៗ។ ការប៉ាន់ស្មានត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសវិធីសាស្ត្ររំលស់អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់។ ការប្រើប្រាស់ជាក់ស្តែងនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ អាចខុសគ្នាពីការប៉ាន់ស្មានដែលបានប្រើប្រាស់ ដូចនេះរំលស់នាពេលអនាគតអាចត្រូវបានកែតម្រូវឡើងវិញ។

តម្លៃយោងរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខាររបស់ រ.ទ.ស.ភ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៥ នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ៤.៣ ការបន្ថែមដើមទុនពីម្ចាស់ភាគហ៊ុន

នៅពេលដែលម្ចាស់ភាគហ៊ុន បានបន្ថែមទ្រព្យសកម្ម បំណុល និងមូលធននៃប្រតិបត្តិការរោងចក្រផលិតទឹកស្អាតខេត្តត្បូងឃ្មុំ (ហៅកាត់ថា គម្រោងខេត្តត្បូងឃ្មុំ) និងទ្រព្យសកម្មនៃអង្គភាពរដ្ឋាករទឹកខេត្តព្រះសីហនុ ឱ្យ រ.ទ.ស.ភ ការវិនិច្ឆ័យត្រូវបានអនុវត្តថាតើ ប្រតិបត្តិការគួរកត់ត្រាជាការរួមបញ្ចូលគ្នានៃអាជីវកម្មតែមួយ ឬទ្រព្យសកម្មផ្សេងដែលបន្ថែមដោយម្ចាស់ភាគហ៊ុន។ ដើម្បីធ្វើការវិនិច្ឆ័យ រ.ទ.ស.ភ បានវាយតម្លៃ ទ្រព្យសកម្ម បំណុល ប្រតិបត្តិការ និងដំណើរការ ដែលជាកម្មវត្ថុនៃប្រតិបត្តិការប្រឆាំងនឹងនិយមន័យនៃអាជីវកម្មនៅក្នុង ស.រ.ហ.អ.ក ៣ ការរួមបញ្ចូលគ្នានៃអាជីវកម្មតែមួយ។

## ៤. ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត គណនេយ្យសំខាន់ៗ (ត)

### ៤.៣ ការបន្ថែមដើមទុនពីម្ចាស់ភាគហ៊ុន (ត)

ក្នុងការកត់ត្រាគំរោងត្បូងឃ្មុំ និងទ្រព្យសកម្មនៃអង្គភាពរដ្ឋាករទឹកខេត្តព្រះសីហនុ តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលដែលអាចកំណត់អត្តសញ្ញាណប្រើប្រាស់ ត្រូវបានទទួលស្គាល់។ ការកំណត់តម្លៃសមស្របនៃការបន្ថែមទ្រព្យសកម្ម និងបំណុល គឺផ្អែកលើការវិនិច្ឆ័យរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ការផ្លាស់ប្តូរណាមួយនៅក្នុងការសន្មតទាំងនេះនឹងមានផលប៉ះពាល់នៃតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលដែលបានបន្ថែម។

តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុល ត្រូវបានបង្ហាញនៅកំណត់សម្គាល់ ១៣(គ) នៃរបាយ-ការណ៍ហិរញ្ញវត្ថុ។

### ៤.៤ ឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មកិច្ចសន្យា

សំវិធានធនឱនភាពតម្លៃសំរាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មកិច្ចសន្យា គឺផ្អែកលើការសន្មតពីហានិភ័យនៃការខកខានមិនបានទូទាត់សង និងអត្រាការខាតបង់ឥណទានរំពឹងទុក។ រ.ទ.ស.ភ ប្រើប្រាស់ការវិនិច្ឆ័យក្នុងការធ្វើការសន្មត និងជ្រើសរើសធាតុចូលក្នុងការគណនាឱនភាពតម្លៃដោយផ្អែកលើប្រវត្តិរបស់ រ.ទ.ស.ភ ស្ថានភាពទីផ្សារបច្ចុប្បន្ន ក៏ដូចជាការប៉ាន់ស្មាននាពេលខាងមុខនៅចុងគ្រារបាយការណ៍នីមួយៗ។

ពត៌មានអំពីការខាតបង់នៃឱនភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មកិច្ចសន្យារបស់ រ.ទ.ស.ភ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៣១(ខ)(១) នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ៤.៥ ការទទួលស្គាល់ចំណូលទាក់ទងនឹងចំណូលពីថ្លៃទឹកបង្គរ

ចំណូលថ្លៃទឹកបង្គរត្រូវបានទទួលស្គាល់ដោយផ្អែកលើបរិមាណទឹកផលិត បរិមាណទឹកដែលបានចេញវិក័យបត្រ បរិមាណទឹកបាត់បង់ជាមធ្យម និងពន្ធជាមធ្យមតាមប្រភេទអតិថិជន។ ក្រុមប្រឹក្សាភិបាលប្រើប្រាស់ស្ថិតិនៃអត្រាបរិមាណទឹកបាត់បង់ និងពន្ធជាមធ្យមដោយផ្អែកលើបទពិសោធន៍កន្លងមកដែលមិនអាចឆ្លុះបញ្ចាំងពីអត្រាពិតប្រាកដ និងស្ថានភាពនាពេលបច្ចុប្បន្នឱ្យបានត្រឹមត្រូវនោះឡើយ។

### ៤.៦ ការទទួលស្គាល់ចំណូលទាក់ទងនឹងកម្រៃពីការផ្តល់សេវាសាងសង់

រ.ទ.ស.ភ ទទួលស្គាល់កម្រៃពីការផ្តល់សេវាកម្មសាងសង់ និងចំណាយក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើប្រាស់ដំណើរការបញ្ចប់នៃកិច្ចសន្យាកាតព្វកិច្ច។ ដំណើរការបញ្ចប់នៃកិច្ចសន្យាកាតព្វកិច្ច ត្រូវកំណត់ដោយសមាមាត្រនៃថ្លៃដើមសំណង់ដែលកើតឡើងលើការងារដែលបានបំពេញមកទល់បច្ចុប្បន្ន ជាមួយនឹងថ្លៃដើមសាងសង់ដែលរំពឹងទុក។

## ៤. ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត គណនេយ្យសំខាន់ៗ (ត)

### ៤.៦ ការទទួលស្គាល់ចំណូលទាក់ទងនឹងកម្រៃពីការផ្តល់សេវាសាងសង់ (ត)

ការវិនិច្ឆ័យសំខាន់ៗត្រូវបានធ្វើឡើង ដើម្បីកំណត់ដំណើរការបញ្ចប់នៃកិច្ចសន្យាកាតព្វកិច្ច វិសាលភាពនៃថ្លៃដើមសាងសង់ដែលបានកើតឡើង ការប៉ាន់ប្រមាណនៃចំណូល និងចំណាយពីការសាងសង់ ក៏ដូចជាការទទួលបានមកវិញនៃគម្រោងសាងសង់។ ដើម្បីធ្វើការវិនិច្ឆ័យ រ.ទ.ស.ភ ធ្វើការវាយតម្លៃដោយផ្អែកលើបទពិសោធន៍កន្លងមក។

### ៤.៧ ការវាស់វែងពន្ធលើប្រាក់ចំណូល

ការវិនិច្ឆ័យសំខាន់គឺចាំបាច់ក្នុងការកំណត់ការប៉ាន់ស្មានពន្ធក្នុងគ្រា និងពន្ធពន្យារ ព្រោះបំណុលពន្ធចុងក្រោយសម្រាប់ រ.ទ.ស.ភ មិនមានភាពច្បាស់លាស់។ នៅពេលដែលលទ្ធផលចុងក្រោយនៃពន្ធដែលត្រូវបានកំណត់ដោយអាជ្ញាធរពន្ធដារ ទឹកប្រាក់បង់ពន្ធនេះអាចខុសគ្នាពីការប៉ាន់ស្មានដំបូងនៃប្រាក់ពន្ធដែលត្រូវបង់។ ចំនួនដែលខុសគ្នានោះអាចមានផលប៉ះពាល់លើពន្ធក្នុងគ្រាពន្ធពន្យា និងពន្ធមិនផ្ទាល់ក្នុងគ្រា ដែលបានកំណត់។ រ.ទ.ស.ភ នឹងធ្វើនិយ័តកម្មពន្ធក្នុងគ្រា ឬពន្ធពន្យារដែលពាក់ព័ន្ធនឹងឆ្នាំមុនក្នុងគ្រាបច្ចុប្បន្នលើភាពខុសគ្នាទាំងនោះ។

ចំណាយពន្ធលើប្រាក់ចំណូលរបស់ រ.ទ.ស.ភ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២៧ នៃរបាយការណ៍ហិរញ្ញវត្ថុ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីធ្លី ពាន់រៀល | អគារ ពាន់រៀល | គ្រឿងចក្រ ពាន់រៀល | បំពង់បង្ហូរទឹក ពាន់រៀល | បរិក្ខារមន្ទីរពិសោធន៍ ពាន់រៀល | គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ ពាន់រៀល | បរិក្ខារអគ្គិសនី ពាន់រៀល | យានយន្ត ពាន់រៀល | វ៉ាននិងឧបករណ៍ ពាន់រៀល | នាឡិកាទឹក ពាន់រៀល | បណ្តាញតចូលផ្ទះ ពាន់រៀល | ការងារកំពុងដំណើរការ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១៧៦.៥៧៦.១៥៥ | ៤១៤.៧៥២.២៣០ | ១៣៤.៧៨៧.២២១ | ៧០១.០៩៦.៧៨៥ | ២.៩៣៨.៥០៤ | ២៥.២៩២.២១៨ | ១៦៣.៥៩៣.៦៨០ | ៤៩.៧៥០.៣៩០ | ៣៩.៧៧៣.២៦៨ | ១២.៨០៤.០០២ | ២៤.១១៥.០៣១ | ៦៩៣.៣៤៣.៥២៤ | ២.៤៣៨.៨២៣.០០៨ |
| ការទិញបន្ថែម | - | ៤៣.០៤៨ | ៨៩.៣៧៥ | - | - | ២.៩៥៧.៣៤៣ | ៨២.៤៨៣ | ១៥២.១៦៩ | ២៥០.៥១៥ | ៣.៤៥១ | - | ២៨៣.៥៤៦.៤២៨ | ២៨៧.១២៤.៨១២ |
| ការផ្ទេរ | - | ១.១៩១.៥៩២ | ១.៣៨៦.១៦០ | ២៣.០២០.០៤៧ | - | - | ២៧៩.៧៨៤ | - | ៧៦២.៨៥៥ | ៧៣២.៣៤០ | ៦.២៧៩.០០២ | (៣៣.៦៥១.៧៨០) | - |
| ការផ្ទេរទៅទ្រព្យសកម្មអរូបី | - | - | - | - | - | - | - | - | - | - | - | (១.១២៥.០០០) | (១.១២៥.០០០) |
| ការផ្ទេរពីសន្និធិ | - | - | ១.២៣៦.០៧៣ | - | ១៨៥.១៩៦ | - | ៧១៥.៦៤៣ | ៣៣.១២១ | ៤.៦៥២.៦៥០ | ៤០.៤៩៣ | - | ៧៣.៩១២.០៧២ | ៨០.៧៧៥.២៤៩ |
| ការជំរះចេញពីបញ្ជី | - | - | - | - | - | - | - | - | - | - | - | (១៣៦.៨៣៩) | (១៣៦.៨៣៩) |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២២ | ១៧៦.៥៧៦.១៥៥ | ៤១៥.៩៨៦.៨៧០ | ១៣៧.៤៩៨.៨២៩ | ៧២៤.១១៦.៨៣២ | ៣.១២៣.៧០០ | ២៨.២៤៩.៥៦១ | ១៦៤.៦៧១.៥៩០ | ៤៩.៩៣៥.៦៨០ | ៤៥.៤៣៩.២៨៨ | ១៣.៥៨០.២៨៦ | ៣០.៣៩៤.០៣៣ | ១.០១៥.៨៨៨.៤០៥ | ២.៨០៥.៤៦១.២៣០ |
| **រំលស់បង្គរ** | | | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | - | ៨៤.៩១៥.២៤២ | ៦៥.២២២.០៤៤ | ២០៩.៣៩៦.០៣៨ | ៨៤៣.៣៩៨ | ១៦.៨៣៧.៧២៣ | ៩៩.៤០៣.៥៥៩ | ៣៨.២៨៥.៥៩០ | ១៨.៤៥៨.១០១ | ៧.៧៣៤.០៥៣ | ៣.៨៦២.៦៤១ | - | ៥៤៤.៩៥៨.៣៨៩ |
| រំលស់ក្នុងគ្រា | - | ៨.៨៨០.៥២៩ | ៧.៤៤០.៦១៣ | ១៩.២៤០.២០៧ | ៣៥១.១០១ | ២.៣៨៣.៨៣២ | ៧.៩៨២.០៣៦ | ៣.៤១៤.២១៨ | ៣.៧៣២.៨៣៤ | ១.៧៨៣.២៤០ | ២.២៥២.៣១៨ | - | ៥៧.៤៦០.៩២៧ |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២២ | - | ៩៣.៧៩៥.៧៧១ | ៧២.៦៦២.៦៥៧ | ២២៨.៦៣៦.២៤៥ | ១.១៩៤.៤៩៩ | ១៩.២២១.៥៥៥ | ១០៧.៣៨៥.៥៩៥ | ៤១.៦៩៩.៨០៨ | ២២.១៩០.៩៣៥ | ៩.៥១៧.២៩៣ | ៦.១១៤.៩៥៩ | - | ៦០២.៤១៩.៣១៦ |
| **តម្លៃយោង** | | | | | | | | | | | | | |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២២ | ១៧៦.៥៧៦.១៥៥ | ៣២២.១៩១.០៩៨ | ៦៤.៨៣៦.១៧២ | ៤៩៥.៤៨០.៥៨៨ | ១.៩២៩.២០១ | ៩.០២៨.០០៦ | ៥៧.២៨៥.៩៩៥ | ៨.២៣៥.៨៧២ | ២៣.២៤៨.៣៥៣ | ៤.០៦២.៩៩៤ | ២៤.២៧៩.០៧៤ | ១.០១៥.៨៨៨.៤០៥ | ២.២០៣.០៤១.៩១៤ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | ដីធ្លី<br>ពាន់រៀល | អគារ<br>ពាន់រៀល | គ្រឿងចក្រ<br>ពាន់រៀល | បំពង់បង្ហូរទឹក<br>ពាន់រៀល | បរិក្ខារមន្ទីរពិសោធន៍<br>ពាន់រៀល | គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ<br>ពាន់រៀល | បរិក្ខារអគ្គិសនី<br>ពាន់រៀល | យានយន្ត<br>ពាន់រៀល | រ៉ាននិងឧបករណ៍<br>ពាន់រៀល | នាឡិកាទឹក<br>ពាន់រៀល | បណ្តាញតចូលផ្ទះ<br>ពាន់រៀល | ការងារកំពុងដំណើរការ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ១៧៤.២៣៨.៣៨១ | ៣៣៣.៤៥៣.១០២ | ១០៥.៧៥៣.៧៤៣ | ៦៤៥.៨២០.០១០ | ៨៤៩.៣៨៧ | ២៣.១១៥.០៣២ | ១៥១.២៥៦.០៧១ | ៤៥.៨៧៨.៩២២ | ២៧.៦៣៧.៥៩៤ | ៩.៥២៦.៧៧៩ | ១៧.៤៧៤.៦៣០ | ៥៤០.៣៦៥.៦៩៤ | ២.០៧៥.៣៦៩.៣៤៥ |
| ការទិញបន្ថែម | - | ១១៧.៨៩៨ | ២.៤០៤.៣៥៥ | - | ៣៤៨.២៩៤ | ២.៨០១.៥៦៣ | ១.៣៧៧.៤៨២ | ៣.២៧៧.៥១៧ | ២.០៣៦.០០០ | ១៥.២៣៥ | - | ២៨១.៧៣៧.០៧០ | ២៩៤.១១៥.៤១៤ |
| ការទិញដោយការបន្ថែមដើមទុន (កំណត់សម្គាល់ ១៣(គ)) | ២.៣៣៧.៧៧៤ | ៣១.១៩៩.១៤០ | ៥.១៨៨.០៨៩ | ២៨.៩០០.៣៣០ | ១.០០៧.៤៣៣ | ១២៨.២៧៦ | ៣.២៥៣.២០៧ | - | ៦.១៩៦.២៥៤ | ៥.៧៧៤ | ២៥.៩៨៣ | - | ៧៨.១៩២.២៦០ |
| ការផ្ទេរ | - | ៥៩.៨០០.០៣៦ | ២៣.៤៥០.៥៨៨ | ២៦.៦០០.៩៦២ | ៧៦៥.៧៨៩ | ៦៦.០១៣ | ១០.១៩០.៩៧៨ | ១.០៧៩.១២៤ | ៣.៩៧៦.៩៥៥ | ៣.២៥៦.២១៤ | ៦.៦១៤.៤១៨ | (១៣៥.៨០១.០៧៧) | - |
| ការផ្ទេរទៅទ្រព្យសកម្មអរូបី | - | - | - | - | - | - | - | - | - | - | - | (១៦.៤៣១) | (១៦.៤៣១) |
| ការផ្ទេរពីសន្និធិ | - | - | - | - | - | - | - | - | - | - | - | ៧.២១២.៤៤៦ | ៧.២១២.៤៤៦ |
| ការជំរះចេញពីបញ្ជី | - | (៩.៧៦៧.៩៤៦) | (២.០០៩.៥៥៤) | (២២៤.៥១៧) | (៣២.៣៩៩) | (៨១៨.៦៦៦) | (២.៤៨៤.០៥៨) | (៤៨៥.១៧៣) | (៧៣.៥៣៥) | - | - | (១៥៤.១៧៨) | (១៦.០៥០.០២៦) |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២១ | ១៧៦.៥៧៦.១៥៥ | ៤១៤.៧៥២.២៣០ | ១៣៤.៧៨៧.២២១ | ៧០១.០៩៦.៧៨៥ | ២.៩៣៨.៥០៤ | ២៥.២៩២.២១៨ | ១៦៣.៥៩៣.៦៨០ | ៤៩.៧៥០.៣៩០ | ៣៩.៧៧៣.២៦៨ | ១២.៨០៤.០០២ | ២៤.១១៥.០៣១ | ៦៩៣.៣៤៣.៥២៤ | ២.៤៣៨.៨២៣.០០៨ |
| **រំលស់បង្គរ** | | | | | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | - | ៨១.៥៩៥.៦៣៦ | ៦០.១៩៣.៥៧៩ | ១៩១.១៧៨.១៣៨ | ៦៧០.៨៦៦ | ១៥.២៦១.៧៥៨ | ៩៤.៣៨៦.២៣៥ | ៣៤.៨៣៧.១៣០ | ១៥.៣៥៩.៦៤៨ | ៦.០៩៨.១៧៩ | ២.១៨៦.០៧៧ | - | ៥០១.៧៦៧.២៤៦ |
| រំលស់ក្នុងគ្រា | - | ៨.០៦៤.២៩៤ | ៦.៧៦១.៤៨៣ | ១៨.៣២២.១៨៤ | ២០៤.៩៣១ | ២.៣៧៦.៨៥៨ | ៧.៣៦៤.០៤៧ | ៣.៩៣៣.៦៣៣ | ៣.១៥២.១២៥ | ១.៦៣៥.៨៧៤ | ១.៦៧៦.៥៦៤ | - | ៥៣.៤៩១.៩៩៣ |
| ការជំរះចេញពីបញ្ជី | - | (៤.៧៤៤.៦៨៨) | (១.៧៣៣.០១៨) | (១០៤.២៨៤) | (៣២.៣៩៩) | (៨០០.៨៩៣) | (២.៣៤៦.៧២៣) | (៤៨៥.១៧៣) | (៥៣.៦៧២) | - | - | - | (១០.៣០០.៨៥០) |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២១ | - | ៨៤.៩១៥.២៤២ | ៦៥.២២២.០៤៤ | ២០៩.៣៩៦.០៣៨ | ៨៤៣.៣៩៨ | ១៦.៨៣៧.៧២៣ | ៩៩.៤០៣.៥៥៩ | ៣៨.២៨៥.៥៩០ | ១៨.៤៥៨.១០១ | ៧.៧៣៤.០៥៣ | ៣.៨៦២.៦៤១ | - | ៥៤៤.៩៥៨.៣៨៩ |
| **តម្លៃយោង** | | | | | | | | | | | | | |
| នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២១ | ១៧៦.៥៧៦.១៥៥ | ៣២៩.៨៣៦.៩៨៨ | ៦៩.៥៦៥.១៧៧ | ៤៩១.៧០០.៧៤៧ | ២.០៩៥.១០៦ | ៨.៤៥៤.៤៩៥ | ៦៤.១៩០.១២១ | ១១.៤៦៤.៨០០ | ២១.៣១៥.១៦៧ | ៥.០៦៩.៩៤៩ | ២០.២៥២.៣៩០ | ៦៩៣.៣៤៣.៥២៤ | ១.៨៩៣.៨៦៤.៦១៩ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

ក្នុងអំឡុងការិយបរិច្ឆេទ រ.ទ.ស.ភ បានធ្វើការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដោយទូទាត់ជាសាច់ប្រាក់ដូចខាងក្រោម៖

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ការទិញបន្ថែម | ២៨៧.១២៤.៨១២ | ២៩៤.១១៥.៤១៤ |
| មូលធនកម្មលើការប្រាក់លើទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | (៥.៥០៥.០៩៦) | (៤.៣៩៨.៤៦៩) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ទូទាត់ជាសាច់ប្រាក់ | ២៨១.៦១៩.៧១៦ | ២៨៩.៧១៦.៩៤៥ |

## ៦. ទ្រព្យសកម្មអរូបី

| | កំណត់សម្គាល់ | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|---|
| **កម្មវិធី** | | | |
| **ថ្លៃដើម** | | | |
| នាថ្ងៃទី១ ខែមករា | | ២៥.០០៧.៩០០ | ២៣.៨៥៨.៤០៧ |
| ការទិញបន្ថែម | | ៣៩០.០៧៥ | ១.១៣៣.០៦២ |
| ការផ្ទេរពីសន្និធិ | | ៣៨.៣៨១ | - |
| ការផ្ទេរពី ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ១.១២៥.០០០ | ១៦.៤៣១ |
| នាថ្ងៃទី៣១ ខែធ្នូ | | ២៦.៥៦១.៣៥៦ | ២៥.០០៧.៩០០ |
| **រំលស់បង្គរ** | | | |
| នៅថ្ងៃទី០១ ខែមករា | | ១២.៤៧៧.៦២២ | ១០.៧៧៥.២០៣ |
| រំលស់ក្នុងឆ្នាំហិរញ្ញវត្ថុ | | ១.៩៩៤.១៤៧ | ១.៧០២.៤១៩ |
| នាថ្ងៃទី៣១ ខែធ្នូ | | ១៤.៤៧១.៧៦៩ | ១២.៤៧៧.៦២២ |
| **តម្លៃយោង** | | | |
| នាថ្ងៃទី៣១ ខែធ្នូ | | ១២.០៨៩.៥៨៧ | ១២.៥៣០.២៧៨ |

## ៧. សន្និធិ

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| បំពង់ និងបរិក្ខារចែកចាយទឹកស្អាត | ១១៧.៩០៥.៥០២ | ១១៤.៧៨៨.៨៦៧ |
| នាឡិកាទឹក | ៩.២១៨.៨៩៤ | ៨.៨១៣.១៣០ |
| គ្រឿងបន្លាស់ និងឧបករណ៍ផ្សេង | ៧.៤៧៤.៣៤០ | ៩.៦៩៤.២៩១ |
| សារធាតុគីមី | ២.០៥៧.០០៤ | ៣៤៨.៥២៨ |
| ធុងទឹក និងកញ្ចប់ផ្សេងៗ | ១០០.២១៦ | ១០០.២១៦ |
| សន្និធិកំពុងដឹកជញ្ជូន* | ៥.៨០៥.០៥២ | ៦២៤.៨២៩ |
| វត្ថុធាតុដើមផ្សេងទៀត | ១០.១៧៦.០៧០ | ៩.៣៦១.៦៤៧ |
| | ១៥២.៧៣៧.០៧៨ | ១៤៣.៧៣១.៥០៨ |

* សន្និធិកំពុងដឹកជញ្ជូន គឺសំដៅដល់បំពង់មេដែលបានមកដល់កំពង់ផែនៃប្រទេសកម្ពុជា។

ថ្លៃដើមនៃសន្និធិរបស់ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ជាចំណាយក្នុងអំឡុងការិយបរិច្ឆេទគឺ ១៧.០៩៤លានរៀល (ឆ្នាំ២០២១៖ ១២.៧០៥លានរៀល)។

## ៨. គណនីអតិថិជនពាណិជ្ជកម្ម និង គណនីត្រូវទទួលផ្សេងៗ

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| **គណនីពាណិជ្ជកម្ម** | | |
| គណនីត្រូវទទួលលក្ខណៈគ្រួសារ | ១.១១៩.៩២៧ | ១.៥៤១.៣៩៣ |
| គណនីត្រូវទទួលលក្ខណៈអាជីវកម្ម | ១.៣០០.៩៥៩ | ១.០៦២.៩០៣ |
| គណនីត្រូវទទួលលក្ខណៈរដ្ឋបាលសាធារណៈ | ១១.៦៧៣.២៨១ | ១២.២០៩.៩៤៧ |
| តំណាងចែកចាយទឹក | ១០៣.៦៤៧ | ៤៤.២១៥ |
| ដក៖ ការខាតបង់លើឱនភាព(គណនីត្រូវទទួលលក្ខណៈគ្រួសារ) | (៥.៥៥៣) | (៥.៥៥៣) |
| | ១៤.១៩២.២៦១ | ១៤.៨៥២.៩០៥ |

## ៨. គណនីអតិថិជនពាណិជ្ជកម្ម និង គណនីត្រូវទទួលផ្សេងៗ (ត)

| | ២០២២ | ២០២១ |
|---|---|---|
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| **មិនមែនគណនីពាណិជ្ជកម្ម** | | |
| ប្រាក់ធានាសំរាប់ប្រតិបត្តិការ | ២.៨៨៧.៧៦៩ | ២.៨៨៧.៧៦៩ |
| ការប្រាក់ត្រូវទទួល | ២.៣០៨.៨៧០ | ១.០០៩.២៩៨ |
| បុរេប្រទានទៅអ្នកផ្គត់ផ្គង់ | ៦៣៦.១៧៣ | ២០៨.៦៦៥ |
| អាករលើតម្លៃបន្ថែមត្រូវទទួល - សុទ្ធ | ១៤៦.៧៤៦ | ៦២៤.២៧១ |
| គណនីត្រូវទទួលផ្សេងៗ | ៨.០៩៣.១២១ | ៥.២៩២.២៥៩ |
| | ១៤.០៧២.៦៧៩ | ១០.០២២.២៦២ |
| | ២៨.២៦៤.៩៤០ | ២៤.៨៧៥.១៦៧ |

(ក) គណនីអតិថិជនពាណិជ្ជកម្មគឺមិនមានការប្រាក់ ហើយលក្ខខណ្ឌឥណទានធម្មតាដែលផ្តល់ដោយ រ.ទ.ស.ភ មាន រយៈពេល ១ខែ (ឆ្នាំ២០២១៖ ១ខែ) និងសំរាប់រដ្ឋបាលសាធារណៈមានរយៈពេល ១ឆ្នាំ (ឆ្នាំ២០២១៖ ១ឆ្នាំ) គិតពីថ្ងៃចេញវិកិយបត្រ។ លក្ខខណ្ឌឥណទានផ្សេងទៀតត្រូវបានវាយតម្លៃ និងអនុម័តតាមករណីជាក់ស្តែង។

<u>គណនីអតិថិជនដែលបានធ្វើឱនភាព</u>

គណនីអតិថិជនពាណិជ្ជកម្មរបស់ រ.ទ.ស.ភ ត្រូវបានធ្វើឱនភាពនៅចុងការិយបរិច្ឆេទរាយការណ៍ និងការផ្ទៀងផ្ទាត់លើការប្រែប្រួលនៃឱនភាពគណនីអតិថិជនពាណិជ្ជកម្មមានដូចខាងក្រោម៖

| | ២០២២ | ២០២១ |
|---|---|---|
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| នាថ្ងៃទី១ ខែមករា/ថ្ងៃទី៣១ ខែធ្នូ | ៥.៥៣៣ | ៥.៥៣៣ |

(ខ) គណនីត្រូវទទួលលក្ខណៈរដ្ឋបាលសាធារណៈ សំដៅលើគណនីត្រូវទទួលពីអង្គភាពរដ្ឋ។

## ៩. ទ្រព្យសកម្មកិច្ចសន្យា ឬ បំណុលកិច្ចសន្យា

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្មកិច្ចសន្យា** | | | |
| ទ្រព្យសកម្មកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ | (ក) | ៣.៥៣៣.៨៩៨ | ៥៣៦.០៥១ |
| ទ្រព្យសកម្មកិច្ចសន្យាទាក់ទងនឹងការលក់ទឹកស្អាត | (ខ) | ៨៩.២៣៤.៤៧៦ | ៦៥.៤៨៨.៥២៩ |
| | | ៩២.៧៦៨.៣៧៤ | ៦៦.០២៤.៥៨០ |
| **បំណុលកិច្ចសន្យា** | | | |
| បំណុលកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ | (គ) | ៤.៤៥៦.៧៥៦ | ១.៧៨៨.៨៩៤ |

(ក) ទ្រព្យសកម្មកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាសេវាសាងសង់ តំណាងឱ្យភាពខុសគ្នានៃពេលវេលាក្នុងការទទួលស្គាល់ចំណូល និងការចេញវិកិយបត្រ។ ការចេញវិកិយបត្រ គឺត្រូវបានកំណត់ និង/ឬ ត្រូវបានចរចាជាមួយ អតិថិជនដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីការបញ្ចប់នៃកិច្ចសន្យា។

(ខ) ទ្រព្យសកម្មកិច្ចសន្យាទាក់ទងនឹងចំណូលថ្លៃទឹក តំណាងឱ្យបរិមាណទឹកដែលបានផ្គត់ផ្គង់ទៅអតិថិជន ប៉ុន្តែមិនទាន់បានចេញវិកិយបត្រនៅចុងការិយបរិច្ឆេទ។ ទ្រព្យសកម្មកិច្ចសន្យាទាំងនេះ ត្រូវបានផ្ទេរទៅគណនីត្រូវទទួលនៅពេលមានសិទ្ធក្នុងការទទួលបានផលប្រយោជន៍សេដ្ឋកិច្ចដោយឥតលក្ខខណ្ឌ ដែលកើតឡើងនៅពេល រ.ទ.ស.ភ ចេញវិកិយបត្រ។

(គ) បំណុលកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាសេវាការសាងសង់ តំណាងឱ្យសាច់ប្រាក់ដែលទទួលបានមុនសំរាប់សេវាការសាងសង់ដែលបានផ្តល់ឱ្យក្នុងការពង្រីកប្រព័ន្ធចែកចាយទឹក ទៅឱ្យអ្នកផ្គត់ផ្គង់ទឹកតាមខេត្ត។ ចំណូល ពន្យា ត្រូវបានទទួលស្គាល់ជាចំណូលនៅពេលកាតព្វកិច្ចប្រតិបត្តិការត្រូវបានបំពេញ។

(ឃ) <u>បម្រែបម្រួលជាសារវន្តនៃសមតុល្យកិច្ចសន្យា</u>

| | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|
| **ទ្រព្យសកម្មកិច្ចសន្យា (ក)** | | |
| នាថ្ងៃទី១ ខែមករា | ៥៣៦.០៥១ | ៤.៨៦១.២៧០ |
| ការកើនឡើងនៃចំណូលទទួលស្គាល់កម្រៃពីការផ្តល់សេវាសាងសង់មិនទាន់ចេញវិកិយបត្រទៅអតិថិជន | ១២.៨០៧.៧១៨ | ១៥.២២០.៥១៥ |
| ការថយចុះនៃវិកិយបត្រដែលបានចេញទៅអតិថិជន | (៩.៨០៩.៨៧១) | (១៩.៥៤៥.៧៣៤) |
| នាថ្ងៃទី៣១ ខែធ្នូ | ៣.៥៣៣.៨៩៨ | ៥៣៦.០៥១ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៩. ទ្រព្យសកម្មកិច្ចសន្យា ឬ បំណុលកិច្ចសន្យា (ត)

(ឃ) <u>បម្រែបម្រួលជាសារវន្តនៃសមតុល្យកិច្ចសន្យា(ត)</u>

| | ២០២២ | ២០២១ |
|---|---|---|
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| **ទ្រព្យសកម្មកិច្ចសន្យា (ខ)** | | |
| នាថ្ងៃទី១ ខែមករា | ៦៥.៤៨៨.៥២៩ | ៣៨.០៦១.២៧៧ |
| ការកើនឡើងនៃចំណូលទទួលស្គាល់សំរាប់ការលក់ទឹកមិនទាន់ចេញវិកិយបត្រទៅអតិថិជន | ៣២០.៥១០.៧២៩ | ៣១០.៧៧៧.០០៨ |
| ការថយចុះនៃវិកិយបត្រដែលបានចេញទៅអតិថិជន | (២៩៦.៧៦៤.៧៨២) | (២៨៣.៣៤៩.៧៥៦) |
| នាថ្ងៃទី៣១ ខែធ្នូ | ៨៩.២៣៤.៤៧៦ | ៦៥.៤៨៨.៥២៩ |
| | | |
| **បំណុលកិច្ចសន្យា** | | |
| នាថ្ងៃទី១ ខែមករា | ១.៧៨៨.៨៩៤ | ៣.៦១៦.៥៦៦ |
| ការកើនឡើងពីបុរេប្រទានដែលទទួលបានពីអតិថិជនប៉ុន្តែចំណូលមិនទាន់បានទទួលស្គាល់ | ២.៦៦៧.៨៦២ | ១.៧៥១.២៥៦ |
| ការថយចុះពីចំណូលដែលបានទទួលស្គាល់សំរាប់ទំនិញនិងសេវាកម្មមិនទាន់ចេញវិកិយបត្រដែលបានផ្ទេរទៅអតិថិជន | - | (៣.៥៧៨.៩២៨) |
| នាថ្ងៃទី៣១ ខែធ្នូ | ៤.៤៥៦.៧៥៦ | ១.៧៨៨.៨៩៤ |

## ១០. ឥណទានផ្តល់ឱ្យបុគ្គលិក

| | ២០២២ | ២០២១ |
|---|---|---|
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| គណនីត្រូវទទួលពីនិយោជិត | ៨.២១៧.៥២៥ | ៨.២១៧.៥២៥ |
| ដក៖ ការខាតបង់ឱនភាព | (២៦០.៨៧៤) | (២៦០.៨៧៤) |
| | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |

## ១០. ឥណទានផ្តល់ឱ្យបុគ្គលិក (ត)

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមប្រឹក្សាភិបាលបានអនុម័តសំណើ ផ្តល់ភាគហ៊ុនអណ្តែត ១០% ទុកបម្រុងសំរាប់និយោជិក រ.ទ.ស.ភ។ ចំនួនភាគហ៊ុនដែលត្រូវបែងចែកទៅនិយោជិតម្នាក់ៗ ត្រូវបានកំណត់នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២។ កាលបរិច្ឆេទនេះត្រូវបានចាត់ទុកជាការថ្ងៃអនុម័តលើគម្រោងភាគហ៊ុនពេលអនាគតដែលបានផ្តល់ឱ្យនិយោជិកម្នាក់ៗ។ កម្ចីដែលបានបង់នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២ សរុបជាទឹកប្រាក់ចំនួន ៨.២១៨ លានរៀល។ រ.ទ.ស.ភ ផ្តល់កម្ចីឥតការប្រាក់ដែលមានលក្ខខណ្ឌ ៣ឆ្នាំសំរាប់និយោជិក និងមន្ត្រីជាន់ខ្ពស់ក្នុងការទិញភាគហ៊ុនទាំងនេះ។ នៅថ្ងៃកំណត់ កម្ចីត្រូវតែសងទៅ រ.ទ.ស.ភ ក្នុងទឹកប្រាក់ពេញលេញ។ តាមរយៈរបាយការណ៍នៃអង្គប្រជុំក្រុមប្រឹក្សាភិបាលកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ និយោជិកត្រូវបានអនុញ្ញាតជួញដូរភាគហ៊ុនរបស់ខ្លួនប្រសិនបើកម្ចីត្រូវបានសង។

កម្ចីនេះមានកាលកំណត់នៅខែមេសា ឆ្នាំ២០១៥។ ប៉ុន្តែ ដោយសារការធ្លាក់ថ្លៃនៃតម្លៃភាគហ៊ុន គណៈគ្រប់គ្រងបានសម្រេចចិត្តធ្វើសំវិធានធនសំរាប់ឱនភាពមកត្រឹមតម្លៃភាគហ៊ុននៅការិយបរិច្ឆេទរាយការណ៍ ដោយផ្អែកលើការរំពឹងទុករបស់គណៈគ្រប់គ្រងលើតម្លៃដែលនឹងកើតជាក់ស្តែង ប្រសិនបើនិយោជិតលក់ភាគហ៊ុនទាំងនេះដើម្បីសង់ប្រាក់កម្ចី។

ក្រុមប្រឹក្សាភិបាល ស្ថិតក្នុងដំណាក់កាលរង់ចាំមតិយោបល់ពីនិយ័តករមូលបត្រកម្ពុជាលើគម្រោងភាគហ៊ុនពេលអនាគតដែលបានផ្តល់ឱ្យនិយោជិកនៅការិយបរិច្ឆេទរាយការណ៍នៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

<u>ឥណទានផ្តល់ឱ្យបុគ្គលិកដែលបានធ្វើឱនភាព</u>

ឥណទានផ្តល់ឱ្យបុគ្គលិករបស់ រ.ទ.ស.ភ ដែលបានធ្វើឱនភាពនៅការិយបរិច្ឆេទរាយការណ៍ និងការផ្ទៀងផ្ទាត់លើបម្រែបម្រួលនៃឱនភាពឥណទានផ្តល់ឱ្យបុគ្គលិកមានដូចខាងក្រោម៖

| | **២០២២**<br>**គិតជាពាន់រៀល** | **២០២១**<br>**គិតជាពាន់រៀល** |
|---|---|---|
| នាថ្ងៃទី១ ខែមករា/៣១ ខែធ្នូ | ២៦០.៨៧៤ | ២៦០.៨៧៤ |

## ១១. ការវិនិយោគរយៈពេលខ្លី

ទាំងនេះតំណាងឱ្យប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុ សម្រាប់រយៈពេលចន្លោះពី ៩ ទៅ១២ខែ (ឆ្នាំ២០២១៖ ៩ ទៅ ១២ខែ) ហើយទទួលបានការប្រាក់ពី ៣.៥០% ទៅ ៥.៧៥% (ឆ្នាំ២០២០៖ ៣.៥០% ទៅ ៤.៧៥%) ក្នុងមួយឆ្នាំ។

## ១២. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| សាច់ប្រាក់ និងសមតុល្យធនាគារ | (ក) | ៤៤.៦៩០.៩១៥ | ៦៨.៣៦៣.៥៣៨ |
| ប្រាក់តម្កល់រយៈពេលខ្លី (កំឡុងពេល ៣ខែ) | (ខ) | ១៦.៤៦៨.០០០ | ២១.២៩៦.០០០ |
| | | ៦១.១៥៨.៩១៥ | ៨៩.៦៥៩.៥៣៨ |

(ក) សមតុល្យធនាគារទទួលបានអត្រាការប្រាក់ចន្លោះពី ០,៥% ទៅ២% (ឆ្នាំ២០២១៖ ០,៥% ទៅ ២%) ក្នុងមួយឆ្នាំ។ នៅក្នុងសាច់ប្រាក់ និងសមតុល្យធនាគារ មានទឹកប្រាក់ចំនួន ៤.៤៤២.៤៧៦.០០០ រៀល (ឆ្នាំ២០២១៖ ២.៧៩៣.៨៨៥.០០០រៀល) ដែលមាននៅរតនាគារជាតិ រតនាគារក្រុងភ្នំពេញ រតនាគារខេត្តត្បូងឃ្មុំ និងរតនាគារខេត្តកណ្តាល ដែលគ្មានគិតការប្រាក់។

(ខ) នេះជាប្រាក់បញ្ញើកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុដែលមានរយៈពេល ៣ខែ (២០២១៖ ៣ខែ) និងទទួលបានការប្រាក់ចន្លោះពី ២,២៥% ទៅ ២,៧៥% (២០២១៖ ១,២៥% ទៅ ២,៧៥%) ក្នុងមួយឆ្នាំ។

## ១៣. ដើមទុន និងបុព្វលាភភាគហ៊ុន

| | កំណត់សម្គាល់ | ចំនួនភាគហ៊ុន | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|---|
| ភាគហ៊ុនធម្មតា | (ក) | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ |
| ភាគហ៊ុនប្រភេទ A | (ខ) | ៣៩១.១០០.៩៤២ | ៣៩១.១០០.៩៤២ | ៣៩១.១០០.៩៤២ |
| បុព្វលាភភាគហ៊ុន | | - | ៦៣.១៥៣.១៧៨ | ៦៣.១៥៣.១៧៨ |
| ទុនបម្រុង | (គ) | - | ៧៩.៥៣១.៨២៥ | ៧៨.០៨៨.៦០៤ |
| | | ៤៧៨.០៧៤.១០៤ | ៦២០.៧៥៩.១០៧ | ៦១៩.៣១៥.៨៨៦ |

### ១៣. ដើមទុននិងបុព្វលាភភាគហ៊ុន (ត)

(ក) នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមប្រឹក្សាភិបាលបានអនុម័តលើការបំបែកដើមទុនដែលមាន ចំនួន ៤៦៥.០២៨.០០០រៀល ទៅជាភាគហ៊ុនធម្មតាចំនួន៧៣.៩២៧.១៨៧ភាគហ៊ុន និងភាគហ៊ុនប្រភេទA ចំនួន៣៩១.១០០.៩៤២ ភាគហ៊ុនដែលមានតម្លៃចារិក ១.០០០រៀលក្នុងមួយហ៊ុន។ ភាគហ៊ុនប្រភេទA ដែលកាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនមានសិទ្ធទទួលបានការប្រាក់ ឬភាគលាភទេ និង ទទួលបានសិទ្ធ និងមានលក្ខខណ្ឌដូចដែលបានរៀបរាប់លម្អិតក្នុងកថាខណ្ឌ ១២.២ នៃលក្ខន្តិកៈរបស់ រ.ទ.ស.ភ ដែលបានចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២។

(ខ) នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានក្លាយជាក្រុមហ៊ុនដំបូងដែលបានចុះបញ្ជីក្នុងផ្សារមូលបត្រ កម្ពុជាដោយជោគជ័យ។ ចំនួនភាគហ៊ុនធម្មតាសរុប មានចំនួន ៨៦.៩៧៣.១៦២ហ៊ុន ដែលមានតម្លៃចារិក ១.០០០រៀលក្នុងមួយហ៊ុន។ ថ្លៃដើមក្នុងការបោះផ្សាយ ១៣.០៤៥.៩៧៥ហ៊ុនដំបូង មានចំនួន ៦.០០០ លានរៀលដែលបានកាត់កងជាមួយបុព្វលាភភាគហ៊ុន។ ភាគហ៊ុនធម្មតាដែលបានបោះផ្សាយទាំងអស់ត្រូវ បានទូទាត់រួច។ ភាគហ៊ុនិកធម្មតាមានដូចខាងក្រោម៖

| | ចំនួនភាគហ៊ុន | % |
|---|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៧៣.៩២៧.១៨៧ | ៨៥% |
| ភាគហ៊ុនិកផ្សេងទៀត | ១១.៧៤១.៦០៦ | ១៤% |
| ភាគហ៊ុននាពេលអនាគតដែលបានផ្តល់ឱ្យនិយោជិក * | ១.៣០៤.៣៦៩ | ១% |
| | ៨៦.៩៧៣.១៦២ | ១០០% |

* យោងតាមរបាយការណ៍នៃអង្គប្រជុំក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ និយោជិកទាំងអស់ត្រូវ បានអនុញ្ញាតឱ្យជួញដូរភាគហ៊ុនរបស់ខ្លួន ប្រសិនបើបំណុលត្រូវបានទូទាត់រួច។

ភាគហ៊ុនធម្មតាទាំងអស់ត្រូវបានធ្វើចំណាត់ថ្នាក់ស្មើៗគ្នាដោយផ្អែកលើទ្រព្យសកម្មនៅសល់របស់ រ.ទ.ស.ភ។

## ១៣. ដើមទុននិងបុព្វលាភភាគហ៊ុន (ត)

(គ) តារាងខាងក្រោមសង្ខេបពីចំនួនទ្រព្យសកម្មដែលបានទទួលស្គាល់ និងបំណុលដែលត្រូវទទួលរងនាថ្ងៃបន្ថែមដើមទុន។

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| សន្និធិ | | ១.៤៤៣.២២១ | - |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | - | ៧៨.១៩២.២៦០ |
| គណនីអតិថិជនពាណិជ្ជកម្ម | | - | ៧២.១៦៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | | - | ១.០៩៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | | - | (១៤៩.៧១៤) |
| ប្រាក់លើកទឹកចិត្តបុគ្គលិកបង្គរ | | - | (២៧.២០០) |
| **ទ្រព្យសកម្មសុទ្ធដែលបានបន្ថែម** | | ១.៤៤៣.២២១ | ៧៨.០៨៨.៦០៤ |

<u>២០២២</u>

នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើនដើមទុនរបស់ខ្លួននៅ រ.ទ.ស.ភ ដោយការបញ្ចូលបន្ថែមនូវសន្និធិទៅក្នុង រ.ទ.ស.ភ ដែលមានទឹកប្រាក់សរុប ១.៤៤៣.២២១.០០០ ដោយគ្មានការបោះផ្សាយភាគហ៊ុនបន្ថែមរបស់ រ.ទ.ស.ភ។

យោងតាមលិខិតលេខ១៣៥០៥ ដែលចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការណែនាំដល់ រ.ទ.ស.ភ អោយកត់ត្រា ការបន្ថែមដើមទុននេះ ទៅជាដើមទុនក្នុង រ.ទ.ស.ភ។

<u>២០២១</u>

នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើនដើមទុនរបស់ខ្លួននៅ រ.ទ.ស.ភ ដោយបញ្ចូលបន្ថែមនូវទ្រព្យសកម្ម បំណុល និងមូលធន របស់ប្រតិបត្តិការរោងចក្រផលិតទឹកស្អាតខេត្តត្បូងឃ្មុំ (ហៅកាត់ថា គម្រោងខេត្តត្បូងឃ្មុំ) ទៅអោយ រ.ទ.ស.ភ ដែលមានចំនួនសរុប ៧៨.០៨៨.៦០៤.០០០រៀល ដោយគ្មានបោះផ្សាយភាគហ៊ុនបន្ថែមរបស់ រ.ទ.ស.ភ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ១៣. ដើមទុននិងបុព្វលាភភាគហ៊ុន (ត)

(គ) តារាងខាងក្រោមសង្ខេបពីចំនួនទ្រព្យសកម្មដែលបានទទួលស្គាល់ និងបំណុលដែលត្រូវទទួលរងនាថ្ងៃបន្ថែមដើមទុន។ (ត)

**<u>២០២១</u> (ត)**

យោងតាមលិខិតលេខ៦២២៨ ស.ហ.វ ដែលចុះនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការណែនាំដល់ រ.ទ.ស.ភ អោយកត់ត្រា ការបន្ថែមដើមទុននេះ ទៅជាដើមទុនក្នុង រ.ទ.ស.ភ។

នៅក្នុងទ្រព្យសកម្ម និងបំណុលដែលបានបន្ថែមដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាថ្ងៃបន្ថែមដើមទុននៃគម្រោងខេត្តត្បូងឃ្មុំ ដែលមានធាតុចូល (រោងចក្រផលិតទឹកស្អាត ចង្វាក់ផលិតកម្ម និងកំលាំងពលកម្ម)។ រ.ទ.ស.ភ បានកំណត់ថា ធាតុចូលបន្ថែម និងចង្វាក់ផលិតកម្មនឹងបង្កើនចំណូលបន្ថែម។ រ.ទ.ស.ភ បានសន្និដ្ឋានថា ការបន្ថែមនេះជាទ្រព្យសកម្មដាច់ដោយឡែក។

ការគ្រប់គ្រងគម្រោងខេត្តត្បូងឃ្មុំនឹងធ្វើឱ្យ រ.ទ.ស.ភ បង្កើនទីផ្សារនៃការផលិតទឹកតាមរយៈការទទួលបានអតិថិជនរបស់គម្រោងខេត្តត្បូងឃ្មុំ។ រ.ទ.ស.ភ ក៏រំពឹងទុកថានឹងកាត់បន្ថយថ្លៃដើមតាមរយៈការចំណេញបរិមាណសេដ្ឋកិច្ចនេះ។

ក្នុងអំឡុងការិយបរិច្ឆេទ គម្រោងខេត្តត្បូងឃ្មុំបន្ថែមចំណូលចំនួន២៩៤.៩៤៤.០០០រៀល។

តម្លៃសមស្របនៃការបន្ថែមដើមទុន ត្រូវបានផ្អែកលើទ្រព្យសកម្មសុទ្ធនៃគម្រោងខេត្តត្បូងឃ្មុំដែលត្រូវបានវាយតម្លៃដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នាថ្ងៃបន្ថែមដើមទុន។

រ.ទ.ស.ភ មិនមានចំណាយលើថ្លៃផ្សេងៗដែលពាក់ព័ន្ធនឹងការបន្ថែមដើមទុននេះទេ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

### ១៤. ទុនបម្រុង

| | ទុនបម្រុង ដើមទុន ពាន់រៀល | ទុនបម្រុង តាមច្បាប់ ពាន់រៀល | ទុនបម្រុងទូទៅ ពាន់រៀល | ទុនបម្រុង សំរាប់ការអភិវឌ្ឍ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ១.៦៤៨.៤៣៥ | ២៧.៧០០.៣៨៥ | ២៧.៧០០.៣៨៥ | ២៩៥.៤២៤.៣២៥ | ៣៥២.៤៧៣.៥៣០ |
| ការផ្ទេរពីចំណេញរក្សាទុក | - | ៤.៤១៧.៥៩២ | ៤.៤១៧.៥៩២ | ៥៦.៧២៩.៦៩៦ | ៦៥.៥៦៤.៨៨០ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ១.៦៤៨.៤៣៥ | ៣២.១១៧.៩៧៧ | ៣២.១១៧.៩៧៧ | ៣៥២.១៥៤.០២១ | ៤១៨.០៣៨.៤១០ |
| ការផ្ទេរពីចំណេញរក្សាទុក | - | ៦.៤៦៣.៦៩៤ | ៦.៤៦៣.៦៩៤ | ១១២.៣០២.២៧៧ | ១២៥.២២៩.៦៦៥ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ១.៦៤៨.៤៣៥ | ៣៨.៥៨១.៦៧១ | ៣៨.៥៨១.៦៧១ | ៤៦៤.៤៥៦.២៩៨ | ៥៤៣.២៦៨.០៧៥ |

(ក) យោងតាមលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌទី៤៤ ការបែងចែកភាគលាភនិងទុនបម្រុងត្រូវបានធ្វើដូចខាងក្រោម៖

ចំណេញរក្សាទុកត្រូវបានបែងចែកដូចខាងក្រោម៖

i ផ្តល់ជាប្រាក់រង្វាន់របស់គណៈគ្រប់គ្រង និងបុគ្គលិក

- ប្រាក់ខែ ១ខែសំរាប់និយោជិកទាំងអស់ ប្រសិនបើចំណេញសុទ្ធនៅចន្លោះពី ៥% ទៅ ១០% នៃចំណាយប្រតិបត្តិការ
- ប្រាក់ខែ ២ខែសំរាប់និយោជិកទាំងអស់ ប្រសិនបើចំណេញសុទ្ធនៅចន្លោះពី ១០% ទៅ ២០% នៃចំណាយប្រតិបត្តិការ
- ប្រាក់ខែ ៣ខែសំរាប់និយោជិកទាំងអស់ ប្រសិនបើចំណេញសុទ្ធលើសពី ២០% នៃចំណាយប្រតិបត្តិការ

ii ២% សម្រាប់ប្រាក់សោធននិវត្តន៍ និងអសមត្ថភាពវិជ្ជាជីវៈ

iii ៥% សម្រាប់ទុនបម្រុងតាមច្បាប់

iv ៥% សម្រាប់ទុនបម្រុងទូទៅ

v ៥% សម្រាប់មូលនិធិសង្គម ដែលនឹងត្រូវកត់ត្រាជាចំណាយក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

### ១៤. ទុនបម្រុង (ត)

(ក) យោងតាមលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌទី៤៤ ការបែងចែកភាគលាភនិងទុនបម្រុងត្រូវបានធ្វើដូចខាងក្រោម៖ (ត)

ចំនួនទឹកប្រាក់នៅសល់បន្ទាប់ពីការបែងចែកខាងលើនឹងត្រូវបន្តបែងចែកដូចខាងក្រោម៖

vi ទុនបម្រុងសំរាប់ការវិនិយោគពេលអនាគត (ចំណេញរក្សាទុក) ដែលត្រូវមានការអនុម័តដោយក្រុមប្រឹក្សាភិបាល

vii ទឹកប្រាក់នៅសល់បន្ទាប់ពីបែងចែកទុនបម្រុង សំរាប់ការការវិនិយោគទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៨៥% និងវិនិយោគិនសាធារណៈ១៥%។

(ខ) ការប្រើប្រាស់ទុនបម្រុងក្នុងការបង់ទៅសកម្មភាពសង្គម គឺអនុលោមតាមលិខិតលេខ២៨៤ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០។ សកម្មភាពសង្គមទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ក្រុមយោធានៅតាមបណ្ដាខេត្តមួយចំនួន។ សកម្មភាពការងារត្រូវបន្តដល់ឆ្នាំ២០១១ ដោយយោងតាមលិខិតរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ លេខ២២១០ សហវ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១។

### ១៥. ប្រាក់កម្ចី

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| **បំណុលរយៈពេលវែង** | | |
| ប្រាក់កម្ចីមិនមានការធានា | ៩៨៦.៤៩៥.៧១៧ | ៧៩០.៣៥៩.៧៥០ |
| **បំណុលរយៈពេលខ្លី** | | |
| ប្រាក់កម្ចីមិនមានការធានា | ២៣.៤៩៩.១៥៨ | ២៣.១២៨.៥១៨ |
| **ប្រាក់កម្ចីសរុប** | ១.០០៩.៩៩៤.៨៧៥ | ៨១៣.៤៨៨.២៦៨ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ១៥. ប្រាក់កម្ចី (ត)

លក្ខខណ្ឌនៃប្រាក់កម្ចីនៅសល់មានដូចខាងក្រោម៖

| | រូបិយប័ណ្ណ | អត្រាការប្រាក់ ធម្មតា | ឆ្នាំនៃ កាលវសាន្ត | ២០២២ ពាន់រៀល | ២០២១ ពាន់រៀល |
|---|---|---|---|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | | | |
| - JICA | យេន | 0,៦៦0% | ២0៤៩ | ៣៧.៨៦៩.៨៣៩ | ៤៥.២00.៦៥0 |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ធនាគារ អភិវឌ្ឍន៍អាស៊ី | SDR | ១,៦៥0% | ២0៣៧ | ៣២.៨១0.0៩៥ | ៣៦.៤៩៩.៥៩៦ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង | | | | | |
| - ឥណទានលេខ ១១២១ 0១ F | អឺរ៉ូ | 0,២៥0% | ២0២៥ | ៤៤.00១.៤0៨ | ៦៤.៩១៧.0៦៥ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង | | | | | |
| - ឥណទានលេខ ១១៧៤ 0១ P | ដុល្លារអាមេរិក | ១,៨00% | ២0៣៧ | ១៤៩.២៩៩.៨៣៨ | ១៤៦.៣៧៥.៥៤៨ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង | | | | | |
| - ឥណទានលេខ ១១៧៦ 0១ S | ដុល្លារអាមេរិក | 0,៩00% | ២0៣៨ | ២៨៥.៤៣៤.៤៨៥ | ២២៣.២៦0.៦៥២ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង | | | | | |
| - ឥណទានលេខ ១២៤៤ 0១ M | ដុល្លារអាមេរិក | 0,៩00% | ២0៣៩ | ១១៨.៤៧៨.៩៥៦ | ៣៤.២៧២.១៤៦ |
| ធនាគារវិនិយោគអឺរ៉ុប | ដុល្លារអាមេរិក | 0,៦១0%-0,៩៦៥% | ២0៤៨ | ៣៤២.១00.២៥៥ | ២៦២.៩៦២.៦១១ |
| **បំណុលមានការប្រាក់សរុប** | | | | ១.00៩.៩៩៤.៨៧៥ | ៨១៣.៤៨៨.២៦៨ |

### ១៥. ប្រាក់កម្ចី (ត)

**បំពានលើកិច្ចព្រមព្រៀងប្រាក់កម្ចី**

រ.ទ.ស.ភ មានប្រាក់កម្ចីមិនមានការធានា ដែលមានតម្លៃយោង ចំនួន ១.០០៩.៩៩៤.៨៧៥.០០០ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ។ ប្រាក់កម្ចីទាំងនេះ មានការប្រាក់ចាប់ពី ០,២៥០% ទៅ ១,៨០០% និងត្រូវសងចន្លោះពេលពី ២ ទៅ ២៦ឆ្នាំ។ ទោះយ៉ាងណាក៏ដោយ ប្រាក់កម្ចីទាំងនេះ មានកិច្ចព្រមព្រៀងប្រាក់កម្ចី ដែល រ.ទ.ស.ភ ត្រូវគោរពតាម បើមិនដូច្នេះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង និងព្យួរ លុបសិទ្ធិរបស់ រ.ទ.ស.ភ ក្នុងការស្នើសុំការទូទាត់បន្ថែមនៃចំនួនដែលមិនទាន់បានដក និងតម្រូវឱ្យសងវិញតាមតម្រូវការនៃសមតុល្យដែលនៅសល់ ប្រសិនបើការបំពានលើកិច្ចព្រមព្រៀងប្រាក់កម្ចីជាសារវន្ត។

រ.ទ.ស.ភ បានហួសពីកម្រិតអានុភាពអតិបរមាគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ទោះយ៉ាងណាក៏ដោយ រ.ទ.ស.ភ ទទួលបានការលុបចោលពីភាគីពាក់ព័ន្ធ ដែលពន្យាដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ហេតុដូចនេះ ប្រាក់កម្ចីពុំមានការសងតាមតម្រូវការ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

### ១៦. ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ

| | ជំនួយរដ្ឋាភិបាល គិតជាពាន់រៀល | ជំនួយរបស់ JICA គិតជាពាន់រៀល | ជំនួយផ្សេងៗ គិតជាពាន់រៀល | ជំនួយរបស់ សហភាពអឺរ៉ុប គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៤.២៤០.៦៤០ | ១៣.៨៩៧.៥៣៩ | ៦៨៣.៩១៤ | - | ១៨.៨២២.០៩៣ |
| រំលស់ក្នុងឆ្នាំ | (១៣៤.០៦៩) | (១.៨៥៣.០០៦) | (២២.៨៣២) | - | (២.០០៩.៩០៧) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ / ថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៤.១០៦.៥៧១ | ១២.០៤៤.៥៣៣ | ៦៦១.០៨២ | | ១៦.៨១២.១៨៦ |
| ជំនួយបន្ថែមក្នុងគ្រា | - | - | - | ៥៤.៤៣៦.១៩៩ | ៥៤.៤៣៦.១៩៩ |
| ការបង់រំលស់ | (១៣៤.០៦៩) | (១.៨៥៣.០០៦) | (២២.៨៣៣) | - | (២.០០៩.៩០៨) |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៣.៩៧២.៥០២ | ១០.១៩១.៥២៧ | ៦៣៨.២៤៩ | ៥៤.៤៣៦.១៩៩ | ៦៩.២៣៨.៤៧៧ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ១៦. ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ (ត)

(ក) ជំនួយរដ្ឋាភិបាល

ជំនួយរដ្ឋាភិបាលជាផលចំណេញកើតចេញពីភាពលម្អៀងនៃអត្រាថេរ ដែលបានប្រើដើម្បីប្តូរប្រាក់ (រៀល/SDR) ក្រោមកិច្ចព្រមព្រៀងឥណទានបន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រ.ទ.ស.ភ ដែលបានចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧ ដែលមានទឹកប្រាក់សរុបចំនួន ៩.៦៩៥.០០០SDR ពីធនាគារអភិវឌ្ឍន៍អាស៊ី។ រ.ទ.ស.ភ បានសម្រេចរក្សាទុកចំណេញពីការប្តូរប្រាក់នេះក្នុងបញ្ជី រ.ទ.ស.ភ ថាជាជំនួយ (ដោយសារមិនមានតម្រូវការឱ្យបង្វិលប្រាក់ចំណេញនេះទៅវិញទេ) ហើយប្រាក់ចំណេញនេះ នឹងត្រូវរំលស់ ដោយផ្អែក លើគោលការណ៍ដូចគ្នានឹងជំនួយពន្យារពេលផ្តល់ឱ្យផ្សេងៗ។

(ខ) ជំនួយ JICA

ជំនួយ JICA ជាជំនួយលើគម្រោងអនុវត្តថាមពលស្អាត ដោយប្រព័ន្ធប្រតិបត្តិការអគ្គិសនីទៅតាមប្រព័ន្ធសូឡា។

(គ) ជំនួយផ្សេងៗ

ជំនួយផ្សេងៗ ជាការឧបត្ថម្ភទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារពីទីស្នាក់ការសហប្រត្តិការអន្តរជាតិរបស់ Association International des Maires Francophones (AIMF) និងក្រុមហ៊ុន KUBOTA Construction Co.. Ltd។

(ឃ) ជំនួយសហភាពអឺរ៉ុប

ជំនួយបន្ថែមតំណាងឱ្យការផ្តល់ជំនួយ សម្រាប់ការទិញសម្ភារសម្រាប់គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង C ក្នុងចំនួនទឹកប្រាក់ ១២.៧០០.០០០ អឺរ៉ូ ក្នុងទម្រង់ជាជំនួយវិនិយោគដែលធ្វើឡើងតាមរយៈថវិកាទូទៅរបស់សហភាពអឺរ៉ុប។

នៅដំណាច់ឆ្នាំហិរញ្ញវត្ថុ រ.ទ.ស.ភ បានទទួលការទូទាត់នៃជំនួយឥតសំណងសរុបចំនួន ១២.៥៧៤.៨៦៤ អឺរ៉ូ ឬស្មើនឹង ៥៤.៤៣៦.១៩៩.០០០ រៀល នៅពេលបំពេញលក្ខខណ្ឌកិច្ចសន្យា។ មិនមានការកាត់រំលោះទាក់ទងនឹងការផ្តល់ជំនួយដូចនៅចុងឆ្នាំហិរញ្ញវត្ថុនោះទេ ដោយសារការសាងសង់គម្រោងទឹកបាក់ខែង C មិនទាន់បញ្ចប់នៅឡើយ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

### ១៧. ចំណូលពន្ធពន្យារ

| | នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ គិតជាពាន់រៀល | កត់ត្រាក្នុងរបាយការណ៍ ចំណេញ ឬខាត គិតជាពាន់រៀល | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | (៧៤.២១៥.៤៥២) | (៦.២៥១.០៦៦) | (៨០.៤៦៦.៥១៨) |
| សំវិធានធនលើសន្និធិផុតកំណត់ | ៥០.៦៤៥ | (៤០.៥៦៤) | ១០.០៨១ |
| សំវិធានធនលើបំណុលមិនអាចទារបាន | ៥២២.៨៥៨ | (៤៦៩.៥៧៣) | ៥៣.២៨៥ |
| អត្ថប្រយោជន៍និយោជិក | ២.៩៥៣.១៣៩ | ១២៦.៣៧១ | ៣.០៧៩.៥១០ |
| ការប្តូររូបិយប័ណ្ណមិនពិត | (១.៦១៨.៤៨៩) | ១.៩២៥.៤១៥ | ៣០៦.៩២៦ |
| | (៧២.៣០៧.២៩៩) | (៤.៧០៩.៤១៧) | (៧៧.០១៦.៧១៦) |

| | នាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ពាន់រៀល | កត់ត្រាក្នុងរបាយការណ៍ ចំណេញ ឬខាត ពាន់រៀល | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ពាន់រៀល |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | (៦៨.០០៤.០៩០) | (៦.២១១.៣៦២) | (៧៤.២១៥.៤៥២) |
| សំវិធានធនលើសន្និធិផុតកំណត់ | ៥០.៦៤៥ | - | ៥០.៦៤៥ |
| សំវិធានធនលើបំណុលមិនអាចទារបាន | ៥២២.៨៥៨ | - | ៥២២.៨៥៨ |
| អត្ថប្រយោជន៍និយោជិក | ២.៩៣០.១៤៩ | ២២.៩៩០ | ២.៩៥៣.១៣៩ |
| ការប្តូររូបិយប័ណ្ណមិនពិត | ១.៩៩៣.៧៨១ | (៣.៦១២.២៧១) | (១.៦១៨.៤៨៩) |
| | (៦២.៥០៦.៦៥៧) | (៩.៨០០.៦៤៣) | (៧២.៣០៧.២៩៩) |

## ១៨. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ

| | កំណត់សម្គាល់ | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| **រយៈពេលវែង៖** | | | |
| គណនីត្រូវបង់ផ្សេងៗ | | | |
| ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | (ក) | ៧៦.៨០១.៧០៥ | ៦៩.៤៤៦.០៧៣ |
| **រយៈពេលខ្លី៖** | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | | | |
| ភាគីទីបី | (ខ) | ៤៨.០៧៨.៧១០ | ៣៣.២៥១.០៦៤ |
| ទឹកប្រាក់គ្រោងសំរាប់ការងារកំពុងសាងសង់ | | ២៣.២០៨.០៧៥ | ៣៨.២៨៣.០៩៩ |
| | | ៧១.២៨៦.៧៨៥ | ៧១.៥៣៤.១៦៣ |
| **គណនីត្រូវបង់ផ្សេងៗ** | | | |
| ប្រាក់លើកទឹកចិត្តបុគ្គលិកបង្ករ | | ៩.៩៩៣.២២៦ | ៩.២៤១.២៣៧ |
| ទឹកប្រាក់ជំពាក់សាលារាជធានីភ្នំពេញ | | ៥៧.៨៣០.៥៩៤ | ៤៧.៤៥៥.៩៥៨ |
| ប្រាក់ធានាប្រតិបត្តិការ | | ៦៧.៣៩០ | ៦៧.៣៤៤ |
| ពន្ធត្រូវបង់ផ្សេងៗ | | ៣៨៥.៩០៣ | ២៩៣.២៥៨ |
| អតីតភាពការងារ | | ៦.០៧១.៤៣៧ | ៦.១៤៦.០៧៦ |
| គណនីត្រូវបង់ផ្សេងៗ | | ៩.០២៥.៨១៧ | ៧.២៣១.៥០៩ |
| | | ៨៣.៣៧៤.៣៦៧ | ៧០.៤៣៥.៣៨២ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ (រយៈពេលខ្លី) | | ១៥៤.៦៦១.១៥២ | ១៤១.៩៦៩.៥៤៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ (រយៈពេលវែង និងរយៈពេលខ្លី) | | ២៣១.៤៦២.៨៥៧ | ២១១.៤១៥.៦១៨ |

(ក) ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញត្រូវបានប្រមូលពីអតិថិជនដោយផ្អែកតាមទំហំនាឡិកាទឹកមុនពេលភ្ជាប់បណ្តាញ និងត្រូវបានកត់ត្រាជាប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញក្នុងបំណុលរយៈពេលវែង។

(ខ) គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជជាគណនីគ្មានការប្រាក់ ហើយលក្ខខណ្ឌឥណទានធម្មតាដែលផ្តល់ជូន រ.ទ.ស.ភ ចាប់ពី១ខែ ទៅ៣ខែ (ឆ្នាំ២០២១៖ ១ ខែ ទៅ៣ខែ)។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)**

## ១៩. ចំណូល

| | ២០២២ | ២០២១ |
|---|---|---|
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| ការលក់ទឹកស្អាត៖ | | |
| - អ្នកប្រើប្រាស់តាមផ្ទះ | ១១០.៨៧៣.៥១៩ | ១១២.២៩០.៧៧៤ |
| - អ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ១៥១.៨៧០.១៥៣ | ១២៨.៥៨២.០៩៩ |
| - ស្ថាប័នរដ្ឋបាលសាធារណៈ | ១៩.៦៧១.០៣៦ | ២១.៥០០.១៨៥ |
| - អ្នកបោះដុំ | ១០.៣១៧.៣៨៩ | ៩.៣៣៣.៣៤៥ |
| បង្គត់ភាពខុសគ្នាលើប្រាក់ ចំណូលពីការលក់ទឹកស្អាត | ៧០.៤៤២ | ៦៦.២៤៩ |
| ដក៖ ការលុបចោលវិក្កយបត្រ | (៦.៥១៣.៣២១) | (៣.១៨៨.៤០២) |
| | ២៨៦.២៨៩.២១៨ | ២៦៨.៥៨៤.២៥០ |
| | | |
| ចំណូលបានពីការភ្ជាប់បណ្តាញទឹកស្អាតតាមផ្ទះ | ៨.៨១៩.៤៨៣ | ៩.៧៣៥.៩៧៣ |
| ចំណូលការផ្លាស់ប្តូរនាឡិកាទឹក | ៤.២២២.៧៥៤ | ៣.៨៧១.១៤៤ |
| ការលក់គ្រឿងបន្លាស់ និង នាឡិកាទឹក | ៣៩២.០៥២ | ១៧៨.៤៣០ |
| | ២៩៩.៧២៣.៥០៧ | ២៨២.៣៦៩.៧៩៧ |

## ២០. ចំណេញ/(ខាត)សុទ្ធពីការប្តូររូបិយប័ណ្ណបរទេស

| | ២០២២ | ២០២១ |
|---|---|---|
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណបរទេស | | |
| - ពិតពីការប្តូររូបិយប័ណ្ណបរទេស | ២.៦៥៩.៤៤០ | (៥៦១.៨១៥) |
| - មិនពិតពីការប្តូររូបិយប័ណ្ណបរទេស | (៦.១៤០.៦០៦) | ២.៨៣៥.៧៩៩ |
| | (៣.៤៨១.១៦៦) | ២.២៧៣.៩៨៤ |

### ២១. ចំណូលផ្សេងៗ

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ជំនួយរដ្ឋាភិបាល និងជំនួយផ្សេងៗ | ២.០០៩.៩០៨ | ២.០០៩.៩០៧ |
| ការលក់គ្រឿងបន្លាស់ និង នាឡិកាទឹក | ១៥.២៤០.៦៥០ | ១៦.៤១៤.៤៣០ |
| ចំណូលបានពីការពិន័យ | ២៩០.០៤២ | ១៦៥.៩៤៥ |
| ការលុបចោលភាគលាភ | - | ៣៦.៣៧២.១៧៧ |
| ចំណូលផ្សេងៗ | ៣.៩៣៧.៧៣៣ | ៣.២៩៧.០២៨ |
| | ២១.៤៧៨.៣៣៣ | ៥៨.២៥៩.៤៨៧ |

### ២២. ចំណាយលើអត្ថប្រយោជន៍និយោជិក

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្សនិយោជិក | ៣៥.១៣០.៨៦៣ | ៣២.៧៦៧.៧៦៤ |
| បុព្វលាភ | ១១.៤៥២.៥២៩ | ១០.៥០៩.៥០៦ |
| ប្រាក់ឧបត្ថម្ភ | ៩.៥១០.៥៥២ | ៨.៦៨០.៨១៦ |
| អតីតភាពការងារ | ១.១៥៣.៨៦២ | ១.១៩៣.៣៥៧ |
| ប្រាក់ឈ្នួលអ្នកម៉ៅការ | ៨៨៦.៥៦៣ | ១.០២៥.៩៦៧ |
| ចំណាយផ្សេងៗទាក់ទងនឹងនិយោជិក | ១២.០៤១.០៥៣ | ៩.៤៥៣.៨២៧ |
| | ៧០.១៧៥.៤២២ | ៦៣.៦៣១.២៣៧ |

## ២៣. វត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ក្លរីន | ៤.៦០៦.១៣៩ | ៣.២៨៣.៤៧៧ |
| ប៉ូលី អាលុយមីញ៉ូម ក្លរីត | ៦.១៤០.៨១៦ | ៥.០៨៤.៩៤៧ |
| អំបិល | ៩១៤.២៩៩ | ៨០២.៩៤៦ |
| វត្ថុធាតុដើមផ្សេងទៀត | ៤៧៩.៤៨៦ | ៣៧០.៦១២ |
| | ១២.១៤០.៧៤០ | ៩.៥៤១.៩៨២ |

## ២៤. វត្ថុធាតុដើមសម្រាប់ការតភ្ជាប់បណ្តាញនៅតាមគេហដ្ឋាន

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| វត្ថុធាតុដើមសំរាប់ការតភ្ជាប់បណ្តាញនៅតាមគេហដ្ឋាន | ៣.៣០០.៣៣០ | ២.២៧០.២២៧ |
| ការប្តូរនាឡិកាទឹក | ១.០៦៥.៣៣៨ | ៦០៦.៥៤០ |
| ថ្លៃដើមបំពង់ | ៣៥.៧៧៩ | ១៨.៩៧២ |
| ថ្លៃដើមផ្សេងៗ | ៥៥១.៩២៤ | ២៦៨.០២៩ |
| | ៤.៩៥៣.៣៧១ | ៣.១៦៣.៧៦៨ |

## ២៥. ចំណូលការប្រាក់

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ | ៤.៦៥៦.៦១៨ | ២.៧០៦.០៤៤ |
| ចំណូលមិនពិតពីការប្តូររូបិយប័ណ្ណ | ១៣.០៨១.១២៨ | ១០.៨៤៩.០២០ |
| | ១៧.៧៣៧.៧៤៦ | ១៣.៥៥៥.០៦៤ |

## ២៦. ចំណាយការប្រាក់

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ចំណាយការប្រាក់លើប្រាក់កម្ចី | ៩.១១៥.៥៣០ | ៦.៤៣៦.៦៧៧ |
| ខាតមិនពិតពីការប្តូររូបិយប័ណ្ណលើប្រាក់កម្ចី | ៨.៤៩៤.២៦២ | ២.៧៥៦.៥៧១ |
| ការប្រាក់ដែលបានធ្វើមូលធនកម្មលើ<br>ទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | (៥.៥០៥.០៩៦) | (៤.៣៩៨.៤៦៩) |
| | ១២.១០៤.៦៩៦ | ៤.៧៩៤.៧៧៩ |

## ២៧. ពន្ធលើប្រាក់ចំណូល

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| **ពន្ធលើប្រាក់ចំណូល** | | |
| - ក្នុងការិយបរិច្ឆេទ | ១៧.៦២០.៦១០ | ២៤.៥២៣.៥៩៣ |
| - សំវិធានធនខ្វះក្នុងការិយបរិច្ឆេទមុន | - | ២.២៥៨.៤៣៣ |
| | ១៧.៦២០.៦១០ | ២៦.៧៨២.០២៦ |
| **ពន្ធពន្យារ** | | |
| ភាពខុសគ្នាបណ្តោះអាសន្ន | ៤.៧០៩.៤១៧ | ៩.៨០០.៦៤៣ |
| | ២២.៣៣០.០២៧ | ៣៦.៥៨២.៦៦៩ |

## ២៧. ពន្ធលើប្រាក់ចំណូល (ត)

ការផ្ទៀងផ្ទាត់ការគណនាពន្ធលើប្រាក់ចំណូលតាមអត្រាពន្ធ ជាមួយចំណាយពន្ធលើប្រាក់ចំណូលដូចដែលបានបង្ហាញក្នុងរបាយការណ៍ចំណូលមានដូចខាងក្រោម៖

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ចំណេញមុនកាត់កងពន្ធ | ១៣០.៥១៥.៨៩២ | ១៦៥.៨៥៦.៥៨៦ |
| ពន្ធលើប្រាក់ចំណេញដោយប្រើអត្រាពន្ធស្របច្បាប់ ២០% (ឆ្នាំ២០២១៖ ២០%) | ២៦.១០៣.១៧៨ | ៣៣.១៧១.៣១៧ |
| ផលប៉ះពាល់ពន្ធកើតឡើងពី៖ | | |
| - ចំណាយមិនអាចកាត់កងបាន | ១១៥.៣៣០ | ៣៣១.២០១ |
| - ភាពខុសគ្នាបណ្តោះអាសន្ន | (៣.៨៨៨.៤៨១) | ៨២១.៧១៨ |
| - សំវិធានធនខ្វះនៃពន្ធលើប្រាក់ចំណូលក្នុងការិយបរិច្ឆេទមុន | - | ២.២៥៨.៤៣៣ |
| ចំណាយពន្ធលើប្រាក់ចំណូលក្នុងការិយបរិច្ឆេទ | ២២.៣៣០.០២៧ | ៣៦.៥៨២.៦៦៩ |

## ២៨. ចំណេញក្នុងមួយភាគហ៊ុន

### ចំណេញក្នុងមួយភាគហ៊ុនធម្មតាគោល

ចំណេញក្នុងមួយភាគហ៊ុនធម្មតាគោល ផ្អែកលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលបែងចែកទៅភាគហ៊ុនិក រ.ទ.ស.ភ និងចំនួនហ៊ុនធម្មតាដែលនៅមានជាមធ្យមក្នុងការិយបរិច្ឆេទ ដែលបានគណនាដូចខាងក្រោម៖

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ចំណេញបែងចែកទៅភាគហ៊ុនិក រ.ទ.ស.ភ | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ |
| ចំនួនភាគហ៊ុនគិតជាមធ្យម | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ |
| ចំណេញក្នុងមួយហ៊ុនគោល | ១.២៤៣,៩០ | ១.៤៨៦,៣៧ |
| ចំណេញក្នុងមួយហ៊ុនថយចុះ | ១.២៤៣,៩០ | ១.៤៨៦,៣៧ |

## ២៨. ចំណេញក្នុងមួយភាគហ៊ុន (ត)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមានដោយសន្មតថាមានការផ្ទេរភាគហ៊ុនថយចុះ ដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

គិតត្រឹមការិយបរិច្ឆេទនេះ រ.ទ.ស.ភ មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ។ ដូចនេះចំណេញក្នុងមួយភាគហ៊ុនថយចុះ មានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន។

## ២៩. ភាគលាភ

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| **ទទួលស្គាល់ក្នុងក្នុងអំឡុងការិយបរិច្ឆេទ** | | |
| ភាគលាភក្នុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃ៣១០រៀល ក្នុងមួយភាគហ៊ុនធម្មតា* | ៤.០៤៤.២៥២ | - |
| ភាគលាភក្នុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ តម្លៃ២៦២រៀល ក្នុងមួយភាគហ៊ុនធម្មតា | - | ២២.៧៨៦.៩៦៥ |

* ក្រុមប្រឹក្សាភិបាលកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ បានប្រកាស និងអនុម័តលើភាគលាភចំនួន ៣១០ រៀលក្នុងមួយភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ។

អនុលោមតាមលិខិតយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ៩ ខែសីហា ឆ្នាំ២០២១ រ.ទ.ស.ភ ត្រូវបានលើកលែងការបង់ភាគលាភដោយ រ.ទ.ស.ភ ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរហូតដល់ឆ្នាំហិរញ្ញវត្ថុបញ្ចប់ឆ្នាំ ២០២៤ ជាមួយនឹងភាគលាភនៃឆ្នាំហិរញ្ញវត្ថុដែលបញ្ចប់ឆ្នាំ ២០២៥ នឹងត្រូវបន្តដូចការអនុវត្តធម្មតារបស់ រ.ទ.ស.ភ។

អាស្រ័យហេតុនេះ ភាគលាភដែលបានទទួលស្គាល់ក្នុងអំឡុងពេលហិរញ្ញវត្ថុត្រូវបានផ្ទេរសម្រាប់ភាគហ៊ុនិកដែលនៅសល់របស់ រ.ទ.ស.ភ ខណៈដែលចំណែកសម្រាប់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានផ្ទេរពីប្រាក់ចំណូលរក្សាទុកទៅទុនបម្រុងអភិវឌ្ឍន៍របស់ រ.ទ.ស.ភ ដោយផ្ទាល់។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)**

## ៣០. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

រ.ទ.ស.ភ មានប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធដូចខាងក្រោម៖

(ក) ស្ថាប័នពាក់ព័ន្ធរាជរដ្ឋាភិបាល

សាជីវកម្មដែលភ្ជាប់ទៅនឹងរាជរដ្ឋាភិបាល គឺមានពាក់ព័ន្ធជាមួយ រ.ទ.ស.ភ ដែលត្រូវបានកាន់កាប់ភាគហ៊ុនដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្ថាប័នដែលគ្រប់គ្រងដោយផ្ទាល់ដោយរាជរដ្ឋាភិបាល ត្រូវបានសំដៅទាំងស្រុងជាស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹង រ.ទ.ស.ភ។

រាជរដ្ឋាភិបាល និងស្ថាប័នដែលគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺជាភាគីពាក់ព័ន្ធជាមួយនឹង រ.ទ.ស.ភ។ រ.ទ.ស.ភ បានធ្វើប្រតិបត្តិការជាមួយស្ថាប័នជាច្រើន ដែលរួមមានមិនត្រឹមតែការទិញទំនិញប៉ុណ្ណោះទេ ថែមទាំងរួមមានការប្រើប្រាស់ទឹកជាសាធារណៈ និងការដាក់ប្រាក់បញ្ញើ។

រាល់ប្រតិបត្តិការទាំងអស់ដែលបានកត់ត្រាដោយ រ.ទ.ស.ភ ជាមួយស្ថាប័នរាជរដ្ឋាភិបាល ដែលពាក់ព័ន្ធ គឺត្រូវបានធ្វើឡើងក្នុងសកម្មភាពអាជីវកម្មធម្មតារបស់ រ.ទ.ស.ភ ស្តីពីលក្ខខណ្ឌចរចា ឬលក្ខខណ្ឌប្រហាក់ប្រហែលនឹង ស្ថាប័នផ្សេងទៀត ដែលមិនមែនជាស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ លើកលែងតែមានការបង្ហាញនៅកន្លែងផ្សេងទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

រ.ទ.ស.ភ បានពាក់ព័ន្ធយ៉ាងសំខាន់នៅក្នុងដំណើរការ និងការចែកចាយទឹកដែលជាផ្នែកមួយនៃប្រតិបត្តិការធម្មតារបស់ខ្លួន។ សេវាកម្មទាំងនេះត្រូវបានអនុវត្តជាប្រចាំ លើលក្ខខណ្ឌពាណិជ្ជកម្មដែលត្រូវបានអនុវត្តជាមួយអតិថិជនទាំងអស់។ ប្រតិបត្តិការទាំងនេះត្រូវបានបង្កើតឡើងដោយផ្អែកលើលក្ខខណ្ឌដែលមិនខុសគ្នាជាសារវន្តពីប្រតិបត្តិការជាមួយភាគីដែលមិនពាក់ព័ន្ធគ្នា។

ក្រៅពីប្រតិបត្តិការ និងសមតុល្យសំខាន់ៗជាមួយបុគ្គលនីមួយៗ ដូចបានបង្ហាញនៅកន្លែងផ្សេងទៀតនៅក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល រ.ទ.ស.ភ មានប្រតិបត្តិការសំខាន់ៗជាសមូហភាព ប៉ុន្តែមិនមានប្រតិបត្តិការឯកបុគ្គលឡើយ។

(ខ) លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗ

លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗសរុបត្រូវបានវិភាគដូចខាងក្រោម៖

| | **២០២២** | **២០២១** |
|---|---|---|
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗ | ២.៣៨០.៥៧២ | ២.៤៣៥.៤៦៣ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ

### (ក) ការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុ

តារាងខាងក្រោមជាការវិភាគឧបករណ៍ហិរញ្ញវត្ថុ ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាមថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុដោយយោងតាមអ្វីដែលគេតែងតាំងឱ្យ៖

| | តម្លៃត្រូវបានរំលស់<br>គិតជាពាន់រៀល | តម្លៃយោង<br>គិតជាពាន់រៀល |
|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | |
| ការវិនិយោគរយៈពេលខ្លី | ១២៦.១១៨.៤១៦ | ១២៦.១១៨.៤១៦ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ២៧.៤៨២.០២១ | ២៧.៤៨២.០២១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៦១.១៥៨.៩១៥ | ៦១.១៥៨.៩១៥ |
| ប្រាក់កម្ចីនិយោជិត | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| | ២២២.៧១៦.០០៣ | ២២២.៧១៦.០០៣ |
| **បំណុលហិរញ្ញវត្ថុ** | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ២៣១.០៧៦.៩៥៤ | ២៣១.០៧៦.៩៥៤ |
| ប្រាក់កម្ចី | ១.០០៩.៩៩៤.៨៧៥ | ១.០០៩.៩៩៤.៨៧៥ |
| | ១.២៤១.០៧១.៨២៩ | ១.២៤១.០៧១.៨២៩ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | |
| ការវិនិយោគរយៈពេលខ្លី | ៦៨.១៦៣.៨៣៣ | ៦៨.១៦៣.៨៣៣ |
| គណនីអតិថិជនពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | ២៤.០៤២.២៣១ | ២៤.០៤២.២៣១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៨៩.៦៥៩.៥៣៨ | ៨៩.៦៥៩.៥៣៨ |
| ប្រាក់កម្ចីនិយោជិត | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| | ១៨៩.៨២២.២៥៣ | ១៨៩.៨២២.២៥៣ |
| **បំណុលហិរញ្ញវត្ថុ** | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ២១១.១២២.៣៦០ | ២១១.១២២.៣៦០ |
| ប្រាក់កម្ចី | ៨១៣.៤៨៨.២៦៨ | ៨១៣.៤៨៨.២៦៨ |
| | ១.០២៤.៦១០.៦២៨ | ១.០២៤.៦១០.៦២៨ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

### ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពអាជីវកម្មរបស់ រ.ទ.ស.ភ ប្រឈមនឹងហានិភ័យហិរញ្ញវត្ថុជាច្រើនដែលកើតឡើងពីប្រតិបត្តិការ និងការ ប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ។ ហានិភ័យហិរញ្ញវត្ថុសំខាន់ៗរួមមានហានិភ័យឥណទានហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យលំហូរសាច់ប្រាក់ ហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់។ ក្រុមប្រឹក្សាភិបាលធ្វើការត្រួតពិនិត្យឡើងវិញ និងយល់ព្រមលើគោលការណ៍សំរាប់ការគ្រប់គ្រងហានិភ័យនីមួយៗ ដូចដែលបានសង្ខេបខាងក្រោម៖

#### ១. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ហិរញ្ញវត្ថុដល់ រ.ទ.ស.ភ ដែលអាចកើតឡើងលើឧបករណ៍ហិរញ្ញវត្ថុ ប្រសិនបើគូរភាគីអាចនឹងមិនអាចបំពេញកាតព្វកិច្ចទូទាត់សង។ រ.ទ.ស.ភ ប្រឈមមុខនឹងហានិភ័យឥណទានកើតឡើងពីសកម្មភាពប្រតិបត្តិការ (ចម្បងគឺគណនីអតិថិជនពាណិជ្ជកម្ម) និងពីសកម្មភាពហិរញ្ញប្បទាន រួមទាំងសាច់ប្រាក់ និងសាច់ប្រាក់សមមូល។ រ.ទ.ស.ភ មានគោលការណ៍ឥណទាន ហើយការប្រឈមនឹងហានិភ័យឥណទានត្រូវបានគ្រប់គ្រងតាមរយៈការអនុម័តលើឥណទាន កំរឹតឥណទាន និងនីតិវិធីតាមដាន។

#### គណនីអតិថិជនពាណិជ្ជកម្ម និងទ្រព្យសកម្មកិច្ចសន្យា

ហានិភ័យឥណទានដែល រ.ទ.ស.ភ ងាយរងផលប៉ះពាល់គឺ តាមរយៈគណនីអតិថិជនពាណិជ្ជកម្ម និងទ្រព្យសកម្មកិច្ចសន្យាដែលត្រូវទទួលពីអតិថិជន។ អាយុកាលឥណទានសម្រាប់អ្នកប្រើប្រាស់តាមផ្ទះ និងអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម គឺ ១ខែ និង ១ឆ្នាំ សម្រាប់គ្រឹះស្ថានសាធារណៈ។ រ.ទ.ស.ភ បានធ្វើការគ្រប់គ្រងយ៉ាងដិតដល់លើគណនីពាណិជ្ជកម្ម ដើម្បីកាត់បន្ថយហានិភ័យ។ សមតុល្យដែលហួសកំណត់ ត្រូវបានពិនិត្យឡើងវិញយ៉ាងទៀតទាត់ដោយក្រុមប្រឹក្សាភិបាល។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ១. ហានិភ័យឥណទាន (ត)

ប្រមូលផ្តុំនៃព័ត៌មានហានិភ័យឥណទាន

រ.ទ.ស.ភ កំណត់ហានិភ័យឥណទានប្រមូលផ្តុំនៃគណនីអតិថិជនពាណិជ្ជកម្ម ដោយផ្អែកតាមមូលដ្ឋានដែលកំពុងដំណើរការ។ ប្រមូលផ្តុំនៃព័ត៌មានហានិភ័យឥណទាននៃគណនីអតិថិជនពាណិជ្ជរបស់ រ.ទ.ស.ភ នៅចុងគ្រារាយការណ៍មានដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | គិតជាពាន់រៀល | % | គិតជាពាន់រៀល | % |
| គណនីត្រូវទទួលតាមគេហដ្ឋាន | ១.១១៤.៣៧៤ | ៨% | ១.៥៣៥.៨៤០ | ១០% |
| គណនីត្រូវទទួលអាជីវកម្ម | ១.៣០០.៩៥៩ | ៩% | ១.០៦២.៩០៣ | ៧% |
| គណនីត្រូវទទួលរដ្ឋាបាលសាធារណៈ | ១១.៦៧៣.២៨១ | ៨២% | ១២.២០៩.៩៤៧ | ៨២% |
| គណនីត្រូវទទួលតំណាងចែកចាយទឹក | ១០៣.៦៤៧ | ១% | ៤៤.២១៥ | ១% |
| | ១៤.១៩២.២៦១ | | ១៤.៨៥២.៩០៥ | |

រ.ទ.ស.ភ មិនរំពឹងថាតម្លៃយោងដែលបានកត់ត្រានៅចុងគ្រារាយការណ៍នីមួយៗ មានភាពខុសគ្នាជាសារវន្តពីតម្លៃដែលនឹងត្រូវបានទទួលបាននោះទេ។

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជនពាណិជ្ជកម្ម រ.ទ.ស.ភ តម្រូវឱ្យកក់ប្រាក់មុនពេលមានការតភ្ជាប់នាឡិកាទឹក។ ចំពោះអង្គភាពរដ្ឋមិនចាំបាច់មានប្រាក់កក់ទេ ដោយសារ រ.ទ.ស.ភ ជឿថានឹងអាចប្រមូលបានពីអង្គភាពទាំងនោះតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ប្រភពនៃហិរញ្ញវត្ថុសំរាប់អង្គភាពទាំងនោះ) ដែលក៏ជាភាគហ៊ុនិក និងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ។

គោលនយោបាយកាត់បន្ថយប្រាក់កក់ទៅអតិថិជន ដែលមិនទាន់បានសងបំណុលក្នុងកំឡុងពេលលក្ខខណ្ឌឥណទាន។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

**១. ហានិភ័យឥណទាន (ត)**

**សាច់ប្រាក់ សាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី**

ក្នុងសាច់ប្រាក់ និងសាច់ប្រាក់សមមូលមានចំនួន ៤.៤៤២.៤៧៦.០០០រៀល (២០២១៖ ២.៧៩៣.៨៥៥.០០០រៀល) ត្រូវបានដាក់នូវរតនាគាជាតិ រតនាគារក្រុងភ្នំពេញ រតនាគារខេត្តត្បូងឃ្មុំនិងរតនាគារខេត្តកណ្ដាល។

ដើម្បីកាត់បន្ថយហានិភ័យឥណទានសំរាប់ប្រាក់នៅធនាគារ និងការវិនិយោគរយៈពេលខ្លី (ប្រាក់បញ្ញើរយៈពេលកំណត់នៅធនាគារ) រ.ទ.ស.ភ បានដាក់បញ្ញើនៅធនាគារផ្សេងៗដោយប្រើប្រាស់ធនាគារធំៗមួយចំនួនដែលល្បីៗក្នុងប្រទេសកម្ពុជា។

**២. ហានិភ័យសាច់ប្រាក់ងាយស្រួល**

ហានិភ័យសាច់ប្រាក់ងាយស្រួលគឺជាហានិភ័យដែល រ.ទ.ស.ភ នឹងជួបផលលំបាកក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដល់ថ្ងៃកំណត់។ រ.ទ.ស.ភ ប្រឈមមុខនឹងហានិភ័យសាច់ប្រាក់ងាយស្រួលចម្បងពីភាព មិនត្រូវគ្នានៃកាលវសានរវាងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ ការប្រឈមមុខនឹងហានិភ័យសាច់ប្រាក់ងាយស្រួល ជាចំបងកើតឡើងពីគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ និងកម្ចី។

កម្មវត្ថុរបស់ រ.ទ.ស.ភ គឺគ្រប់គ្រងតុល្យភាពរវាងការបន្តការផ្ដល់ហិរញ្ញប្បទាន និងភាពបត់បែនតាមរយៈការសម្របសម្រួលប្រចាំការ។ រ.ទ.ស.ភ បានគ្រប់គ្រងសាច់ប្រាក់ងាយស្រួលគ្រប់គ្រាន់ និងភាពមានស្រាប់នៃ មូលនិធិដើម្បីបំពេញតម្រូវការប្រើប្រាស់សាច់ប្រាក់ប្រចាំថ្ងៃ ស្របពេលដែលគ្រប់គ្រងការត្រួតត្រា និងសន្តិសុខលើបម្រែបម្រួលសាច់ប្រាក់។ រ.ទ.ស.ភ ប្រើប្រាស់លំដាប់លំដោយនៃប្រតិបត្តិការដើម្បីទទួលបាននូវផលប្រយោជន៍ជាធំពីលំហូរមូលនិធិ ដើម្បីឱ្យពួកគេគ្រប់គ្រងប្រកបដោយមានប្រសិទ្ធភាព ដើម្បីបង្កើនប្រាក់ចំណូលពីការវិនិយោគ និងកាត់បន្ថយថ្លៃដើមនៃការខ្ចីប្រាក់។ នាយកដ្ឋានរតនាគាររបស់រ.ទ.ស.ភ ក៏ត្រូវធានាឱ្យបានថាមានកន្លែងគ្រប់គ្រាន់ដើម្បីសម្របសម្រួលមូលនិធិ និងទ្រព្យដែលអាចប្តូរយកប្រាក់សម្រាប់តម្រូវការថវិការរយៈពេលខ្លី និងរយៈពេលវែង។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ២. ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

<u>ការវិភាគកាលវសាន្ត</u>

ការវិភាគកាលវសាន្តនៃបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយផ្អែកលើការទូទាត់ ធម្មតាតាមកិច្ចសន្យានៅកាលបរិច្ឆេទនៃរបាយការណ៍មានដូចខាងក្រោមៈ

| | | លំហូរសាច់ប្រាក់តាមកិច្ចសន្យា | | | |
|---|---|---|---|---|---|
| | តម្លៃយោង | តាមតម្រូវការ ឬក្នុងពេល ១ ឆ្នាំ | ចន្លោះពី១ ទៅ៥ឆ្នាំ | លើសពី ៥ឆ្នាំ | សរុប |
| | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជ និងគណនី ត្រូវទទួលផ្សេងៗ | ២៣១.០៧៦.៩៥៤ | ១៥៤.២៧៥.២៤៩ | - | ៧៦.៨០១.៧០៥ | ២៣១.០៧៦.៩៥៤ |
| ប្រាក់កម្ចី | ១.០០៩.៩៩៤.៨៧៥ | ២៣.៤៩៩.១៥៨ | ២០០.៧៦៥.១៧៤ | ៧៨៥.៧៣០.៥៤៣ | ១.០០៧.៧៦២.៥៧៩ |
| | ១.២៤១.០៧១.៨២៩ | ១៧៧.៧៧៤.៤០៧ | ២០០.៧៦៥.១៧៤ | ៨៦២.៥៣២.២៤៨ | ១.២៣៨.៨៣៩.៥៣៣ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ២. ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

ការវិភាគកាលវសាន្ត (ត)

ការវិភាគកាលវសាន្តនៃបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយផ្អែកលើការទូទាត់ ធម្មតាតាមកិច្ចសន្យានៅកាលបរិច្ឆេទនៃរបាយការណ៍មានដូចខាងក្រោម៖ (ត)

| | | លំហូរសាច់ប្រាក់តាមកិច្ចសន្យា | | | |
|---|---|---|---|---|---|
| | តម្លៃយោង | តាមតម្រូវការ ឬក្នុងពេល ១ ឆ្នាំ | ចន្លោះពី១ ទៅ៥ឆ្នាំ | លើសពី ៥ឆ្នាំ | សរុប |
| | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | ២១១.១២២.៣៦០ | ១៤១.៦៧៦.២៨៧ | - | ៦៩.៤៤៦.០៧៣ | ២១១.១២២.៣៦០ |
| ប្រាក់កម្ចី | ៨១៣.៤៨៨.២៦៨ | ២៣.២២៩.២៣៥ | ១៦៩.១៤៨.១៤៧ | ៦២៩.០៦៨.៨៥៦ | ៨២១.៤៤៦.២៣៨ |
| | ១.០២៤.៦១០.៦២៨ | ១៦៤.៩០៥.៥២២ | ១៦៩.១៤៨.១៤៧ | ៦៩៨.៥១៤.៩២៩ | ១.០៣២.៥៦៨.៥៩៨ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### (៣) ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណបរទេស គឺជាហានិភ័យនៃការប្រែប្រួលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុ ដែលជាលទ្ធផលបានពីការប្តូរដោយប្រើអត្រាប្តូរប្រាក់បរទេស។ ការប្រឈមរបស់ រ.ទ.ស.ភ នឹងហានិភ័យនៃការប្តូរ ដោយប្រើអត្រាប្តូរប្រាក់បរទេសទាក់ទងជាចម្បងទៅនឹងសកម្មភាពប្រតិបត្តិការរបស់ រ.ទ.ស.ភ (នៅពេលដែលសាច់ប្រាក់ និងសាច់ប្រាក់សមមូល ការវិនិយោគរយៈពេលខ្លី ការទិញ និងកម្ចីដែលជារូបិយប័ណ្ណបរទេស)។

ការមិនទប់ស្កាត់ហានិភ័យនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលមិនមែនជារូបិយប័ណ្ណគោលមានដូចខាងក្រោម៖

| | ២០២២<br>គិតជាពាន់រៀល | ២០២១<br>គិតជាពាន់រៀល |
|---|---|---|
| ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុដែល មិនគិតជារូបិយប័ណ្ណមុខងារ៖ | | |
| <u>សាច់ប្រាក់ និងសាច់ប្រាក់សមមូល</u> | | |
| ដុល្លារអាមេរិក | ៣៤.៨៩៤.៣៨៥ | ២៦.៤៦៣.២៨៦ |
| <u>ការវិនិយោគរយៈពេលខ្លី</u> | | |
| ដុល្លារអាមេរិក | ៩១.១១៨.៤១៦ | ៦៨.១៦៣.៨៣៤ |
| <u>គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ</u> | | |
| ដុល្លារអាមេរិក | ៨១.៩៩៣.២៥០ | ៤៧.៦១៨.៨៨០ |
| អឺរ៉ូ | ២៣.៩៩១.៨៥៤ | ២១.៣៨៩.៩៩២ |
| | ១០៥.៩៨៥.១០៤ | ៦៩.០០៨.៨៧៣ |
| <u>ប្រាក់កម្ចី</u> | | |
| ដុល្លារអាមេរិក | ៨៩៥.៣១៣.៥២៨ | ៦៦៦.៨៧០.៩៥៧ |
| អឺរ៉ូ | ៤៣.៩៩៩.០៦១ | ៦៤.៩១៧.០៦៥ |
| Speacial Drawing Right | ៣២.៨១០.១០២ | ៣៦.៤៩៩.៥៩៦ |
| យេន | ៣៧.៨៧២.១៨៤ | ៤៥.២០០.៦៥០ |
| | ១.០០៩.៩៩៤.៨៧៥ | ៨១៣.៤៨៨.២៦៨ |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (៣) ហានិភ័យរូបិយប័ណ្ណបរទេស (ត)

ការវិភាគភាពប្រែប្រួលលើហានិភ័យរូបិយប័ណ្ណបរទេស

ការប្រឈមចម្បងនៃរូបិយប័ណ្ណបរទេសរបស់ រ.ទ.ស.ភទាក់ទងជាចម្បងទៅលើ ដុល្លារអាមេរិក អឺរ៉ូ special drawing right ("SDR") និងយេន។

តារាងខាងក្រោមបង្ហាញពីការវិភាគជាមួយនឹងការប្រែប្រួល ដែលអាចកើតមានឡើងលើដុល្លារអាមេរិក អឺរ៉ូ special drawing right និងយេន ជាមួយនឹងធាតុផ្សេងៗទៀតដែលនៅដដែល៖

| | បម្រែបម្រួលអត្រា % | ២០២២ គិតជាពាន់រៀល | ២០២១ គិតជាពាន់រៀល |
|---|---|---|---|
| ដុល្លារអាមេរិក/រៀល | +៣% | (២៥.៣៨៨.៥៧៩) | (១៨.៥៨៥.៩៦៥) |
| | -៣% | ២៥.៣៨៨.៥៧៩ | ១៨.៥៨៥.៩៦៥ |
| អឺរ៉ូ/រៀល | +៣% | (២.០៣៩.៧២៧) | (២.៥៨៧.៧៦៦) |
| | -៣% | ២.០៣៩.៧២៧ | ២.៥៨៧.៧៦៦ |
| SDR/រៀល | +៣% | (៩៨៤.៣០៣) | (១.០៩០.៥៨៩) |
| | -៣% | ៩៨៤.៣០៣ | ១.០៩០.៥៨៩ |
| យេន/រៀល | +៣% | (១.១៣៦.១៦៦) | (១.៣៥៣.៥២៣) |
| | -៣% | ១.១៣៦.១៦៦ | ១.៣៥៣.៥២៣ |

### (៤) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ អាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### (៤) ហានិភ័យអត្រាការប្រាក់ (ត)

ស្របពេលដែលលទ្ធផលប្រតិបត្តិការអាចរងផលប៉ះពាល់ដោយសារការប្រែប្រួលនៃអត្រាការប្រាក់ រ.ទ.ស.ភ ធ្វើការត្រួតពិនិត្យយ៉ាងជាប់លាប់ទៅលើផលប៉ះពាល់សុទ្ធនៃប្រតិបត្តិការ ដែលមានគោលបំណងតែមួយក្នុងការកាត់បន្ថយការប្រឈមនឹងហានិភ័យអត្រាការប្រាក់។ អភិបាលយល់ឃើញថាមិនមានផលប៉ះពាល់ជាសារវន្តណាមួយពីហានិភ័យអត្រាការប្រាក់ទេ ដោយសារតែប្រតិបត្តិការមិនមានភាពជាសារវន្ត ត្រូវបានធ្វើឡើងក្នុងអត្រាការប្រាក់ដែលមិនមានភាពជាសារវន្ត។ ដូច្នេះហើយ គ្មានការវិភាគភាពប្រែប្រួលត្រូវបានបានបង្ហាញទេ។

#### (៥) តម្លៃសមស្រប

តារាងខាងក្រោម បង្ហាញពីតម្លៃយោង និងតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ វាមិនបានរួមបញ្ចូលនូវព័ត៌មានរបស់តម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលមិនបានវាស់វែងនៅតម្លៃសមស្រប ប្រសិនបើតម្លៃយោងមានតម្លៃប្រហាក់ប្រហែលសមហេតុផលនឹងតម្លៃសមស្រប។

គណនីអតិថិជនពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ ទ្រព្យសកម្មកិច្ចសន្យាកម្ចីផ្តល់ឱ្យនិយោជិត ការវិនិយោគរយៈពេលខ្លី សាច់ប្រាក់និងសាច់ប្រាក់សមមូល គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ បំណុលកិច្ចសន្យា មិនត្រូវបានរួមបញ្ចូលក្នុងតារាងខាងក្រោមទេ។ តម្លៃយោងរបស់វា គឺមានតម្លៃប្រហាក់ប្រហែលសមហេតុផលនឹងតម្លៃសមស្រប។

| | តម្លៃយោង<br>គិតជាពាន់រៀល | តម្លៃសមស្របនៃ<br>ឧបករណ៍ហិរញ្ញវត្ថុ<br>មិនប្រើប្រាស់<br>វិធីសាស្រ្តតម្លៃសមរម្យ<br>គិតជាពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចី** | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ១.០០៩.៩៩៤.៨៧៥ | ៨៦៨.៥៦៩.៦៨៨ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៨១៣.៤៨៨.២៦៨ | ៨២១.៤៤៦.២៣៨ |

## ៣១. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### (៥) តម្លៃសមស្រប (ត)

**តម្លៃសមស្រប កម្រិតទី៣**

<u>តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុមិនប្រើប្រាស់វិធីសាស្រ្តតម្លៃសមរម្យ</u>

តម្លៃសមស្របនៃប្រាក់កម្ចី ត្រូវបានកំណត់ដោយប្រើវិធីសាស្រ្តលំហូរសាច់ប្រាក់បច្ចុប្បន្ន ដោយផ្អែកលើអត្រាការប្រាក់ ដែលឆ្លុះបញ្ចាំងពីអត្រាខ្ចីរបស់អ្នកបោះផ្សាយលក់នៅចុងគ្រារាយការណ៍។

## ៣២. ចំណាយជាប់កិច្ចសន្យា

នៅចុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន រ.ទ.ស.ភ មានចំណាយជាប់កិច្ចសន្យាទៅលើ៖

| | ២០២២ | ២០២១ |
|---|---|---|
| | **គិតជាពាន់រៀល** | **គិតជាពាន់រៀល** |
| ការសាងសង់រោចក្រផលិតទឹកស្អាត | ១០១.៧៤០.០៦៨ | ៣៩៣.៧៣៣.៨៥២ |
| សេវាពិគ្រោះយោបល់ | ៩.៨៩១.៧២២ | ៧.៧៧១.៩៥៦ |
| ការទិញបំពង់ដែក បរិក្ខារនិងគ្រឿងបន្លែម | ២៣.១២០.៣៩៩ | ៣.៤០៥.០៦០ |
| | ១៣៤.៧៥២.១៨៩ | ៤០៤.៩១០.៨៦៨ |

## ៣៣. ព័ត៌មានតាមផ្នែក

ព័ត៌មានតាមផ្នែកគឺមានលក្ខណៈថ្មីនៅក្នុងប្រទេសកម្ពុជា ហើយមានលក្ខណៈជាសារពើពន្ធជាច្រើន និងការផ្លាស់ប្តូរជាយឹកញាប់ក្នុងច្បាប់ ដែលមានលក្ខណៈមិនច្បាស់លាស់ និងប្រែប្រួលតាមការបកស្រាយ។ ជាទូទៅការបកស្រាយផ្សេងគ្នាកើតមានក្នុងចំណោមអាជ្ញាធរ និងច្បាប់ពន្ធ។ សារពើពន្ធត្រូវស្របតាមការត្រួតពិនិត្យ និងតាមដានដោយ អាជ្ញាធរ ដែលត្រូវបានអនុញ្ញាតដោយច្បាប់ ដើម្បីធ្វើការពិន័យជាសារវន្ត និងពិន័យការប្រាក់។

### ៣៤. យថាភាពនៃពន្ធ

ប្រព័ន្ធនៃពន្ធនៅក្នុងប្រទេសកម្ពុជា គឺមានភាពថ្មី និងត្រូវបានកំណត់លក្ខណៈដោយប្រភេទពន្ធជាច្រើន និងការផ្លាស់ប្តូរជានិច្ចកាលនៃបទបញ្ញត្តិ ដែលជាធម្មតាមានលក្ខណៈមិនសូវជាក់លាក់មានភាពផ្ទុយគ្នា និងប្រែប្រួលទៅតាមការបកប្រែ។ជានិច្ចកាល ការបកប្រែផ្សេងៗគ្នាកើតមានក្នុងចំណោមអាជ្ញាធរពន្ធ និងយុត្តាធិការជាច្រើនខុសៗគ្នា។ ពន្ធត្រូវតែត្រួតពិនិត្យឡើងវិញ និងស៊ើបអង្កេតដោយអាជ្ញាធរជាច្រើនដែលអនុញ្ញាតដោយច្បាប់ក្នុងការប្រតិបត្តិការផាកពិន័យធ្ងន់ធ្ងរ ការពិន័យព្រហ្មទណ្ឌ និងការពិន័យលើការប្រាក់។

ការពិតទាំងនេះប្រហែលជា អាចបង្កើតហានិភ័យនៃពន្ធនៅក្នុងប្រទេសកម្ពុជាខ្លាំងជាងនៅប្រទេសដទៃទៀត។ អ្នកដឹកនាំជឿជាក់ថា រ.ទ.ស.ភ បានផ្តល់យ៉ាងគ្រប់គ្រាន់សម្រាប់បំណុលពន្ធដោយផ្អែកលើការបកប្រែបទបញ្ញាតិនៃពន្ធ។ ប៉ុន្តែអាជ្ញាធរដែលពាក់ព័ន្ធអាចមានការបកប្រែផ្សេងគ្នា ហើយឥទ្ធិពលរបស់វាអាចមានសារៈសំខាន់ខ្លាំង។

### ៣៥. ការគ្រប់គ្រងមូលធន

គោលនយោបាយរបស់ រ.ទ.ស.ភ គឺដើម្បីប្រាកដថាមានមូលធនគ្រប់គ្រាន់នៅក្នុងការបន្តមុខងារតាមច្បាប់របស់ខ្លួន។ ដើម្បីជោគជ័យ រ.ទ.ស.ភ ត្រួតពិនិត្យភាពគ្រប់គ្រាន់នៃមូលធន ដោយរួមបញ្ចូលទាំងតម្រូវការចំណាយមូលធន គោលនយោបាយរដ្ឋាភិបាល តម្រូវការច្បាប់ និងលទ្ធភាពរបស់ខ្លួនក្នុងការជ្រៀតចូលទីផ្សារមូលធន។ រ.ទ.ស.ភ កំណត់និយមន័យដើមទុន ជាមូលធន។

គ្មានការប្រែប្រួលវិធីសាស្ត្ររបស់ រ.ទ.ស.ភ ក្នុងការគ្រប់គ្រងមូលធន ក្នុងអំឡុងការិយបរិច្ឆេទបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

### ៣៦. ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងឆ្នាំហិរញ្ញវត្ថុ

ឯកឧត្តម ស៊ឹម ស៊ីថា រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨ យោងតាមអនុក្រឹត្យលេខ ៣១ អនក្រ.តត ចុះថ្ងៃ ទី០៦ ខែមករា ឆ្នាំ២០២៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨។

លោក ម៉ា ណូរ៉ាវីន ជាអគ្គនាយករងទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធផលិតកម្ម ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៨ តំណាងនិយោជិត រ.ទ.ស.ភ តាមរយៈលទ្ធផលនៃការបោះឆ្នោត នៅថ្ងៃចន្ទ ទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់មន្ត្រី-និយោជិត រ.ទ.ស.ភ។

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣៧. ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ត្រូវបានអនុញ្ញាតឱ្យចេញផ្សាយស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣។

Baker Tilly (Cambodia) Co., Ltd.
Certified Public Accountants
No. 87, Street 294,
Sangkat Boeung Keng Kang 1,
120102, Khan Boeung Keng Kang,
Phnom Penh, Cambodia.

T: +855 23 987 100/
+855 23 987 388

info@bakertilly.com.kh
www.bakertilly.com.kh

លេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

### មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា "រ.ទ.ស.ភ" ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិត ផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់របស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានបង្ហាញ នៅទំព័រទី៧ ដល់ ទី៨១។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។



Baker Tilly (Cambodia) Co., Ltd. trading as Baker Tilly is a member of the global network of Baker Tilly International Ltd., the members of which are separate and independent legal entities.

lេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ក)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.សអ.ក")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពី រ.ទ.ស.ភ ដោយស្របតាមក្រមសីលធម៌វិជ្ជាជីវៈគណនេយ្យករ (IESBA Code) ដែលចេញផ្សាយដោយក្រុមប្រឹក្សាក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ និងតាមតម្រូវការរបស់វិទ្យាស្ថាន គណនេយ្យករ និងសវនករកម្ពុជា (KICPAA Code)។ យើងខ្ញុំបានបំពេញទំនួលខុសត្រូវលើក្រមសីលធម៌ផ្សេងទៀត ស្របតាម IESBA និងតម្រូវការក្រមសីលធម៌របស់ KICPAA។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល គឺមានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## បញ្ហាសវនកម្មសំខាន់ៗ

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយណា ដែលនៅក្នុងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំមានសារៈសំខាន់បំផុតក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហាទាំងនេះត្រូវបានដោះស្រាយនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ទាំងមូល និងជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំនាពេលបន្ទាប់ ហើយយើងខ្ញុំមិនមានការបញ្ចេញមតិយោបល់ដាច់ដោយឡែកចំពោះបញ្ហាទាំងនេះឡើយ។

### ក. តម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងការវាយតម្លៃអាយុកាលប្រើប្រាស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

***យោងតាមកំណត់សម្គាល់ ៣.៣ កំណត់សម្គាល់ ៤.២ និងកំណត់សម្គាល់ ៥ នៃរបាយការណ៍ហិរញ្ញវត្ថុ***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខាររបស់ រ.ទ.ស.ភ មានចំនួន ២,២០៣ ពាន់លានរៀល។

lេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**បញ្ហាសវនកម្មសំខាន់ៗ (ត)**

**ក. តម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងការវាយតម្លៃអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)**

***យោងតាមកំណត់សម្គាល់ ៣.៣ កំណត់សម្គាល់ ៤.២ និងកំណត់សម្គាល់ ៥ នៃរបាយការណ៍ហិរញ្ញវត្ថុ (ត)***

យើងខ្ញុំផ្តោតលើតម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដោយសារតែគណនីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារភាគច្រើន តំណាងឱ្យទ្រព្យសកម្មសរុបរបស់ រ.ទ.ស.ភ ហើយការវិនិច្ឆ័យជាក់លាក់របស់គណៈគ្រប់គ្រងត្រូវបានពាក់ព័ន្ធក្នុងការកំណត់អាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ។ ដោយហេតុថាទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារមានលក្ខណៈជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ កំហុសខុសឆ្គងក្នុងការ ប៉ាន់ស្មានអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ អាចបណ្តាលឱ្យមានការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ។

ហេតុដូចនេះ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្មសំខាន់។

ការឆ្លើយតបរបស់យើងខ្ញុំ៖

- យើងខ្ញុំបានត្រួតពិនិត្យភាពស្រមស្របលើការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង នៃអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដូចខាងក្រោម៖
  ១ ពិភាក្សាជាមួយគណៈគ្រប់គ្រង លើផែនការប្រតិបត្តិការរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ
  ២ វាយតម្លៃការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង នៃអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារថ្មីដែលបានទិញចូលដោយពិនិត្យលើឯកសារពាក់ព័ន្ធ ដូចជាឯកសារគម្រោង ការវាយតម្លៃបច្ចេកទេស និងការបញ្ជាក់ពីអ្នកផ្គត់ផ្គង់
  ៣ ត្រួតពិនិត្យការវិភាគរបស់គណៈគ្រប់គ្រង លើការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដែលរួមបញ្ចូល ការកំណត់អត្តសញ្ញាណលក្ខខណ្ឌ ដែលអាចបង្ហាញពីការផ្លាស់ប្តូរមានលក្ខណៈជាសារវន្ត ទៅលើអាយុកាលប្រើប្រាស់ដែលបាន ប៉ាន់ស្មាន ដូចជាការប្រើប្រាស់ទ្រព្យសកម្មរំពឹងទុក ការសឹករិចរិលប៉ាន់ស្មាន បច្ចេកទេស ឬ ភាពហួសសម័យ និងកំហិតផ្លូវច្បាប់ ឬកំហិតស្រដៀងគ្នាលើការប្រើប្រាស់ទ្រព្យសកម្ម

លេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**បញ្ហាសវនកម្មសំខាន់ៗ (ត)**

**ក. តម្លៃយោងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងការវាយតម្លៃអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)**

ការឆ្លើយតបរបស់យើងខ្ញុំ៖ (ត)

៤ ប្រៀបធៀបអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ជាមួយនឹងអង្គភាពក្នុង វិស័យទឹកភ្លើង ដោយផ្អែកលើព័ត៌មានជាសាធារណៈនៃអង្គភាពទាំងនេះ និង

៥ វាយតម្លៃភាពពេញលេញនៃការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

- យើងខ្ញុំបានសង្កេតមើលទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ តាមរយៈការកំណត់វិធីសាស្ត្រការជ្រើសគំរូរបស់យើងខ្ញុំ។

ដោយផ្អែកលើនីតិវិធីដែលបានអនុវត្តខាងលើ យើងខ្ញុំពុំរកឃើញភាពខុសឆ្គងជាសារវន្តទេ លើកលែងតែចំណុចខ្វះខាតនៃការគ្រប់គ្រងលើកំណត់សម្គាល់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារមួយចំនួន។

**ខ. តម្លៃយោងនៃប្រាក់កម្ចី ការវាយតម្លៃលើការប្តូររូបិយប័ណ្ណបរទេស និងរូបិយប័ណ្ណមុខងារ**

***យោងតាមកំណត់សម្គាល់ ២.៤ កំណត់សម្គាល់ ៣.១ កំណត់សម្គាល់ ៣.២(ក)(i) កំណត់សម្គាល់ ៤.១ កំណត់សម្គាល់ ១៥ កំណត់សម្គាល់ ២៥ កំណត់សម្គាល់ ២៦ នៃរបាយការណ៍ហិរញ្ញវត្ថុ***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃយោងនៃប្រាក់កម្ចីរបស់ រ.ទ.ស.ភ មានចំនួន ១,០០៩ពាន់លានរៀល ចំណេញ ឬខាតមិនបានទទួលស្គាល់ពីការប្តូររូបិយប័ណ្ណបរទេសលើប្រាក់កម្ចី មានចំនួន ១៣ពាន់លានរៀល និង ៨ពាន់លានរៀល រៀងគ្នា សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

យើងខ្ញុំផ្តោតលើចំណុចនេះ ដោយសារតែរូបិយប័ណ្ណបរទេសកំណត់ ដោយគណនីប្រាក់កម្ចីភាគច្រើនតំណាងឱ្យបំណុលសរុបរបស់ រ.ទ.ស.ភ និងការវិនិច្ឆ័យជាក់លាក់របស់គណៈគ្រប់គ្រងត្រូវបានពាក់ព័ន្ធក្នុងការកំណត់រូបិយប័ណ្ណមុខងាររបស់ រ.ទ.ស.ភ។

**បញ្ហាសវនកម្មសំខាន់ៗ (ត)**

ខ. **តម្លៃយោងនៃប្រាក់កម្ចី ការវាយតម្លៃលើការប្តូររូបិយប័ណ្ណបរទេស និងរូបិយប័ណ្ណមុខងារ (ត)**

***យោងតាមកំណត់សម្គាល់ ២.៤ កំណត់សម្គាល់ ៣.១ កំណត់សម្គាល់ ៣.២(ក)(៧) កំណត់សម្គាល់ ៤.១ កំណត់សម្គាល់ ១៥ កំណត់សម្គាល់ ២៥ កំណត់សម្គាល់ ២៦ នៃរបាយការណ៍ហិរញ្ញវត្ថុ (ត)***

ដោយហេតុថាប្រាក់កម្ចីមានលក្ខណៈជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ កំហុសខុសឆ្គងក្នុងការកំណត់រូបិយប័ណ្ណមុខងាររបស់ រ.ទ.ស.ភ និងការប្តូររូបិយប័ណ្ណបរទេសអាចបណ្តាលឱ្យមានការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ។

ហេតុដូចនេះ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្មសំខាន់។

ការឆ្លើយតបរបស់យើងខ្ញុំ៖

- យើងខ្ញុំបានត្រួតពិនិត្យភាពស្រមស្របលើការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង នៃការកំណត់រូបិយប័ណ្ណមុខងាររបស់ រ.ទ.ស.ភ ដូចខាងក្រោម៖
  - ១ ពិភាក្សាជាមួយគណៈគ្រប់គ្រង លើប្រតិបត្តិការនៃ រ.ទ.ស.ភ និងតម្រូវការតាមច្បាប់ របស់អង្គភាពដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាខ្មែររៀល
  - ២ វាយតម្លៃភាពសមស្របនៃការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង ដែលរួមបញ្ចូល ការពិចារណាលើស្ថានភាពសេដ្ឋកិច្ចបឋមដែល រ.ទ.ស.ភ ប្រតិបត្តិ រូបិយប័ណ្ណ និងបទប្បញ្ញត្តិ ដែលជះឥទ្ធិពលជាចម្បងទៅលើតម្លៃលក់ និងរូបិយប័ណ្ណដែលមូលនិធិបានពី ឬប្រើក្នុងសកម្មភាពហិរញ្ញប្បទាន និងសកម្មភាពវិនិយោគរៀងគ្នា និង
  - ៣ វាយតម្លៃភាពពេញលេញនៃការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- យើងខ្ញុំបានត្រួតពិនិត្យភាពស្រមស្របលើការប្តូររូបិយប័ណ្ណបរទេស កំណត់ដោយគណនីប្រាក់កម្ចីនៅចុងការិយបរិច្ឆេទដូចខាងក្រោម៖
  - ១ ត្រួតពិនិត្យអត្រាប្តូរប្រាក់បរទេសដែលបានប្រើដោយប្រៀបធៀបអត្រា ដែលបានប្រើទៅនឹងអត្រាដែលបានចេញផ្សាយដោយដោយធនាគារជាតិនៃកម្ពុជា និង
  - ២ ធ្វើការគណនាឡើងវិញ លើការគណនាលម្អៀងពីការប្តូររូបិយប័ណ្ណមិនបានទទួលស្គាល់ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវជាក់លាក់។

ដោយផ្អែកលើនីតិវិធីដែលបានអនុវត្តខាងលើ យើងខ្ញុំពុំរកឃើញភាពខុសឆ្គងជាសារវន្តទេ ។

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**បញ្ហាសវនកម្មសំខាន់ៗ (ត)**

**គ. ការចាត់ថ្នាក់ និងតម្លៃសមស្របនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសង**

***យោងតាមកំណត់សម្គាល់ ១៨ នៃរបាយការណ៍ហិរញ្ញវត្ថុ***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃយោងនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញរបស់ រ.ទ.ស.ភ មានចំនួន ៧៦ពាន់លានរៀល។

យើងខ្ញុំផ្តោតលើចំណុចនេះ ដោយសារតែការវិនិច្ឆ័យត្រូវបានអនុវត្តដោយគណៈគ្រប់គ្រងក្នុងការកំណត់ចំណាត់ថ្នាក់ និងតម្លៃសមស្របនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ ជាប់ជាបំណុលរយៈពេលវែងរបស់ រ.ទ.ស.ភ។

ហេតុដូចនេះ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្មសំខាន់។

ការឆ្លើយតបរបស់យើងខ្ញុំ៖

- យើងខ្ញុំបានពិភាក្សាជាមួយគណៈគ្រប់គ្រងលើការវិនិច្ឆ័យ និងការសន្មតក្នុងការកំណត់ការចាត់ថ្នាក់នៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ។
- យើងខ្ញុំបានពិភាក្សាជាមួយគណៈគ្រប់គ្រងលើតម្លៃសមស្រប ដែលអាចនឹងប៉ះពាល់ដល់ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ។
- យើងខ្ញុំត្រួតពិនិត្យភាពត្រឹមត្រូវ លើតម្លៃយោងនៃប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ ដោយអនុវត្តនីតិវិធីពិនិត្យ លើបម្រែបម្រួលក្នុងអំឡុងការិយបរិច្ឆេទ នៅក្នុងគណនីគ្រប់គ្រងប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ។

ដោយផ្អែកលើនីតិវិធីដែលបានអនុវត្តខាងលើ យើងខ្ញុំពុំរកឃើញភាពខុសឆ្គងជាសារវន្តទេ លើកលែងតែចំណុចខ្វះខាតនៃការគ្រប់គ្រង លើការកំណត់អត្តសញ្ញាណនៃប្រាក់កក់ថ្លៃទឹក ដែលត្រូវបង្វិលសងវិញដែលយោងពីការិយបរិច្ឆេទមុន។

លេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**បញ្ហាសវនកម្មសំខាន់ៗ (ត)**

**ឃ. ការទទួលស្គាល់នៃចំណូលបង្គរពីការលក់ទឹក**

***យោងតាមកំណត់សម្គាល់ ៣.៦ កំណត់សម្គាល់ ៣.១១ កំណត់សម្គាល់ ៤.៥ កំណត់សម្គាល់ ៩ នៃរបាយការណ៍ហិរញ្ញវត្ថុ***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃយោងនៃចំណូលបង្គរពីការលក់ទឹកបានបញ្ចូលនៅក្នុងទ្រព្យសកម្មកិច្ចសន្យា និងចំណូលរបស់ រ.ទ.ស.ភ មានចំនួន ៨៩ ពាន់លានរៀល។

យើងខ្ញុំផ្តោតលើចំណុចនេះ ដោយសារតែចំនួននៃចំណូលបង្គរពីការលក់ទឹក បានទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានប៉ះពាល់ដោយការប៉ាន់ស្មានខុសៗគ្នា ដែលរួមបញ្ចូលការវិនិច្ឆ័យជាក់លាក់ដែលបានអនុវត្តដោយគណៈគ្រប់គ្រង និងជាពិសេសទាក់ទងនឹងការកំណត់បរិមាណទឹកដែលបានផលិត ចំណូលពីការលក់ទឹកដែលបានបោះវិក្កយបត្រ អត្រាទឹកបាត់បង់ និងអត្រាពន្ធដែលពាក់ព័ន្ធ។

ហេតុដូចនេះ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្មសំខាន់។

ការឆ្លើយតបរបស់យើងខ្ញុំ៖

- យើងខ្ញុំបានត្រួតពិនិត្យភាពស្រមស្របនៃការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង នៃការកំណត់ចំណូលបង្គរពីការលក់ទឹករបស់ រ.ទ.ស.ភ ដូចខាងក្រោម៖
  - ១ ពិភាក្សាជាមួយគណៈគ្រប់គ្រងលើការកំណត់វិធីសាស្ត្រ សម្រាប់ប្រើប្រាស់ក្នុងការទាញយកចំណូលបង្គរពីការលក់ទឹក
  - ២ ធ្វើការតវ៉ានឹងការសន្មតសំខាន់ៗដែលប្រើប្រាស់ដោយគណៈគ្រប់គ្រង ជាពិសេសបរិមាណទឹកដែលបានផលិត អត្រាទឹកបាត់បង់ និងអត្រាពន្ធដែលពាក់ព័ន្ធ និង
  - ៣ ធ្វើការគណនាឡើងវិញ លើការគណនាចំណូលបង្គរពីការលក់ទឹក ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវជាក់លាក់។
- យើងខ្ញុំបានត្រួតពិនិត្យការគ្រប់គ្រង ដែលមានការចូលរួមជាមួយអ្នកឯកទេសព័ត៌មានវិទ្យារបស់យើងខ្ញុំ ដោយក្នុងចំណោមនោះធ្វើការប្រៀបធៀបព័ត៌មានលម្អិតនៃចំនួនចំណូល នៅក្នុងប្រព័ន្ធគណនេយ្យជាមួយនឹងប្រភពឯកសារ ការកត់ត្រាចំណូលទទួលបាន ក្នុងប្រព័ន្ធគណនីពាណិជ្ជ ការផ្ទៀតផ្ទាត់បញ្ជីសាច់ប្រាក់សរុប ជាមួយសាច់ប្រាក់ទទួលបាន និងការកត់ត្រាចំណូលទទួលបានទៅបញ្ជីធំទូទៅ។

លេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

# របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ
# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**បញ្ហាសវនកម្មសំខាន់ៗ (ត)**

**ឃ. ការទទួលស្គាល់នៃចំណូលបង្ករពីការលក់ទឹក (ត)**

ការឆ្លើយតបរបស់យើងខ្ញុំ៖ (ត)

- យើងខ្ញុំបានពិនិត្យការបោះវិក្កយបត្រជាបន្តបន្ទាប់នៃចំណូលបង្ករពីការលក់ទឹក។

ដោយផ្អែកលើនីតិវិធីដែលបានអនុវត្តខាងលើ យើងខ្ញុំពុំរកឃើញភាពខុសឆ្គងជាសារវន្តទេ។

**ង. ឱនភាពនៃគណនីអតិថិជនពាណិជ្ជកម្ម**

***យោងតាមកំណត់សម្គាល់ ៣.២ (ក)(១) កំណត់សម្គាល់ ៣.៨(ក) កំណត់សម្គាល់ ៤.៤ កំណត់សម្គាល់ ៣១(ក) នៃ របាយការណ៍ហិរញ្ញវត្ថុ***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ តម្លៃយោងនៃគណនីអតិថិជនពាណិជ្ជកម្មមានចំនួន ១៤ ពាន់លានរៀល។

យើងខ្ញុំផ្តោតលើចំណុចនេះ ដោយសារតែការវិនិច្ឆ័យត្រូវបានអនុវត្ត ដោយគណៈគ្រប់គ្រងក្នុងការកំណត់ប្រូបាប៊ីលីតេនៃការខកខានសង និងអត្រាការខាតបង់រំពឹងទុកនៃគណនីអតិថិជនពាណិជ្ជកម្ម ដែលអាចបណ្តាលឱ្យមានការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ។

ហេតុដូចនេះ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្មសំខាន់។

ការឆ្លើយតបរបស់យើងខ្ញុំ៖

- យើងខ្ញុំបានស្វែងយល់ពីការបង្កើតឡើង និងការអនុវត្តការគ្រប់គ្រងដែលទាក់ទងនឹងការត្រួតពិនិត្យរបស់អ្នកគ្រប់គ្រងលើគណនីត្រូវទទួលមិនទាន់សង និងការគណនាឱនភាព។
- យើងខ្ញុំបានពិភាក្សាជាមួយគណៈគ្រប់គ្រង លើផលប៉ះពាល់ដែលអាចកើតមាននៃឱនភាពសំរាប់គណនីអតិថិជនពាណិជ្ជកម្ម ដោយពិចារណាថាអតិថិជនទាំងនោះមិនមានលទ្ធភាពក្នុងការសង។
- យើងខ្ញុំបានវាយតម្លៃតាមភាពសមហេតុផល និងការគណនាការខាតបង់ឥណទានរំពឹងទុក ដោយអនុវត្តនីតិវិធីបន្ទាប់បន្សំនៃការសងត្រឡប់រយៈពេល ៣ឆ្នាំដែលគ្របដណ្តប់ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២។

ដោយផ្អែកលើនីតិវិធីដែលបានអនុវត្តខាងលើ យើងខ្ញុំពុំរកឃើញភាពខុសឆ្គងជាសារវន្តទេ។

លេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

## របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ភ)
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

### ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

គណៈគ្រប់គ្រងរបស់ រ.ទ.ស.ភ មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍ក្រុមប្រឹក្សាភិបាល (ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ និងរបាយការណ៍របស់សវនករនោះទេ) ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករឯករាជ្យនេះ និងផ្នែកផ្សេងទៀត រួមបញ្ចូលរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងថានឹងត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនេះ។

មតិសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ មិនគ្របដណ្តប់លើព័ត៌មានផ្សេងៗ ហើយយើងខ្ញុំក៏មិនបញ្ចេញមតិសន្និដ្ឋានជានាណាមួយទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ និងទន្ទឹមនឹងនេះពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយ របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឬការយល់ដឹងរបស់យើងខ្ញុំទទួលបានពីការធ្វើសវនកម្ម ឬបើមិនដូច្នោះទេមានកំហុសឆ្គងជាសារវន្ត។

ប្រសិនបើផ្អែកលើកិច្ចការដែលយើងខ្ញុំ បានអនុវត្តលើព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តទៅលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់ រ.ទ.ស.ភ មានភារៈទទួលខុសត្រូវលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ និងបង្ហាញនូវភាពត្រឹមត្រូវ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ គណៈគ្រប់គ្រងក៏មានភារៈទទួលខុសត្រូវផងដែរ ចំពោះការត្រួតពិនិត្យផ្ទៃក្នុង ដោយគណៈគ្រប់គ្រងកំណត់នូវភាពចាំបាច់សម្រាប់ការរៀបចំ របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឱ្យជៀសផុតពីការបង្ហាញកំហុសឆ្គងជាសារវន្ត ដោយសារការក្លែងបន្លំ ឬកំហុសឆ្គង។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គណៈគ្រប់គ្រងមានភារៈទទួលខុសត្រូវវាយតម្លៃលទ្ធភាពរបស់ រ.ទ.ស.ភ ក្នុងការបន្តនិរន្តរភាព ការបង្ហាញព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាព និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែគណៈគ្រប់គ្រងមានបំណងរំលាយ រ.ទ.ស.ភ ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យណាផ្សេងក្រៅពីធ្វើបែបនេះ។

bakertilly

លេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ (ត)**

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចរបស់ រ.ទ.ស.ភ មានភារៈទទួលខុសត្រូវចំពោះការត្រួតពិនិត្យដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ទាំងមូលមិនមានការបង្ហាញកំហុសឆ្គងជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិយោបល់នៃសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា សវនកម្មដែលធ្វើឡើងដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារ ការក្លែងបន្លំ ឬកំហុសឆ្គង ឬក៏រួមបញ្ចូលគ្នា ដែលត្រូវបានរំពឹងថានឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយពឹងផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវ ការវិនិច្ឆ័យដែលប្រកបដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈដ្ឋានមន្ទិលនិយមក្នុងកំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏ ៖

- ធ្វើការកំណត់ និងវាយតម្លៃហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង រចនា និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការក្លែងភ្លាំង ការលុបចោលដោយចេតនា បំណកស្រាយមិនពិត ឬការបំពានលើនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបានការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណង ដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

bakertilly

លេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ (ត)**

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវ ការវិនិច្ឆ័យដែលប្រកបដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងកំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏ ៖ (ត)

- វាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យ ដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពរបស់ក្រុមប្រឹក្សាភិបាល និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានថា តើភាពមិនច្បាស់លាស់ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលសង្ស័យជាសារវន្ត ទៅលើលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬប្រសិនបើការបង្ហាញព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើងខ្ញុំ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនបញ្ឈប់និរន្តភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញនៃទម្រង់ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលរួមបញ្ចូលទាំងការបង្ហាញព័ត៌មាន និវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍នានា តាមលក្ខណៈដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំផ្តល់ព័ត៌មានជូនអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ស្តីពីបញ្ហា វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលរួមមានចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុង ដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់សេចក្តីបញ្ជាក់ជូនអ្នក ដែលទទួលបន្ទុកលើអភិបាលកិច្ចនូវសេចក្តីអះអាងថា យើងខ្ញុំអនុវត្តតាមតម្រូវការផ្នែកក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធនឹងឯករាជ្យភាព ព្រមទាំងបានជូនដំណឹងពួកគាត់នូវរាល់ទំនាក់ទំនងទាំងអស់ និងបញ្ហាផ្សេងៗ ដែលយើងខ្ញុំយល់ថាមានផលប៉ះពាល់ចំពោះឯករាជ្យភាពរបស់យើងខ្ញុំ ហើយរួមជាមួយនឹងការអនុវត្តវិធានការនានា ដើម្បីលុបបំបាត់នូវការគំរាមកំហែង ឬអនុវត្តនូវវិធីសាស្ត្រការពារ។

bakertilly

លេខចុះបញ្ជីពាណិជ្ជកម្ម៖ Co.០៨៣៩ Et/២០១២

**របាយការណ៍របស់សវនករឯករាជ្យចំពោះសមាជិកនៃ**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ (ត)**

យោងតាមបញ្ហានានាដែលយើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច យើងខ្ញុំកំណត់ថាបញ្ហាទាំងនោះ ជាបញ្ហាដែលមានផលប៉ះពាល់ជាសារវន្ត ចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ក្នុងការិយបរិច្ឆេទ និងជាបញ្ហាសវនកម្មសំខាន់។ យើងខ្ញុំពណ៌នាបញ្ហាទាំងនេះនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ លើកលែងតែវាត្រូវបានហាមឃាត់ដោយច្បាប់ ឬបទប្បញ្ញត្តិនានា ក្នុងការលាតត្រដាងជាសាធារណៈ ឬនៅក្នុងករណីដ៏កម្របំផុត ដែលយើងខ្ញុំកំណត់ថាបញ្ហានោះមិនគួរត្រូវបានបង្ហាញ នៅក្នុងរបាយការណ៍របស់យើងខ្ញុំទេ ដោយសារការបង្ហាញពីបញ្ហានេះ នឹងបណ្តាលឱ្យមានផលវិបាកអវិជ្ជមាន ដែលត្រូវបានរំពឹងថានឹងបណ្តាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

**បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក**
គណនេយ្យករជំនាញ

**ឧកញ៉ា Tan Khee Meng**
គណនេយ្យករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 15 MAR 2023

# ឧបសម្ព័ន្ធ ៤

## លទ្ធផលពិនិត្យគុណភាពទឹក ពីរោងចក្រផលិតទឹកស្អាតចំការមន

TEST REPORT 7191297902-01-CHM22-PN

# TEST REPORT: 7191297902-01-CHM22-PN

| | |
|---|---|
| Date: 28 DEC 2022 | Tel: +65 6973 6164 |
| Client's Ref: | Email: na.pi@tuvsud.com |

**Note:** This report is issued subject to the Testing and Certification Regulations of the TÜV SÜD Group and the General Terms and Conditions of Business of TÜV SÜD PSB Pte Ltd. In addition, this report is governed by the terms set out within this report.

PSB Singapore

Add value.
Inspire trust.

## SUBJECT

Analysis of Drinking Water Sample

## CLIENT

Phnom Penh Water Supply Authority (PPWSA)
#45, Street 106, Phnom Penh12202
Cambodia

Attention: Mr. Keo Heng

## DATE OF SAMPLE SUBMISSION / TESTING

24 Nov 2022 / 25 Nov to 27 Dec 2022

## DESCRIPTION OF SAMPLE

One water sample was received and labelled as "Drinking Water"

## METHOD OF TEST

APHA-AWWA-WEF 22nd Edition 2012 - Standard Methods for the Examination of Water and Wastewater

| | |
|---|---|
| USEPA Method 200.8 | Determination of Trace Elements in Waters and Wastes by ICP-MS |
| USEPA Method 300.1 | Determination of Inorganic Anions in Drinking Water by Ion Chromatography |
| USEPA Method 508 | Determination of Chlorinated Pesticides in Water by GC/ECD |
| USEPA Method 515 | Determination of Chlorinated Acids in Drinking Water by Liquid-Liquid Extraction, Derivitization, and GC/ECD |
| USEPA Method 524.3 | Measurement of Purgeable Organic Compounds in Water By Capillary Column GC/MS |
| USEPA Method 525.2 | Determination of Organic Compounds in Drinking Water by Liquid-Solid Extraction and Capillary Column GC/MS |
| USEPA Method 551.1 | Determination of Chlorination Disinfection Byproducts, Chlorinated Solvents, and Halogenated Pesticides/Herbicides in Drinking Water by Liquid-Liquid Extraction and GC/ECD |
| USEPA Method 552.2 | Determination of Haloacetic Acids and Dalapon in Drinking Water by Liquid-Liquid Extraction, Derivatization and GC/ECD |

Determination of EDTA and NTA by Solid Phase Extraction, Derivatization and GC/MS
Determination of Bromate by Derivatization and GC/MS (SIM mode)

TÜV SÜD PSB

**Laboratory:**
**TÜV SÜD PSB Pte. Ltd.**
**TÜV SÜD @ IBP**
15 International Business Park
Singapore 609937

Phone : +65-6778 7777
E-mail: info.sg@tuvsud.com
https://www.tuvsud.com/en-sg
Co. Reg : 199002667R

**Regional Head Office:**
**TÜV SÜD Asia Pacific Pte. Ltd.**
**TÜV SÜD @ IBP**
15 International Business Park
Singapore 609937

## TEST REPORT: 7191236287-01-CHM20-PN
28 DEC 2022

PSB Singapore

**RESULTS**

| Test parameter | | Drinking water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| **Microbiological Parameter** | | | | |
| Escherichia coli | cfu/100mL | Not detected | 1 | < 1 |
| | | | | |
| **Physical Parameters** | | | | |
| Color | Hazen | Not detected | 2.5 | 15 |
| Conductivity at 25ºC | µS/cm | 122 | - | - |
| Odour | | Unobjectionable | - | - |
| pH @ 25°C | units | 7.2 | - | - |
| Total Dissolved Solids | mg/L | 73 | 1 | - |
| Turbidity | NTU | 0.26 | 0.1 | 5 |
| | | | | |
| **Chemical Parameters** | | | | |
| Acrylamide | mg/L | Not detected | 0.0004 | 0.5 |
| Alachlor | mg/L | Not detected | 0.001 | 0.02 |
| Aldicarb | mg/L | Not detected | 0.005 | 0.01 |
| Aldrin & Dieldrin | mg/L | Not detected | 0.00001 | 0.00003 |
| Antimony | mg/L | Not detected | 0.001 | 0.02 |
| Arsenic | mg/L | Not detected | 0.001 | 0.01 |
| Atrazine and its chloro-s-triazine metabolites | mg/L | Not detected | 0.001 | 0.1 |
| Atrazine | mg/L | Not detected | 0.001 | - |
| Aluminium | mg/L | 0.007 | 0.001 | - |
| Barium | mg/L | 0.05 | 0.001 | 1.3 |
| Benzene | mg/L | Not detected | 0.001 | 0.01 |
| Benzo (a) pyrene | mg/L | Not detected | 0.0001 | 0.0007 |
| Boron | mg/L | Not detected | 0.01 | 2.4 |
| Bromate | mg/L | Not detected | 0.005 | 0.01 |
| Bromodichloromethane | mg/L | Not detected | 0.001 | 0.06 |
| Bromoform | mg/L | Not detected | 0.001 | 0.1 |
| Cadmium | mg/L | Not detected | 0.001 | 0.03 |
| Carbofuran | mg/L | Not detected | 0.001 | 0.007 |
| Carbon Tetrachloride | mg/L | Not detected | 0.001 | 0.004 |
| Chlorate | mg/L | Not detected | 0.3 | 0.7 |
| Chlordane (total isomers) | mg/L | Not detected | 0.0001 | 0.0002 |
| Chlorine (Free) | mg/L | Not detected | 0.1 | 5 |
| Chlorite | mg/L | Not detected | 0.1 | 0.7 |
| Chlorate | mg/L | 0.3 | 0.1 | 0.7 |
| Chloroform | mg/L | Not detected | 0.001 | 0.3 |
| Chlorotoluron | mg/L | Not detected | 0.005 | 0.03 |
| Chlorpyrifos | mg/L | Not detected | 0.001 | 0.03 |
| Chromium (in all forms as a total) | mg/L | Not detected | 0.01 | 0.05 |
| Copper | mg/L | Not detected | 0.01 | 2 |
| Cyanazine | mg/L | Not detected | 0.0001 | 0.0006 |
| Cyanide | mg/L | Not detected | 0.1 | - |

PSB Singapore

**RESULTS** (Continued)

| Test parameter | | Drinking water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| Cyanogen chloride (as cyanide) | mg/L | Not detected | 0.1 | - |
| Chloride | mg/L | 14.3 | 0.1 | - |
| 2,4-D (2,4-dichlorophenoxyacetic acid) in free acid form | mg/L | Not detected | 0.004 | 0.03 |
| 2,4-DB [2,4-Dichlorophenoxy) butyric acid] | mg/L | Not detected | 0.004 | 0.09 |
| DDT & Metabolites | mg/L | Not detected | 0.0001 | 0.001 |
| Di(2-Ethylhexyl) phthalate | mg/L | Not detected | 0.001 | 0.008 |
| 1,2-Dibromo-3-chloropropane (DBCP) | mg/L | Not detected | 0.001 | 0.001 |
| Dibromoacetonitrile | mg/L | Not detected | 0.003 | 0.07 |
| Dibromochloromethane | mg/L | Not detected | 0.001 | 0.1 |
| 1,2-Dibromoethane (Ethylene Dibromide) | mg/L | Not detected | 0.0001 | 0.0004 |
| Dichloroacetate | mg/L | Not detected | 0.01 | 0.05 |
| Dichloroacetonitrile | mg/L | Not detected | 0.003 | 0.02 |
| Dichlorobenzene, 1,2- | mg/L | Not detected | 0.001 | 1 |
| Dichlorobenzene, 1,4- | mg/L | Not detected | 0.001 | 0.3 |
| Dichloroethane, 1,2- | mg/L | Not detected | 0.001 | 0.03 |
| Dichloroethene (cis & trans), 1,2- | mg/L | Not detected | 0.001 | 0.05 |
| Dichloromethane | mg/L | Not detected | 0.001 | 0.02 |
| Dichloropropane, 1,2- | mg/L | Not detected | 0.001 | 0.04 |
| Dichloropropene, 1,3- | mg/L | Not detected | 0.001 | 0.02 |
| Dichlorprop | mg/L | Not detected | 0.004 | 0.1 |
| Dicofol | mg/L | Not detected | 0.001 | - |
| Dimethoate | mg/L | Not detected | 0.001 | 0.006 |
| Dioxane, 1,4- | mg/L | Not detected | 0.01 | 0.05 |
| Endrin | mg/L | Not detected | 0.0001 | 0.0006 |
| Epichlorohydrin | mg/L | Not detected | 0.0001 | 0.0004 |
| Ethylbenzene | mg/L | Not detected | 0.001 | 0.3 |
| Edetic acid (EDTA-Ethylene Diamine Tetraacetic Acid) in free acid form | mg/L | Not detected | 0.01 | 0.6 |
| Fenoprop (2,4,5-TP; 2,4,5-trichlorophenoxy propionic acid) | mg/L | Not detected | 0.004 | 0.009 |
| Fluoride | mg/L | Not detected | 0.1 | 1.5 |
| Hexachlorobutadiene (HCBD) | mg/L | Not detected | 0.0001 | 0.0006 |
| Hydroxyatrazine | mg/L | Not detected | 0.1 | 0.2 |
| Isoproturon | mg/L | Not detected | 0.005 | 0.009 |
| Iron | mg/L | Not detected | 0.02 | - |
| Lead | mg/L | Not detected | 0.001 | 0.01 |
| Lindane | mg/L | Not detected | 0.0001 | 0.002 |
| MCPA (4-Chloro-2-methylphenoxyacetic acid) | mg/L | 0.006 | 0.006 | - |
| Mecoprop (MCPP; [2(2-methyl-chlorophenoxy) propionicacid] | mg/L | 0.005 | 0.004 | 0.01 |
| Mercury, in inorganic form | mg/L | Not detected | 0.001 | 0.006 |
| Methoxychlor | mg/L | Not detected | 0.001 | 0.02 |
| Metolachlor | mg/L | Not detected | 0.001 | 0.01 |
| Microcystin-LR, in free and cellbound forms as a total | mg/L | Not detected | 0.0005 | 0.001 |
| Molinate | mg/L | Not detected | 0.001 | 0.006 |
| Monochloramine | mg/L | Not detected | 0.1 | 3 |
| Monochloroacetic acid (chloroacetic acid) | mg/L | Not detected | 0.001 | 0.02 |
| Manganese | mg/L | 0.02 | 0.01 | - |
| Molybdenum | mg/L | Not detected | 0.02 | - |

PSB Singapore

**RESULTS** (Continued)

| Test parameter | | Drinking water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| Nitrate (as N) | mg/L | 0.3 | 0.02 | 11 |
| Nickel | mg/L | Not detected | 0.01 | 0.07 |
| Nitrilotriacetic acid (NTA) | mg/L | Not detected | 0.1 | 0.2 |
| Nitrite (as N) | mg/L | Not detected | 0.1 | 0.9 |
| Nitrate plus nitrite combined | units | 0.3 | 0.12 | 1 |
| Nitrisodimethylamine (NDMA) | mg/L | Not detected | 0.00001 | 0.0001 |
| Pendimethalin | mg/L | Not detected | 0.001 | 0.02 |
| Pentachlorophenol (PCP) | mg/L | Not detected | 0.001 | 0.009 |
| Perchlorate | mg/L | Not detected | 0.005 | 0.07 |
| Permethrin | mg/L | Not detected | 0.04 | - |
| Pyriproxyfen | mg/L | Not detected | 0.04 | - |
| Selenium | mg/L | Not detected | 0.001 | 0.04 |
| Simazine | mg/L | Not detected | 0.001 | 0.002 |
| Sodium | mg/L | 9.67 | 0.01 | - |
| Styrene | mg/L | Not detected | 0.001 | 0.02 |
| Sulfate as $SO_4^{2-}$ | mg/L | 3.0 | 0.1 | - |
| Silica (as $SiO_2$) | mg/L | 10.6 | 0.02 | - |
| Terbuthylazine (TBA) | mg/L | Not detected | 0.001 | 0.007 |
| Tetrachloroethene | mg/L | Not detected | 0.001 | 0.04 |
| Toluene | mg/L | Not detected | 0.001 | 0.7 |
| Trichloroethene | mg/L | Not detected | 0.001 | 0.02 |
| Trichlorophenol, 2,4,6- | mg/L | Not detected | 0.001 | 0.2 |
| 2,4,5-T (2,4,5-Trichlorophenoxyacetic acid) | mg/L | Not detected | 0.004 | 0.009 |
| Trichloroacetate | mg/L | Not detected | 0.01 | 0.2 |
| Trifluralin | mg/L | Not detected | 0.001 | 0.02 |
| Total Trihalomethanes Ratio[#] | unit | Not detected | 0.04 | < 1 |
| Total Organic Carbon (TOC) | mg/L | 2.0 | 1 | - |
| Total Alkalinity (as $CaCO_3$) | mg/L | 30.2 | 1 | - |
| Total Hardness as ($CaCO_3$) | mg/L | 31.1 | 0.007 | - |
| Total Phosphorus (as P) | mg/L | Not detected | 0.1 | - |
| Uranium | mg/L | Not detected | 0.001 | 0.03 |
| Vinyl Chloride | mg/L | Not detected | 0.0001 | 0.0003 |
| Xylenes | mg/L | Not detected | 0.001 | 0.5 |

Note:
1. * Specification is based on WHO Guideline for Drinking Water Quality, 4th Edition 2011.
2. # The sum of the ratio of the concentration of each to its respective guideline value should not exceed 1.

PSB Singapore

## REMARKS

The parameters tested for the water sample complied with the WHO Guidelines for Drinking-Water Quality, 4th Edition 2011.

**KATHERINE J. AGPOON**
CHEMIST

**DR. PI NA**
EXECUTIVE CHEMIST
ENVIRONMENTAL MONITORING
CHEMICAL & MATERIALS

**Please note that this Report is issued under the following terms :**

1. This report applies to the sample of the specific product/equipment given at the time of its testing/calibration. The results are not used to indicate or imply that they are applicable to other similar items. In addition, such results must not be used to indicate or imply that TÜV SÜD PSB approves, recommends or endorses the manufacturer, supplier or user of such product/equipment, or that TÜV SÜD PSB in any way "guarantees" the later performance of the product/equipment. Unless otherwise stated in this report, no tests were conducted to determine long term effects of using the specific product/equipment.

2. The sample/s mentioned in this report is/are submitted/supplied/manufactured by the Client. TÜV SÜD PSB therefore assumes no responsibility for the accuracy of information on the brand name, model number, origin of manufacture, consignment or any information supplied.

3. Nothing in this report shall be interpreted to mean that TÜV SÜD PSB has verified or ascertained any endorsement or marks from any other testing authority or bodies that may be found on that sample.

4. This report shall not be reproduced wholly or in parts and no reference shall be made by the Client to TÜV SÜD PSB or to the report or results furnished by TÜV SÜD PSB in any advertisements or sales promotion.

5. Unless otherwise stated, the tests were carried out in TÜV SÜD PSB Pte Ltd, 15 International Business Park Singapore 609937.

6. The tests carried out by TÜV SÜD PSB and this report are subject to TÜV SÜD PSB's General Terms and Conditions of Business and the Testing and Certification Regulations of the TÜV SÜD Group.

Effective 01 January 2021

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)**

---

: + ៨៥៥(២៣) ៧២៤ ០៤៦

: ir@ppwsa.com.kh

: WWW.PPWSA.COM.KH

---

អគារលេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា